**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០០៨

# ស្តីពី

# ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

# ២០០៦-២០១០

ជំរុញកំណើន បង្កើតការងារ ធានាសមធម៌ និងប្រសិទ្ធភាព

ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

ខែវិច្ឆិកា ឆ្នាំ២០០៨

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

# អារម្ភកថា

ក្នុងរយៈពេលពីរឆ្នាំកន្លះដំបូងនៃការអនុវត្ត ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) ២០០៦-២០១០*** ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពធំៗគួរជាទីមោទនៈ នៅក្នុងស្ទើរតែគ្រប់វិស័យនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដើម្បីកសាងធនធានមនុស្ស អភិវឌ្ឍសមត្ថភាពស្ថាប័ន ពង្រឹងហេដ្ឋារចនា-សម្ព័ន្ធ និង បង្កើតបរិយាកាសអំណោយផលសម្រាប់ទាក់ទាញការវិនិយោគ ទាំងក្នុង និង ក្រៅប្រទេស ក្នុងគោលដៅធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និង ការកាត់បន្ថយភាពក្រីក្រ ។

កម្ពុជាបានធ្វើសមាហរណកម្មខ្លួនចូលទៅក្នុងតំបន់ និង ពិភពលោក ហើយកំពុងដើរតួនាទីយ៉ាងសកម្មក្នុងកិច្ចដំណើរការប្រកបដោយជីវភាពនេះ ក្នុងឋានៈជាសមាជិកស្មើភាព និង ស្មើសិទ្ធិ ក្នុងអង្គការនានាទាំងកម្រិតអនុតំបន់ តំបន់ អន្តរតំបន់ និង ពិភពលោក ។ ទន្ទឹមនឹងនេះ នៅលើមូលដ្ឋាននៃការអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង គោលនយោបាយរូបិយវត្ថុដ៏ប្រយ័ត្នប្រយែង និង ស៊ីសង្វាក់គ្នាគួបផ្សំជាមួយនឹងគោលនយោបាយសេដ្ឋកិច្ចទីផ្សារបើកចំហ រាជរដ្ឋាភិបាលធានាបាននូវការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចប្រកបដោយស្ថិរភាព និង ភាពអនុគ្រោះសម្រាប់ការអភិវឌ្ឍ ។ កំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងតួលេខ ២ ខ្ទង់ ក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ បានជួយបង្កើតការងារ បង្កើនចំណូល និង កែលម្អផលិតកម្ម និង ផលិតភាព ទាំងផ្នែកបរិមាណ ទាំងផ្នែកគុណភាព ហើយបានទាញទម្លាក់អត្រានៃភាពក្រីក្រពីប្រមាណជិត ៣៥% នៅឆ្នាំ ២០០៤ ឱ្យចុះមកនៅត្រឹមប្រមាណ ៣០% នៅចុងឆ្នាំ ២០០៧ គឺមានការថយចុះជាង ១% ក្នុងមួយឆ្នាំ ។ អភិបាលកិច្ចនៅក្នុងប្រទេសត្រូវបានកែលម្អឱ្យកាន់តែប្រសើរឡើង ។ វិសាលភាព និង គុណភាពនៃសេវាសាធារណៈ ក៏ត្រូវបានពង្រីក និង ពង្រឹងជាបន្តបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការដ៏ទទូចរបស់ប្រជាជនកម្ពុជា ។

ទោះជាដូច្នេះក្ដី វឌ្ឍនភាពត្រូវតែបានជំរុញឱ្យលឿនជាងមុន មានមូលដ្ឋានទូលាយជាងមុន និង មានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងវិស័យជាច្រើន ហើយបញ្ហាប្រឈមទាំងឡាយដែលកំពុងមាន និង ដែលមានពីមុន ត្រូវដោះស្រាយតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នា ។ កំណែទម្រង់ជាច្រើនក្នុងការងារអភិបាលកិច្ចត្រូវតែជំរុញឱ្យបានលឿនបន្ថែមទៀត ក្នុងនោះ រួមមានការប្រកាសចេញ និង ការដាក់ឱ្យអនុវត្តច្បាប់ជាមូលដ្ឋាន ការ

បង្កើនប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយក្នុងការផ្តល់ និង ការគ្រប់គ្រងទំនិញ និង សេវាសាធារណៈ ការលើកកម្ពស់សមត្ថភាពជំនាញ ការធ្វើប្រសើរឡើងជាងមុននូវការសម្របសម្រួលក្នុងចំណោមក្រសួង- ស្ថាប័នទាំងឡាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាការជំរុញឱ្យមានការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ ។ ជាការពិត ការបន្តផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត ជាពិសេសទៅលើតំបន់ជនបទ គឺជាការងារចាំបាច់ ដែលនឹងជួយប្រែក្លាយតំបន់ទាំងនោះ ឱ្យទៅជាមជ្ឈមណ្ឌលដែលមានការអភិវឌ្ឍជាងមុនសម្រាប់កំណើនសេដ្ឋកិច្ច ហើយ ដែលនឹងជួយផងដែរដល់ការកាត់បន្ថយភាពក្រីក្រ ដែលមានកម្រិតខ្ពស់នៅតំបន់នោះ ។ បញ្ហាដែលព្រួយបារម្ភមួយទៀត គឺការធានាកែលម្អសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និង សមភាពយេនឌ័រ ដែលជាប្រការត្រូវយកចិត្តទុកដាក់ដោះស្រាយឱ្យបានច្រើនជាងមុន ។

ជារួម នៅក្នុងឆ្នាំកន្លងទៅនេះ ពិភពលោកបានជួបប្រទះនឹងការផ្លាស់ប្តូរជាច្រើន ដែលពោរពេញទៅដោយភាពច្របូកច្របល់ ដែលបានកើតឡើងភ្លាមៗ ដោយពុំអាចដឹងមុនបាន ដូចជាការឡើងចុះយ៉ាងលឿននៃតម្លៃប្រេងឆៅ និង ទំនិញចាំបាច់មួយចំនួន កង្វះខាតស្បៀងអាហារ និង ការផ្ទុះឡើងនូវវិបត្តិទីផ្សារហិរញ្ញវត្ថុដ៏ខ្លាំងក្លាក្នុងពេលថ្មីនេះ ។ ដំណើរវិវត្តទាំងនេះ បានធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់ប្រជាជនរាប់លាននាក់ ជាពិសេស ក្នុងទ្វីបអាស៊ី ហើយបានដាក់ការអភិវឌ្ឍ និង ការកាត់បន្ថយភាពក្រីក្រ ដែលយើងសម្រេចបានដោយលំបាកនាពេលកន្លងមក ទៅក្នុងហានិភ័យនៃការត្រឡប់ក្រោយវិញ ។ ជាការពិត កម្រិតអតិផរណាខ្ពស់ បានប៉ះពាល់យ៉ាងខ្លាំង និង មុនគេលើប្រជាជនក្រីក្រ ។ ប្រការនេះ អាចទាញប្រជាជនមួយចំនួន ឱ្យធ្លាក់ទៅនៅក្រោមបន្ទាត់នៃភាពក្រីក្រវិញ ។

ដោយសារតែបានធ្វើសមាហរណកម្មកាន់តែច្រើនឡើង នៅក្នុងតំបន់ និង ពិភពលោក កម្ពុជាក៏បានទទួលផលប៉ះពាល់ពីព្រឹត្តការណ៍ទាំងនេះដែរ ហើយកំណើនសេដ្ឋកិច្ចរបស់កម្ពុជា នឹងមិនមានកម្រិតខ្ពស់ដូចនៅក្នុងបណ្តាឆ្នាំថ្មីៗនេះទេ ។

ការវិវត្តដូចបានពោលពីខាងដើម មិនមែនគ្រាន់តែជាបញ្ហាចម្បងធំៗ ដែលត្រូវប្រឈមនៅពេលខាងមុខនោះទេ ប៉ុន្តែ ក៏ផ្តល់ផងដែរនូវកាលានុវត្តភាពដ៏មានតម្លៃ សម្រាប់ការកែប្រែទ្រង់ទ្រាយមូលដ្ឋានសេដ្ឋកិច្ចកម្ពុជា ឱ្យមានចីរភាពជាងមុន ហើយមិនពឹងផ្អែកតែលើវិស័យពីរ ឬ បី ដែលអាចងាយរងគ្រោះដោយសារវិបត្តិពីក្រៅប្រទេស ។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជា បានផ្តោតការយកចិត្តទុកដាក់លើកំណើនក្នុងវិស័យកសិកម្ម ដែលនៅមានសក្តានុពលខ្ពស់ មិនទាន់ប្រើប្រាស់អស់នៅឡើយ និង លើការអភិវឌ្ឍនៅតំបន់ជនបទ សំដៅពង្រឹកមូលដ្ឋានសេដ្ឋកិច្ច និង ដើម្បីធ្វើឱ្យកំណើននេះ មានចីរភាពក្នុងរយៈពេលវែងក៏ដូចជាការកាត់បន្ថយភាពក្រីក្រដែលមានកម្រិតខ្ពស់នៅតំបន់ជនបទ ឱ្យបានឆាប់រហ័ស ។ លទ្ធផល នឹងត្រូវអាចទទួលបានភ្លាមៗ តាមរយៈការបង្កើនផលិតភាពកសិកម្ម និង ការបង្កើនចំណូលប្រជាជននៅតំបន់ជនបទ ។

លទ្ធផលនៃការបោះឆ្នោត ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ កន្លងមក ដែលត្រូវបានសាធារណៈជាតិ និង អន្តរជាតិ ទទួលស្គាល់ថា មានលក្ខណៈសេរី យុត្តិធម៌ ត្រឹមត្រូវ និង មានតម្លាភាព បានឆ្លុះបញ្ចាំងឱ្យ

ឃើញយ៉ាងប្រចក្សនូវឆន្ទៈគាំទ្រយ៉ាងពេញលេញ និង ដ៏មោះមុត ពីសំណាក់ប្រជាពលរដ្ឋដ៏ច្រើនលើសលប់ និង ពីគ្រប់មជ្ឈដ្ឋាន ទៅលើភាពចាំបាច់ក្នុងការបន្តកិច្ចដឹកនាំកសាងប្រទេស នៅលើមាគ៌ានៃការអភិវឌ្ឍ និង កំណែទម្រង់រដ្ឋក្នុងគ្រប់វិស័យ ឆ្ពោះទៅរកវឌ្ឍនភាព និង វិបុលភាពដ៏រុងរឿង ។ ដូច្នេះ រាជរដ្ឋាភិបាលនីតិកាលទី ៤ នេះ មានកាតព្វកិច្ចបន្តបេសកកម្មដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្រ ក្នុងការប្តេជ្ញាចិត្តឥតរាថយ និង ក្នុងភាពកាន់តែស្វាហាប់ ដើម្បីពន្លឿនកិច្ចអភិវឌ្ឍ និង ជំរុញអនុវត្តកំណែទម្រង់រដ្ឋយ៉ាងស៊ីជម្រៅ និង ទូលំទូលាយ ។ ក្នុងស្មារតីនេះហើយ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ និង ប្តេជ្ញាជំរុញអនុវត្តឱ្យបានជោគជ័យ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់បំផុត នូវ ***«យុទ្ធសាស្ត្រចតុកោណ» ដំណាក់កាលទី ២*** ដែលជា ***«របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច»*** នៃ ***«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៃនីតិកាលទី ៤ នៃរដ្ឋសភា»*** នេះ ។

ខ្ញុំមានសេចក្តីរីករាយ ដោយកត់សម្គាល់ឃើញថា ***របាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្ត ផយអជ ២០០៦-២០១០*** ក្តោបយកនូវការវិវត្តទាំងអស់ ដែលបានកើតមានឡើង ចាប់តាំងពី ខែ មករា ឆ្នាំ ២០០៦ មក តាមរបៀបមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង មានគុណភាពផ្នែកខ្លឹមសារ ដោយមិនលម្អៀងទៅផ្នែកណាមួយ ។ ឯកសារនេះ បង្ហាញពីរូបភាពរួមនៃស្ថានភាពរបស់កម្ពុជាទាំងមូល ក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ហើយផ្តល់នូវការណែនាំសម្រាប់ការអនុវត្តនៅពេលខាងមុខ ។ របាយការណ៍នេះ បានសង្កត់ធ្ងន់លើការកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស តាមរយៈគោលនយោបាយ និង សកម្មភាពគាំទ្រអ្នកក្រ ។ ក្នុងន័យនេះ ទាមទារឱ្យមានកំណើនម៉ាក្រូសេដ្ឋកិច្ចរឹងមាំ មានមូលដ្ឋានទូលាយជាងមុន មានសមត្ថភាពប្រកួតប្រជែងជាងមុន ព្រមទាំងមានមូលដ្ឋានប្រកបដោយពិពិធភាពនៅតំបន់ជនបទ និង ដោយផ្តែកលើការបង្កើនផលិតភាពកសិកម្ម រួមជាមួយនឹងការធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងដីធ្លី និង ការជំរុញការអភិវឌ្ឍជនបទ ។

រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចចិត្តថា អាណត្តិ ***ផយអជ ២០០៦-២០១០*** នឹងត្រូវបានពន្យារទៅដល់ឆ្នាំ ២០១៣ ដើម្បីឱ្យស្របគ្នាជាមួយនឹង ***«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៤»*** នៃរដ្ឋសភា ដែលមាន ***យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២*** ជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច ។ ខ្លឹមសារលម្អិតពាក់ព័ន្ធនឹងការងារនេះ នឹងត្រូវបានបង្ហាញយ៉ាងពេញលេញក្នុងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ***ផយអជ*** លើកក្រោយ ។

***របាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្ត ផយអជ*** គឺជាឯកសារមួយយ៉ាងសំខាន់ និង ជារបៀបវារៈការងារមួយ ដែលសំដៅឆ្ពោះទៅរកសកម្មភាពសម្រាប់រយៈពេលដ៏ឆាប់ខាងមុខ ។ ជោគជ័យរបស់កម្មវិធី និង គោលនយោបាយទាំងឡាយ ដែលបានកំណត់នៅក្នុងរបាយការណ៍នេះ នឹងអាស្រ័យយ៉ាងខ្លាំងលើការប្រើប្រាស់ឱ្យបានប្រសើរបំផុតនូវធនធានទាំងអស់ (ហិរញ្ញប្បទានសហប្រតិបត្តិការពីក្រៅប្រទេស និង ការវិភាជថវិកាជាតិ) តាមរបៀបមួយដែលមានការសម្របសម្រួលគ្នាល្អ ដើម្បីធ្វើឱ្យមានការប្រើប្រាស់នូវកម្លាំងសរុបបញ្ចូលគ្នា ក្នុងការសំដៅឆ្ពោះទៅរកលទ្ធផល ។

ក្នុងន័យនេះ ខ្ញុំសូមសំណូមពរដល់ដៃគូអភិវឌ្ឍន៍របស់យើងទាំងអស់ ឱ្យធ្វើកិច្ចសហប្រតិបត្តិការយ៉ាងពេញលេញ តាមរយៈការផ្តល់គ្រប់ព័ត៌មានដែលទាក់ទងនឹងការងារ និង ចំណាយផ្នែកហិរញ្ញវត្ថុទៅដល់ក្រសួង-ស្ថាប័នដែលជាសមភាគីការងារនីមួយៗ ក្នុងនោះ រួមទាំងក្រុមការងារបច្ចេកទេសដែលកំពុងដំណើរការ សំដៅធានាថា សកម្មភាពដែលមានការសម្របសម្រួលដើម្បីលទ្ធផល អាចនឹងត្រូវបានធ្វើឡើងក្រោមភាពជាអ្នកដឹកនាំ និង ដោយមានភាពជាម្ចាស់របស់កម្ពុជា ។

ភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

# សញ្ញាជាតិ និង ទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា





# គំនូសបំព្រួញយុទ្ធសាស្ត្រចតុកោណ



# មាតិកា


អារម្ភកថា ............ i

សញ្ញាជាតិ និងទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា ............ v

គំនូសបំព្រួញយុទ្ធសាស្ត្រចតុកោណ ............ vi

មាតិកា ............ vii

កម្ពុជា : សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ ............ ix

**ជំពូកទី១** : សេចក្តីផ្តើម និងសេចក្តីសង្ខេប ............ ១

**ជំពូកទី២** : វឌ្ឍនភាព ការរំពឹងទុក និងសំណើគោលនយោបាយ ............ ១០

**ជំពូកទី៣** : គោលដៅនិងចំណុចដៅអាទិភាព ............ ៨១

**ជំពូកទី៤** : ការកំណត់ចំណាយ ធនធាន និង ការរៀបចំកម្មវិធី ............ ៨៧

**ជំពូកទី៥** : ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ............ ៩៦

**ជំពូកទី៦** : សេចក្តីសន្និដ្ឋាន ............ ៩៨


# តារាង


តារាង ២.១ : ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ............ ៣៥

តារាង ២.២ : វឌ្ឍនភាពនិងចំណុចដៅក្នុងវិស័យកសិកម្ម ............ ៤៣

តារាង ២.៣ : វឌ្ឍនភាពនិងចំណុចដៅក្នុងការអភិវឌ្ឍជនបទ ............ ៤៧

តារាង ២.៤ : វឌ្ឍនភាពនិងចំណុចដៅក្នុងវិស័យអប់រំ ............ ៧១

តារាង ២.៥ : វឌ្ឍនភាពនិងចំណុចដៅក្នុងវិស័យសុខាភិបាល ............ ៧៥

តារាង ៣.១ : ស្ថានភាពនៃការសម្រេចបាននូវចំណុចដៅសំខាន់ៗ ............ ៨៣

តារាង ៣.២ : គោលដៅម៉ាក្រូ និងសូចនាករសំខាន់ៗរបស់ *ផយអជ* ............ ៨៤

តារាង ៤.១ : ចំណាយវិស័យសាធារណៈលើ *ផយអជ ២០០៦-២០០៨* ............ ៨៨

តារាង ៤.២ : កម្រិតនៃការវិនិយោគវិស័យសាធារណៈដែលត្រូវការសម្រាប់ ២០០៦-២០១០ ............ ៨៩

តារាង ៤.៣ : ការបែងចែកធនធានតាមវិស័យ របស់ *ផយអជ* ២០០៦-២០១០ ............ ៩៤


# ប្រអប់


ប្រអប់ ២.១ ផលប៉ះពាល់នៃការវិវត្តរបស់សាកលលោក មកលើកម្ពុជា ............ ១៦

ប្រអប់ ២.២ ការកាត់បន្ថយភាពក្រីក្រ : ការងារដែលត្រូវធ្វើចំពោះមុខ ............ ២០

ប្រអប់ ២.៣ ការតម្រឹមតម្រង់ ការប្រើប្រាស់ និងគណនេយ្យភាព នូវធនធានរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស... ៣២

ប្រអប់ ២.៤ បញ្ហាប្រឈមក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ ៣៩
ប្រអប់ ២.៥ តម្រូវការចាំបាច់ក្នុងវិស័យកសិកម្ម ........ ៤៤
ប្រអប់ ២.៦ បញ្ហាក្នុងការគ្រប់គ្រងដីធ្លី ........ ៥២

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១.១ កម្ពុជា : សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ........ ១០០
ឧបសម្ព័ន្ធ ១.២ កម្ពុជា : ការប៉ាន់ស្មានការបែងចែកចំណាយចរន្តនៃថវិកា ........ ១០២
ឧបសម្ព័ន្ធ ១.៣ កម្ពុជា : ព្យាករណ៍ការវិនិយោគសម្រាប់ ឆ្នាំ២០០៦-២០១០ ........ ១០៣
ឧបសម្ព័ន្ធ ២.១ កម្មវិធីវិនិយោគសាធារណៈ ២០០៦-២០០៨ : តារាងទី ១ : សង្ខេបតាមវិស័យ ........ ១០៥
ឧបសម្ព័ន្ធ ២.២ កម្មវិធីវិនិយោគសាធារណៈ ២០០៧-២០០៩ : តារាងទី ១ : សង្ខេបតាមវិស័យ ........ ១០៧
ឧបសម្ព័ន្ធ ២.៣ កម្មវិធីវិនិយោគសាធារណៈ ២០០៨-២០១០ : តារាងទី ១ : សង្ខេបតាមវិស័យ ........ ១០៩
ឧបសម្ព័ន្ធ ២.៤ កម្មវិធីវិនិយោគសាធារណៈ ២០០៩-២០១១ : តារាងទី ១ : សង្ខេបតាមវិស័យ ........ ១១១
ឧបសម្ព័ន្ធ ៣ ក្របខ័ណ្ឌនៃការតាមដានត្រួតពិនិត្យ ការអនុវត្ត *ផយអជ* ........ ១១៣
ឧបសម្ព័ន្ធ ៤.១ ពាក្យបំព្រួញ ........ ១១៩
ឧបសម្ព័ន្ធ ៤.២ គេហទំព័ររបស់ក្រសួង-ស្ថាប័ន នៃរាជរដ្ឋាភិបាលកម្ពុជា ........ ១២១

# កម្ពុជា : សូចនាករសេដ្ឋកិច្ច_សង្គមកិច្ចសំខាន់ៗ

ព័ត៌មានទូទៅ (២០០៤)

| | |
|---|---|
| ផ្ទៃដីសរុបៈ គម² | ១៨១.០៣៥ |
| ចំនួនខេត្ត-ក្រុង | ២៤ |
| ចំនួនទីប្រជុំជន រួមទាំង ទីក្រុងភ្នំពេញ | ១៦២ |
| ចំនួនស្រុក-ខ័ណ្ឌ | ១៨៥ |
| ចំនួនឃុំ-សង្កាត់ | ១.៦២១ |
| ចំនួនភូមិ | ១៣.៨៤៨ |
| ឆ្នាំសារពើពន្ធ | មករា-ធ្នូ |
| រូបិយវត្ថុ | រៀល (៛) |

សម្គាល់ : តួលេខឆ្នាំ២០០៥ និង២០១០ ដែលបានបង្ហាញនៅក្នុង *ផយអជ* ត្រូវបានកែតម្រូវ នៅក្នុងកន្លែងមួយចំនួន ដោយផ្អែកលើទិន្នន័យថ្មីៗ ឫអង្កេតនានា ។

| | **សូចនាករសំខាន់ៗ** | **ឯកតា** | **២០០៥** | **២០០៦** | **២០០៧** | **២០០៨ ជាន់ស្មាន** | **២០១០ ព្យាករណ៍** |
|---|---|---|---|---|---|---|---|
| **១.00** | **កម្រិតនៃភាពក្រីក្រ** | | **(២០០៤)** | | | | |
| ១.០១ | សរុបទូទាំងប្រទេស | %នៃប្រជាជន | ៣៤,៧ | ពុំមានតួលេខ | ៣០,១ | | ២៥,០ |
| ១.០២ | ភ្នំពេញ | % នៃប្រជាជន | ៤,៦ | ពុំមានតួលេខ | ០,៨ | | |
| ១.០៣ | ទីប្រជុំជនផ្សេងទៀត | % នៃប្រជាជន | ២៤,៧ | ពុំមានតួលេខ | ២១,៩ | | |
| ១.០៤ | ជនបទ | % នៃប្រជាជន | ៣៩.២ | ពុំមានតួលេខ | ៣៤,៧ | | |
| ១.០៥ | ប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ម្ហូបអាហារ | % នៃប្រជាជន | ១៩.៧ | ពុំមានតួលេខ | ១៨,០ | | ១៣,០ |
| **២.00** | **បញ្ហាយេនឌ័រ** | | | | | | |
| ២.០១ | ស្ត្រីក្នុងកម្លាំងពលកម្ម (ក.ព) : វិស័យកសិកម្ម | %នៃ ក.ព សរុប | ៥២,៥ | ពុំមានតួលេខ | | | ៥០,០ |
| ២.០២ | វិស័យឧស្សាហកម្ម | %នៃ ក.ព សរុប | ៥៣,៥ | ពុំមានតួលេខ | | | ៥០,០ |
| ២.០៣ | វិស័យសេវាកម្ម | %នៃ ក.ព សរុប | ២៧,០ | ពុំមានតួលេខ | | | ៣៧,០ |
| **៣.00** | **ប្រជាជន** | | | | | | |
| ៣.០១ | សរុប : ជំរឿន ខែមីនា ឆ្នាំ២០០៨ | លាននាក់ | | | | ១៣,៤ | ពុំមានតួលេខ |
| ៣.០២ | ដង់ស៊ីតេប្រជាជន | ក្នុងមួយគម² | | | | ៧៥ | |
| ៣.០៣ | បុរសធៀបនឹងស្ត្រី | ស្ត្រី១០០នាក់ | | | | ៩៤,២ | |
| ៣.០៤ | អាយុ ០-១៤ | % នៃប្រជាជន | ៣៩,០ | | | ពុំមានតួលេខ | |
| ៣.០៥ | អាយុ ១៥-៦៤ | % នៃប្រជាជន | ៥៧,០ | | | ពុំមានតួលេខ | |
| ៣.០៦ | អាយុ ៦៤៥និង លើសពី៦៥ | % នៃប្រជាជន | ៥,០ | | | ពុំមានតួលេខ | |
| ៣.០៧ | ជនបទ | % នៃប្រជាជន | | | | ៨០,៥ | |
| ៣.០៨ | ទីប្រជុំជន | % នៃប្រជាជន | | | | ១៩,៥ | |
| ៣.០៩ | អត្រាកំណើនប្រចាំឆ្នាំ | % | ១,៨១ | | | ១,៥៤ | |
| ៣.១០ | អត្រាបង្កើតកូនសរុប (ក្នុងស្ត្រីម្នាក់) | កំណើតរស់ | ៣,៤ | | | ពុំមានតួលេខ | |
| ៣.១១ | អាយុកាលមធ្យមសង្ឃឹមរស់ពីកំណើត : ប្រុស | ឆ្នាំ | ៦១,០ | ៦១,៨ | ៦២,៥ | ៦៣,១ | ៦៤,១ |
| | ស្ត្រី | ឆ្នាំ | ៦៥,៤ | ៦៦,២ | ៦៦,៩ | ៦៧,៥ | ៦៨,៥ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ ប៉ាន់ស្មាន | ២០១០ ព្យាករណ៍ |
|---|---|---|---|---|---|---|---|
| **៤.00** | **ម៉ាក្រូសេដ្ឋកិច្ច** | | | | | | |
| ៤.0១ | *ផសស* ប្រចាំឆ្នាំ (គិតតាមថ្លៃថេរ ឆ្នាំ២000) | ពាន់លានរៀល | ២២.00៩ | ២៤.៣៨0 | ២៦.៨៦៨ | ២៨.៧៣៦ | ៣២.៧៥៩ |
| ៤.0២ | : កសិកម្ម | % | ២៩,៤ | ២៨,0 | ២៦,៧ | ២៦,១ | ២៤,៨ |
| ៤.0៣ | : ឧស្សាហកម្ម | % | ២៦,៨ | ២៨,៦ | ២៨,១ | ២៨,៣ | ២៨,៩ |
| ៤.0៤ | : សេវាកម្ម | % | ៣៨,៥ | ៣៨,៣ | ៣៨,៣ | ៣៨,៧ | ៣៩,៦ |
| ៤.0៥ | *ផសស* សម្រាប់ប្រជាជនម្នាក់ | ពាន់រៀល | ១.៨៦២ | ២.១0៨ | ២.៤១៦ | ២.៨៩២ | ៣.៥0៥ |
| ៤.0៦ | *ផសស* សម្រាប់ប្រជាជនម្នាក់ | ដុល្លារ | ៤៥៥ | ៥១៤ | ៥៩៤ | ៧១៦ | ៨៤២ |
| ៤.0៧ | អត្រាកំណើន *ផសស* (ថ្លៃថេរ ឆ្នាំ២000) | % | ១៣,៣ | ១0,៨ | ១0,២ | ៧,0 | ៧,0 |
| ៤.0៨ | អតិផរណា (មធ្យមប្រចាំឆ្នាំ) | % | ៥,៨ | ៤,៧ | ៥,៩ | ២0,0 | ៤,0 |
| ៤.0៩ | អត្រាប្តូរប្រាក់ | រៀល/ដុល្លារ | ៤.១១៧ | ៤.0៥៨ | ៤.000 | ៤.១៣0 | ៤.១៦៣ |
| ៤.១0 | ទុនបំរុងអន្តរជាតិដុល | ចំនួនខែនាំចូល | ២,២ | ២,២ | ២,៩ | ៣,0 | ៣,៥ |
| ៤.១១ | ទុនបំរុងបរទេសដុល | លានដុល្លារ | ៩១៥ | ១.0៩៧ | ១.៦១៦ | | ២.៥២១ |
| ៤.១២ | ការវិនិយោគផ្ទាល់ពីបរទេស (ប្រចាំឆ្នាំ) | លានដុល្លារ | ៣៨១ | ៤៨៣ | ៨៦៨ | ៩៤៤ | ៨២៥ |
| **៥.00** | **សារពើពន្ធ** | | | | | | |
| ៥.0១ | ចំណូលថវិកាសរុប | %នៃ *ផសស* | ១0,៦ | ១១,៤ | ១២,១ | ១២,៥ | ១៣,១ |
| ៥.0២ | ចំណូលពន្ធ | %នៃ *ផសស* | ៧,៧ | ៨,0 | ១0,២ | ១0,៤ | ១១,0 |
| ៥.0៣ | ចំណាយថវិកាសរុប | % នៃ *ផសស* | ១៣,២ | ១៤,១ | ១៤,៨ | ១៤,៧ | ១៤,0 |
| ៥.0៤ | ក្នុងនោះ — ចំណាយចរន្ត | %នៃ *ផសស* | ៧,៦ | ៧,៩ | ៨,២ | ៨,២ | ៨,៥ |
| ៥.0៥ | អតិរេកចរន្ត | ពាន់លានរៀល | ៤៧១,0 | ៣៥៥,៨ | ១.១១៦,៤ | ១.៥១៥,៨ | ១.៩៥១,0 |
| ៥.0៦ | រួមចំណែកក្នុងការវិនិយោគផ្ទាល់ពីបរទេស (ពន្ធនាំចូល ...) | %នៃ *ផសស* | ៥,២ | ៥,៦ | ៥,៥ | ៥,២ | ៥,៥ |
| **៦.00** | **វិស័យហិរញ្ញវត្ថុ** | | | | | | |
| ៦.0១ | ធនាគារពាណិជ្ជកម្ម | ចំនួន | ១៥ | ១៥ | ១៧ | | |
| ៦.0២ | ឥណទានមិនទាន់ទូទាត់សង | ពាន់លានរៀល | ២.៣១៧ | ៣.៥0២ | ៦.២៣៤ | | |
| ៦.0៣ | ស្ថាប័នមីក្រូហិរញ្ញវត្ថុ | ចំនួន | ១៦ | ១៦ | ១៧ | | |
| ៦.0៤ | ឥណទានមិនទាន់ទូទាត់សង | ពាន់លានរៀល | ២0៤,៥៧ | ៣៥៧,0៤ | ៦១៧,៩0 | | |
| **៧.00** | **ជំនួយអភិវឌ្ឍន៍ផ្លូវការ (រួមទាំងអង្គការក្រៅរដ្ឋាភិបាល)** | | | | ប៉ាន់ស្មាន | ព្យាករណ៍ | ព្យាករណ៍ |
| ៧.0១ | សរុប | លានដុល្លារ | ៦១0 | ៨0៩ | ៧១៩ | ៧៣៦ | - |
| ៧.0២ | ជំនួយបច្ចេកទេស | លានដុល្លារ | ២៦0 | ២៨៨ | ២១0 | ១៣៣ | - |
| ៧.0៣ | ជំនួយវិនិយោគ | លានដុល្លារ | ២៩0 | ៣៥៤ | ៣៩៩ | ៤៤១ | - |
| ៧.0៤ | ជំនួយផ្សេងៗទៀត | លានដុល្លារ | ៦0 | ១៦៧ | ១១0 | ១៦២ | - |
| **៨.00** | **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | | | | |
| ៨.0១ | ផ្ទៃដីដំណាំ | ពាន់ហត | ២.៨៩៣ | ៣.0៤៨ | ៣.១១៧ | ៣.៣00 | ៣.៥00 |
| ៨.0២ | ផ្ទៃដីស្រោចស្រព | ពាន់ហត | ៦៣២ | ៧២១ | ៧៧៣ | ៨២៧ | ៨៦៧ |
| ៨.0៣ | ផ្ទៃដីដាំដុះស្រូវ | ពាន់ហត | ២.៤៤៣ | ២.៥៤១ | ២.៥៨៥ | ២.៦00 | ២.៦៥0 |
| ៨.0៤ | ទិន្នផលស្រូវក្នុងមួយហិកតា | តោន | ២,៤៨ | ២,៤៩ | ២,៦២ | ២,៦0 | ២,៨0 |
| ៨.0៥ | ឡូតិ៍នេសាទ | គម² | ៤.១៥២ | ៤.១៥0 | ៤.១៥0 | ៤.១៥0 | ៤.១៥0 |
| ៨.0៦ | សម្រាប់សហគមន៏នេសាទ | % | ៥៦ | ៥៦ | ៥៦ | ៥៦ | ៥៦ |
| ៨.0៧ | ត្រី : នេសាទបាន (ពីគ្រប់ប្រភព) | តោន | ៤១0.000 | ៥១៦.000 | ៤៨២.000 | ៥00.000 | ៤៥0.000 |

| | សូចនាករសំខាន់ៗ | ឯកតា | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ ប៉ាន់ស្មាន | ២០១០ ព្យាករណ៍ |
|---|---|---|---|---|---|---|---|
| ៨.០៨ | ផ្ទៃដីគ្របដណ្ដប់ដោយព្រៃឈើ | %នៃផ្ទៃដី | ៥៩ | ៥៩ | | | ៦០ |
| ៨.០៩ | ព្រៃឈើដាំដុះឡើងវិញ (សរុបផ្ទៃដីដាំដុះតាំងពីឆ្នាំ១៩៨៥) | ហត | ១៥.៧២៩ | ១៦.៨២៥ | ២៦.៣៨៦ | | ៣០.០០០ |
| ៨.១០ | ការប្រើប្រាស់អុសសម្រាប់ដុត | %គ្រួសារសរុប | ៨៤ | ៨៤ | | | ៦១ |
| ៨.១១ | កំណែទម្រង់ដី : ប័ណ្ណកម្មសិទ្ធិដែលបានផ្ដល់ជូនកសិករ | %នៃក្បាលដីសរុបទូទាំងប្រទេស | ១៥,០ | ១៧,០ | ១៨,២ | ២០,០ | ២៤,០ |
| **៩.០០** | **ការអភិវឌ្ឍជនបទ** | | | | | | |
| ៩.០១ | ផ្លូវថ្នល់ដែលបានស្ដារ (នៃប្រវែងសរុប ២៨.០០០ គម) | គម | ២២.៧០០ | ២២.៩៦៤ | ២៣.៧២៩ | | ២៥.០០០ |
| ៩.០២ | ការទទួលបានទឹកស្អាត (ជនបទ) | %នៃប្រជាជន | ៤១,៦ | ៤២,៦ | ៤៥,៥ | | ៤៥,០ |
| ៩.០៣ | ការទទួលបានអនាម័យ (ជនបទ) | %នៃប្រជាជន | ១៦,៤ | ១៦.៥ | ១៦,៧ | | ២៥.០ |
| **១០.០០** | **ឧស្សាហកម្ម** | | | | | | |
| ១០.០១ | ផលិតផលកម្មន្តសាល | ពាន់លានរៀល | ១១.១៣២ | ១៥.១១៦ | ១៦.៧៩៨ | ១៧.៩៧៣ | ២០.៩៧៥ |
| ១០.០២ | ក្នុងនោះ ឧស្សាហកម្មសំលៀកបំពាក់ : ផលិតផល | ពាន់លានរៀល | ៨.៩១៦ | ១០.៨៩៦ | ១១.៧៧២ | ១២.៩៩៦ | ១៤.៤១២ |
| ១០.០៣ | : កម្លាំងពលកម្ម | នាក់ | ៣០៥.៦៧៨ | ៣០៧.៩០២ | ៣៦៩.៨១៣ | ៣៧៦.០០០ | ៣៩៣.៧៧៣ |
| **១១.០០** | **ថាមពល** | | | | | | |
| ១១.០១ | ថាមពលដែលបានប្រើប្រាស់: ប្រេងសាំង & ម៉ាស៊ូត | តោន | ១៩៦.៣២៣ | ២២៧.៩០៨ | | | ៣១៧.៣៥០ |
| ១១.០២ | អគ្គិសនីដែលផលិតបាន | គីកាវ៉ាត់ម៉ោង | ៨៩៤ | ១.០៧៣ | ១.៥០៥ | ១.៩០០ | ២.៥០០ |
| ១១.០៣ | ប្រវែងបណ្ដាញខ្សែបញ្ជូនថាមពល (១១៥ KVA) | គម | ១៣៤ | ២៧៩ | ៣២៣ | ៣២៣ | ៦៧៤ |
| ១១.០៤ | ចំនួនគ្រួសារប្រើប្រាស់ថាមពល | ចំនួន | ២០៨.៤៧៦ | ២៥០.០០០ | ៤០១.២៦២ | ៤៤៥.០០០ | ៦៥០.០០០ |
| ១១.០៥ | ការប្រើប្រាស់ថាមពលរបស់ប្រជាជនម្នាក់ ក្នុង១ឆ្នាំ | គវ៉ម | ៦២ | ៧២ | ១០០ | ១២៤ | ១៥៩ |
| **១២.០០** | **ដឹកជញ្ជូន** | | | | | | |
| ១២.០១ | ផ្លូវជាតិ និងផ្លូវខេត្ត : សរុប | គម | ១១.៤៩៤ | ១១.៤៩៤ | | | ១១.៤៩៤ |
| ១២.០២ | ផ្លូវកៅស៊ូ | គម | ២.១០០ | ២.៦២១ | ២.៥១២ (មិនរួមបញ្ចូលផ្លូវខេត្ត) | | ៤.១០០ |
| ១២.០៣ | ផ្លូវដែក | គម | ៦៥០ | ៦៥០ | ៦៥០ | ៦៥០ | ៦៥០ |
| ១២.០៤ | កំពង់ផែអន្តរជាតិ | ចំនួន | ២ | ២ | ២ | ២ | ២ |
| ១២.០៥ | អាកាសយានដ្ឋានអន្តរជាតិ | ចំនួន | ២ | ២ | ៣ | ៣ | ៣ |
| **១៣.០០** | **ទូរគមនាគមន៍** | | | | | | |
| ១៣.០១ | ទូរសព្ទ័ដែលកំពុងប្រើប្រាស់ (ខ្សែ និងចល័ត) | ពាន់គ្រឿង | ៨៨២ | ១.១៧៩ | ២.៣៣៧ | ២.៩៣២ | ៣.៧០០ |
| ១៣.០២ | អ្នកប្រើប្រាស់អ៊ិតធ័រណែត | នាក់ | ៨.៦៣២ | ៨.៩៦០ | ១០.៨៣១ | ១៣.៦៩៨ | ២២.៥០០ |
| **១៤.០០** | **ទេសចរណ៍** | | | | | | |
| ១៤.០១ | ចំនួនភ្ញៀវទេសចរណ៍មកដល់ | លាននាក់ | ១,៤២ | ១,៧០ | ២,០៥ | ២,៣៥ | ៣,២០ |
| ១៤.០២ | ចំណូលប៉ាន់ស្មានជា រូបិយប័ណ្ណបរទេស | លានដុល្លារ | ៨៣២ | ១.០៤៩ | ១.៤០០ | ១.៦០០ | ២.២២៣ |
| ១៤.០៣ | ចំនួនបន្ទប់សណ្ឋាគារ | បន្ទប់ | ១៥.៤៦៥ | ១៧.៩១៤ | ២០.៤៧០ | ២៣.៦៤៥ | ២៤.៣៥៥ |
| **១៥.០០** | **ព័ត៌មានសាធារណៈ** | | | | | | |
| ១៥.០១ | អង្គភាពសារព័ត៌មានជាភាសាខ្មែរ (ចំនួនចុះបញ្ជី) | អង្គភាព | ២៩២ | ៤២០ | ៤៩៧ | ៤៩៧ | ៥០០ |
| ១៥.០២ | អង្គភាពសារព័ត៌មានជាភាសាបរទេស (ចំនួនចុះបញ្ជី) | អង្គភាព | ២៥ | ២៧ | ២៧ | ២៨ | ៣០ |
| ១៥.០៣ | ចំនួនស្ថានីយ៍វិទ្យុក្នុងស្រុក (ស្ថានីយកណ្ដាល និងខេត្ត) | ចំនួន | ២១ | ២២ | ២៦ | ៤១ | ៤៧ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ ប៉ាន់ស្មាន | ២០១០ ព្យាករណ៍ |
|---|---|---|---|---|---|---|---|
| ១៥.០៤ | ចំនួនស្ថានីយ៍ទូរទស្សន៍ក្នុងស្រុក (ស្ថានីយកណ្តាល និងខេត្ត) | ចំនួន | ១៤ | ១៤ | ១៤ | ១៤ | ១៧ |
| **១៦.០០** | **សុខាភិបាល** | | | | | | |
| ១៦.០១ | អត្រាមរណភាពកុមារអាយុក្រោម១ឆ្នាំ | ក្នុង ១.០០០ កំណើតរស់ | ៦៦ | ៦៥ | | | ៦០ |
| ១៦.០២ | អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ | ក្នុង ១.០០០ កំណើតរស់ | ៨២ | ៨២ | | | ៧៥ |
| ១៦.០៣ | អត្រាមរណភាពមាតា | ក្នុង ១០០.០០០ កំណើតរស់ | ៤៧២ | | | | ២៤៣ |
| ១៦.០៤ | ការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ | % | ៤៤ | ៣៦ | ៤៦ | ៤៨ | ៥៥ |
| ១៦.០៥ | ករណីជម្ងឺគ្រុនចាញ់ : ព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ | ក្នុង១០០០ករណី | ៧,៣០ | ៥,១០ | ៤,០ | | ៣.៥ |
| ១៦.០៦ | ប្រេវ៉ាឡង់ជម្ងឺរបេងសួតវិជ្ជមានបេកា | ក្នុង១០០.០០០ | ២៦៩ | ពុំមានតួលេខ | ២៣៤* | ២២៥ | ២១៤ |
| ១៦.០៧ | ហ៊ីវ/អេដស៍ : អត្រាប្រេវ៉ាឡង់ចំណោមមនុស្សពេញវ័យ | %(១៥-៤៩ឆ្នាំ) | ០,៩ | ០,៩ | ០,៩ | <០,៦ | <០.៦ |
| ១៦.០៨ | មន្ទីរពេទ្យបង្អែក | ចំនួន | ៦៩ | ៦៩ | ៧៤ | ៧៦ | ៧៦ |
| ១៦.០៩ | មណ្ឌលសុខភាព | ចំនួន | ៩៦៥ | ៩៧២ | ៩៥៦ | ៩៨៥ | ១.២៤៦ |
| ១៦.១០ | ការទទួលបានទឹកស្អាត (ទីប្រជុំជន) | %នៃប្រជាជន | ៣៥ | ៣៧ | ៤០ | | ៧៥ |
| ១៦.១១ | ការទទួលបានអនាម័យ (ទីប្រជុំជន) | %នៃប្រជាជន | ៥៥ | | | | ៦៧ |
| **១៧.០០** | **អប់រំ** | | **២០០៥/០៦** | **២០០៦/០៧** | **២០០៧/០៨** | **២០០៨/០៩** | **២០០៩/១០** |
| ១៧.០១ | សាលាបឋមសិក្សា | ចំនួន | ៦.២៧៧ | ៦.៣៦៥ | ៦.៤៧៦ | | ពុំមានតួលេខ |
| ១៧.០២ | អត្រាពិតនៃការសិក្សា : សរុប | % | ៩១,៣ | ៩២,១ | ៩៣,៣ | | ១០០ |
| ១៧.០៣ | ប្រុស | % | ៩៣,០ | ៩៣,២ | ៩៣,២ | | ១០០ |
| ១៧.០៤ | ស្រី | % | ៨៩,៧ | ៩១,០ | ៩៣,៣ | | ១០០ |
| ១៧.០៥ | អត្រាគង់វង្សសិស្សថ្នាក់ទី១-ទី៦ | % | ៤៩,៣ | ៥២,៥ | | | ១០០ |
| ១៧.០៦ | ចំនួននៃសាលាមធ្យមសិក្សាបឋមភូមិ | ចំនួន | ៩១១ | ១.១១២ | ១.៣០៣ | | |
| ១៧.០៧ | អត្រាពិតនៃការសិក្សា : សរុប | % | ៣១,៣ | ៣៣,៧ | ៣៤,៨ | | ៥០ |
| ១៧.០៨ | ប្រុស | % | ៣២,១ | ៣៤,៣ | ៣៣,៧ | | ៥០ |
| ១៧.០៩ | ស្រី | % | ៣០,៤ | ៣៣,១ | ៣៥,៩ | | ៥០ |
| ១៧.១០ | អត្រាគង់វង្សសិស្សថ្នាក់ទី១-ទី៩ | % | ២៦,៣ | ២៩,៣ | | | ៥០ |
| ១៧.១១ | ចំនួនអក្ខរជនសរុបអាយុ ១៥-២៤ឆ្នាំ | % | ៨៤,៧ | ៨៤,៧ | ៨៤,៧ | | ៩៥ |
| **១៨.០០** | **កម្មវិធីសម្អាតមីន** | | | | | | |
| ១៨.០១ | ជនរងគ្រោះដោយសារមីនប្រចាំឆ្នាំ (ស្លាប់ និង របួស) | នាក់ | ៨៧៥ | ៤៥០ | ៣៥២ | ២៩០ | ២០៥ |
| ១៨.០២ | សរុបផ្ទៃដីដែលបានបោសសម្អាតមីន និងកាកសំណល់យុទ្ធភ័ណ្ឌសេសសល់ពីសង្គ្រាម[១] | ហត | ៣៣.០៣៦ | ៣៧.៣១១ | ៤២.៣១២ | ៤៥.៨៤៨ | ៥០.០០០ |
| | | | | | | | |

*សម្គាល់ : ចំពោះតួលេខលម្អិត សូមអានកថាខណ្ឌក្នុងជំពូក២ តាមលំដាប់នៃមុំរបស់យុទ្ធសាស្ត្រចតុកោណ ឬស្រាវជ្រាវក្នុងគេហទំព័ររបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន។*

** តួលេខប៉ាន់ស្មាន*

[១] តួលេខសរុបនៃផ្ទៃដីដែលបានបោសម្អាតមីន និងកាកសំណល់យុទ្ធភ័ណ្ឌសេសសល់ពីសង្គ្រាម គិតត្រឹមឆ្នាំនីមួយៗ ។

# ជំពូកទី១

## សេចក្តីផ្តើម និង ខ្លឹមសារសង្ខេប

១.០១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(*ផយអជ*) ២០០៦-២០១០ ដែលបានរៀបចំឡើង ក្នុងឆ្នាំ២០០៥ តាមរយៈ ការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រម ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ បន្ទាប់ពីមានការពិនិត្យពិភាក្សាយ៉ាងល្អិតល្អន់ជាច្រើនកម្រិត នៅក្នុងរង្វង់រាជរដ្ឋាភិបាលកម្ពុជា និង នៅក្នុងរដ្ឋសភានិងព្រឹទ្ធសភា ។ ផែនការនេះ តំណាងឱ្យការឯកភាពគ្នាមួយយ៉ាងទូលំទូលាយ លើការអភិវឌ្ឍរបស់កម្ពុជានាពេលអនាគត ហើយក៏ឆ្លុះបញ្ចាំងឱ្យឃើញជារូម អំពីគោលដៅនិងអាទិភាពចម្បងៗរបស់ប្រជាជនកម្ពុជា ក៏ដូចជា អំពីសក្តានុពលដែលមានលក្ខណៈប្រាកដនិយម និងលទ្ធភាពដែលអាចអនុវត្តបានជាក់ស្តែងនាពេលអនាគត ។ ដោយហេតុថា*ផយអជ* គឺជាឯកសារដែលអាចកែសម្រួលបានតាមស្ថានភាពជាក់ស្តែង និងសម្រាប់ការអនុវត្តជាក់ស្តែង នោះការអនុវត្តនិងវឌ្ឍនភាពក្នុងការអនុវត្តផែនការនេះ ត្រូវតែតាមដានត្រួតពិនិត្យនិងវាយតម្លៃយ៉ាងទៀងទាត់ ដើម្បីឱ្យការកែតម្រូវសមស្របទាំងឡាយអាចធ្វើទៅបាន ហើយក៏ដើម្បីឱ្យ គោលដៅ ចំណុចដៅ និងផែនការទាំងឡាយ អាចត្រូវបានកែតម្រូវឱ្យបានស្របគ្នាទៅនឹងទិន្នន័យថ្មីៗ និងស្ថានភាពជាក់ស្តែងផ្សេងៗទៀត ។

១.០២ ការអនុវត្ត*ផយអជ* ដែលបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ២០០៦ បានបញ្ចប់រយៈពេលពាក់កណ្តាលអាណត្តិរបស់ខ្លួន (រយៈពេលពីរឆ្នាំកន្លះ) នៅក្នុងខែមិថុនា ឆ្នាំ២០០៨ ។ ដោយមានការតាមដានត្រួតពិនិត្យនិងវាយតម្លៃយ៉ាងទៀងទាត់នៅកម្រិតវិស័យ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំកម្រិតជាតិសម្រាប់ឆ្នាំ២០០៦ ត្រូវបានរៀបចំឡើងនៅក្នុងឆ្នាំ២០០៧ ។ វិស័យនីមួយៗនិងក្រសួងទាំងឡាយ បានធ្វើការរៀបចំការវាយតម្លៃ អំពីការងាររបស់ខ្លួនដែលត្រូវបានធ្វើឡើងក្នុងរយៈពេលបួនឆ្នាំកន្លងមកទៅនេះ និងអំពីទិសដៅការងារដែលត្រូវធ្វើនាពេលអនាគត[១] ។

១.០៣ របាយការណ៍ពាក់កណ្តាលអណត្តិនេះ ពិនិត្យមើលជាលក្ខណៈសរុប នូវវឌ្ឍនភាពដែលបានធ្វើឱ្យកើតមានឡើង ក្នុងរយៈពេលពីរឆ្នាំកន្លះ ដោយលើកឡើងអំពីចំណុចខ្វះខាត និងមូលហេតុរបស់វា ។ របាយការណ៍នេះវាយតម្លៃប្រកបដោយភាពប្រាកដនិយម អំពីការងារដែលត្រូវធ្វើក្នុងពេលខាងមុខ ដោយលើកឡើងអំពីកិច្ចការដែលត្រូវយកចិត្តទុកដាក់ជាចាំបាច់ បញ្ហាប្រឈមដែលត្រូវជំនះ និងហានិភ័យដែលអាចស្មានទុកជាមុនបានដែលត្រូវគិតគូរដល់ ។ ការប្រែប្រួលនិងវឌ្ឍនភាពទាំងអស់ ដែលបានលើកឡើងរួចមកហើយ នៅក្នុងរបាយការណ៍

[១] ដូចបានបង្ហាញនៅក្នុងសន្និសិទជាតិមួយ នាចុងខែឧសភា ឆ្នាំ២០០៨ ។

វឌ្ឍនភាពប្រចាំឆ្នាំសម្រាប់២០០៦ ក៏មានរួមបញ្ចូលផងដែរ នៅក្នុងរបាយការណ៍ពាក់កណ្តាលអាណត្តិនេះ[១] ។ ឯកសារនេះ មិនមែនជាឯកសារមួយដែលគ្រាន់តែប្រមូលចងក្រងផ្តុំគ្នានូវការងារ ដែលត្រូវបានធ្វើឡើង និងដែលត្រូវធ្វើនៅក្នុងវិស័យទាំងអស់នោះទេ ។ របាយការណ៍នេះ គឺជាការវាយតម្លៃទិសដៅ និងជារបាយការណ៍ស្តីពីវឌ្ឍនភាពដែលមានរហូតមកទល់នឹងពេលនេះ និងស្តីពីការណែនាំដើម្បីពិនិត្យសិក្សាមើលអំពីគោលដៅទាំងឡាយ និងដើម្បីអនុវត្តឱ្យបានសម្រេចនូវគោលដៅទាំងនោះ តាមរបៀបមួយដែលមានលក្ខណៈសរុប និងដែលធ្វើឱ្យមានតុល្យភាពផ្នែកខ្លឹមសារ ។ ឯកសារនេះ ធ្វើការវិភាគបញ្ចូលគ្នានូវ ការសិក្សាស្រាវជ្រាវទាំងឡាយដែលបានធ្វើរួចមកហើយ និងការងារដែលនឹងត្រូវធ្វើ ។ របាយការណ៍នេះ ប្រមូលផ្តុំការយកចិត្តទុកដាក់លើវិស័យជាអាទិភាពទាំងឡាយ ស្របពេលដែលកម្លាំងជំរុញនឹងត្រូវរក្សាឱ្យមាននៅក្នុងវិស័យដទៃទៀត សម្រាប់លទ្ធផលដែលបានពីការប្រឹងប្រែងរួមគ្នា ។ ព័ត៌មានលម្អិតបន្ថែមលើសពីនេះស្តីពី វឌ្ឍនភាព ការវិភាគ និងកម្មវិធីទាំងឡាយអាចមាននៅក្នុងរបាយការណ៍នានា របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ[២] ។

១.០៤ ការពិគ្រោះយោបល់ និងការពិភាក្សាលម្អិតជាមួយអ្នកមានចំណែកពាក់ព័ន្ធសំខាន់ៗ និងការពិគ្រោះយោបល់រួមគ្នាជាមួយក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជា ជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ត្រូវបានធ្វើឡើង នៅក្នុងការរៀបចំរបាយការណ៍ពាក់កណ្តាលអណត្តិនេះ ដែលបានទាញយកនិងវិភាគ ព័ត៌មានទិន្នន័យ ទស្សនៈនិងការផ្តល់យោបល់ពី :

- ក្រសួង-ស្ថាប័នទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។
- ដៃគូអភិវឌ្ឍន៍នានា (ស្ថាប័នពហុភាគី ទ្វេភាគី និងអង្គការក្រៅរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងអង្គការសង្គមស៊ីវិល)[៣] ។
- អង្កេតផ្លូវការ និងការរកឃើញរបស់អង្កេតទាំងនោះ ។
- ការសិក្សាស្រាវជ្រាវ និងឯកសារបោះពុម្ពផ្សាយផ្សេងៗទៀត ។

១.០៥ ហេតុការណ៍និងការប្រែប្រួលទាំងឡាយ ដ៏គួរឱ្យកត់សម្គាល់ជាងគេ ដែលបានកើតមានឡើង ចាប់តាំងពីខែមករា ឆ្នាំ២០០៦ រហូតមកទល់ឥឡូវនេះ (ខែកញ្ញា ឆ្នាំ២០០៨) មាន ដូចខាងក្រោម :

- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ នៅក្នុងឆ្នាំ២០០៧ ដែលត្រូវបានធ្វើឡើងដោយគ្មានអំពើហិង្សា មានរបៀបរៀបរយ ហើយដោយសេរីនិងយុត្តិធម៌ ។

---

[១] យោងតាមន័យនេះ ព័ត៌មានដែលបានលើកឡើងរួចមកហើយ នៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំសម្រាប់ឆ្នាំ២០០៦ អាចត្រូវបានលើកឡើងម្តងទៀតនៅក្នុងកន្លែងជាច្រើន ក្នុងរបាយការណ៍នេះ ។

[២] សូមមើលបញ្ជីគេហទំព័រ នៅក្នុងឧបសម្ព័ន្ធ ៤.២ ។

[៣] នៅក្នុងករណីជាច្រើន ក្រុមការងារបច្ចេកទេសចម្រុះរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ត្រូវបានធ្វើឱ្យមានការចូលរួមនៅក្នុងការពិគ្រោះយោបល់ ។

ការប្រកាសផ្សាយទិន្នន័យរបស់អង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជាឆ្នាំ២០០៥ នៅក្នុងឆ្នាំ២០០៦ ។

ការរៀបចំនិងការបោះពុម្ពផ្សាយរបាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ២០០៧ នៅក្នុងឆ្នាំ២០០៧ ។

ការរៀបចំអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៧ ។

ការធ្វើជំរឿនទូទៅនូវប្រជាជនកម្ពុជាឆ្នាំ២០០៨ លទ្ធផលដំបូងប៉ាន់ស្មានថា ប្រជាជនកម្ពុជាមានចំនួន ១៣,៤លាននាក់ នៅក្នុងខែមីនា ឆ្នាំ២០០៨ ដោយមានអត្រាកំណើនមធ្យមប្រចាំឆ្នាំ ១,៥៤ភាគរយ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅ[១] ។

ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់នីតិកាលទី៤ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ដែលត្រូវបានធ្វើឡើងដោយគ្មានអំពើហិង្សា មានរបៀបរៀបរយ ហើយដែលត្រូវបានទទួលស្គាល់ជាទូទៅដោយអ្នកពាក់ព័ន្ធនិងគណៈបក្សនយោបាយទាំងអស់ថា មានភាពយុត្តិធម៌និងត្រឹមត្រូវ ដោយអនុញ្ញាតឱ្យមានសេរីភាពពេញលេញសម្រាប់ការបញ្ចេញមតិដោយចំហ ដោយគ្មានឧបសគ្គណាមួយ ។

រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ឆ្នាំ២០០៨-២០១៣ ត្រូវបានបង្កើតឡើង ហើយបានប្រកាសថា នឹងបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណជំហានទី២ ដែលជា *"របៀបវារៈគោលនយោបាយសេដ្ឋកិច្ច-សង្គមកិច្ច"* នៃ *"កម្មវិធីនយោបាយ"* របស់ខ្លួន ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានសម្រេចចិត្តថា ដំណាក់កាលនៃ*ផយអជ* និងផែនការយុទ្ធសាស្ត្រតាមវិស័យ ត្រូវរៀបចំឱ្យដូចគ្នានឹងដំណាក់កាលនៃយុទ្ធសាស្ត្រចតុកោណជំហានទី២[២] ។

១.០៦ សមិទ្ធផលមួយចំនួនដូចមានរៀបរាប់ខាងក្រោម គឺស្ថិតនៅក្នុងចំណោមសមិទ្ធផលធំៗ ដែលបានធ្វើឱ្យកើតមានឡើង នៅក្នុងរយៈពេលពីរឆ្នាំកន្លះកន្លងទៅនេះ :

សន្តិភាពផ្ទៃក្នុង ស្ថេរភាពនយោបាយនិងសង្គម និងសន្តិសុខ ត្រូវបានបន្តលើកកម្ពស់និងពង្រឹងបន្ថែមទៀត។

អភិបាលកិច្ចសាធារណៈ ត្រូវបានបន្តកែលម្អ តាមរយៈ កំណែទម្រង់ប្រព័ន្ធច្បាប់ និងកំណែទម្រង់រដ្ឋបាលសាធារណៈ តាមរូបភាពជាច្រើន ។

ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ត្រូវបានកែលម្អនិងពង្រឹង ជាបន្ថែមទៀត ។ ( ឆ្នាំ២០០០ ត្រូវបានប្រើប្រាស់ជាឆ្នាំគោល សម្រាប់គ្រប់ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចទាំងអស់ ) ។

ទោះបីបន្ទាប់ពីបានឈានដល់កម្រិតខ្ពស់នៃកំណើន គឺ ១៣,៣ភាគរយ នៅក្នុងឆ្នាំ២០០៥ ក៏ដោយ ក៏ផលិតផលក្នុងស្រុកសរុប ( *ផសស*) នៅតែបន្តកើនឡើងនៅក្នុងកម្រិតខ្ពស់ ទោះបីជាមានការថយចុះខ្លះនៅក្នុងពេលថ្មីៗកន្លងទៅនេះក៏ដោយ ។ ទន្ទឹមនឹងនេះ កំណើន*ផសស* ហាក់ដូចជាបន្តបានមកតែពី

[១] សូមអានកថាខណ្ឌ ២.៨៦ ។ ព័ត៌មានលម្អិតមាននៅក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ ។

[២] សូមអានកថាខណ្ឌ ២.១៤ ដល់ ២.១៦ ។

ប្រភពពីរ-បី ដដែល គឺឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ទេសចរណ៍ និងសំណង់ ដែលបាននាំឱ្យមានកំណើនទូទៅ ។

ការងារសារពើពន្ធ បានបន្តភាពល្អប្រសើរ ជាមួយនឹងការកើនឡើងយ៉ាងលឿននៃចំណូល និងការកើនឡើងបន្តិចម្តងៗ នៃវិភាជន៍ថវិកាដល់វិស័យសង្គមកិច្ច ។

កម្រិតអតិផរណា ត្រូវបានស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងល្អ រហូតដល់ឆ្នាំ២០០៦ ប៉ុន្តែកម្រិតអតិផរណា មាននិន្នាការកើនឡើងនៅក្នុងចុងឆ្នាំ២០០៧ និងក្នុងឆ្នាំ២០០៨ ។

វិស័យឯកជន បានរីកចម្រើនយ៉ាងខ្លាំង ជាមួយនឹងការរីកលូតលាស់នៃស្ថាប័នហិរញ្ញវត្ថុ និងការវិនិយោគដោយសារមានការប្រែប្រួលជាវិជ្ជមានជាច្រើន ។

ការកើនឡើងនៃទំនុកចិត្តនិងភាពកក់ក្តៅជាងមុនរបស់ផ្នែកឯកជនចំពោះអនាគតរបស់កម្ពុជា កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ការធ្វើឱ្យប្រសើរឡើងច្រើនទ្វេរការប្រមូលចំណូល គឺគ្រាន់តែជាឧទាហរណ៍មួយចំនួនតូច ដែលផ្តល់ភស្តុតាង ពីការលើកកម្ពស់តម្លាភាព ភាពដែលអាចដឹងជាមុនបាន និងគណនេយ្យភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយដែលជាសូចនាករដែលបង្ហាញយ៉ាងច្បាស់ពីការថយចុះនៃកម្រិតអំពើពុករលួយក្នុងប្រព័ន្ធការងាររបស់រាជរដ្ឋាភិបាលកម្ពុជា ។

កំណើនក្នុងវិស័យកសិកម្ម ជាពិសេស ផលិកម្មស្រូវ នៅតែបន្តមានកំណើន ទោះបីក្នុងកម្រិតថយចុះជាងមុន បន្ទាប់ពីបានឈានដល់កម្រិតខ្ពស់ដែលមិនធ្លាប់មានពីមុន នៅក្នុងឆ្នាំ២០០៥ ដោយមានស្ថានភាពអនុគ្រោះពីអាកាសធាតុ និងការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធស្រោចស្រពរបស់រាជរដ្ឋាភិបាលកម្ពុជា ។

វិស័យផ្សេងៗទៀត បានបង្ហាញពីការរីកចម្រើនដែលបានកើតមានឡើងជាបន្តបន្ទាប់ ។

ការរីកចម្រើនទាំងនេះ ត្រូវបានប៉ាន់ស្មានថា នឹងកាត់បន្ថយភាពក្រីក្រពីកម្រិត ៣៤,៧ភាគរយ ក្នុងឆ្នាំ២០០៤ ដល់ ៣០,១ភាគរយ នៅឆ្នាំ២០០៧ ដែលជាការប៉ាន់ស្មានចុងក្រោយបំផុតផ្អែកលើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ២០០៧ ។

ការធ្វើឱ្យប្រសើរឡើងដ៏គួរឱ្យកត់សម្គាល់ជាច្រើន ដែលបានទទួលស្គាល់ជាទូទៅ បានកើតមានឡើងនៅក្នុងវិស័យសង្គមកិច្ចសំខាន់ៗមួយចំនួន : សូចនាករសំខាន់ៗ បានមកពីអង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ដូចជា អត្រាមរណភាពទារក អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ និងអត្រាប្រេវ៉ាឡង់ហ៊ីវ/អេដស៍ មានស្ថានភាពល្អប្រសើរជាងស្ថានភាពដែលបានប៉ាន់ស្មានពីមុនយ៉ាងច្រើន ហើយក្នុងករណីខ្លះ បានសម្រេចរួចហើយនូវចំណុចដៅដែលបានកំណត់សម្រាប់ឆ្នាំ២០១០ ។

សូចនាករក្នុងវិស័យអប់រំ បានបង្ហាញពីភាពប្រសើរឡើងនៅក្នុងវិស័យនេះ ។

១.០៧ ទោះជាដូចនេះក្តី វឌ្ឍនភាពនៅក្នុងរយៈពេលពីរឆ្នាំកន្លះកន្លងទៅនេះ មានកម្រិតទាបជាងការរំពឹងទុក ឬក៏ស្ថិតនៅទ្រឹង ឬក្នុងករណីខ្លះ បញ្ហានានាបាននឹងកំពុងលេចឡើងនៅក្នុងទិដ្ឋភាព ដូចតទៅ :

ទន្ទឹមនឹងយុទ្ធសាស្ត្រនៅតាមវិស័យមួយចំនួន ត្រូវបានរៀបចំឡើងនិងកំពុងត្រូវបានអនុវត្តនោះ នៅវិស័យជាច្រើនទៀតក៏នឹងត្រូវរៀបចំយុទ្ធសាស្ត្រ[១] ដូចនេះដែរ ។

- ពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ច ទៅជាវិស័យផលិតផ្សេងៗទៀត ដែលបានចាប់ផ្ដើមរួចហើយ ត្រូវការជំរុញបន្ថែមទៀត ។

ផលិតកម្មនិងផលិតភាពនៃវិស័យកសិកម្មទាំងមូល មិនទាន់បានលើកកម្ពស់ឱ្យបានខ្លាំងក្លានៅឡើយ ។

កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ប្រព័ន្ធច្បាប់ ត្រូវធ្វើឱ្យមានវឌ្ឍនភាពបន្ថែមទៀត ។

ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ដែលជាកត្តាចម្បងនៃកំណើន ហាក់ដូចជាស្ថិតនៅស្ថេរនៅឡើយ ។

ការតម្រឹមតម្រង់ធនធានរបស់ដៃគូអភិវឌ្ឍន៍ជាមួយនឹង*ផយអជ* មិនបានដំណើរការល្អនោះទេ ទោះបីជាមានការទទួលខុសត្រូវជាច្រើន ដែលបានកំណត់នៅក្នុងវេទិកាអន្តរជាតិទាំងឡាយ ការឯកភាពគ្នាកម្រិតប្រទេស ដែលត្រូវបានធ្វើឡើងដោយស្ថាប័នអ្នកផ្ដល់ជំនួយក៏ដោយ ។

ក្រុមការងារបច្ចេកទេសចម្រុះរវាងរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ជាច្រើនមិនទាន់ចាប់ផ្ដើមការពិនិត្យមើលឡើងវិញនូវកម្មវិធីកំពុងដំណើរការទាំងឡាយ ដើម្បីតម្រឹមតម្រង់ និងតម្រង់ទិសជាថ្មីឡើងវិញនូវកម្មវិធីទាំងនោះ ជាមួយនឹងអាទិភាពរបស់*ផយអជ* នៅឡើយ ទោះបីជាមានការអំពាវនាវយ៉ាងច្បាស់ពីថ្នាក់ដឹកនាំកំពូលរបស់រាជរដ្ឋាភិបាលកម្ពុជា[២] ក៏ដោយ ។

នៅក្នុងរង្វង់រាជរដ្ឋាភិបាលកម្ពុជា ការងារជាច្រើនដែលនឹងត្រូវធ្វើឡើងជាចាំបាច់ រួមមាន (ក) លើកកម្ពស់និងកែលម្អកិច្ចសហការអន្តរនាយកដ្ឋាននិងអន្តរក្រសួង (ខ) ការធ្វើឱ្យមានវឌ្ឍនភាពក្នុងការធ្វើសុខដុមនីយកម្មដំណើរការ*ផយអជ* កម្មវិធីវិនិយោគសាធារណៈ ការរៀបចំថវិកាប្រចាំឆ្នាំ[៣] (គ) ការធ្វើសុខដុមនីយកម្មមូលដ្ឋានទិន្នន័យរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមូលដ្ឋានទិន្នន័យរបស់កម្មវិធីវិនិយោគរបស់ក្រសួងផែនការ ដែលមានសារៈសំខាន់សម្រាប់ការធ្វើឱ្យប្រសើរឡើង នូវការសម្របសម្រួលនិងការតាមដានត្រួតពិនិត្យជំនួយរបស់ដៃគូអភិវឌ្ឍន៍) ។

១.០៨ **ជាការពិត ការប្រែប្រួលសំខាន់ៗភាគច្រើនបំផុត**នៅក្នុងដំណាក់កាលនេះ ដែលបានចាប់ផ្ដើមភ្លាមៗនៅក្នុងអំឡុងពេលចុងឆ្នាំ២០០៧ ហើយមានសន្ទុះយ៉ាងលឿន និងកំពុងបន្តទៅមុខទៀតឥតថមថយនៅក្នុងឆ្នាំ២០០៨ គឺជាបាតុភូតសាកលដ៏គួរឱ្យព្រួយបារម្ភចំនួនបួនដែលគេមិនអាចដឹងមុនបាន ហើយកំពុងនៅតែវិវត្ត និងកំពុងត្រូវបានគេស្វែងយល់ពីមូលហេតុរបស់វា ។ បាតុភូតទាំងនេះ មិនត្រឹមតែគំរាមកំហែងដល់ អនាគតសាកលលោកនិង

---

[១] ព័ត៌មានលម្អិតមាននៅក្នុងចំណុច នៃកថាខណ្ឌ ២.០៨ ។

[២] អារម្ភកថារបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុង*ផយអជ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ* និងសុន្ទរកថាផ្សេងៗទៀតក្នុងវេទិកាក្នុងនិងក្រៅប្រទេស ។

[៣] សូមអាន កថាខណ្ឌ ៤.១០ ផងដែរ ។

កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង បង្ហាញនូវសញ្ញាដ៏គួរឱ្យព្រួយបារម្ភ អំពីការរិចរិលនៃកម្លាំងជំរុញនិងជោគជ័យដែលសម្រេចបានរួចហើយ ជាពិសេស នៅក្នុងការកាត់បន្ថយភាពក្រីក្រ :

- ការកើនឡើងយ៉ាងលឿននៃតម្លៃអន្តរជាតិរបស់ប្រេងឥន្ធនៈ ដែលកំពុងមានការថយចុះតិចតួចពីកម្រិតខ្ពស់បំផុត បានធ្វើឱ្យមានការកើនឡើងតម្លៃនៃការចំណាយលើសកម្មភាពសេដ្ឋកិច្ចភាគច្រើនបំផុត ។

  វិបត្តិហិរញ្ញវត្ថុ និងការធ្លាក់ចុះភ្លាមៗយ៉ាងខ្លាំងនៃបរិមាណឥណទានសម្រាប់ការខ្ចីចងការពីធនាគារ ឬការកើនឡើងភ្លាមៗនៃតម្លៃការប្រាក់ខ្ចីពីធនាគារ ដែលបានលេចឡើងនៅក្នុងទំហំមួយដែលមិនធ្លាប់មានពីមុន កំពុងតែកើតមានជាបន្ត ដោយមិនមានបង្ហាញពីសញ្ញាណាមួយនៃទីបញ្ចប់ឡើយ ។ បាតុភូតទាំងនេះដែលមានផលប៉ះពាល់ទូទាំងពិភពលោក បានធ្វើឱ្យល្បឿនសេដ្ឋកិច្ចនៅក្នុងប្រទេសភាគច្រើនបំផុត មានការថយចុះ ហើយប្រទេសមួយចំនួនក្នុងចំណោមប្រទេសទាំងនោះ បានឈានទៅដល់មាត់ច្រកនៃការធ្លាក់ចុះសេដ្ឋកិច្ច ។

  អតិផរណាកើតមានជាទូទៅនៅទូទាំងពិភពលោក ក្នុងថ្លៃទំនិញសំខាន់ៗ ។

  ថ្លៃស្បៀងអាហារបានកើតឡើងជិតពីរដង នៅក្នុងពីរឆ្នាំចុងក្រោយនេះ ហើយភាគច្រើនការកើនឡើងដ៏លឿននេះបាននិងកំពុងកើតឡើងនៅក្នុងឆ្នាំ២០០៨ ។ ថ្លៃស្រូវ/អង្ករតែមួយមុខបានកើនឡើងជិតបីដងចាប់តាំងពីឆ្នាំ២០០៧ ។

១.០៩ ការវិវត្តប្រែប្រួលទាំងអស់ ដែលបានលើកឡើងដោយសង្ខេបនៅក្នុងកថាខ័ណ្ឌមុនៗ បង្ហាញនូវភាពចាំបាច់បំផុត ក្នុងការប្រឹងប្រែងអនុវត្ត ដោយមានថាមភាពនិងការប្តេជ្ញាចិត្តជាថ្មី ដើម្បីធ្វើឱ្យសម្រេចបាននូវអាទិភាពដែលគាំទ្រប្រជាជនក្រីក្រនិងជនបទ ដែលបានកំណត់រួចមកហើយនៅក្នុង*ផយអជ* ដូចជា **ការអភិវឌ្ឍកសិកម្មនិងជនបទ**[១] ។ អាទិភាពនេះ គឺជាអាទិភាពតែមួយគត់ ដែលអាចផ្តល់នូវផលប្រយោជន៍ចំពោះមុខនិងយូរអង្វែង ក៏ដូចជា បណ្តាញសុវត្ថិភាពដ៏ឆាប់រហ័សសម្រាប់ប្រជាជនក្រីក្រ ដែលភាគច្រើនរស់នៅតំបន់ជនបទ អាចបង្កើនអំណាចទិញនិងសុខុមាលភាពរបស់ពួកគាត់ ហើយអាចធ្វើពិពិធកម្មនិងពង្រឹងសេដ្ឋកិច្ចទូទៅ នៅលើមូលដ្ឋានមួយដែលមានចីរភាព ។ លទ្ធភាពដ៏ធំមួយនឹងអាចមានសម្រាប់ការបង្កើន និងផលិតភាពនិងការធ្វើពិពិធកម្មផលិតកម្ម ។ រាជរដ្ឋាភិបាលកម្ពុជា ផ្តល់អាទិភាពខ្ពស់បំផុតដល់ កិច្ចខិតខំប្រឹងប្រែងអនុវត្តឱ្យបានសម្រេចនូវគោលដៅនេះ ។

១.១០ ជាមួយគ្នានឹងកិច្ចខិតខំប្រឹងប្រែងអនុវត្តឱ្យសម្រេចបាន នូវគោលដៅនិងចំណុចដៅផ្សេងទៀត ដែលបានកំណត់និងគូសបញ្ជាក់រួចមកហើយនៅក្នុង*ផយអជ* សម្រាប់ការកាត់បន្ថយភាពក្រីក្រយ៉ាងលឿន ជាពិសេស

[១] *ផយអជ* បានបែងចែក ៦០ភាគរយ នៃការវិនិយោគ ទៅដល់តំបន់ជនបទ ។

នៅតំបន់ជនបទដាច់ស្រយាល រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈនឹងផ្តោតការយកចិត្តទុកដាក់ជាពិសេស លើអាទិភាពខ្ពស់ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមទាំងឡាយ ដែលបានរកឃើញនៅក្នុងការវិភាគពីមុនៗ និងការវិភាគថ្មីៗ ដែលនឹងបញ្ចប់ក្នុងពេលឆាប់ៗ ។ រាជរដ្ឋាភិបាលកម្ពុជា រំពឹងរង់ចាំកិច្ចសហប្រតិបត្តិការយ៉ាងពេញលេញពីដៃគូអភិវឌ្ឍន៍នៅពេលណាចាំបាច់នៅក្នុងការប្រឹងប្រែងអនុវត្តយ៉ាងសកម្ម ដើម្បីឱ្យសម្រេចបាននូវគោលដៅ និងចំណុចដៅទាំងនោះ ។ បញ្ហាប្រឈមទាំងនោះរួមមាន ដូចខាងក្រោម :

ត្រូវរក្សាកម្រិតអតិផរណាដែលបណ្តាលយ៉ាងច្រើនមកពីកត្តាក្រៅប្រទេស ឱ្យស្ថិតនៅក្នុងកម្រិតទាបល្មម ។

ត្រូវរក្សាស្ថេរភាពនិងកំណើនម៉ាក្រូសេដ្ឋកិច្ច ទោះបីជាមានសម្ពាធពីអតិផរណានិងពីកត្តាក្រៅប្រទេសក៏ដោយ ។

ត្រូវផ្តល់នូវបណ្តាញសុវត្ថិភាពសង្គមដល់ប្រជាជនក្រីក្រ នៅក្នុងអំឡុងពេលដែលមានបញ្ហាអតិផរណា ជាពិសេស ក្នុងពេលដែលមានកង្វះស្រូវ/អង្ករ តាមរយៈ ការជួយបំពេញថ្លៃនិងការមិនយកពន្ធលើមុខទំនិញសំខាន់ៗ សម្រាប់ក្រុមគោលដៅ ។

ត្រូវការពារស្ថេរភាពនិងការលើកកម្ពស់ផ្នែកសារពើពន្ធ ទោះបីជាមានសម្ពាធបន្ថែមមកលើចំណូល និងចំណាយដែលបានបង្កើនឡើង ។

បង្កើនល្បឿនដំណើរការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ។

ត្រូវធានាឱ្យមានការប្រើប្រាស់យ៉ាងប្រសើរបំផុតនូវធនធានសម្រាប់ការអភិវឌ្ឍ ហើយសម្រាប់ការងារនេះ ត្រូវមានការប្រឹងប្រែងអនុវត្តឱ្យបានឆាប់រហ័ស និងត្រូវតម្រឹមតម្រង់នូវធនធានរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់ ជាមួយនឹងអាទិភាពរបស់ *ផយអជ* ។

ការធ្វើសុខដុមនីយកម្មរវាងដំណើរការរបស់ *ផយអជ* កម្មវិធីវិនិយោគសាធារណៈ និងការរៀបចំថវិកានៅក្នុងរង្វង់រាជរដ្ឋាភិបាលកម្ពុជា និងត្រូវផ្គុំគ្នានូវមូលដ្ឋានទិន្នន័យរបស់គណៈកម្មាធិការនីតិសម្បទានិងអភិ-វឌ្ឍន៍កម្ពុជា របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាមួយនឹងមូលដ្ឋានទិន្នន័យរបស់កម្មវិធីវិនិយោគរបស់ក្រសួងផែនការ ដើម្បីទទួលបាននូវស្ថានភាពជាក់ស្តែង ហើយដើម្បីធ្វើឱ្យដៃគូអភិវឌ្ឍន៍ក្រៅប្រទេសអាចតម្រង់ធនធានរបស់ពួកគេឡើងវិញមកជាមួយនឹងអាទិភាពរបស់ *ផយអជ* ។

ត្រូវធានាថាចំណូលមកពីប្រេងកាត ក៏ដូចជាមកពីធនធានធម្មជាតិទាំងអស់ ដែលជាកេរ្តិ៍មរតករួមរបស់ប្រជាជនកម្ពុជាទាំងអស់ ដែលត្រូវបានរំពឹងថា បានចាប់ពីឆ្នាំ២០១១ ត្រូវបានប្រើប្រាស់តាមរបៀបមួយប្រកបដោយការប្រុងប្រយ័ត្ន សំដៅផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់ក្នុងពេលបច្ចុប្បន្ន និងពេលអនាគត ។

១.១១ ដោយផ្អែកលើកត្តាទាំងអស់ តម្រូវការចំណាយសរុប សម្រាប់ការវិនិយោគសាធារណៈ ពីឆ្នាំ២០០៦-២០១០ បានកើនឡើង ២០ភាគរយ ពោលគឺ ពី ៣.៥០០ ដល់ ៤.២០០លានដុល្លារអាមេរិក ។

១.១២ កត្តាជាច្រើនដែលពិបាកប៉ាន់ស្មានជាមុន នៅតែបង្កការលំបាកដល់ការងារដែលត្រូវធ្វើនៅពេលខាងមុខ ដោយតម្រូវឱ្យមានការប្រកាន់យកនូវការប្រុងប្រយ័ត្នយ៉ាងខ្ជាប់ខ្ជួន :

- ស្ថានភាពពិភពលោក នឹងមិនមានភាពប្រសើរឡើងវិញបានឆាប់ៗទេ ឬនៅតែអាក្រក់ ហើយនឹងកាន់តែធ្លាក់ចុះក្នុងវិបត្តិថែមទៀត ។
- ជំនួយរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសមានការធ្លាក់ចុះ គិតតាមតម្លៃពិត ហើយនឹងមិនតម្រឹមតម្រូវជាមួយនឹងអាទិភាពរបស់ *ផយអជ* បានភ្លាមៗទេ ។
- ការប្រែប្រួលយ៉ាងខ្លាំងនៃអាកាសធាតុបង្កើតឱ្យកើតមានឡើងនូវគ្រោះធម្មជាតិផ្សេងៗ ខុសពីធម្មតា ។
- ជំងឺប្លែកៗ លេចឡើងនិងរីករាលដាលភ្លាមៗ ដូចជា ជំងឺគ្រុនផ្ដាសាយបក្សី ជាដើម ។
- ចំណូលដែលបានរំពឹងទុកថាបានមកពីធនធានប្រេងកាតនិងឧស្ម័នធម្មជាតិ ត្រូវបានពន្យារបន្តទៀត ។

១.១៣ ទិដ្ឋភាពទាំងអស់របស់ *ផយអជ* ដូចជា វឌ្ឍនភាពដែលមានរហូតមកទល់ពេលនេះ ការព្យាករណ៍និងកម្មវិធីទាំងឡាយ ព្រមទាំងចំណុចដៅនិងចំណាយផ្នែកហិរញ្ញវត្ថុដែលបានធ្វើបច្ចុប្បន្នភាព ក៏ដូចជា អាទិភាពទាំងឡាយ ដូចបានលើកឡើងខាងលើនឹងត្រូវពិពណ៌នាលម្អិតនៅក្នុងជំពូកនិងឧបសម្ព័ន្ធបន្តបន្ទាប់ :

*ជំពូកទី២* : វឌ្ឍនភាព ការរំពឹងទុកជាមុន និង គម្រោងការងារ

*ជំពូកទី៣* : គោលដៅ និង ចំណុចដៅ អាទិភាព

*ជំពូកទី៤* : ការកំណត់ចំណាយ ធនធាន និង ការរៀបចំកម្មវិធី

*ជំពូកទី៥* : ការតាមដានត្រួតពិនិត្យ និង វាយតម្លៃ

*ជំពូកទី៦ :* សេចក្ដីសន្និដ្ឋាន

**ឧបសម្ព័ន្ធ**

*ឧបសម្ព័ន្ធ ១.១* : កម្ពុជា : សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ

*ឧបសម្ព័ន្ធ ១.២* : កម្ពុជា : ការប៉ាន់ស្មានការបែងចែកចំណាយចរន្តនៃថវិកា

*ឧបសម្ព័ន្ធ ១.៣* : កម្ពុជា : ការព្យាករណ៍ការវិនិយោគសម្រាប់ ឆ្នាំ២០០៦-២០១០

*ឧបសម្ព័ន្ធ ២.១* : កម្មវិធីវិនិយោគសាធារណៈ ២០០៦-២០០៨ : តារាងទី ១ : សង្ខេបតាមវិស័យ

*ឧបសម្ព័ន្ធ ២.២* : កម្មវិធីវិនិយោគសាធារណៈ ២០០៧-២០០៩ : តារាងទី ១ : សង្ខេបតាមវិស័យ

*ឧបសម្ព័ន្ធ ២.៣* : កម្មវិធីវិនិយោគសាធារណៈ ២០០៨-២០១០ : តារាងទី ១ : សង្ខេបតាមវិស័យ

*ឧបសម្ព័ន្ធ ២.៤* : កម្មវិធីវិនិយោគសាធារណៈ ២០០៩-២០១១ : តារាងទី ១ : សង្ខេបតាមវិស័យ

*ឧបសម្ព័ន្ធ ៣* : ក្របខ័ណ្ឌតាមដានត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

*ឧបសម្ព័ន្ធ ៤.១* : ពាក្យបំព្រួញ

*ឧបសម្ព័ន្ធ ៤.២* : គេហទំព័ររបស់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា

# ជំពូកទី២

## វឌ្ឍនភាព ការរំពឹងទុក និងសំណើគោលនយោបាយ

២.០១ ដោយបានងើបចេញពីយុគ្គសម័យដ៏ខ្មៅងងឹតនៃប្រវត្តិសាស្ត្ររបស់ខ្លួន នៅក្នុងខែមករា ឆ្នាំ១៩៧៩ កម្ពុជាបានចាប់ផ្តើមកសាងប្រទេសជាតិដោយខ្លួនឯងឡើងវិញពីគំនរផេះផង់ ទោះបីជាមានការផ្តាច់ចេញដ៏អយុត្តិធម៌ពីសហគមន៍អន្តរជាតិ រហូតដល់ឆ្នាំ១៩៩១ ក៏ដោយ ។ ដោយផ្អែកលើមូលដ្ឋានដ៏រឹងមាំនេះ និងបន្ទាប់ពីការបោះឆ្នោតជាសាកលនៅឆ្នាំ១៩៩៣ ទៅតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសមក វឌ្ឍនភាពដែលបានជំរុញឱ្យមានរួចហើយ បានចាប់ផ្តើមនៅក្នុងការកសាងស្ថាប័ន និងសេដ្ឋកិច្ច ប៉ុន្តែត្រូវបានបង្កការលំបាកដោយអស្ថេរភាពនយោបាយ និងការបះបោរប្រឆាំងនឹងរដ្ឋាភិបាលដោយកម្លាំងមិនស្របច្បាប់ ។ ទើបតែចាប់តាំងពីឆ្នាំ១៩៩៨មកប៉ុណ្ណោះ ដែលវឌ្ឍនភាពពិតប្រាកដអាចចាប់ផ្តើមកើតមានឡើងបានជាមួយនឹងសន្តិភាពពេញលេញនៅទូទាំងផ្ទៃប្រទេស ។ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) ២០០៦-២០១០* ត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានរឹងមាំនៃ ស្ថេរភាព សន្តិភាព មូលដ្ឋានសេដ្ឋកិច្ច ព្រមទាំងកំណត់នូវ គោលដៅ និងផែនការ ដើម្បីវឌ្ឍនភាពរឹងមាំនិងប្រកបដោយចិរភាព តាមរបៀបមួយដែលបញ្ចូលគ្នានូវគ្រប់យុទ្ធសាស្ត្រតាមវិស័យទាំងអស់ដោយផ្តោតលើគោលនយោបាយគាំទ្រអ្នកក្រីក្រ និងគាំទ្រតំបន់ជនបទ ។

២.០២ រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់យ៉ាងច្បាស់ជាថ្មីម្តងទៀត នៅក្នុង*ផយអជ* ពីចក្ខុវិស័យរបស់ខ្លួន ក្នុងការដឹកនាំប្រទេសកម្ពុជាឆ្ពោះទៅមុខ ដោយផ្អែកលើគោលការណ៍[១] ដូចខាងក្រោម :

- ការប្រកាន់ខ្ជាប់នូវលទ្ធិប្រជាធិបតេយ្យក្នុងអភិបាលកិច្ច ដែលពលរដ្ឋកម្ពុជាគ្រប់រូបអាចធ្វើការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនដោយសេរី ដើម្បីដឹកនាំសង្គមជាតិនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។
- ការការពារសិទ្ធិបុគ្គល និងសិទ្ធិមនុស្ស រួមទាំងសេរីភាពពេញលេញក្នុងការបញ្ចេញមតិ ។
- ការថែរក្សាសន្តិភាព ស្ថេរភាពនយោបាយ នីតិរដ្ឋ សមភាព និងសណ្តាប់ធ្នាប់សង្គម ។
- រាជរដ្ឋាភិបាលកម្ពុជាគ្រប់លំដាប់ថ្នាក់ត្រូវមាន ការឆ្លើយតប ការទទួលខុសត្រូវ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសមត្ថភាពអាចដឹងជាមុនបានយ៉ាងពេញលេញ ។
- រាជរដ្ឋាភិបាលកម្ពុជាត្រូវធានាឱ្យមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច បង្កើតនិងថែរក្សាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងស្ថាប័នសំខាន់ៗ ក៏ដូចជា បង្កើតបរិស្ថានលើកទឹកចិត្តនិងក្របខ័ណ្ឌច្បាប់មួយសម្រាប់កិច្ចដំណើរការ និងការរីកចម្រើនរបស់វិស័យឯកជន ។

---

[១] *ផយអជ,* កថាខណ្ឌ ៥.០២ ។

រាជរដ្ឋាភិបាលកម្ពុជា ត្រូវផ្តល់សេវាសង្គមសំខាន់ៗ សម្រាប់ការបង្កើតនិងការលើកកម្ពស់មូលធនមនុស្ស (វិស័យសុខាភិបាល អប់រំ ការអភិវឌ្ឍវប្បធម៌ជាតិ) ហើយក្នុងន័យនេះ ត្រូវបង្កើតបរិស្ថានមួយដែលអាចឱ្យបុគ្គលគ្រប់រូបធ្វើការស្វែងរកនិងធ្វើឱ្យសម្រេចនូវសក្តានុពលពេញលេញរបស់ពួកគេ និងធ្វើការរួមចំណែកលើកកម្ពស់សុខុមាលភាពផ្ទាល់ខ្លួនរបស់ពួកគេ និងការរីកចម្រើនរបស់ប្រទេសជាតិ ។

រាជរដ្ឋាភិបាលកម្ពុជាត្រូវធានាការគ្រប់គ្រងប្រកបដោយចីរភាព លើបរិស្ថាននិងធនធានធម្មជាតិរបស់ជាតិ (ព្រៃឈើ ជលផល ដី ទឹក និងជីវចម្រុះ)ដែលស្ថានភាពជីវភាពរស់នៅនិងសុខុមាលភាពរបស់មនុស្សត្រូវផ្អែកលើមូលដ្ឋានទាំងនេះ ។

២.០៣ បន្ថែមលើនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានបញ្ជាក់នៅក្នុង*ផយអជ* ដែរថា ក្នុងរយៈពេល១០ឆ្នាំខាងមុខ (២០០៦-២០១៥) គឺជា*ទសវត្សរ៍មួយនៃកាលានុវត្តភាព* និងគឺជាពេលវេលាដែលត្រូវទាញការផ្តោតការយកចិត្តទុកដាក់ពី "ការអង្កេតនិងសិក្សាកម្រិតខ្ពស់ សម្រាប់បង្កើតនិងសកម្មភាពជាក់ស្តែង ដើម្បីជំរុញវឌ្ឍនភាពនៅក្នុងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា[១]" ។ បណ្តាយុទ្ធសាស្ត្រ និងសកម្មភាព ដែលត្រូវសម្រេចឱ្យបាននោះគឺ :

បញ្ចូលការកាត់បន្ថយភាពក្រីក្រ និងបញ្ហាសមធម៌យេនឌ័រ ទៅក្នុងគ្រប់សកម្មភាពទាំងអស់ ។

ជំរុញឱ្យកំណែទម្រង់ទាំងឡាយនៅក្នុងវិស័យទាំងអស់ឱ្យបានលឿន ដោយកំណែទម្រង់ទាំងនេះនឹងផ្តល់ផលប្រយោជន៍សម្រាប់រយៈពេលវែង ប៉ុន្តែសម្រាប់រយៈពេលខ្លី កំណែទម្រង់ទាំងនេះអាចនឹងធ្វើឱ្យមានការលំបាកក្នុងការធ្វើការសម្រេចចិត្ត ។

ជំរុញនិងសម្រួលឱ្យមានកំណើនម៉ាក្រូសេដ្ឋកិច្ចប្រកបដោយសមធម៌ ដែលបែងចែកបានសមស្របតាមតំបន់និងតាមវិស័យ ដែលមានលក្ខណៈជាប្រព័ន្ធ ដែលរឹងមាំ និងប្រកបដោយចីរភាព ដែលអាចផ្តល់កាលានុវត្តភាពនិងផលប្រយោជន៍បានទាន់ពេលវេលាចំពោះប្រជាជនគ្រប់រូប ។

បង្កើនឱ្យបានខ្លាំងនូវ "ការវិនិយោគពិតប្រាកដ " សម្រាប់កំណើន ដូចជា ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (ទីប្រជុំជន ជនបទ និងជាតិ) ក្នុងវិស័យផលិតនានា ដូចជា កសិកម្មនិងឧស្សាហកម្ម និងក្នុងការអភិវឌ្ឍមនុស្ស (វិស័យសុខាភិបាល និងអប់រំ) ។

តម្រង់ទិសដៅទៅរកប្រជាជនដែលខ្វះខាតបំផុត និងដែលទទួលបានសេវាកម្មតិចតួចបំផុត រួមមានប្រជាជនដែលខ្វះសមត្ថភាពពលកម្មនិងប្រជាជនជាជនជាតិដើមភាគតិច និងវិស័យទាំងឡាយណាដែលជួយកាត់បន្ថយភាពក្រីក្របានឆាប់រហ័ស ។

---

[១] *ផយអជ* កថាខណ្ឌ ៨.០៥ ។

រក្សាតុល្យភាពដោយមានការគិតគូរហ្មត់ចត់រវាងវិធីសាស្ត្រពីលើ-ចុះក្រោម (ការកែទម្រង់នៅថ្នាក់ជាតិ) និងវិធីសាស្ត្រពីក្រោម-ឡើងលើ (ថ្នាក់មូលដ្ឋាន) ។

ផ្តោតការយកចិត្តទុកដាក់លើសកម្មភាពទាំងឡាយ ដែលមានការសាកល្បងត្រឹមត្រូវ ត្រូវការចំណាយទាប និងអាចផ្តល់ផលខ្ពស់នៅថ្នាក់មូលដ្ឋានដែលនៅទីនោះការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស នឹងបង្ហាញពីសក្តានុពល មានផលប៉ះពាល់ខ្លាំងនិងជាវិជ្ជមាន និង/ឬ ផ្តល់ផលប្រយោជន៍ផ្ទាល់ដល់អ្នកក្រ ។

ធ្វើឱ្យល្អប្រសើរកត្តាសម្រាប់បង្កើនផលិតភាព (មូលធន ពលកម្ម ដី និងធនធានធម្មជាតិនិងកត្តាផ្សេងៗទៀត) ក្នុងគ្រប់សកម្មភាពទាំងអស់ ។

ជំរុញវិស័យវិទ្យាសាស្ត្រ និងការប្រើប្រាស់បច្ចេកវិទ្យា ។

ប្រើប្រាស់កម្លាំងពលកម្មមនុស្សឱ្យបានច្រើនតាមដែលអាចធ្វើបានសម្រាប់គ្រប់ការងារសាងសង់ ដើម្បីបង្កើនចំណូលរបស់គ្រួសារ ជាពិសេស នៅតំបន់ជនបទ ។

យកចិត្តទុកដាក់លើការកសាងសមត្ថភាពមនុស្សនិងស្ថាប័ននៅគ្រប់វិស័យនិងគ្រប់កម្រិត ដើម្បីបង្កើត និងធ្វើឱ្យមានចីរភាពនូវក្រុមមនុស្សសំខាន់ៗដែលមានជំនាញច្បាស់លាស់ និងមូលធនមនុស្ស ។

រៀបចំជាបណ្តើរៗនូវយន្តការដើម្បីធានាថា មូលនិធិច្រើនបំផុតដែលអាចមានត្រូវបានតម្រង់ទិសតាមរយៈថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តសកម្មភាពអភិវឌ្ឍន៍ទាំងឡាយ ។

២.០៤ វឌ្ឍនភាពលើការអនុវត្ត *ផយអជ* រហូតដល់ខែកញ្ញា ឆ្នាំ២០០៨ ត្រូវបានកត់សម្គាល់ដោយជោគជ័យលេចធ្លោនៅក្នុងវិស័យគន្លឹះមួយចំនួន និងវឌ្ឍនភាពតិចតួចនៅក្នុងវិស័យផ្សេងៗទៀត ។ ទន្ទឹមនឹងនេះ បញ្ហាប្រឈមថ្មីៗស្រាប់តែបានលេចឡើងភ្លាមៗនៅក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ ដែលបានបោកបក់លើពិភពលោកទាំងមូល និងធ្វើឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់សមិទ្ធផលសម្រេចបានកន្លងមក និងរហូតដល់ទៅធ្វើឱ្យមានហានិភ័យនៃការដើរថយក្រោយវិញទៀតផង ។

២.០៥ ជំពូកនេះពិនិត្យមើល និងផ្តល់ទស្សនៈម៉ាក្រូអំពី វឌ្ឍនភាពឬកង្វះខាតវឌ្ឍនភាពនៅក្នុងរយៈពេលពីរឆ្នាំកន្លះកន្លងមក (ពីខែមករា ឆ្នាំ២០០៦ ដល់ ខែកញ្ញា ឆ្នាំ២០០៨) ស្វែងយល់ពីលទ្ធភាពនាពេលអនាគត និងលើកឡើងនូវសំណើគោលនយោបាយនានាសម្រាប់រយៈពេលនៅសល់នៃ*ផយអជ* ។ ការពិនិត្យមើលនេះ គឺជាការពិនិត្យមើលដ៏ទូលាយមួយផ្អែកលើទស្សនៈជាតិ ពោលគឺមិនមែនជាបញ្ជីលម្អិតនៃការងារទាំងអស់ ដែលកំពុងត្រូវធ្វើ ឬនឹងត្រូវធ្វើ ដោយក្រសួង-ស្ថាប័ន ឬ ដៃគូអភិវឌ្ឍន៍នានា រួមទាំងអង្គការក្រៅរដ្ឋាភិបាល ក៏ដូចជា អង្គការសង្គមស៊ីវិលនិងផ្នែកឯកជននោះទេ ។ ព័ត៌មាន និងការវិភាគបន្ថែមនិងលម្អិត គប្បីត្រូវបានរកមើលនៅក្នុង

របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍អង្កេតនានា ដែលទាក់ទងនឹងវិស័យ ឬក្រសួង-ស្ថាប័នពាក់ព័ន្ធ[១] ។ ចំណុចដែលត្រូវយកចិត្តទុកដាក់នោះ គឺថាគោលដៅភាគច្រើនបំផុតដែលបានលើកឡើង ជារួមមានលក្ខណៈជាបរិមាណ ។ ទិដ្ឋភាពផ្នែកគុណភាព ទោះបីជាសំខាន់ក្តី ក៏មិនអាចវាស់បានដោយងាយស្រួលទេ ប៉ុន្តែត្រូវអាចមើលឃើញច្បាស់ និងអាចត្រូវគេស្វែងយល់បានបន្ទាប់ពីបានឆ្លងកាត់រយៈពេលមួយយូរ តាមរយៈការកែលម្អជាក់ស្តែងតាមវិធីផ្សេងៗ ។

២.០៦ ដោយប្រើយុទ្ធសាស្ត្រចតុកោណជាក្របខ័ណ្ឌរួម ដូចដែល *ផយអជ* បានធ្វើរួចមកហើយ ជំពូកនេះពិនិត្យមើលរយៈពេលទាំងស្រុងតាំងពីខែមករា ឆ្នាំ២០០៦ រហូតដល់ខែកញ្ញា ឆ្នាំ២០០៨ និងដាក់បញ្ចូលការវិវត្តទាំងឡាយដែលបានលើកឡើងរួចហើយ នៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០០៦[២] ។ ជំពូកនេះ :

ផ្តោតការយកចិត្តទុកដាក់ និងធ្វើការវិភាគយ៉ាងជិតដល់ទៅលើគោលនយោបាយ និងទៅលើគ្រប់ការប្រែប្រួលសំខាន់ៗក្នុងឆ្នាំ២០០៦ ក្នុងគ្រប់វិស័យទាំងអស់ រួមទាំងបណ្តាមូលហេតុដែលនាំឱ្យសម្រេចបានជោគជ័យ និងនាំឱ្យមិនសម្រេចបានជោគជ័យ ។

ផ្តល់នូវតារាងទិន្នន័យប្រៀបធៀប ឬទិន្នន័យសម្រាប់ឆ្នាំនីមួយៗ ។

បង្ហាញពីអាទិភាព យុទ្ធសាស្ត្រ ផែនការ និងបញ្ហាប្រឈមចំពោះមុខ ។

២.០៧ សមិទ្ធផលនិងការអភិវឌ្ឍធំៗនៅក្នុងរយៈពេលនេះ រួមមាន :

ការពង្រឹងនិងការកែលម្អសន្តិសុខផ្ទៃក្នុង ស្ថេរភាព និងសន្តិភាព ។

ការកែលម្អនៅក្នុងស្ថេរភាពនយោបាយ ដែលត្រួសត្រាយផ្លូវឱ្យមានអភិបាលកិច្ចកាន់តែប្រសើរឡើងជាពិសេស ដោយសារមានវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ២០០៦ ដែលអនុញ្ញាតឱ្យច្បាប់ទាំងអស់អាចត្រូវបានអនុម័តដោយមានសម្លេងឆ្នោតគាំទ្រត្រឹមតែលើស ៥០ភាគរយប៉ុណ្ណោះ ដែលជាហេតុធ្វើឱ្យមានការផ្លាស់ប្តូរ ដើម្បីភាពប្រសើរជាងមុននៃបទប្បញ្ញត្តិច្បាប់ដែលធ្វើឱ្យមានការលំបាកនិងយឺតយូរ ដោយសារភាពចាំបាច់ ត្រូវមានសម្លេងឆ្នោតគាំទ្រ ២/៣ ។

ការបន្តមានកំណើនសេដ្ឋកិច្ចខ្លាំងក្លា និងការអនុវត្តថវិការឹងមាំ ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់លើកទីពីរ ដោយសេរីនិងយុត្តិធម៌ នៅឆ្នាំ២០០៧ ។

ការធ្វើជំរឿនទូទៅនូវប្រជាជនរាស្ត្ររបស់ប្រជាជនកម្ពុជាលើកទីពីរ នៅក្នុងខែមីនា ឆ្នាំ២០០៨ ។ យោងទៅតាមលទ្ធផលដំបូង ប្រជាជនកម្ពុជាសរុបត្រូវបានប៉ាន់ស្មានថា មាន ១៣,៤លាននាក់ ដោយ

[១] សូមអានឧបសម្ព័ន្ធ៨.២ : បញ្ជីគេហទំព័ររបស់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ។

[២] ទិដ្ឋភាពមួយចំនួននៃទិដ្ឋភាពជាច្រើនដែលបានលើករួចមកហើយនៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០០៦ អាចនឹងត្រូវបានលើកឡើងម្តងទៀតនៅទីនេះ។

មានអត្រាកំណើនមធ្យមប្រចាំឆ្នាំ ១,៥៤ភាគរយ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅ[១] ។ ការវិភាគស៊ីជម្រៅលើទិន្នន័យទាំងអស់ នឹងផ្ដល់ព័ត៌មានដ៏មានសារៈសំខាន់សម្រាប់រៀបចំគោលនយោបាយផ្សេងៗ ដែលផ្ដោតលើគោលដៅច្បាស់លាស់នាពេលអនាគត ។

វឌ្ឍនភាពគួរឱ្យចាប់អារម្មណ៍នៅក្នុងវិស័យសង្គមកិច្ចនានា : ទិន្នន័យដែលបានមកពីអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០០៥ បានបង្ហាញពីវឌ្ឍនភាពដែលមានលក្ខណៈប្រសើរជាងការប៉ាន់ស្មាននៃសូចនាករសុខភាពសំខាន់ៗជាច្រើន ។

ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់នីតិកាលទី៤ នៃរដ្ឋសភា កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៨ ដែលមានការចូលរួមដោយសេរីពីភាគីពាក់ព័ន្ធទាំងអស់ ។

រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានបង្កើតឡើងសម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ឆ្នាំ២០០៨-២០១៣ បានប្រកាសថា អនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ គឺជា *"របៀបវារៈគោលនយោបាយ សេដ្ឋកិច្ច-សង្គមកិច្ច"* នៃ *"កម្មវិធីនយោបាយ"* របស់ខ្លួន ។

២.០៨ ទិដ្ឋភាពមួយចំនួននៅក្នុងចំណោមចំណុចខ្វះខាត និងបញ្ហាប្រឈមនានា ក្នុងពេលអនាគត រួមមានដូចខាងក្រោម :

កម្រិតភាពក្រីក្រ ជាពិសេស នៅភាពក្រីក្រនៅជនបទ ទោះបីជាមានការថយចុះ ក៏នៅតែមានកម្រិតខ្ពស់នៅឡើយ ។ កម្រិតភាពក្រីក្រត្រូវថយចុះយ៉ាងហោចណាស់មួយភាគរយ ជារៀងរាល់ឆ្នាំ ។

កំណើនសេដ្ឋកិច្ច នឹងនៅតែបន្តផ្អែកលើមូលដ្ឋានតូចចង្អៀត និងប្រមូលផ្ដុំនៅតែតំបន់ទីប្រជុំជន ដោយធ្វើឱ្យមានការកើនឡើងនៃវិសមភាពចំណូលរវាងអ្នកមាននិងអ្នកក្រ ជាពិសេស រវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ ។

ការប្រមូលផ្ដុំដីធ្លី និងភាពគ្មានដីធ្លី កំពុងត្រូវបានគេសង្កេតឃើញថាមាននិន្នាការកើនឡើង ។

អនាធិបតេយ្យតាមរូបភាពនៃការកាន់ដីខុសច្បាប់ ការកាន់កាប់ដីរដ្ឋនិងដីក្នុងតំបន់ការពារដោយខុសច្បាប់ និងការកាប់ឈើខុសច្បាប់នៅតែបន្តមាន ។ ជាមួយគ្នានេះ ភាពក្រីក្រ និងបម្លាស់ប្ដូរទីលំនៅក្នុងប្រទេស បានដាក់សម្ពាធបន្ថែមទៀតទៅលើធនធានធម្មជាតិ ។

ទោះបីជា មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងចុះឈ្មោះចូលរៀន ក៏ដោយ ក៏ការចុះឈ្មោះចូលរៀនរបស់កុមារមានអាយុលើសវ័យចូលសិក្សា និងបញ្ហាគុណភាពនៃការសិក្សានៅតែជាបញ្ហាចម្បង ។

[១] សូមអានកថាខណ្ឌ ២.៨៥ និង គេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ ។

វឌ្ឍនភាពនៅក្នុងធ្វើឱ្យសម្រេចការអប់រំមូលដ្ឋាន៩ឆ្នាំ នៅមានកម្រិតនៅឡើយ ជាពិសេស ការសិក្សាក្រោយបឋមសិក្សា ។

ការផលិតនិងការជួញដូរគ្រឿងញៀន បង្កបញ្ហាសង្គម ដោយគំរាមកំហែងសុខមាលភាពយុវជនកម្ពុជាក្នុងពេលបច្ចុប្បន្ន និងពេលអនាគត ។

កង្វះពលកម្មជំនាញ សម្ដែងឱ្យឃើញពីឧបស័គ្គមួយដល់ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ទាំងនៅតំបន់ទីប្រជុំជន ទាំងនៅតំបន់ជនបទ ។

ការផ្គត់ផ្គង់សេវាសុខាភិបាលសាធារណៈ នៅមានកម្រិតនៅឡើយ ទោះបីជាមានការកែលម្អយ៉ាងលឿននៅក្នុងកម្មវិធីមួយចំនួន ដូចជា ការត្រួតពិនិត្យ មេរោគអេដស៍/ជម្ងឺអេដស៍ ជម្ងឺរបេង និងជម្ងឺគ្រុនចាញ់ជាដើមក៏ដោយ ។ អត្រាមរណៈមាតាខ្ពស់ដែលនៅតែបន្តមាន គឺជាបញ្ហាកង្វល់មួយដែលត្រូវយកចិត្តទុកដាក់ជាពិសេស ។

បណ្ដាញសុវត្ថិភាពសង្គមសម្រាប់ប្រជាជនក្រីក្រ នៅមិនទាន់ត្រូវបានរៀបចំបង្កើតឡើង ជាលក្ខណៈស្ថាប័ននៅឡើយ ។

ជាទូទៅ សមត្ថភាពស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា នៅមិនទាន់ស្មើគ្នាពីស្ថាប័នមួយទៅស្ថាប័នមួយ នៅឡើយ មួយផ្នែកដោយសារប្រាក់បៀវត្សរ៍ និងការឧបត្ថម្ភមានកម្រិតទាប ។

បណ្ដាយុទ្ធសាស្ត្រឬផែនការតាមវិស័យ ត្រូវតែបានរៀបចំឡើងសម្រាប់វិស័យជាច្រើន ។ កន្លងមកយុទ្ធសាស្ត្របែបនេះត្រូវបានរៀបចំឡើងរួចហើយសម្រាប់វិស័យសំខាន់ៗមួយចំនួន ដូចជា កសិកម្ម អប់រំ សុខាភិបាល អាហារូបត្ថម្ភ ហ៊ីវ/អេដស៍ នេសាទ ថាមពល ពាណិជ្ជកម្ម អភិបាលកិច្ច កំណែទម្រង់ច្បាប់និងតុលាការ និងវិមជ្ឈការ ។

ផលិតកម្មនិងផលិតភាពនៃវិស័យកសិកម្មទាំងមូល នៅមិនទាន់ត្រូវបានលើកកម្ពស់ឱ្យបានខ្លាំងក្លានៅឡើយ ដើម្បីធ្វើឱ្យសម្រេចបាននូវសក្ដានុពលពេញលេញ ។

– ទោះបីជាជំនួយអភិវឌ្ឍន៍ក្រៅប្រទេសសម្រាប់កម្ពុជា បានបង្ហាញឱ្យឃើញពីការកើនឡើងតិចតួច ជាពិសេស ដោយសារមានការបញ្ចូលនូវជំនួយពីដៃគូ "មិនមែនប្រពៃណី" ដែលមានរហូតនឹងពេលនេះក៏ដោយ ក៏ជំនួយពីបណ្ដាប្រទេសជឿនលឿននៅក្នុងកម្រិតពិភពលោកត្រូវបានប៉ាន់ស្មានថា មានការថយចុះ (សូមអានកឋាខ័ណ្ឌ ២.៣០) ។

ការតម្រឹមតម្រង់ធនធានរបស់ដៃគូអភិវឌ្ឍន៍មកជាមួយនឹង*ផយអជ* មិនបានដំណើរការល្អនោះទេ ទោះបីជាមានការទទួលខុសត្រូវជាច្រើនដែលបានកំណត់នៅក្នុងវេទិកាអន្តរជាតិទាំងឡាយ ការឯកភាពគ្នាកម្រិតប្រទេសដែលត្រូវបានធ្វើឡើងដោយស្ថាប័នអ្នកផ្ដល់ជំនួយក៏ដោយ ។

នៅក្នុងរង្វង់រាជរដ្ឋាភិបាលកម្ពុជា ការងារជាច្រើនដែលនឹងត្រូវធ្វើឡើងជាចាំបាច់ រួមមាន : (ក) លើកកម្ពស់និងកែលម្អកិច្ចសហការអន្តរនាយកដ្ឋាននិងអន្តរក្រសួង (ខ) ការធ្វើឱ្យមានវឌ្ឍនភាពក្នុងការធ្វើសុខុដុមនីយកម្មដំណើរការ *ផយអជ* កម្មវិធីវិនិយោគសាធារណៈ ការរៀបចំថវិកាប្រចាំឆ្នាំ (គ) ការធ្វើសុខុដុមនីយកម្មមូលដ្ឋានទិន្នន័យ របស់គណៈកម្មាធិការទីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមូលដ្ឋានទិន្នន័យរបស់កម្មវិធីវិនិយោគរបស់ក្រសួងផែនការ ដែលមានសារៈសំខាន់ សម្រាប់ការធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួល និងការតាមដានត្រួតពិនិត្យជំនួយរបស់ដៃគូអភិវឌ្ឍន៍[១] និង (ឃ) ការប្រើប្រាស់កម្មវិធីវិនិយោគសាធារណៈ ដើម្បីចរចាជាមួយដៃគូអភិវឌ្ឍន៍អំពីជំនួយ ដែលត្រូវការសម្រាប់គាំទ្រដល់អាទិភាពទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

**ប្រអប់ ២.១**

**ផលប៉ះពាល់នៃការវិបត្តិរបស់សាកលលោកមកលើកម្ពុជា**

១. ថ្លៃប្រេងនៅលើទីផ្សារអន្តរជាតិ ដែលជាប្រភពថាមពលដែលជះឥទ្ធិពលដល់ទាំងអស់គ្នា បានកើនឡើងយ៉ាងលឿនជាបន្តបន្ទាប់ តាំងពីចុងឆ្នាំ២០០៧ ហើយបន្ទាប់ពីបានកើនដល់មានកម្រិតខ្ពស់មិនធ្លាប់មានពីមុនមក ១៤៧ដុល្លារ នៅក្នុងខែកក្កដា ឆ្នាំ២០០៨ (កើនឡើងក្នុងអត្រាមួយគួរឱ្យភ្ញាក់ផ្អើលជាខ្លាំង ១២១ភាគរយ លើតម្លៃ ៦៦,៤៧ដុល្លារ នៅក្នុងខែមេសា ឆ្នាំ២០០៧) ថ្លៃប្រេងក៏បានធ្លាក់ចុះមកនៅត្រឹម ១០០ដុល្លារ (នៅតែមានកម្រិតខ្ពស់ជាងច្រើនពីកម្រិតដែលមានក្នុងខែមេសា ឆ្នាំ២០០៧) ។ ការកើនឡើងយ៉ាងលឿនបែបនេះបាន ជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងមកលើទិដ្ឋភាពទាំងមូលនៃសកម្មភាពសេដ្ឋកិច្ច-សង្គមកិច្ច ។ នៅមិនទាន់មានការព្យាករណ៍ណាមួយគួរឱ្យអាច ទុកចិត្តបានដែលហ៊ានអះអាងបញ្ជាក់ថា តើនៅពេលណាការប្រែប្រួលយ៉ាងឆាប់រហ័សរបស់ថ្លៃប្រេងនេះនឹងអាចបញ្ចប់បាន ហើយថាតើនៅក្នុងកម្រិតណាដែលថ្លៃប្រេងនឹងអាចមានស្ថេរភាព ។

២. កង្វះខាតស្បៀងអាហារ បានកើតឡើង ជាមួយនឹងការធ្វើសន្និធិធញ្ញជាតិសំខាន់ៗ ជាពិសេស អង្ករ ដែលជាអាហារប្រចាំថ្ងៃរបស់មនុស្សរាប់ពាន់លាននាក់ ហើយបានឈានដល់កម្រិតដែលមិនធ្លាប់មានពីមុនមក ។ ថ្វីបើប្រទេសកម្ពុជា អាចផ្គត់ផ្គង់ខ្លួនឯងគ្រប់គ្រាន់ ហើយថែមទាំងនាំចេញអង្ករដែលមានគុណភាពខ្ពស់ក្តី ក៏ស្ថានភាពស្បៀងអាហារអាចចុះដុនដាបយ៉ាងលឿន ប្រសិនបើអាកាសធាតុអាក្រក់ នៅក្នុងរដូវវស្សាណាមួយធ្វើឱ្យថយចុះនូវផលិតកម្មស្រូវ ។

៣. ថ្លៃស្បៀងអាហារបានកើនឡើងយ៉ាងខ្លាំង ។ ថ្លៃអង្ករបានឡើងថ្លៃពីរដងនៅក្នុងទីផ្សារអន្តរជាតិ ចាប់តាំងពីដើមឆ្នាំ២០០៧ រហូតដល់ត្រឹមាសទីមួយនៃឆ្នាំ២០០៨ ហើយបានកើនឡើងពីរដង គ្រាន់នៅក្នុងតែបួនខែដំបូង នៃឆ្នាំ២០០៨ ។ ពាក្យដែលគេនិយាយជាញឹកញាប់ នៅទូទាំងពិភពលោក គឺថា *"សករាជនៃស្បៀងអាហារថោកបានបញ្ចប់ហើយ"* ។ ម៉្យាងទៀត ប្រជាជនជនបទនៅប្រទេសកម្ពុជាការឡើង ថ្លៃនេះ ហាក់ដូចជាមិនត្រូវបានទាញយកប្រយោជន៍ពីការឡើងថ្លៃនេះទេ ដោយហេតុថា ផលស្រូវលើសពីតម្រូវការរបស់ខ្លួន ត្រូវបានលក់តាំងពីដើមឆ្នាំ២០០៨ តាមតម្លៃនៅពេលនោះទេ ។ ម៉្យាងទៀត ការឡើងថ្លៃបែបនេះ នឹងធ្វើឱ្យស្បៀងអាហារចាំបាច់មិនបានដល់ដៃប្រជាជន ក្រីក្រនៅក្នុងរដូវមិនអំណោយផលទេ ។ ស្ថានភាពនេះ មានផលប៉ះពាល់ធ្ងន់ធ្ងរសម្រាប់ប្រជាជនភាគច្រើន ដែលចំណាយប្រមាណពី ៥០ ទៅ ៦០ភាគរយនៃចំណូលរបស់ខ្លួនសម្រាប់តែម្ហូបអាហារមួយមុខ ហើយស្ថានភាពនេះគំរាមកំហែងដល់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ជាពិសេស សន្តិសុខស្បៀងនិងអាហារូបត្ថម្ភរបស់អ្នកក្រីក្រ (វិទ្យាស្ថានសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា បានធ្វើការសិក្សាពីផលប៉ះពាល់នៃការកើនឡើងថ្លៃទំនិញ មកលើជីវភាពប្រជាជន) ។

៤. នៅទូទាំងសាកលលោក អតិផរណាដែលមួយផ្នែកបណ្តាលមកពីថ្លៃប្រេង ក៏កើនឡើងជាបន្តបន្ទាប់ផងដែរ ។ នៅប្រទេសកម្ពុជា អតិផរណាត្រូវបានរំពឹងថានឹងឡើងខ្ពស់ដល់កម្រិតមិនដែលមានពីមុន គឺខ្ពស់ជាង ២០ភាគរយ នៅក្នុងប្រាំបួនខែដើមឆ្នាំ២០០៨ ។ តម្លៃទំនិញសំខាន់ៗ ដូចជាប្រេងឆា សម្ភារៈសំណង់ដូចជា ដែក ស៊ីម៉ង់ និងទំនិញផ្សេងៗទៀតបានកើនឡើងដោយបានធ្វើឱ្យតម្លៃនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងអាគារកើនឡើង និងដោយបានបណ្តាលឱ្យមានការឡើងថ្លៃឥតស្រាកស្រាន និងការលំបាកក្នុងការព្យាករណ៍តម្លៃនៃសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ។

[១] សូមអានកថាខណ្ឌ ៤.១០ ។

**ប្រអប់ ២.១ (ត)**

៥. ទីផ្សារហិរញ្ញវត្ថុនៅគ្រប់ទីកន្លែង ត្រូវបានទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមាន ដោយនាំទៅដល់ការធ្លាក់ចុះភ្លាមៗយ៉ាងខ្លាំងនៃបរិមាណឥណទានសម្រាប់ការខ្ចីចងការពីធនាគារ ឬការកើនឡើងភ្លាមៗនៃតម្លៃការខ្ចីចងការពីធនាគារ ហើយទីបញ្ចប់នៃសភាពការណ៍នេះមិនទាន់លេចឡើងឱ្យឃើញនៅឡើយ ។ សភាពការណ៍នេះ បានបន្ថយល្បឿនសេដ្ឋកិច្ចនៃប្រទេសស្ទើរតែទាំងអស់ក្នុងពិភពលោក ដោយបាននាំប្រទេសមួយចំនួនទៅជិតដល់ដំណើរដួលចុះនៃសេដ្ឋកិច្ច ហើយដោយបានការប្រើប្រាស់និងតម្រូវការ ទំនិញនិងសេវាកម្មទាំងឡាយ ។ កិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ដែលត្រូវបានធ្វើឡើងនៅក្នុងការអភិវឌ្ឍប្រទេសជាតិដើម្បីគាំទ្រស្ថាប័នហិរញ្ញវត្ថុ តាមរយៈការបញ្ចូលទុនរបស់វិស័យសាធារណៈ នឹងគំរាមកំហែងដល់កំណើនទុនដែលទុកសម្រាប់ប្រើប្រាស់ សម្រាប់ជំនួសកម្រិតនៃជំនួយអភិវឌ្ឍន៍ដែលកំពុងមានការថយចុះនៅក្នុងកម្រិតពិភពលោកទាំងមូល ។

៦. បញ្ហាទាំងនេះ មានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំងដល់សេដ្ឋកិច្ចកម្ពុជា ដោយធ្វើឱ្យកម្ពុជាមិនអាចរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងកម្រិតពីរខ្ទង់ដែលសម្រេចបានក្នុងរយៈពេលពីរ-បីឆ្នាំចុងក្រោយនេះ ។ ឧទាហរណ៍ ធាតុផ្សំចម្បងៗទាំងបី សម្រាប់ឱ្យមានកំណើនសេដ្ឋកិច្ចលឿននៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដែលបានបង្កើតការងារ និងបានជះឥទ្ធិពលយ៉ាងល្អទៅដល់តំបន់ជនបទ ទំនងជាត្រូវបានកាត់បន្ថយល្បឿន :

- ល្បឿននៃការរីកចម្រើនរបស់កម្មន្តសាលកាត់ដេរនឹងអាចមានការថយចុះ ដោយកំពុងប្រឈមមុខនឹងកំណើននៃចំណាយ (រួមទាំងប្រាក់បៀវត្សរ៍និងការដឹកជញ្ជូន) ការប្រកួតប្រជែងពីបណ្តាប្រទេសជិតខាង ហើយនិងការធ្លាក់ចុះនៃតម្រូវការនៅបរទេស ។ កំណើន ការងារជាពិសេស សម្រាប់ស្ត្រី និងឥទ្ធិពលពហុមេគុណនៃកំណើនការងារ នឹងប្រឈមមុខនឹងហានិភ័យ ។
- អត្រាកំណើនក្នុងវិស័យទេសចរណ៍ អាចរងផលប៉ះពាល់ ដោយសារតែមានការកើនឡើងនៃចំណាយក្នុងការធ្វើដំណើរ ដែលបណ្តាលមកពីតម្លៃខ្ពស់របស់ប្រេងឥន្ធនៈ និងការចំណាយផ្សេងៗទៀត ។ ជាថ្មីម្តងទៀត កំណើនការងារ និងឥទ្ធិពលពហុមេគុណរបស់វានឹងត្រូវទទួលរងផលប៉ះពាល់ជាអវិជ្ជមាន ។
- វិស័យសំណង់អាចនឹងមានការថយចុះ ដោយសារការកើនឡើងនៃតម្លៃមិនអាចព្យាករណ៍មុនបាន របស់សំភារៈសំណង់សំខាន់ៗ ដោយជះឥទ្ធិពលជាអវិជ្ជមានលើការងារដែលពាក់ព័ន្ធនឹងជំនាញជាច្រើន ។

៧. សេដ្ឋកិច្ចដែលកំពុងមានល្បឿនយឺត ការកាត់បន្ថយឬការលើកលែងពន្ធដល់ការវិនិយោគដែលបង្កើតការងារ និងការផ្តល់ការឧបត្ថម្ភធនផ្ទាល់សម្រាប់ស្បៀងអាហារ ។ល។ ទោះបីជាមានសារៈសំខាន់ខ្លាំងដល់ការបង្កើតនូវបណ្តាញសុវត្ថិភាពសង្គមចាំបាច់ក៏ដោយ ក៏នឹងអាចមានផលប៉ះពាល់លើស្ថានភាពសារពើពន្ធផងដែរ ។

៨. អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលកម្ពុជានៅតែរក្សាការយកចិត្តទុកដាក់ក្នុងកម្រិតខ្ពស់លើព្រឹត្តិការណ៍សាកលលោក ដើម្បីធានាថា ជំហានសមស្របនិងទាន់ពេល អាចត្រូវបានអនុវត្ត ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើប្រជាជនកម្ពុជា ជារួម និងជាពិសេស លើប្រជាជនក្រីក្រនៅជនបទ ក៏ដូចជា ដើម្បីរក្សាវឌ្ឍនភាពនៃសេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅកាន់គោលដៅដែលចង់បាន ។

៩. ស្ថានភាពដែលនៅកំពុងវិវត្តនេះ បានចោទជាបញ្ហាប្រឈមបន្ទាន់និងស្មុគ្រស្មាញជាច្រើន ។ បញ្ហាទាំងនេះ ត្រូវតែបានប្រែក្លាយឱ្យទៅជាកាលានុវត្តភាពដែលមានសារៈសំខាន់និងទាន់ពេលវេលា ដើម្បីវិនិយោគនៅតំបន់ជនបទនិងក្នុងវិស័យកសិកម្ម ដើម្បីបង្កើនផលិតកម្មនិងចំណូល និងដើម្បីលើកស្ទួយជីវភាពរស់នៅ ដូចដែលមានពិភាក្សានៅក្នុងផ្នែកផ្សេងទៀតនៅក្នុងជំពូកនេះ ។

២.០៩ បើពិនិត្យមើលជាសាកល ស្ថានភាពមួយដ៏គួរឱ្យព្រួយបារម្ភនិងដែលធ្វើឱ្យបាត់ស្ថេរភាព ដែលគេមិនបានគិតជាមុន និងដែលនៅកំពុងតែវិវត្តនៅឡើយ និងដែលគេមិនទាន់បានយល់អស់នៅឡើយ បានកើតឡើងតាំងពីចុងឆ្នាំ២០០៧ ហើយបានបង្កើនល្បឿននិងបានចុះដុនដាបកាន់តែធ្ងន់ធ្ងរឡើងនៅក្នុងឆ្នាំ២០០៨ ។ ប្រការនេះបានធ្វើឱ្យមានការបារម្ភ មិនត្រឹមតែលើក្តីសង្ឃឹមអនាគតក្នុងទូទាំងពិភពលោកទេ ប៉ុន្តែថែមទាំងលើការការពារនាពេលអនាគតនូវសមិទ្ធផលនានាដែលសម្រេចបានរួចហើយផងដែរ ជាពិសេស នៅក្នុងការកាត់បន្ថយភាពក្រីក្រ

និងការធ្វើឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ ដោយជៀសមិនរួច ប្រការនេះមានផលប៉ះពាល់ទូលាយ និងរយៈពេលខ្លី ក៏ដូចជា រយៈពេលវែងផងដែរលើប្រទេសកម្ពុជាដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ឡើងវិញលើអាទិភាពមួយចំនួនដែលបានកំណត់រួចហើយ ដើម្បីទប់ទល់នឹងផលប៉ះពាល់លើប្រជាជនងាយរងគ្រោះ ។ លក្ខណៈសម្គាល់និងផលប៉ះពាល់ធំៗនៃប្រការនេះដែលពង្រឹងគ្នាទៅវិញទៅមក ត្រូវបានបង្ហាញជូននៅក្នុងប្រអប់ ២.១ ។

២.១០ ទោះបីជារាជរដ្ឋាភិបាលកម្ពុជា បន្តរក្សាការតាមដានកម្រិតខ្ពស់លើស្ថានភាពដែលកំពុងវិវត្តនេះ និងចាត់វិធានការសមស្រប ដើម្បីកាត់បន្ថយផលប៉ះពាល់នៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ដំណោះស្រាយបន្ទាន់ដែលមានឥទ្ធិពលរយៈពេលវែង គឺជាការងារចាំបាច់ដែលអាចត្រូវបានចាប់ផ្ដើមអនុវត្តភ្លាមៗ ហើយនឹងមានឥទ្ធិពលលើការធ្វើឱ្យមានស្ថេរភាពសេដ្ឋកិច្ចដោយការធ្វើពិពិធកម្មមូលដ្ឋាន ។ វិស័យឯកជនបានរីកចម្រើនយ៉ាងលឿននៅក្នុងបរិយាកាសអំណោយផល ដែលបង្កើតឡើងដោយគោលនយោបាយជឿនលឿនរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយក្នុងរយៈពេលវែងអាចសម្របសម្រួលខ្លួនទៅនឹងកត្តាទាំងឡាយ ដែលនឹងកើតមានឡើងពីខាងក្រៅប្រទេស ។ ប៉ុន្តែវិស័យជនបទនិងកសិកម្មដែលនៅទីនោះភាគច្រើននៃប្រជាជនកម្ពុជារស់នៅ និងជាអ្នកក្រីក្រនៅតែស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ។ សក្ដានុពលដ៏ធំធេងដែលនៅមិនទាន់ត្រូវបានប្រើប្រាស់នៅក្នុងវិស័យកសិកម្មនៅឡើយ ដែលក្នុងនោះផលិតភាពនឹងត្រូវបានបង្កើនឡើងអាចបង្កើនលទ្ធផលការងារ ការងារធ្វើ និងប្រាក់ចំណូលប្រកបដោយចីរភាព ទន្ទឹមនឹងការលើកទឹកដល់សកម្មភាពជនបទផ្សេងៗទៀត រួមទាំងនៅក្នុងការងារកែច្នៃផងដែរ ។ **ហេតុនេះ រាជរដ្ឋាភិបាលកម្ពុជាផ្សារភ្ជាប់អាទិភាពខ្ពស់ទៅនឹងវិស័យជនបទនិងកសិកម្ម** នៅក្នុងការអនុវត្តគោល-នយោបាយគាំទ្រអ្នកក្រីក្ររបស់ខ្លួន ។ រួមជាមួយនឹងការកាត់បន្ថយភាពក្រីក្រដែលជាគោលដៅចម្បងនៅក្នុងខណៈពេលដែលកម្លាំងជំរុញនៃវឌ្ឍនភាពក្នុងវិស័យទាំងអស់ អាចត្រូវបានរក្សាឱ្យនៅមានជាបន្តនោះ ការយកចិត្តទុកដាក់នឹងត្រូវបានផ្ដោតទៅលើការបន្តកំណើនម៉ាក្រូសេដ្ឋកិច្ច និងកំណើនប្រកបដោយចីរភាពដែលមានមូលដ្ឋានចម្រុះដោយមានការបង្កើនឡើងនូវកាលានុវត្តភាព និងផលប្រយោជន៍នៅតំបន់ជនបទ ដែលនៅទីនោះអត្រាភាពក្រីក្រមានកម្រិតខ្ពស់ ។ បញ្ហានានាដែលត្រូវដោះស្រាយជាបន្ទាន់ រួមមាន បញ្ហាទាំងឡាយដែលពាក់-ព័ន្ធនឹង : (១) ការបែងចែកនិងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លី (២) ការលើកទឹកចិត្តដល់ការប្រើប្រាស់ដីឱ្យបានល្អដើម្បីដាំដំណាំសមស្រប (៣) ការស្រោចស្រពបន្ថែមនិងការស្រោចស្រពផ្សេងទៀត (៤) ការប្រើកត្តាផលិតកម្មដែលមានគុណភាពប្រសើរជាងមុន ជាពិសេស ពូជ (៥) ការលើកកម្ពស់សកម្មភាពគាំទ្រតាមរយៈ សេវាកម្មផ្សព្វផ្សាយ (៦) ការកែលម្អការគ្រប់គ្រងក្រោយការប្រមូលផលនិងកិច្ចខិតខំប្រឹងប្រែងដែលមានតម្លៃបន្ថែម (៧) ការធ្វើឱ្យប្រសើរជាងមុននូវហេដ្ឋារចនាសម្ព័ន្ធជនបទ រួមទាំង ការធ្វើឱ្យប្រសើរឡើងនូវការទទួលបានទឹកស្អាត និងប្រព័ន្ធអនាម័យ និង (៨) ការលើកកម្ពស់ការងារសុខភាព និងការងារអប់រំ ។ ការងារទាំងនេះនឹងត្រូវបានពិភាក្សាលម្អិត នៅក្នុងផ្នែកពាក់ព័ន្ធនៃជំពូកនេះ ។

## ការកាត់បន្ថយភាពក្រីក្រ

២.១១ កំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ក្នុងល្បឿនលឿននិងក្នុងកម្រិតខ្ពស់ ដែលត្រូវបានជួយសម្រួលដោយការវិនិយោគរបស់ផ្នែកឯកជន ដែលកំពុងទាញយកប្រយោជន៍ពីគោលនយោបាយជាវិជ្ជមានរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលផ្ដល់នូវបរិស្ថានអំណោយផល បានមានឥទ្ធិពលខ្លាំងក្លាដូចដែលចង់បាននៅតាមតំបន់ជនបទ ផងដែរ ។ ការងារផ្ទាល់និងប្រយោលរបស់អ្នកគ្មានការងារធ្វើដែលមិនមានជំនាញជាក់លាក់ ត្រូវបានគេសង្កេតឃើញតាមរយៈការហូរចូលនៃយុវជនមករស់នៅតាមតំបន់ទីប្រជុំជនដែលមានកំពុងមានការអភិវឌ្ឍ តាមរយៈកំណើនសេដ្ឋកិច្ច និងការផ្ញើប្រាក់ទៅផ្ទះ ដើម្បីជួយគ្រួសារនៅតាមតំបន់ជនបទ ។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគនៅតាមតំបន់ជនបទ និងកិច្ចខិតខំប្រឹងប្រែងផ្សេងៗទៀតសម្រាប់គាំទ្រប្រជាជនក្រីក្រ របស់រាជរដ្ឋាភិបាលកម្ពុជា បានជួយធ្វើឱ្យមានការថយចុះជាបន្តបន្ទាប់នៃកម្រិតភាពក្រីក្រ ។ ការវិភាគដំបូងលើទិន្នន័យ ដែលបានមកពីអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៧[១] ដែលមានកម្រិតតូចជាងអង្កេតមុនៗ ប៉ាន់ស្មានថាកម្រិតភាពក្រីក្រ បានថយចុះពី ៣៤,៧ភាគរយ ក្នុងឆ្នាំ២០០៤ មកនៅត្រឹម ៣០,១ភាគរយ នៅក្នុងឆ្នាំ២០០៧ ដោយបង្ហាញឱ្យឃើញពីការកាត់បន្ថយភាពក្រីក្រ បានជាងមួយភាគរយ ក្នុងមួយឆ្នាំ ។ កម្រិតភាពក្រីក្រ បានធ្លាក់ចុះនៅកម្រិតថ្នាក់ក្រោមជាតិទាំងអស់ ពោលគឺ ថយចុះពី ៤,៦ភាគរយ មកត្រឹម ០,៨ភាគរយ នៅភ្នំពេញ -- ថយចុះពី ២៤,៧ភាគរយ មកត្រឹម ២១,៩ភាគរយ នៅតំបន់ទីប្រជុំជនផ្សេងៗទៀត -- ហើយថយចុះពី ៣៩,២ភាគរយ មកត្រឹម ៣៤,៧ភាគរយ នៅតំបន់ជនបទ ។ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៩ ដែលមានលក្ខណៈទូលំទូលាយជាងនឹងផ្ដល់នូវការយល់ដឹងពីស្ថានភាពភាពក្រីក្រ ដែលមានលក្ខណៈបច្ចុប្បន្នភាពជាង ។

២.១២ ទោះជាដូចនេះក្ដី ភាពក្រីក្រនៅតែបន្តមានកម្រិតខ្ពស់ គឺលើ ៥០ភាគរយ នៅតាមតំបន់ជនបទដាច់ស្រយាលខ្លះ ដែលមិនបានទទួលផលប្រយោជន៍ពីវឌ្ឍនភាពទូទៅនៅក្នុងប្រទេស (សូមមើលផែនទី) ។ ជារួម កត្តាទាំងឡាយ រួមផ្សំជាមួយនឹងសម្ពាធទាំងឡាយនៅក្នុងប្រទេសដែលជំរុញឱ្យមានការកើនឡើងនៃអតិផរណា (ប្រអប់ ២.១) មិនត្រឹមតែគម្រាមកំហែងដល់ការថយចុះនៃអត្រាភាពក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យមានការដើរថយក្រោយទៀតផង ដោយសារអាចមានការធ្លាក់ចុះនៃប្រជាជនទៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ។ វិធានការបន្ទាន់ គឺជាការងារចាំបាច់ ហើយនឹងត្រូវធ្វើឡើងដើម្បីធានាឱ្យមាននូវការការពារសមិទ្ធផលដែលសម្រេចបានកន្លងមក និងបណ្ដាញសុវត្ថិភាពសង្គម សម្រាប់ប្រជាជនដែលមានភាពងាយរងគ្រោះជាងគេ តាមរយៈការឧបត្ថម្ភធន និងការងារប្រើកម្លាំងពលកម្មច្រើន ដូចជា កម្មវិធីស្បៀងពលកម្ម ជាដើម ។ ប៉ុន្តែនៅក្នុងនិន្នាការបច្ចុប្បន្ន កិច្ចខិតខំប្រឹងប្រែងរួមគ្នាជាច្រើនថែមទៀត មានភាពចាំបាច់សម្រាប់ការកាត់បន្ថយភាពក្រីក្រឱ្យធ្លាក់មកត្រឹម ២៥ភាគរយ នៅឆ្នាំ២០១០ និង ១៩,៥ភាគរយ នៅឆ្នាំ២០១៥ ។

[១] អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៧ គ្របដណ្ដប់ត្រឹមតែ ៣.៦០០គ្រួសារ ធៀបនឹង អ.ស.ស.ក ឆ្នាំ២០០៤ គ្របដណ្ដប់ដល់ទៅ ១២.០០០គ្រួសារ ។

២.១៣ រាជរដ្ឋាភិបាលកម្ពុជានឹងធានាថា បរិយាកាសម៉ាក្រូសេដ្ឋកិច្ចនៅតែត្រូវបានធ្វើឱ្យមានស្ថេរភាព ដើម្បីគាំទ្រការកាត់បន្ថយភាពក្រីក្រ ។ ការបញ្ចូលរួមគ្នានូវគោលនយោបាយនិងកិច្ចខិតខំប្រឹងប្រែង ដែលលក្ខណៈគាំទ្រអ្នកក្ររបស់រាជរដ្ឋាភិបាលកម្ពុជា គឺជាមធ្យោបាយតែមួយគត់ដែលអាចមានឥទ្ធិពលជាវិជ្ជមានលើស្ថានភាពនៃភាពក្រីក្រ។ ជាពិសេស ការផ្តោតការយកចិត្តទុកដាក់លើប្រជាជននិងតំបន់ទាំងឡាយដែលទទួលសេវាកម្មមិនគ្រប់គ្រាន់ ក៏ដូចជាកម្មវិធីពិសេសនានាដែលជំរុញនិងគាំទ្រមូលដ្ឋាន ត្រូវបានគេរំពឹងថានឹងទទួលបានផ្លែផ្កា ។ ប៉ុន្តែ លទ្ធផលភ្លាមៗ អាចត្រូវធ្វើឱ្យសម្រេចបាន តែតាមរយៈអន្តរាគមន៍ផ្ទាល់ក្នុងការកាត់បន្ថយភាពក្រីក្រ ដោយអនុវត្តកម្មវិធីថ្មីៗ (សូមមើលប្រអប់ ២.២) ។

**ប្រទេសកម្ពុជា: ផែនទីភាពក្រីក្រ ឆ្នាំ២០០៤**




**ប្រអប់ ២.២**

**ការកាត់បន្ថយភាពក្រីក្រ : ការងារដែលត្រូវធ្វើចំពោះមុខ**

១. កត្តានានាក្នុងសាកលលោក ដែលបានលើកឡើងដោយសង្ខេបក្នុងប្រអប់២.១ មានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំងចំពោះកម្រិតនៃភាពក្រីក្រលើពិភពលោក ដែលប៉ះពាល់មកលើកម្ពុជា ផងដែរ ។ អ្នកក្រីក្រពុំមានភាពប្រែប្រួលនៃចំណូល ដើម្បីទប់ទល់នឹងសម្ពាធអតិផរណា ហើយលទ្ធភាពទទួលបានស្បៀងអាហារនិងអាហារូបត្ថម្ភ នឹងអាចរងឥទ្ធិពលអវិជ្ជមានបន្ថែមទៀត ។ កត្តាទាំងអស់នេះ នឹងអាចជាហានិភ័យ ដែលធ្វើឱ្យភាគច្រើននៃប្រជាជនដែលទើបតែរស់នៅលើខ្សែបន្ទាត់ភាពក្រីក្របន្តិចអាចធ្លាក់មកនៅក្រោមខ្សែបន្ទាត់ភាពក្រីក្រវិញ ។ រាជរដ្ឋាភិបាលកម្ពុជា នឹងប្រើប្រាស់វិធានការសារពើពន្ធចម្រុះ និងវិធានការផ្សេងៗទៀត ដើម្បីធានាថាស្ថានភាពនេះនឹងមិនកើតមានឡើង ។

២. ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដែលបានកើតឡើងតាមរយៈឥទ្ធិពលជ្រាបចុះក្រោម និងឥទ្ធិពលដែលរីករាលដាលទូលំទូលាយនៃសេដ្ឋកិច្ច ដែលកំពុងកើនឡើងយ៉ាងខ្លាំង បានប្រមូលផ្តុំភាគច្រើនទៅលើកម្មភាពនៅតំបន់ទីប្រជុំជន ។ ទន្ទឹមនឹងពេលដែលកំណើនម៉ាក្រូសេដ្ឋកិច្ចមានសារៈសំខាន់ខ្លាំង ដើម្បីការលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ សកម្មភាពផ្ទាល់និងបន្ទាន់បន្ថែមទៀតក៏មានសារៈសំខាន់ផងដែរ ។

៣. វិធីសាស្ត្រកាត់បន្ថយភាពក្រីក្រ នៅតែបន្តអនុវត្តពីលើចុះក្រោម ដោយមិនមានការផ្តោតការយកចិត្តទុកដាក់ខ្លាំងលើសកម្មភាពនៅមូលដ្ឋានឡើយ ។ ការសិក្សាជាច្រើនត្រូវបានធ្វើរួចហើយ ដែលក្នុងនោះ មួយចំនួនត្រូវបានធ្វើឡើងម្តងទៀត ដោយពុំបានបន្ថែមព័ត៌មានឬចំណេះដឹង មាន

**ប្រអប់ ២.២ (ត)**

ប្រយោជន៍អ្វីឡើយ ។ ការសិក្សាជាច្រើន កំពុងត្រូវបានធ្វើឡើង និងផ្តោតការយកចិត្តទុកដាក់តែលើកម្រិតម៉ាក្រូ ដែលរួមទាំង ការបង្កើតដើម្បី "កំណត់"ប្រជាជនក្រីក្រ ។ អ្នកឯកទេសជាច្រើន ផលិតនូវរបាយការណ៍ដ៏គួរឱ្យទាក់ទាញអារម្មណ៍ ដែលត្រូវបានពិភាក្សាជារួម នៅក្នុងចំណោមដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ដើម្បីពិភាក្សាពី "ជម្រើសគោលនយោបាយ" ។ ប៉ុន្តែភាគច្រើនបំផុតនៃកិច្ចការទាំងនេះ ពុំបានផ្តល់ផលប្រយោជន៍ចំពោះមុខដល់អ្នកក្រីក្រនោះឡើយ ។ លើសពីនេះ តំបន់ដែលមានភាពក្រីក្រត្រូវបានស្គាល់រួចហើយ (សូមមើលផែនទីខាងលើ) ។

៤. ពេលនេះ គឺជាពេលវេលាដែលត្រូវចាប់ផ្តើមអនុវត្តសកម្មភាពជាក់ស្តែងឱ្យបានទូលំទូលាយនៅកម្រិតមូលដ្ឋាន និងកាត់បន្ថយឱ្យបានច្រើន ឬកំណត់អាទិភាពដោយមានការជ្រើសរើសយ៉ាងប្រុងប្រយ័ត្ន ចំពោះការយកចិត្តទុកដាក់លើការសិក្សាស៊ីជម្រៅ ជាលក្ខណៈ "គោលនយោបាយ" ដែលប្រើប្រាស់ចំណាយច្រើន ដោយកម្រិតមិនឱ្យមានច្រើននូវអាទិភាពទាំងឡាយដែលនាំឱ្យមានសកម្មភាពជាក់ស្តែង ។ ការបែរចេញពី "ទីកន្លែងសុខស្រួល" ដែលបានសាកល្បងអស់រយៈពេលជាយូរមកហើយ របស់ការសិក្សាស្រាវជ្រាវទាំងឡាយ និងជំនួយបច្ចេកទេស ដែលបិទបាំងអ្វីៗគ្រប់បែបយ៉ាងក្រោម "ស្លាក" នៃភាពក្រីក្រ ដែលជាទីចូលចិត្តនិងងាយស្រួលសម្រាប់ការអនុវត្តការងារទាំងនេះ ។ កម្មវិធីនានា ដែលផ្តោតលើការច្នៃប្រឌិតថ្មីៗនៃសកម្មភាពផ្ទាល់ ដើម្បីលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ គឺជាការងារចាំបាច់ ដែលអាចជួយផងដែរដល់ការពន្លឿនតម្រូវការយ៉ាងច្រើននៃ "ការផ្ទេរធនធានសុទ្ធ" ។

៥. កិច្ចប្រឹងប្រែងមួយត្រូវបានលើកឡើងនៅក្នុង*ផយអជ* គឺ ការផ្តល់ជាកញ្ចប់នូវគ្រាប់ពូជដែលមានគុណភាពល្អ និងកត្តាផលិតកម្មចាំបាច់មួយចំនួន ក្នុងរូបភាពជាអំណោយដល់ប្រជាជនក្រីក្រ ។ ថ្នាក់ដឹកនាំនិងមន្ត្រីជាន់ខ្ពស់ជាច្រើនរបស់រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងផ្តល់ការឧបត្ថម្ភ នៅក្នុងកិច្ចខិតខំប្រឹងប្រែងជាច្រើន ដើម្បីលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតំបន់ជនបទ ។ កិច្ចប្រឹងប្រែងជាលក្ខណៈឯកជនបែបនេះ ត្រូវបន្តធ្វើនិងបង្កើនឱ្យបានច្រើនថែមទៀត ហើយត្រូវពង្រីកទៅតំបន់ដាច់ស្រយាលជាច្រើនទៀតដែលមានកម្រិតភាពក្រីក្រខ្ពស់ ។

៦. លើសពីនេះ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសគួររំលែកទុកមួយផ្នែកនៃមូលនិធិរបស់ខ្លួន សម្រាប់គោលបំណងខាងលើនេះ នៅក្នុងគម្រោងទាំងឡាយ "ដែលទាក់ទងនឹងភាពក្រីក្រ" ដែលពួកគេអនុវត្ត ឬគាំទ្រ ។ បរិមាណទុនទាំងនេះ គួរតែផ្តល់ដល់មូលនិធិលុបបំបាត់ភាពក្រីក្រ ដើម្បីផ្តល់ដល់ប្រជាជនក្រីក្រនៅក្នុងតំបន់ដែលទទួលរងឥទ្ធិពលខ្លាំងជាងគេនូវការឧបត្ថម្ភទុន និងជំនួយអភិវឌ្ឍន៍ (ដូចជា កត្តាផលិកម្មសំខាន់ៗ ជាដើម) សម្រាប់គោលបំណងផលិតកម្ម ។ ជាមួយគ្នានេះ វិស័យឯកជន គួរតែត្រូវបានលើកទឹកចិត្តឱ្យរួមចំណែកក្នុងមូលនិធិនេះ តាមរូបភាពនៃ "ការលើកលែងពន្ធ" ដែលអាចត្រូវបានអនុវត្តតាមគម្រោង ឬអាចជាផ្នែកនៃកម្មវិធីគាំទ្រថវិការបស់អ្នកផ្តល់ជំនួយច្រើន ដែលបានរៀបចំរួចហើយនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៧. **"ចាប់ផ្តើមធ្វើសកម្មភាពចាប់ពីពេលនេះតទៅ"** គឺជាសារមួយដែលត្រូវយកចិត្តទុកដាក់ ។ លទ្ធផលដ៏គួរឱ្យកត់សម្គាល់ ដែលអាចទទួលបានឆាប់រហ័ស និងគួរជាទីពេញចិត្ត កំពុងទន្ទឹងរង់ចាំ ដែលពុំមានការសិក្សាស្រាវជ្រាវណាមួយអាចត្រូវបានរំពឹងថា សម្រេចបាននូវលទ្ធផលទាំងនេះបានឡើយ ។

២.១៤ ***យុទ្ធសាស្ត្រចតុកោណ****ដើម្បី កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា* គឺជាឯកសារមួយដែលមានលក្ខណៈសរុបរួមសម្រាប់គ្រប់ទិដ្ឋភាពទាំងអស់ ដែលប្រកាសដោយរាជរដ្ឋាភិបាលកម្ពុជា នៅពេលចាប់ផ្តើមការងាររបស់ខ្លួន សម្រាប់អាណត្តិទីបីនៃរដ្ឋសភានៅក្នុងឆ្នាំ២០០៤ ។ រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ២០០៨-២០១៣ បានអះអាងជាថ្មីម្តងទៀតថា យុទ្ធសាស្ត្រចតុកោណ នៅតែបន្តមានសុពលភាព និងបានបញ្ជាក់ថា នឹងអនុវត្តយុទ្ធសាស្ត្រចតុកោណជំហានទី២ ដែលជា *"របៀបវារៈគោលនយោបាយសេដ្ឋកិច្ច-សង្គមកិច្ច"* របស់ខ្លួន ។ យុទ្ធសាស្ត្រចតុកោណជំហានទី២ ក្នុងកថាខណ្ឌទី១២ បញ្ជាក់ថា *"ទិសដៅជាសារវ័ន្តរបស់រាជរដ្ឋាភិបាលកម្ពុជា គឺកសាងជាជំហានៗនូវសង្គមកម្ពុជាមួយ ដែលមានសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម មានការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ព្រមទាំងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរ*

*របស់មនុស្ស មានកោសិកាផ្សារភ្ជាប់គ្នា មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និងវប្បធម៌ជ្រៅជ្រះ មានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងសង្គមជាតិ ទាំងក្នុងគ្រួសារ"* ។ យុទ្ធសាស្ត្រចតុកោណជំហានទី២ (កឋាខ័ណ្ឌទី១១០) បញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាប្ដេជ្ញាយ៉ាងម៉ឺងម៉ាត់ ក្នុងការសម្រេចឱ្យបាននូវគោលដៅជាអាទិភាពរបស់ខ្លួន ដោយ :

- ការធានាឱ្យបាននូវចិរភាពសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម សំដៅលើកស្ទួយនីតិរដ្ឋ ការការពារសិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់មនុស្ស និងប្រជាធិបតេយ្យពហុបក្ស ។
- ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងអត្រា ៧ភាគរយ ក្នុងមួយឆ្នាំ នៅលើមូល-ដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន នៅក្នុងបរិការណ៍អត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់ ។
- ការធានាឱ្យសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រ ឱ្យបានលើសពីមួយភាគរយក្នុងមួយឆ្នាំ និងការធានាកែលម្អសូចនាករសំខាន់ៗក្នុងវិស័យសង្គមកិច្ច ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និងសមភាពយេនឌ័រ ។
- ការធានាបង្កើតវិសាលភាព ប្រសិទ្ធភាព និងគុណភាពនៃសេវាសាធារណៈ ឱ្យកាន់តែប្រសើរឡើងហើយទទួលបាននូវការជឿទុកចិត្ត ។

២.១៥ បន្ថែមលើនេះទៀត យុទ្ធសាស្ត្រចតុកោណជំហានទី២ (កឋាខណ្ឌទី៤០) ក៏បានបញ្ជាក់ដែរថា *"ក្នុងទិសដៅធានាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ដែលជាបុរេលក្ខខណ្ឌនៃការបង្កើតការងារ និងបង្កើនចំណូលរបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តវិធានការពិពិធភាវូបណីយកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា តាមរយៈ ការបង្កើតបរិស្ថានអនុគ្រោះដល់ការវិនិយោគ ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន (ទាំងក្នុងស្រុក និង បរទេស) សម្រាប់ការអភិវឌ្ឍវិស័យសំខាន់ៗ ដូចតទៅ : (១) កសិកម្ម (២) ទឹក និងប្រព័ន្ធស្រោចស្រព (៣) ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (៤) អគ្គិសនី (៥) ការអភិវឌ្ឍធនធានមនុស្ស (៦) ឧស្សាហកម្មអតិពលកម្ម និងឧស្សាហកម្មផលិតទំនិញនាំចេញ (៧) ទេសចរណ៍ (៨) អាជីវកម្មប្រេងកាត ឧស្ម័នធម្មជាតិ និង រ៉ែដទៃទៀត (៩) បច្ចេកវិទ្យាព័ត៌មានគមនាគមន៍ (១០) ពាណិជ្ជកម្ម"* ។

២.១៦ របៀបវារៈគោលនយោបាយសេដ្ឋកិច្ច-សង្គមកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលចែងក្នុងមាត្រារបស់យុទ្ធសាស្ត្រចតុកោណជំហានទី១និងទី២ នឹងត្រូវអនុវត្ត តាមរយៈ *ផយអជ* ដោយបង្ហាញយ៉ាងច្បាស់ និងផ្ដល់អាទិភាពលើ ផែនការ យុទ្ធសាស្ត្រ កម្មវិធី គោលដៅ និងចំណុចដៅ កម្រិតជាតិ និង អនុវត្តជាក់ស្ដែង នូវវិសាលភាពហិរញ្ញវត្ថុជារួម ដើម្បីសម្រេចឱ្យបានរបៀបវារៈទាំងនោះ ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យនានា ក៏ដូចជាឯកសារគោលនយោបាយ ផែនការ និង កម្មវិធីវិនិយោគសាធារណៈ ផ្សេងៗទៀត នឹងត្រូវពង្រីកនូវអាទិភាព

និងគោលដៅទាំងនេះ ហើយបានផ្តល់ជាលម្អិតនូវចំណុចដៅរងដែលនឹងត្រូវអនុវត្តតាមរយៈ ផែនការ សកម្មភាព និងកម្មវិធីវិនិយោគបីឆ្នាំរំកិលទាំងឡាយ ។ ធនធានរបស់ដៃគូអភិវឌ្ឍន៍ និងថវិកាជាតិ នឹងត្រូវប្រើប្រាស់តាមរបៀបចម្រុះរួមគ្នា ដើម្បីអនុវត្តឱ្យបានសម្រេចសកម្មភាពទាំងអស់ដែលមានចែងនៅក្នុង *ផយអជ* កម្មវិធីនិងផែនការតាមវិស័យទាំងនោះ ។ ដូច្នេះ តួនាទីទៅតាមឋានានុក្រម អន្តរទំនាក់ទំនង និងការផ្សារភ្ជាប់ក្នុងចំណោមឯកសារជាច្រើនកម្រិតទាំងនេះមានលក្ខណៈច្បាស់លាស់ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាក៏ទទួលស្គាល់នូវតម្រូវការចាំបាច់ ហើយបានសម្រេចចិត្តធ្វើឱ្យមានភាពស្របគ្នានៃដំណាក់កាលរបស់ឯកសារទាំងនេះជាមួយនឹងដំណាក់កាលរបស់យុទ្ធសាស្ត្រចតុកោណដំហានទី២ ដើម្បីឱ្យគោលដៅនិងចំណុចដៅក្នុងផែនការនិងកម្មវិធីទាំងនោះ មានពេលវេលាកំណត់រួមគ្នា និងចៀសវាងភាពត្រួតគ្នារវាងការរៀបចំរបាយការណ៍ និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ[១] ។

២.១៧ សំណើជាគោលនយោបាយ និងកម្មវិធីរបស់*ផយអជ* ត្រូវបានបង្ហាញទៅតាមទម្រង់របស់យុទ្ធសាស្ត្រចតុកោណ ដោយមាន*អភិបាលកិច្ចល្អ*ជាស្នូលនៃយុទ្ធសាស្ត្រនេះ ។ ជាមួយគ្នានេះ វឌ្ឍនភាពក្នុងការអនុវត្ត*ផយអជ* នៅក្នុងរយៈពេលជាងពីរឆ្នាំកន្លះទៅនេះ រួមជាមួយនឹងការរំពឹងទុកនិងសំណើជាគោលនយោបាយសម្រាប់ពេលអនាគត ត្រូវបានបង្ហាញនៅផ្នែកខាងក្រោម ដោយប្រើប្រាស់ទម្រង់របស់យុទ្ធសាស្ត្រចតុកោណដំហានទី២ ។

## ស្នូលនៃយុទ្ធសាស្ត្រចតុកោណ : អភិបាលកិច្ចល្អ

២.១៨ អភិបាលកិច្ចសាធារណៈល្អ ដែលជាចំណុចស្នូលនៃយុទ្ធសាស្ត្រចតុកោណ ត្រូវការជាចម្បងនូវការចូលរួមជាសាធារណៈ ប្រកបដោយសមធម៌និងយុត្តិធម៌ នៅក្នុងគ្រប់បញ្ហាទាំងអស់ តាមរយៈមធ្យោបាយដែលមានលក្ខណៈប្រជាធិបតេយ្យនិងសន្តិវិធី ដើម្បីធានាថា ឆន្ទៈសេរីនិងជម្រើសដែលត្រូវបានគេដឹងជាមុនរបស់ក្រុមជនភាគច្រើនត្រូវបានអនុម័តយកនិងអនុវត្តព្រមគ្នា និងការការពារសិទ្ធិ និងសុខុមាលភាពរបស់ក្រុមជនភាគតិច ។ ស្ថេរភាពនយោបាយ សន្តិសុខផ្ទៃក្នុង ការប្រកាន់ខ្ជាប់នូវនីតិរដ្ឋ តម្លាភាពភាពអាចរំពឹងទុកបាន និងគណនេយ្យភាពរបស់ស្ថាប័នសាធារណៈមានសារៈសំខាន់ណាស់ចំពោះវឌ្ឍនភាពសេដ្ឋកិច្ចនិងសង្គមកិច្ចប្រកបដោយសណ្តាប់ធ្នាប់ និងដើម្បីការពារសមិទ្ធផលសាធារណៈ ដែលសម្រេចបានមិនឱ្យរងការបំផ្លិចបំផ្លាញដោយសមាសភាពបន្ទុចបង្អាក់ណាមួយឡើយ ។ កិច្ចអភិវឌ្ឍដ៏គួរឱ្យកត់សម្គាល់ក្នុងរយៈពេលពីរឆ្នាំកន្លះចុងក្រោយនេះ រួមមាន :

វិសោធនកម្មរដ្ឋធម្មនុញ្ញដ៏សំខាន់មួយ ដែលត្រួសត្រាយផ្លូវឱ្យច្បាប់ដែលត្រូវអនុម័ត តាមរយៈមតិភាគច្រើននៅក្នុងរដ្ឋសភា ដោយសម្លេងបោះឆ្នោតគាំទ្រ២/៣ ដែលបានធ្វើឱ្យមានការអូសបន្លាយ និងការលំបាក

[១] កថាខណ្ឌទី១៥ នៃយុទ្ធសាស្ត្រចតុកោណដំហានទី២

ក្នុងការបង្កើតរដ្ឋាភិបាលថ្មីបន្ទាប់ពីការបោះឆ្នោត និងធ្វើឱ្យមានការអូសបន្លាយដំណើរការអនុម័តច្បាប់នានា ។

ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់លើកទីពីរ ដែលបានប្រព្រឹត្តទៅនៅក្នុងខែមេសា ឆ្នាំ២០០៧ សម្រាប់ឃុំទាំង១.៦២១ ដែលក្នុងនោះ ៦៨ភាគរយនៃអ្នកមានសិទ្ធិបោះឆ្នោតបានទៅបោះឆ្នោត ក្នុងបរិយាកាសប្រកបដោយសន្តិភាព សេរីភាព និងយុត្តិធម៌ ។ និរន្តរភាពការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី២ ដែលទទួលបន្ទុកអនុវត្តភារកិច្ចរដ្ឋបាលនិងការអភិវឌ្ឍ បន្តពីក្រុមប្រឹក្សាអាណត្តិទី១ ត្រូវបានធានា ។

ការបោះឆ្នោតជាសាកលលើកទីបួន បានប្រព្រឹត្តទៅនៅក្នុងខែកក្កដា ឆ្នាំ២០០៨ សម្រាប់នីតិកាលទីបួននៃរដ្ឋសភា ឆ្នាំ២០០៨-២០១៣ ។ ដោយមានអ្នកមានសិទ្ធិបោះឆ្នោតប្រហែល ៧៥,២ភាគរយ បានចូលរួមដោយគ្មានការរារាំង ការបោះឆ្នោតនេះត្រូវបានប្រកាសទទួលស្គាល់យ៉ាងទូលំទូលាយថា បានប្រព្រឹត្តទៅក្នុងបរិយាកាសបើកទូលាយ និងដោយសេរី ដោយបង្កលក្ខណៈឱ្យគ្រប់រូបក្នុងការចូលរួមនៅមុនពេលបោះឆ្នោត និងក្នុងពេលបោះឆ្នោត ។

ដូចបានបញ្ជាក់រួចហើយ រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ២០០៨-២០១៣ ត្រូវបានបង្កើតឡើង ហើយបានប្រកាសថា យុទ្ធសាស្ត្រចតុកោណដំហានទី២ គឺជាផ្នែកមួយនៃ *"របៀបវារៈគោលនយោបាយសេដ្ឋកិច្ច-សង្គមកិច្ច"* នៃ *"វេទិកានយោបាយ"* របស់ខ្លួន ។

២.១៩ កំណែទម្រង់សំខាន់ៗ ចំនួនបួននៅក្នុងផ្នែកអភិបាលកិច្ចសាធារណៈ នៅតែបន្តជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីសម្រេចបាននូវកិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និងស្ថេរភាព ជាមួយនឹងសមធម៌ កាលានុវត្តភាពស្មើៗគ្នា សមភាពនៅចំពោះមុខច្បាប់ និងយុត្តិធម៌សង្គម ។ ការងារចម្បងៗនៅក្នុងផ្នែកនេះ រួមមាន : *(១) ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (២) កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (៣) កំណែទម្រង់រដ្ឋបាលសាធារណៈ រួមមានទាំងកម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការផង នៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់ និង (៤) កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ* ។ កិច្ចអភិវឌ្ឍន៍សំខាន់ៗដែលសម្រេចបានក្នុងរយៈពេលពីរឆ្នាំកន្លះចុងក្រោយនេះ រួមមាន :

២.២០ **ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ :** បន្ទាប់ពីបានឆ្លងកាត់ដំណាក់កាលជាច្រើននៃការពិនិត្យពិភាក្សាយ៉ាងហ្មត់ចត់មក ច្បាប់ប្រឆាំងអំពើពុករលួយដ៏ពេញលេញមួយកំពុងស្ថិតក្នុងដំណាក់កាលចុងក្រោយនៃការអនុម័ត របស់រាជរដ្ឋាភិបាលកម្ពុជា ។ ច្បាប់នេះនឹងត្រូវបានរៀបចំឡើងឱ្យស្របទៅតាមក្រមព្រហ្មទណ្ឌ ដែលត្រូវអនុម័តដោយអង្គការនីតិបញ្ញត្តិមុនពេលចូលជាធរមាន ។ ទន្ទឹមនឹងនេះ ក្របខ័ណ្ឌគតិយុត្តិ និងយន្តការស្ថាប័នដែលមានស្រាប់ កំពុងត្រូវបានជំរុញឱ្យកាត់បន្ថយ និងទប់ស្កាត់អំពើពុករលួយ ។ ក្នុងន័យនេះ វចនាសម្ព័ន្ធនៃអង្គភាព

ប្រឆាំងអំពើពុករលួយត្រូវបានរៀបចំឡើងវិញតាមរយៈ អនុក្រឹត្យមួយរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ៨៤ អនប្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៦ ។ ការិយាល័យទទួលពាក្យបណ្តឹងមួយត្រូវបានបង្កើតឡើងនៅទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងគោលបំណងលើកស្ទួយការចូលរួមរបស់សាធារណៈជន ក្នុងការផ្តល់និងការទទួលព័ត៌មានដែលពាក់ព័ន្ធនឹងអំពើពុករលួយ ។ លើសពីនេះទៀត សកម្មភាពដាក់ពិន័យនានា ត្រូវបានអនុវត្តចំពោះប្រជាជនសាមញ្ញ និងមន្ត្រីរាជការ ដូចជា មន្ត្រីគយ មន្ត្រីនគរបាល មន្ត្រីតុលាការ និងជនស៊ីវិល ដែលបានឃុបឃិតប្រព្រឹត្តអំពើពុករលួយ ។ នៅក្នុងការងារគ្រប់គ្រងសាធារណៈ តម្លាភាពនិងគណនេយ្យភាពច្រើនជាងមុន កំពុងត្រូវបានធានាឱ្យមាននៅក្នុងការងារលទ្ធកម្មសាធារណៈ ដោយមានកិច្ចដំណើរការដេញថ្លៃប្រកបដោយការប្រកួតប្រជែង ។ យុទ្ធនាការផ្សព្វផ្សាយត្រូវបានចាប់ផ្តើមអនុវត្ត ដើម្បីផ្តល់ព័ត៌មានជូននិងអប់រំដល់សាធារណៈជន និងដើម្បីបញ្ជ្រាបឱ្យមានការយល់ដឹងអំពីគ្រប់ទិដ្ឋភាពអវិជ្ជមានទាំងអស់នៃអំពើពុករលួយដែលក្នុងនោះរួមទាំង មូលហេតុនៃផលប៉ះពាល់ និងផលវិបាក ។ ការកើនឡើងនៃការវិនិយោគរបស់ផ្នែកឯកជន កំណើនម៉ាក្រូសេដ្ឋកិច្ច ការកើនឡើងយ៉ាងឆាប់រហ័សនៃចំណូលរបស់រាជរដ្ឋាភិបាលកម្ពុជា ការធ្វើឱ្យប្រសើរឡើងនូវតម្លាភាពនិងភាពអាចទំពឹងទុកជាមុនក្នុងការងាររបស់រាជរដ្ឋាភិបាលកម្ពុជា និងការធ្វើឱ្យមានប្រសិទ្ធភាពជាងមុននូវនីតិវិធីនិងដំណើរការផ្ទៃក្នុងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺជាសក្ខីភាពគ្រប់គ្រាន់ល្មមដែលបង្ហាញថា ទំនុកចិត្តនិងភាពកក់ក្តៅរបស់ផ្នែកឯកជនចំពោះប្រទេសនេះកំពុងមានការកើនឡើង និងដែលជាសញ្ញាមួយបញ្ជាក់ថា កម្រិតនៃអំពើពុករលួយកំពុងត្រូវបានកាត់បន្ថយ[១] ។ ប៉ុន្តែ ប្រការសំខាន់ដែលត្រូវធ្វើការកត់សម្គាល់ គឺថាគោលនយោបាយលុបបំបាត់អំពើពុករលួយគឺជាកិច្ចខិតខំប្រឹងប្រែងមួយត្រូវការរយៈពេលវែង និងមានបញ្ហាប្រឈមច្រើន ដែលតម្រូវឱ្យមានមធ្យោបាយគ្រប់គ្រាន់ ដែលក្នុងនោះ រួមទាំងការរៀបចំឱ្យមានក្របខ័ណ្ឌស្ថាប័នសមស្រប និងការលើកកម្ពស់ធនធានមនុស្សនិងហិរញ្ញវត្ថុ ។

២.២១ **<u>កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌</u>** : ផែនការសកម្មភាព (ខែមេសា ឆ្នាំ២០០៥) សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ (ខែមិថុនា ឆ្នាំ២០០៣) ត្រូវបានអនុវត្ត ដោយផ្តោតលើគោលដៅនិងសកម្មភាពជាយុទ្ធសាស្ត្រចំនួនប្រាំពីរ ដែលបានលើកឡើងនៅក្នុង *ផយអជ* ។ ច្បាប់និងក្រមជាមូលដ្ឋានមួយចំនួនត្រូវបានអនុម័ត និងចូលជាធរមានរួចហើយ ក្នុងនោះរួមមាន : ក្រមនីតិវិធីរដ្ឋប្បវេណី ចូលជាធរមាននៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមាន នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ក្រមរដ្ឋប្បវេណី ចូលជាធរមាន នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ។ ច្បាប់និងក្រមសំខាន់ៗ មួយចំនួនផ្សេងទៀតក៏ត្រូវបានបង្កើតឡើងផងដែរ ដូចជា ច្បាប់ស្តីពីការប្រឆាំងភេរវកម្ម ដែលបានចូលជាធរមាន នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ និងច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលបានចូលជាធរមាន នៅ

[១] សូមអានផងដែរ នៅក្នុងកថាខណ្ឌ ២.៦៨ ។

ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ។ សេចក្តីព្រាងច្បាប់និងបទប្បញ្ញត្តិផ្សេងៗទៀត ស្តីពីនីតិវិធីច្បាប់ និងតុលាការ ត្រូវបានរៀបចំឡើង ។ គម្រោងតុលាការគំរូបានចាប់ផ្តើមនៅខេត្តកណ្តាល ហើយកំពុងត្រូវបានពង្រីកទៅកាន់តុលាការខេត្ត-ក្រុងបីផ្សេងទៀត គឺតុលាការរាជធានីភ្នំពេញ តុលាការខេត្តបន្ទាយមានជ័យ និងតុលាការខេត្តកំពង់ចាម ។ ទន្ទឹមនឹងនេះ ការសិក្សាស្រាវជ្រាវអំពីការដោះស្រាយវិវាទនៅកម្រិតមូលដ្ឋានក៏កំពុងតែប្រព្រឹត្តទៅតាមកម្មវិធីកំណត់ ។ ការពង្រឹងសមត្ថភាពសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី និងការពង្រឹងការអនុវត្តច្បាប់នៅក្នុងតុលាការត្រូវបានអនុវត្តយ៉ាងសកម្ម ។ ការដាក់ពិន័យយ៉ាងតឹងរឹង និងទាន់ពេលវេលាកំពុងត្រូវបានធ្វើឡើងចំពោះអ្នកដែលបានប្រព្រឹត្តខុសឆ្គងក្នុងប្រព័ន្ធតុលាការ ។ ក្រមសីលធម៌សម្រាប់ចៅក្រម និងព្រះរាជអាជ្ញាត្រូវបានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអនុម័តដាក់ឱ្យអនុវត្ត នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ ហើយក្រមសីលធម៌ សម្រាប់អ្នកអនុវត្តច្បាប់ដទៃទៀតកំពុងត្រូវបានរៀបចំឡើង ។ ការងារដែលត្រូវធ្វើខាងមុខ គឺបន្តជំរុញល្បឿននៃដំណើរការកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ក្នុងនោះរួមទាំងការប្រកាសដាក់ឱ្យអនុវត្តច្បាប់មូលដ្ឋានចំនួនប្រាំបីដែលនៅសេសសល់ (រួមទាំងក្រមព្រហ្មទណ្ឌ) ការកសាងសមត្ថភាពសម្រាប់អ្នកប្រកបវិជ្ជាជីវៈក្នុងការងារច្បាប់និងតុលាការ និងការបង្កើនការយល់ដឹងរបស់សាធារណៈជនពីប្រព័ន្ធយុត្តិធម៌ និងការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ ។

២.២២ **កំណែទម្រង់រដ្ឋបាលសាធារណៈ** : ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រួមជាមួយក្រសួងផ្សេងទៀតបានរៀបចំនិងអនុវត្តយុទ្ធសាស្ត្រនិងផែនការសកម្មភាពរយៈពេលមធ្យមមួយ ដើម្បីកែលម្អគោលនយោបាយបៀវត្សរ៍ និងបែងចែកការងារ នៅក្នុងវិស័យអាទិភាពនានា (អប់រំ សុខាភិបាល និងកសិកម្ម) ។ ក្នុងឆ្នាំ២០០៨ ប្រាក់បៀវត្សរ៍មធ្យមទាបបំផុតប្រចាំខែរបស់មន្ត្រីរាជការបានកើនឡើងដល់ ១១៤ភាគរយ គឺកើនពី ៣០ដុល្លារ នៅឆ្នាំ ២០០៤ ដល់ ៦៤,២ដុល្លារអាមេរិកក្នុងមួយខែ ហើយការកើនឡើង ២០ភាគរយ ជារៀងរាល់ឆ្នាំ ត្រូវបានគ្រោងរក្សាឱ្យបានសម្រាប់ពេលបច្ចុប្បន្ននេះ ។ លើសពីនេះទៀត ប្រាក់លើកទឹកចិត្តដើម្បីលើកកម្ពស់គណនេយ្យភាព និងការអនុវត្តការងាររបស់មន្ត្រីរាជការស៊ីវិល តាមរយៈកម្មវិធីកន្សោមអាទិភាព និងប្រព័ន្ធគំនិតផ្តួចផ្តើមផ្តល់ប្រាក់បំណាច់ផ្អែកលើស្នាដៃការងារ ។ ប្រព័ន្ធប្រាក់ឧបត្ថម្ភនៅតែត្រូវបានបន្តផ្តល់ឱ្យដើម្បីបំពេញបន្ថែមលើប្រាក់បៀវត្សរ៍មូលដ្ឋានសំដៅកែលម្អការជួយគាំទ្រដល់តម្រូវការប្រតិបត្តិការជាអាទិភាពនានា ។ ទំហំសរុបនៃសេវាស៊ីវិលសាធារណៈត្រូវបានធ្វើឱ្យមានស្ថេរភាពតាំងពីឆ្នាំ២០០២ (១៦៥.០០០នាក់ នៅក្នុងឆ្នាំ២០០២ ដល់ ១៧៩.១៩២នាក់ នៅក្នុងឆ្នាំ២០០៨ ដោយមិនរាប់បញ្ចូលបុគ្គលិកបណ្តែត ។ ដោយមានស្ត្រីតែ ៣១ភាគរយ នៅក្នុងសេវាស៊ីវិលសាធារណៈ ការបង្កើនតំណាងរបស់ស្ត្រីនៅក្នុងផ្នែកនេះនៅបន្តជាបញ្ហាមួយ ។ ទោះជាដូចនេះក្តី ជាវិធានការមួយដើម្បីលើកស្ទួយស្ថានភាពរបស់ស្ត្រី គោលនយោបាយផ្តល់ការគាំទ្រហិរញ្ញវត្ថុលើការធានារ៉ាប់រងសង្គមជូនមន្ត្រីរាជ-ការស៊ីវិល ត្រូវបានធ្វើវិសោធនកម្មដើម្បីដាក់បញ្ចូលមរណភាព និងការឈប់សម្រាកមាតុភាព ។ ការងារមួយចំនួននៅក្នុងចំណោមការងារផ្សេងៗទៀត រួមមាន ដូចខាងក្រោម :

កំណែទម្រង់សេវាស៊ីវិលសាធារណៈ រួមទាំងការបង្កើនកម្រិតប្រាក់បៀវត្សរ៍មធ្យម គឺជាការងារបន្ទាន់មួយ ដោយសារការបន្តមាននូវកម្រិតខ្ពស់នៃបណ្តាជនរស់នៅក្រៅប្រទេស ដែលកំពុងតែធ្វើការងារជំនួសពលរដ្ឋកម្ពុជា នៅក្នុងវិស័យជាច្រើន ។ ការអភិវឌ្ឍសមត្ថភាព ត្រូវតែបង្កើនល្បឿន តាមរយៈការផ្តល់ការលើកទឹកចិត្តនានាដែលបានសម្រិតសម្រាំង និងការបណ្តុះបណ្តាលសម្រាប់ក្រុមគោលដៅ ។

លទ្ធភាពទទួលបានប្រព័ន្ធព័ត៌មាន ត្រូវបានទទួលស្គាល់ ដើម្បីសម្រួលឱ្យសាធារណៈជនអាចទទួលបានឯកសារ និងទិន្នន័យរបស់រាជរដ្ឋាភិបាលកម្ពុជា ។

២.២៣ ***<u>វិមជ្ឈការ និង វិសហមជ្ឈការ</u>*** : ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការកំពុងត្រូវបានអនុវត្ត ។ ច្បាប់គ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយក្រុមទីប្រឹក្សាមួយក្រុមចូលរួម ដោយផ្នែកសាធារណៈ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ត្រូវបានអនុម័តដោយរដ្ឋសភា នាដើមឆ្នាំ២០០៨ ហើយបច្ចុប្បន្ននេះកំពុងត្រូវបានចាប់ផ្តើមអនុវត្ត ។ ច្បាប់នេះ ផ្តោតលើការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ កម្មវិធីជាតិមួយរយៈពេល១០ឆ្នាំ សម្រាប់ការអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដែលហៅថា កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កំពុងស្ថិតក្នុងដំណាក់កាលនៃការរៀបចំជាសេចក្តីព្រាងសម្រាប់ការអនុវត្ត ដែលនឹងចាប់ផ្តើមក្នុងឆ្នាំ២០១០ ។ កិច្ចអភិវឌ្ឍផ្សេងៗទៀត រួមមាន :

ការងារទាំងអស់សម្រាប់កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ស្ថិតនៅក្រោមតួនាទីដឹកនាំ និងសម្របសម្រួលរួមរបស់ក្រសួងមហាផ្ទៃ ។ *គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ (គ.ជ.វ.វ.)* ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៦[១] ហើយបានរៀបចំបង្កើតឡើងនូវកម្មវិធីកំណែទម្រង់មួយ ដោយមានរចនាសម្ព័ន្ធស្ថាប័ន ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ព្រមទាំងបានអនុវត្តយ៉ាងរលូននូវសកម្មភាពគ្រោងទុកទាំងឡាយ ។

ដើម្បីកែលម្អមុខងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ បទប្បញ្ញត្តិជាច្រើនផ្សេងទៀតត្រូវបានអនុម័ត ឧទាហរណ៍ដូចជា សេចក្តីណែនាំជាច្រើនដែលពាក់ព័ន្ធនឹងនីតិវិធីជ្រើសរើសមេភូមិ និងការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ជាដើម ។

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើនវិភាជន៍ថវិការបស់ខ្លួន ជូនដល់មូលនិធិឃុំ-សង្កាត់ ពី ១,៥ភាគរយ នៅក្នុងឆ្នាំ២០០២ ដល់ ២,៧០ភាគរយ នៅក្នុងឆ្នាំ២០០៨ ព្រមទាំង បានកៀរគរធនធានខាងក្រៅថែមទៀត ដើម្បីអនុវត្តគម្រោងនិងកម្មវិធីនានា ដែលពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅកម្រិតខេត្ត-ក្រុង ស្រុក-ខណ្ឌ និង ឃុំ-សង្កាត់ ។

---

[១] កម្មវិធីសីលារបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានបញ្ចប់នាឆ្នាំ២០០៦ ហើយត្រូវបានដាក់បញ្ចូលទៅក្នុងការងាររបស់ គ.ជ.វ.វ. ក្នុងខែមករា ឆ្នាំ២០០៧ ។

២.២៤ **<u>កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ</u>** : យោងទៅតាមស្មារតីនៃ *"សៀវភៅសការពារជាតិ"* កំណែទម្រង់ និងការពង្រឹងកងកម្លាំងប្រដាប់អាវុធ ត្រូវបានអនុវត្តឡើងទៅតាមផែនការ តាមរូបភាពនៃការរំសាយទ័ព និងការបង្កើតឡើងនូវកងកម្លាំងប្រដាប់អាវុធមួយមានប្រសិទ្ធភាពជាងមុន ។ សមាមាត្រនៃវិស័យការពារ និងសន្តិសុខជាតិនៅក្នុងផលិតផលក្នុងស្រុកសរុប មានស្ថេរភាពនៅក្នុងកម្រិតប្រហែល ២ភាគរយ (១,៨ភាគរយ ក្នុងឆ្នាំ២០០៥ ឆ្នាំ២០០៦ និងឆ្នាំ២០០៧) ហើយត្រូវបានរំពឹងថានឹងមានកម្រិត ១,៧ភាគរយ នៅឆ្នាំ២០១០ ។ ចំណែកនេះនៅក្នុងថវិកាជាតិ បានថយចុះជាបណ្តើរៗ (២២,៩៣ភាគរយ ក្នុងឆ្នាំ២០០៥ មកត្រឹម ១៨,៨៧ភាគរយ ក្នុងឆ្នាំ២០០៧) ។ រាជរដ្ឋាភិបាលកម្ពុជានឹងធានាថា កងកម្លាំងប្រដាប់អាវុធ នឹងទទួលបានមូលនិធិដែលត្រូវការចាំបាច់ ដើម្បីឱ្យបានស្ថិតនៅក្នុងសភាពត្រៀមខ្លួនជានិច្ច ក្នុងការការពារបូរណភាពទឹកដីរបស់ប្រទេស ដោយធ្វើវិភាជន៍ថវិកាដែលត្រូវការ ដោយមិនធ្វើការកាត់បន្ថយចំណែក ដែលត្រូវកើនឡើងសម្រាប់ការអភិវឌ្ឍ និងសម្រាប់វិស័យសង្គមកិច្ច ។

## បរិស្ថានសម្រាប់គ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

២.២៥ ដើម្បីបង្កើតឡើងនូវបរិស្ថានសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ ទិដ្ឋភាពសំខាន់ៗចំនួនបួន គឺជាកិច្ចការដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវយកចិត្តទុកដាក់ : *(១) សន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម (២) សមាហរណកម្មប្រទេសកម្ពុជាក្នុងតំបន់និងពិភពលោក (៣) ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ រួមមានភាពជាដៃគូជាមួយវិស័យឯកជននិងដៃគូអភិវឌ្ឍន៍ ព្រមទាំងភាពជាដៃគូជាមួយជាមួយនឹងសង្គមស៊ីវិល និង (៤) បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ* ។ ដោយហេតុថា បញ្ហាទាំងនេះជា បញ្ហាអន្តរវិស័យ និងបញ្ហាដែលគ្របដណ្តប់លើវិស័យដទៃទៀត សម្រាប់ "ការកសាងនិងការលើកកម្ពស់ទុនសង្គម" ដែលមានលក្ខណៈអរូបិយ ប៉ុន្តែមានសារៈសំខាន់ នោះវិស័យសាសនានិងវប្បធម៌ ត្រូវស្ថិតនៅក្នុងផ្នែកនេះ ហើយនឹងត្រូវបានពិភាក្សា ខាងក្រោមនេះ ។

២.២៦ **<u>សន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម</u>** : គឺជាមូលដ្ឋានគ្រឹះសម្រាប់កិច្ចខិតខំប្រឹងប្រែង ធ្វើឱ្យមានវឌ្ឍនភាពសម្រាប់រយៈពេលយូរអង្វែង ។ ការប្តេជ្ញាយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះការពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីនិងពហុបក្ស ការពិភាក្សាគ្នា និងការកែតម្រូវគ្នាទៅវិញទៅមក នៅក្នុងចំណោមប្រជាជន ដែលមានទស្សនៈនិងការយល់ឃើញខុសៗគ្នាកំពុងទទួលបានផ្លែផ្កា ។ កិច្ចដំណើរការទាំងនេះកំពុងចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមកម្ពុជា ។ វិសោធនកម្មរដ្ឋធម្មនុញ្ញដែលបានលើកឡើងក្នុងកថាខ័ណ្ឌ២.០៧ បានពង្រឹងបន្ថែមទៀតនូវដំណើរការលទ្ធិប្រជាធិប្រជាធិបតេយ្យ ។ ការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រចំនួនបួនលើក ការបោះឆ្នោតសកលជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ចំនួនពីរលើក និងការបោះឆ្នោតអសកលជ្រើសតាំងសមាជិកព្រឹទ្ធសភាចំនួនមួយលើក ត្រូវបានធ្វើឡើង ។ ស្ថេរភាពនយោបាយ សន្តិសុខ

និងសណ្តាប់ធ្នាប់សាធារណៈដែលកំពុងកើតមាន បានក្លាយជាបរិស្ថានមួយពោរពេញដោយកម្លាំងជំរុញសម្រាប់បន្តការរីកចម្រើននៃសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពខាងការនិយាយស្តី ។ រាជរដ្ឋាភិបាលកម្ពុជា នឹងខិតខំឱ្យអស់ពីសមត្ថភាព ដើម្បីធានាឱ្យបានថា សមិទ្ធផលដែលសម្រេចបានដោយលំបាកនេះ បន្តរីកចម្រើន និងត្រូវបានធ្វើឱ្យជ្រួតជ្រាបយ៉ាងពេញលេញទៅក្នុងសង្គមកម្ពុជា និងផ្នត់គំនិតប្រជាជនកម្ពុជា ។

២.២៧ **<u>សមាហរណកម្មកម្ពុជាក្នុងតំបន់និងពិភពលោក</u>** : ការរួមចំណែកនិងកិច្ចសហប្រតិបត្តិការដ៏សកម្មរបស់កម្ពុជា នៅក្នុងស្ថាប័នអន្តរជាតិ អង្គការតំបន់ និងអង្គការអនុតំបន់ បានផ្តល់អត្ថប្រយោជន៍ដ៏ធំធេងដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ។ នៅកម្រិតតំបន់ ស្ថាប័នទាំងនេះ រួមបញ្ចូលទាំង សមាគមអាស៊ាន និងអង្គការអនុតំបន់ ជាច្រើនផ្សេងទៀត ដែលនៅក្នុងនេះ កម្ពុជាបានដើរតួរនាទីសំខាន់ឆ្ពោះទៅរកការកសាងសហគមន៍អាស៊ានឆ្នាំ២០១៥ ។ សមាជិកភាពរបស់កម្ពុជានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក បានបើកទូលាយឱ្យមានលទ្ធភាពជាច្រើនសម្រាប់កម្ពុជា ចាប់យកនូវឧត្តមភាពក្នុងការប្រកួតប្រជែងរបស់ខ្លួន ។ គោលបំណងដ៏ចម្បងនៃសកម្មភាពទាំងអស់នេះ គឺដើម្បីពង្រឹងនិងលើកស្ទួយកិច្ចសហប្រតិបត្តិការផ្តល់ប្រយោជន៍ទៅវិញទៅមក ដែលកើតមានពីការធ្វើសមាហរណកម្ម សំដៅឈានទៅសម្រេចបាននូវគោលដៅនិងយុទ្ធសាស្រ្តជាអាទិភាពនានា របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រនិងកំណើនរួមនៅក្នុងវិបុលភាព ។ រាជរដ្ឋាភិបាលកម្ពុជា នឹងព្យាយាមធ្វើឱ្យសម្រេចបាននូវការផ្សារភ្ជាប់កម្ពុជាទៅក្នុងតំបន់និងពិភពលោក សំដៅលើកកម្ពស់កិត្តិនាម និងអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើនជឿនលឿន ។

២.២៨ **<u>ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ</u>** : ទិដ្ឋភាពទាំងបីនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងអ្នកមានចំណែកពាក់ព័ន្ធផ្សេងទៀត រួមមានទំនាក់ទំនងជាមួយ (១) សង្គមស៊ីវិល (២) ផ្នែកឯកជន និង (៣) ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។ ចំពោះភាគីពីរខាងដើម :

កិច្ចខិតខំប្រឹងប្រែងដ៏សកម្មត្រូវបានធ្វើជាបន្ត ដើម្បីធ្វើឱ្យមានការពាក់ព័ន្ធនិងការផ្សារភ្ជាប់ជាមួយនឹងគ្រប់ផ្នែកទាំងអស់នៃសង្គមស៊ីវិលនៅក្នុងគ្រប់ទិដ្ឋភាពសមស្របទាំងអស់ នៃកិច្ចដំណើរការរៀបចំផែនការនិងធ្វើសេចក្តីសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរុញឱ្យប្រទេសកម្ពុជារីកចម្រើនឡើង ។ សង្គមស៊ីវិលគឺជាដៃគូដ៏សំខាន់មួយ ហើយអង្គការក្រៅរដ្ឋាភិបាលជាច្រើន ទាំងថ្នាក់ជាតិនិងអន្តរជាតិ បំពេញតួនាទីមួយដ៏សកម្មនិងប្រកបដោយការយកចិត្តទុកដាក់ នៅក្នុងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចក៏ដូចជា ក្នុងការជំរុញលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ។ អង្គការទាំងនេះ មានតំណាង និងរួមចំណែកនៅក្នុងវេទិកាសហប្រតិបត្តិការនិងការពិគ្រោះយោបល់ជាន់ខ្ពស់ជាច្រើន ដូចជា វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងក្រុមការងារ

បច្ចេកទេស ។ ច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាល នឹងត្រូវអនុម័តបន្ទាប់ពីមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ។

នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ផ្នែកឯកជនមានតួនាទីចម្បងជាក្បាលម៉ាស៊ីននិងកម្លាំងនាំមុខសម្រាប់វិនិយោគនិងកំណើនសេដ្ឋកិច្ច[១] ។ ដើម្បីសម្រួលនិងជួយដល់កិច្ចអភិវឌ្ឍន៍និងវឌ្ឍនភាពប្រកបដោយសណ្តាប់ធ្នាប់របស់ផ្នែកឯកជន យន្តការមួយចំនួនត្រូវបានបង្កើតឡើង ។ ដូចដែលបានអនុវត្តរួចមកហើយ កិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការងារសហប្រតិបត្តិការ ដូចជា តាមរយៈវេទិកាពិគ្រោះយោបល់រវាងរដ្ឋាភិបាលនិងផ្នែកឯកជន ត្រូវបានវាយតម្លៃខ្ពស់ដោយផ្នែកឯកជន ហើយទទួលបានផ្លែផ្កា ដូចដែលស្តែងឡើងតាមរូបភាពកំណើនដ៏មាំមួននៃការវិនិយោគរបស់ផ្នែកឯកជន ។ កិច្ចខិតខំប្រឹងប្រែងដ៏ពេញលេញ នឹងត្រូវបន្តធ្វើដើម្បីពង្រឹងនិងធ្វើឱ្យកាន់តែស៊ីជម្រៅនូវទំនាក់ទំនងល្អនិងដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមកជាមួយផ្នែកឯកជន ដោយផ្អែកលើការគោរពច្បាប់និងបទប្បញ្ញត្តិទាំងឡាយយ៉ាងខ្ជាប់ខ្ជួន និងដោយផ្តោតលើអាទិភាពអភិវឌ្ឍន៍ ។

២.២៩ <u>*ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស*</u> ៖ ជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសប្រកបដោយសប្បុរសធម៌ពីដៃគូអភិវឌ្ឍន៍ បានជួយប្រទេសកម្ពុជាយ៉ាងច្រើន ក្នុងការធ្វើឱ្យសម្រេចបាននូវវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់មកដល់ពេលនេះ ។ រាជរដ្ឋាភិបាលកម្ពុជាវាយតម្លៃខ្ពស់ចំពោះជំនួយនេះ ។ ទំនាក់ទំនងសហប្រតិបត្តិការរវាងដៃគូអភិវឌ្ឍន៍ក្រៅប្រទេសនិងរាជរដ្ឋាភិបាលកម្ពុជា បានរីកចម្រើនជាលំដាប់និងកាន់តែមានភាពស៊ីជម្រៅក្នុងបណ្តាឆ្នាំកន្លងមកនេះ ហើយកំពុងតែមានលក្ខណៈរឹងមាំ ដោយផ្អែកលើការយល់ដឹងអំពីតួនាទីនិងតម្រូវការទាំងសងខាង ។ ការរីកចម្រើនជាច្រើននៅក្នុងកិច្ចដំណើរការពិគ្រោះយោបល់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រួមមាន ៖

- ដើម្បីណែនាំដៃគូអភិវឌ្ឍន៍ និងធានាឱ្យបានកាន់តែប្រសើរឡើងនូវការសម្របសម្រួលសមស្របនូវជំនួយទាំងអស់ពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ក្របខ័ណ្ឌយុទ្ធសាស្ត្រមួយសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ត្រូវបានរៀបចំឡើង នៅក្នុងឆ្នាំ ២០០៦ ។
- វេទិកាពិភាក្សាពិគ្រោះយោបល់ធំៗប្រចាំឆ្នាំ ត្រូវបានរៀបចំធ្វើឡើងនៅក្រោមភាពជាម្ចាស់ដ៏ពេញលេញរបស់កម្ពុជា ហើយត្រូវបានដូរឈ្មោះទៅជា *វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា* ដែលត្រូវបានប្រារព្ធធ្វើជាលើកទី១ ក្នុងឆ្នាំ២០០៧ ។
- គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ជួបប្រជុំគ្នាក្នុងមួយឆ្នាំបីដង ដើម្បីពិភាក្សាបញ្ហារួម និងពិនិត្យមើលសូចនាករតាមដានរួមគ្នា ដើម្បីតាមដានត្រួតពិនិត្យពីវឌ្ឍនភាពនៃទិដ្ឋភាពផ្សេងៗរបស់ *ផយអជ* ។

---

[១] ចំណុចនេះ ក៏ត្រូវបានលើកឡើងផងដែរនៅក្នុងកថាខណ្ឌ ២.៦៧ និង ២.៦៨ ។

ក្រុមការងារបច្ចេកទេស ដំណើរការងាររបស់ខ្លួន ដើម្បីសម្របសម្រួលនិងតាមដានត្រួតពិនិត្យវឌ្ឍនភាព ឱ្យបានប្រសើរជាងមុន នៅកម្រិតវិស័យ ។ បន្ទាប់ពីការពិនិត្យមើលឡើងវិញនូវការអនុវត្តតួនាទីដំបូងរបស់ក្រុមការងារបច្ចេកទេស និងដោយមានការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់ គោលការណ៍ណែនាំដ៏ច្បាស់លាស់មួយចំនួន ត្រូវបានប្រកាសចេញ នៅក្នុងឆ្នាំ២០០៦ ។

នីតិវិធីនិងកិច្ចដំណើរការនៃការប្រមូលទិន្នន័យជំនួយរបស់ដៃគូអភិវឌ្ឍន៍ ត្រូវបានធ្វើការកែសម្រួលឱ្យរលូន ហើយមូលដ្ឋានទិន្នន័យនៃជំនួយអភិវឌ្ឍន៍ផ្លូវការ របស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបានធ្វើបច្ចុប្បន្នភាព ជាបន្តបន្ទាប់ ។

ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស កំពុងតែសហការគ្នាច្រើនជាងមុននៅក្នុងចំណោមពួកគេ ហើយបានលើកជូនរាជរដ្ឋាភិបាលកម្ពុជា នូវបញ្ហាបារម្ភរួមទាំងឡាយរបស់ពួកគេ ។

រាជរដ្ឋាភិបាលកម្ពុជា ប្ដេជ្ញាអនុវត្ត "*របៀបវារៈអាក់ក្រាដើម្បីសកម្មភាព*" ដើម្បីបង្កើនប្រសិទ្ធភាពនៃជំនួយអភិវឌ្ឍន៍[១] ។

២.៣០ ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេសសរុបដែលបានផ្ដល់មកកម្ពុជា មានការកើនឡើង ភាគច្រើនដោយសារការបញ្ចូលនូវជំនួយពីដៃគូ "មិនមែនប្រពៃណី" ទាំងឡាយ ដែលមានរហូតមកទល់ពេលនេះ ។ ទោះជាដូចនេះក្ដី ជាលក្ខណៈអន្តរជាតិ ជំនួយអភិវឌ្ឍន៍ពីបណ្ដាប្រទេសជឿនលឿន មិនបានបង្ហាញឱ្យឃើញពីសញ្ញាណាមួយនៃការកើនឡើងទៅដល់កម្រិតដែលបានប្រកាន់យកដោយកិច្ចព្រមព្រៀងទីក្រុងម៉ុងតេរ៉េ ឆ្នាំ២០០១ ទេ ពោលគឺ ០,៧ភាគរយ នៃផលិតផលក្នុងស្រុកសរុបក្នុងមួយឆ្នាំ ផ្ទុយទៅវិញត្រូវបានប៉ាន់ស្មានថាបានធ្លាក់ចុះ ៨,៤ភាគរយ ក្នុងឆ្នាំ២០០៧ បន្ទាប់ពីធ្លាក់ចុះ ៤,៧ភាគរយ ក្នុងឆ្នាំ២០០៦[២] ហើយជាមធ្យមជំនួយនេះមានតែ ០,៤៥ភាគរយ នៃផលិតផលក្នុងស្រុកសរុបរបស់បណ្ដាប្រទេសអភិវឌ្ឍន៍ ។ នៅប្រទេសកម្ពុជា កង្វះខាតមួយចំនួនដែលត្រូវដោះស្រាយនិងជំនះឱ្យបានត្រូវបានសង្កេតឃើញ ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍ស្ដីពីប្រសិទ្ធភាពជំនួយឆ្នាំ២០០៧ (គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា) ។ លើសពីនេះទៀត ការងារដែលត្រូវ :

លើកលែងតែករណីមួយចំនួនតូច ដែលនៅក្នុងនោះ ការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងវិស័យ ត្រូវបានអនុវត្ត (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា) ការតម្រឹមតម្រង់ធនធានរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទៅនឹង*ផយអជ* មិនបានដំណើរការល្អទេ ទោះបីជាមាន

[១] បញ្ហានេះ ត្រូវបានពិភាក្សានៅក្នុងវេទិកាកម្រិតខ្ពស់ទី៣ ក្នុងខែកញ្ញា ឆ្នាំ២០០៨ (វេទិកាពីរមុន ត្រូវបានប្រារព្ធធ្វើនៅទីក្រុងប៉ារីស និងទីក្រុងរ៉ូម)

[២] របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៨

ការសន្យាច្បាស់លាស់នៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនិងទីក្រុងរ៉ូម និងកិច្ចព្រមព្រៀងកម្រិតប្រទេសដែលធ្វើឡើងដោយស្ថាប័នផ្តល់ជំនួយធំៗក្តី ។

ក្រុមការងារបច្ចេកទេសជាច្រើន នៅមិនទាន់បានចាប់ផ្តើមពិនិត្យឡើងវិញនូវកម្មវិធីកំពុងដំណើរការទាំងអស់នៅឡើយទេ ដើម្បីតម្រឹមតម្រង់និងកែតម្រូវទិសដៅនៃកម្មវិធីទាំងនេះទៅនឹងអាទិភាពទាំងឡាយរបស់ *ផយអជ* ក៏ដូចជា ទៅតាមកម្មវិធីវិនិយោគសាធារណៈ ទោះបីជាមានការអំពាវនាវច្បាស់លាស់ពីថ្នាក់ដឹកនាំខ្ពស់បំផុតនៅក្នុងរាជរដ្ឋាភិបាលកម្ពុជាក្តី[១] ។ ក្នុងន័យនេះ ធនធានរបស់ដៃគូអភិវឌ្ឍន៍ដែលត្រូវការចាំបាច់នៅតែត្រូវបានបន្តចំណាយតាមរបៀបដែលធ្លាប់បានធ្វើរួចមកហើយ និងដែលត្រូវបានកំណត់ជាមុន ដោយបង្កើតបានតែការសិក្សាស្រាវជ្រាវជាច្រើននិងជំនួយបច្ចេកទេសដែលត្រូវបានធ្វើត្រួតគ្នា[២] និងដោយមិនបានបន្ថែមឱ្យបានច្រើននូវ "ការផ្ទេរធនធានសុទ្ធ" ដែលត្រូវការយ៉ាងខ្លាំងសម្រាប់អាទិភាពរបស់ប្រទេសកម្ពុជាឡើយ ។

**ប្រអប់ ២.៣**

**ការតម្រឹមតម្រង់ ការប្រើប្រាស់ និងគណនេយ្យភាព នូវធនធានរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស**

១. *ផយអជ* បានអំពាវនាវយ៉ាងច្បាស់លាស់ឱ្យមានការកែប្រែធំៗនៅក្នុងអភិក្រមរបស់ដៃគូអភិវឌ្ឍន៍ ពោលគឺ (១) ងាកចេញពីការសិក្សាកម្រិតខ្ពស់ ដែលត្រូវចំណាយច្រើន ទៅកាន់សកម្មភាពជាក់ស្តែង (២) កាត់បន្ថយជំនួយបច្ចេកទេសឱ្យបានដល់កម្រិតតិចបំផុត តាមការចាំបាច់ និង (៣) ធ្វើឱ្យមាន "ការផ្ទេរធនធានសុទ្ធ" ។ គួរឱ្យស្តាយ វឌ្ឍនភាពមកដល់ពេលនេះ នៅលើចំណុចទាំងបីនេះ មិនទាន់ត្រូវបានជំរុញលើកទឹកចិត្តឱ្យបានខ្លាំងក្លានៅឡើយ ។

២. *ផយអជ* បានណែនាំឱ្យក្រុមការងារបច្ចេកទេសចូលរួមជាបន្ទាន់នៅក្នុងការពិនិត្យមើលឡើងវិញនូវកម្មវិធីនិងគម្រោងកំពុងដំណើរការ ដែលត្រូវបានជួយដោយដៃគូអភិវឌ្ឍន៍ ដើម្បីមើលឱ្យឃើញថា តើកម្មវិធីនិងគម្រោងទាំងនេះស្របគ្នាជាមួយនឹងអាទិភាពទាំងឡាយដែលមានលើកឡើងនៅក្នុង *ផយអជ* ដែរឬទេ ។ ក្រុមការងារបច្ចេកទេសទាំងនេះ ក៏ត្រូវបានស្នើសុំឱ្យពិនិត្យមើលឡើងវិញផងដែរនូវជំនួយបច្ចេកទេសកំពុងដំណើរការទាំងអស់ (ឧទាហរណ៍ ជំនាញការនិងការសិក្សា) និងធ្វើកិច្ចខិតខំប្រឹងប្រែងប្រកបដោយមនសិកា ដើម្បីជៀសវាង ការងារត្រួតគ្នា និងដើម្បីកាត់បន្ថយការបែងចែកមូលនិធិដែលនឹងអាចត្រូវបានបញ្ចេញ សម្រាប់សកម្មភាពដែលដោះស្រាយបញ្ហាសំខាន់ៗជាងមុន ។ ប៉ុន្តែ រហូតមកទល់នឹងពេលនេះ ស្ទើរតែមិនមានក្រុមការងារបច្ចេកទេសណាមួយ ដែលបានធ្វើកិច្ចការនេះទេ មួយផ្នែកដោយសារ ក្រុមការងារបច្ចេកទេសមិនមានព័ត៌មាន គ្រប់គ្រាន់អំពីកម្រិតនិងប្រភេទនៃជំនួយដែលដៃគូអភិវឌ្ឍន៍ក្រៅប្រទេសផ្តល់ឱ្យ ។

៣. គម្រោងជាច្រើននៃមូលដ្ឋានទិន្នន័យស្តីពីជំនួយអភិវឌ្ឍន៍ផ្លូវការ របស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ដែលជាធាតុចូលបានមកតែពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស អាចមិនត្រូវបានបញ្ចូលទៅក្នុងកម្មវិធីវិនិយោគសាធារណៈ ២០០៩-២០១១ ទេ ដោយសារតែក្រសួងនានាដែលពាក់ព័ន្ធនឹងកម្មវិធីវិនិយោគសាធារណៈ មិនបានដឹងពីគម្រោងទាំងនោះ ។ ដូចគ្នានេះដែរ ក្រសួងផែនការមិនស្គាល់គម្រោងជាច្រើន នៅក្នុងមូលដ្ឋានទិន្នន័យ

[១] អារម្ភកថារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុង*ផយអជ* និងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ និងសុន្ទរកថាមួយចំនួននៅក្នុងវេទិកាជាតិនិងអន្តរជាតិ ។

[២] គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា កំពុងរៀបចំ "សេចក្តីណែនាំសម្រាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការបច្ចេកទេសនៅកម្ពុជា" និងកត់សម្គាល់នៅក្នុងឯកសារគោលជំហរសម្រាប់ការពិគ្រោះយោបល់ (មិថុនា ២០០៨) ថា កិច្ចសហប្រតិបត្តិការបច្ចេកទេសនៅតែជា "បញ្ហា" ហើយស្រូបយករហូតដល់ពាក់កណ្តាលនៃជំនួយអភិវឌ្ឍន៍ផ្លូវការ ព្រមទាំងអាចជាប់គាំងនៅក្នុង "លក្ខខណ្ឌស្ថានភាពក្នុងដំណាក់កាលក្រោយវិបត្តិ" ដែលលែងសមស្របនិងហួសសម័យទៅហើយនោះ ហើយបរិមាណដ៏ច្រើននៃកិច្ចសហប្រតិបត្តិការបច្ចេកទេស គឺត្រូវតែ "ទទួលយក" ដោយការបង្ខំចិត្ត ។

### ប្រអប់ ២.៣ (ត)

ស្ដីពីជំនួយអភិវឌ្ឍន៍ផ្លូវការដែលទាក់ទងនឹងក្រុមការងារបច្ចេកទេសផែនការនិងការកាត់បន្ថយភាពក្រីក្រ ។ ការតម្រូវនូវភាពខុសគ្នាទាំងនេះ គឺជាការងារបន្ទាន់ចំពោះមុខ ។ ការងារនេះ ក៏ជាប្រការចាំបាច់ផងដែរដើម្បីធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជា អាចបំពេញនូវការទទួលខុសត្រូវរបស់ខ្លួនចំពោះប្រជាជនកម្ពុជា ដើម្បីបកស្រាយពីការប្រើប្រាស់ជំនួយពីក្រៅប្រទេសដែលត្រូវបានផ្ដល់ឱ្យកម្ពុជា និងដើម្បីតាមដានត្រួតពិនិត្យ "ធនធានសរុប"ដែលនឹងត្រូវចំណាយឱ្យស្របទៅតាមអាទិភាពរបស់ *ផយអជ* ។

៤. *ផយអជ* បានបញ្ជាក់នៅក្នុងកឋាខ័ណ្ឌ៥.១៧ ថា "ការគាំទ្រថវិកា" អាចជាយន្តការដែលចង់បានជាងគេនៃការគាំទ្រពីបរទេស ។ បន្ថែមលើប្រាក់កម្ចី និងគម្រោងជំនួយបច្ចេកទេសមួយចំនួនរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ដែលត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា វឌ្ឍនភាពបន្ថែមទៀតនៅក្នុងការប្រើប្រាស់យន្តការនេះ បានចាប់ផ្ដើមតាមរយៈ ជំនួយដែលមានឈ្មោះថា *ការកាត់បន្ថយភាពក្រីក្រនិងប្រតិបត្តិការកំណើន* ដែលបានគាំទ្រដោយដៃគូអភិវឌ្ឍន៍ជាច្រើនរួមគ្នា ។ ទោះជាដូចនេះក្ដី ភាគច្រើនបំផុតនៃជំនួយពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស នៅតែត្រូវបានគ្រប់គ្រង និងអនុវត្តដោយផ្ទាល់ដោយស្ថាប័នទាំងឡាយដែលពាក់ព័ន្ធដល់ការផ្ដល់ជំនួយ ។ ដោយឡែក ក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា មិនដឹងអំពីការងារជាក់ស្ដែងដែលកំពុងត្រូវបានអនុវត្ត និងអំពីចំណាយរបស់ការងារទាំងនោះឡើយ ។

៥. សូចនាករតាមដានត្រួតពិនិត្យរួមគ្នា ត្រូវបានបង្កើតឡើង និងត្រូវបានត្រូវបានអនុវត្ត ដើម្បីតាមដានត្រួតពិនិត្យវឌ្ឍនភាពក្នុងដំណើរការ ឆ្ពោះទៅសម្រេចគោលដៅរួមនានា ។ ការបង្កើតឱ្យមានសូចនាករតាមដានត្រួតពិនិត្យរួមគ្នា សម្រាប់ឱ្យដៃគូអភិវឌ្ឍន៍ក្រៅប្រទេសសម្រេចឱ្យបាននូវគណនេយ្យភាព ការតម្រឹមតម្រង់ និងសុខុដុមនីយកម្ម គឺជាប្រការចាំបាច់ ដែលត្រូវយកចិត្តទុកដាក់ ដូចគ្នានឹងសូចនាករដទៃទៀត សម្រាប់រាជរដ្ឋា-ភិបាលដែរ ។

៦. តម្រូវការបន្ទាន់ចំពោះមុខគឺ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ដើម្បីតម្រឹមតម្រង់ធនធានរបស់ពួកគេឱ្យបានល្អប្រសើរជាងមុនទៅនឹងអាទិភាពរបស់ *ផយអជ* និងដើម្បីទាញយកប្រយោជន៍ឱ្យបានច្រើនជាងមុនពីកាលានុវត្តភាពក្នុងក្រុមការងារបច្ចេកទេស សំដៅផ្ដល់ដំណឹងជូនរាជរដ្ឋាភិបាលកម្ពុជាអំពីការងាររបស់ពួកគេ និងធ្វើការសម្របសម្រួលឱ្យបានប្រសើរជាមុនក្នុងចំណោមពួកគេ ។

២.៣១ **<u>បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ</u>** : ក្រៅពីការពង្រឹងនូវស្ថេរភាពនយោបាយនិងសង្គម សន្តិភាពនិងសន្តិសុខផ្ទៃក្នុង និងដោយត្រូវបានជួយសម្រួល ដោយកត្តាទាំងនេះសមិទ្ធផលដ៏គួរឱ្យកត់សម្គាល់ត្រូវបានដឹងឬនិងទទួលស្គាល់យ៉ាងទូលំទូលាយថា បានកើតឡើងនៅក្នុងការគ្រប់គ្រងដ៏រឹងមាំនិងជឿនលឿនលើសេដ្ឋកិច្ចនៅក្នុងប្រទេស ។ សមិទ្ធផលទាំងនេះមិនមែនកើតឡើងដោយចៃដន្យ ឬដោយការវិវត្តន៍មួយដែលមានលក្ខណៈធម្មជាតិឡើយ ប៉ុន្តែសមិទ្ធផលទាំងនេះបានកើតឡើងតាមរយៈការគិតគូរនិងការត្រៀមលក្ខណៈយ៉ាងប្រុងប្រយ័ត្ន និងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដែលមានលក្ខណៈវិជ្ជមាន ដែលមានគោលបំណងច្បាស់លាស់ និងដោយឥតឈប់ឈររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានជួយឧបត្ថម្ភដោយដៃគូអភិវឌ្ឍន៍នៅក្នុងទិដ្ឋភាពមួយចំនួន ។

២.៣២ ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចដែលត្រូវបានប៉ាន់ស្មានសម្រាប់ឆ្នាំ២០០៥ ដែលជាឆ្នាំមូលដ្ឋានសម្រាប់ *ផយអជ* ឆ្នាំ២០០៦-២០១០ បានកើនឡើងគួរឱ្យកត់សម្គាល់ ដោយសារតែការវាយតម្លៃកាន់តែជាក់លាក់ជាងមុន ដែលត្រូវបានធ្វើបន្ទាប់ពីការបញ្ចប់ការរៀបចំ *ផយអជ* ។ កត្តាគួរឱ្យកត់សម្គាល់ជាងគេ នៅក្នុងចំណោមកត្តាទាំងឡាយរួមមាន :

កំណើនដ៏ខ្លាំងនៃផលិតផលក្នុងស្រុកសរុបក្នុងកម្រិត ១៣.៣ភាគរយ នៅក្នុងឆ្នាំ២០០៥ ដែលស្មើរតែស្មើពីរដងនៃកម្រិត ៧ភាគរយដែលបានប៉ាន់ស្មានពេលមុននៅក្នុងការរៀបចំ*ផយអជ* ទោះបីជាមានការប្រែប្រួលដែលបណ្ដាលមកពីកត្តាខាងក្រៅ ដូចជាតម្លៃប្រេងបន្តកើនឡើងខ្ពស់ក្ដី និងមួយផ្នែកបណ្ដាលមកពីការកើនឡើងខ្ពស់នៅក្នុងកំណើនវិស័យកសិកម្ម ។ ចាប់តាំងពីពេលនោះមក ផលិតផលក្នុងស្រុកសរុបបានបន្តកើនឡើងប្រកបដោយស្ថេរភាពក្នុងកម្រិតពីរខ្ទង់ ប៉ុន្តែត្រូវបានរំពឹងថា នឹងថយចុះនៅក្នុងឆ្នាំ២០០៨ មកត្រឹម ៧ភាគរយ ដោយសារតែសម្ពាធអតិផរណា ។

កំណើនខ្ពស់ខ្លាំងក្នុងវិស័យកសិកម្ម (ដំណាំ) ក្នុងកម្រិត ២៧.៦ភាគរយ[១] នៅក្នុងឆ្នាំ២០០៥ ស្មើនឹង ៨.០ភាគរយ ដែលត្រូវបានប៉ាន់ស្មាននៅក្នុង*ផយអជ* ដោយត្រូវបានជំរុញដោយលទ្ធផលទទួលបានពីការវិនិយោគនៅក្នុងប្រព័ន្ធស្រោចស្រព និងស្ថានភាពអំណោយផលខ្លាំងនៃអាកាសធាតុ ។ អត្រាកំណើនបានថយចុះតាំងពីពេលនោះមក ប៉ុន្តែនៅតែស្ថិតកម្រិតមួយខ្ពស់នៅឡើយ ។

ដូច្នេះ តួលេខមូលដ្ឋានសម្រាប់ឆ្នាំ២០០៥ ដែលត្រូវបានប៉ាន់នៅក្នុង*ផយអជ* បានកើនឡើង ។ ហេតុនេះគោលដៅនានាសម្រាប់រយៈពេលនៃ*ផយអជ* ក៏បានកើនឡើងផងដែរ ទោះបីជាតួលេខទាំងនោះត្រូវបានផ្អែកលើតួលេខមូលដ្ឋានខ្ពស់ជាងដែលត្រូវកែសម្រួលឡើងវិញក្ដី ។

ហេតុនេះ តួលេខម៉ាក្រូសេដ្ឋកិច្ចទាំងអស់បានឆ្លងកាត់ការកែសម្រួលឡើងវិញ និងត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញលម្អិតជាងនេះ នៅក្នុងតារាង២.១ និង ឧបសម្ព័ន្ធ១.១ និង ១.២ ។

ផលិតផលក្នុងស្រុកសរុបក្នុងប្រជាជនម្នាក់ បានកើនឡើងពី ១,៨៦លានរៀលក្នុងឆ្នាំ២០០៥ ដល់ ២,៤២លានរៀលក្នុងឆ្នាំ២០០៧ ហើយត្រូវបានរំពឹងថានឹងឡើងដល់ ៣,៥០លានរៀលក្នុងឆ្នាំ២០១០ (ធៀបនឹងការប៉ាន់ស្មាននៅក្នុង*ផយអជ* ដែលមានកម្រិត ២,២៤លានរៀលប៉ុណ្ណោះ) ។ ប្រការដែលគួរកត់សម្គាល់នោះ គឺថា ផលិតផលក្នុងស្រុកសរុបក្នុងប្រជាជនម្នាក់ៗ បានកើនឡើងខ្លាំង ពី ៣៩៤ដុល្លារក្នុងឆ្នាំ២០០៤ ដល់ ៥៩៤ដុល្លារ នៅក្នុងឆ្នាំ២០០៧ ។

ចំណូលថវិកាជាតិបានកើនឡើង ក្នុងអត្រា ២៦ភាគរយ ក្នុងមួយឆ្នាំ នៅក្នុងបណ្ដាឆ្នាំថ្មីៗកន្លងទៅនេះ ។ ទោះបីជាមានការកើនឡើងនៃចំណាយចរន្តក៏ដោយ អតិរេកថវិកាចរន្ត ក៏មានការកើនឡើងដែរ (ឧទាហរណ៍ ក្នុងឆ្នាំ២០០៧ កើនឡើង បីដងខ្ពស់ជាងកម្រិតក្នុងឆ្នាំ២០០៦) ។

ឧស្សាហកម្មកាត់ដេរនៅតែបន្តនាំមុខគេ បើគិតតាមការរួមចំណែកជារួមនៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម ដែលបន្ទាប់ពីនេះ មានវិស័យទេសចរណ៍ និងវិស័យសំណង់។

អត្រាប្ដូរប្រាក់ បានស្ថិតនៅស្ថេរភាព ក្នុងកម្រិត ៤.០០០រៀល ក្នុងមួយដុល្លារ ។

---

[១] គណនេយ្យជាតិនៃប្រទេសកម្ពុជា ឆ្នាំ១៩៩៣-២០០៧ ព្រឹត្តិប័ត្រ លេខ ១២ វិទ្យាស្ថានស្ថិតិជាតិ ក្រសួងផែនការ ។

ទុនបម្រុងអន្តរជាតិដុល បានកើនឡើងពី ៩១៥លានដុល្លារ ក្នុងឆ្នាំ២០០៥ ដល់ជាង ២ពាន់លានដុល្លារ នៅក្នុងឆ្នាំ២០០៨ ។

ការវិនិយោគផ្ទាល់ពីបរទេសបានកើនឡើងប្រាំពីរដង ពី ១២១លានដុល្លារអាមេរិក នៅក្នុងឆ្នាំ២០០៤ ដល់ ៨៦៨លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៧ ។

ការរួមចំណែករបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជួយសម្រួលដល់ការវិនិយោគផ្ទាល់ពីបរទេស តាមរយៈ ការលើកលែងពន្ធគយ លើមុខទំនិញទព្វសំភារៈ ជាមធ្យមមានកម្រិតជាង ៥ភាគរយ នៃផលិតផលក្នុង ស្រុកសរុប ជារៀងរាល់ឆ្នាំ ។

## តារាង ២.១ : ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ[១]

*(គិតជា%នៃផសស លើកលែងតែមានការបញ្ជាក់ផ្សេងទៀត)*

| រាយមុខ | ឯកតា | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ (ប៉ាន់ស្មាន) | ២០០៩ (ព្យាករណ៍) | ២០១០ (ព្យាករណ៍) |
|---|---|---|---|---|---|---|---|
| *ផសស* សរុបប្រចាំឆ្នាំ (ថ្លៃថេរឆ្នាំ២០០០) | ពាន់លានរៀល | ២២.០០៩ | ២៤.៣៨០ | ២៦.៨៦៨ | ២៨.៧៣៦ | ៣០.៦០៧ | ៣២.៧៩៩ |
| ចំណែកនៃ *ផសស* : | | | | | | | |
| កសិកម្ម | % | ២៩.៤ | ២៨,០ | ២៦,៧ | ២៦,១ | ២៥,៥ | ២៤,៨ |
| ឧស្សាហកម្ម | % | ២៦,៨ | ២៨,៦ | ២៨,១ | ២៨,៣ | ២៨,៥ | ២៨,៩ |
| សេវាកម្ម | % | ៣៨,៥ | ៣៨,៣ | ៣៨,៣ | ៣៨,៧ | ៣៩,១ | ៣៩,៦ |
| *ផសស* ក្នុងប្រជាជនម្នាក់ | ពាន់រៀល | ១.៨៦២ | ២.១០៨ | ២.៤១៦ | ២.៨៩២ | ៣.២១៧ | ៣.៥០៥ |
| *ផសស* ក្នុងប្រជាជនម្នាក់ | ដុល្លារ | ៤៥៥ | ៥១៤ | ៥៩៤ | ៧១៦ | ៧៧៨ | ៨៤២ |
| *ផសស* ពិត | % ប្រែប្រួល | ១៣,៣ | ១០,៨ | ១០,២ | ៧,០ | ៧,២ | ៧,០ |
| អតិផរណាសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ (មធ្យមភាគប្រចាំឆ្នាំ) | % ប្រែប្រួល | ៥,៨ | ៤,៧ | ៥,៩ | ២០,០ | ១០,០ | ៤,០ |
| ចំណូលថវិកា ភាគរយនៃ *ផសស* | % | ១០,៦ | ១១,៤ | ១២,១ | ១២,៥ | ១២,៨ | ១៣,១ |
| ដែលនៅក្នុងនោះ ចំណូលពន្ធ | % | ៧,៧ | ៨,០ | ១០,២ | ១០,៤ | ១០,៧ | ១១,០ |
| ចំណាយ ភាគរយនៃ *ផសស* | % | ១៣,២ | ១៤,១ | ១៤,៨ | ១៤,៦ | ១៤,៣ | ១៤,០ |
| ចំណាយចរន្ត | % | ៧,៦ | ៧,៩ | ៨,២ | ៨,២ | ៨,២ | ៨,៥ |
| អតិរេកថវិកាចរន្ត | ពាន់លានរៀល | ៤៧១,០ | ៣៩៥,៨ | ១.១១៦,៤ | ១.៥១៥,៨ | ១.៧៤២,០ | ១.៩៥១,០ |
| ការលើកលែងពន្ធសម្រាប់វិនិយោគផ្ទាល់ពីបរទេស | % | ៥,២ | ៥,៦ | ៥,៥ | ៥,២ | ៥,៥ | ៥,៥ |
| អត្រាប្តូរប្រាក់មធ្យមធៀបនឹងមួយដុល្លារ | រៀល | ៤.១១៧ | ៤.០៥៨ | ៤.០០០ | ៤.១៣០ | ៤.១៤៣ | ៤.១៦៣ |
| ទុនបម្រុងអន្តរជាតិដុល | លានដុល្លារ | ៩១៥ | ១.០៩៧ | ១.៦១៦ | ២.១៣៤ | ២.២៦០ | ២.៥២១ |
| ការវិនិយោគផ្ទាល់បរទេស | លានដុល្លារ | ៣៨១ | ៤៨៣ | ៨៦៨ | ៩៤៤ | ៧១៨ | ៨២៥ |

***ប្រភព :*** *វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* **-- *សម្គាល់ :*** *ទិន្នន័យលម្អិត មាននៅក្នុងឧបសម្ព័ន្ធ១.១*

[១] តារាងលម្អិតនៅក្នុងឧបសម្ព័ន្ធ ១.១ និង ១.៣ ។

២.៣៣ *អតិផរណា* ត្រូវបានគ្រប់គ្រងបានយ៉ាងល្អរហូតដល់ត្រីមាសចុងក្រោយនៃឆ្នាំ២០០៧ ទោះបីជាមានកំណើនខ្លាំងនៅក្នុងតម្លៃប្រេងអន្តរជាតិក្តី ។ ប៉ុន្តែ សម្ពាធអតិផរណាពិភពលោក (ប្រអប់ ២.១) កំពុងមានផលប៉ះពាល់លើប្រទេសកម្ពុជា ជាពិសេស ការឡើងថ្លៃខ្ពស់នៃប្រេងឥន្ធនៈសម្រាប់ការដឹកជញ្ជូននិងថាមពល ផលិតផលនាំចូលសំខាន់ៗ ដូចជា ប្រេងឆា និងសម្ភារៈសំណង់ ដូចជាស៊ីម៉ង់ត៍ និងដែកជាដើម ។ លើសពីនេះ វិស័យហិរញ្ញវត្ថុដែលកំពុងរីកលូតលាស់ និងការជួញដូរដើម្បីទុកយកចំណេញក្នុងទីផ្សារអចលនៈទ្រព្យ បានរួមចំណែកបង្កើតជាសម្ពាធអតិផរណា នៅក្នុងប្រទេស ។ អត្រានៃអតិផរណាបានកើនឡើងយ៉ាងខ្ពស់ដល់ជាង ២០ភាគរយនៅក្នុងប្រាំបួនខែដើមឆ្នាំ២០០៨ ហើយនឹងរងឥទ្ធិពលភាគច្រើនពីកត្តាខាងក្រៅនៅពេលអនាគត ថ្វីបើកិច្ចខិតខំប្រឹងប្រែងដើម្បីសម្រាលផលប៉ះពាល់ កំពុងត្រូវបានធ្វើតាមរយៈគោលនយោបាយសមស្របក្តី[១] ។ វិធានការជាច្រើន ផ្សេងទៀត ដែលកំពុងត្រូវបានប្រើប្រាស់ រួមមាន :

- ដើម្បីកាត់បន្ថយជាទូទៅ នូវផលប៉ះពាល់នៃតម្លៃប្រេងខ្ពស់លើអ្នកប្រើប្រាស់និងសេដ្ឋកិច្ចជាទូទៅ ការកាត់បន្ថយពន្ធសម្រាប់ប្រេងឥន្ធនៈកំពុងត្រូវបានផ្តល់ឱ្យ ក្នុងទឹកប្រាក់ចំនួន ៣៥០លានដុល្លារ ក្នុងឆ្នាំ២០០៨ ។ នៅក្នុងរយៈពេល ៦ខែដើមឆ្នាំ២០០៨ ការឧបត្ថមធនដាច់ដោយឡែក សម្រាប់ថ្លៃប្រេងឥន្ធនៈដែលប្រើប្រាស់ដើម្បីផលិតថាមពលអគ្គិសនី មានចំនួន ១២លានដុល្លារអាមេរិក ។
- ការកាត់បន្ថយប្រហាក់ប្រហែលគ្នានេះដែរ ក៏ត្រូវបានផ្តល់ជូនផ្នែកសម្រាប់អគ្គិសនី ក្នុងទឹកប្រាក់ចំនួន ៤១លានដុល្លារ ក្នុងឆ្នាំ២០០៨ ។
- ពន្ធគយលើការនាំចូលលើសំភារៈកសិកម្មសំខាន់ៗ ត្រូវបានកាត់បន្ថយ ។
- ដើម្បីជួយឧស្សាហកម្មទប់ទល់នឹងការប្រកួតប្រជែង និងដើម្បីជួយកម្មករទប់ទល់នឹងតម្លៃចំណាយ ដែលមានអតិផរណា រាជរដ្ឋាភិបាលកម្ពុជាមិនត្រឹមតែបានផ្តល់ការលើកលែងពន្ធជូនដល់រោងចក្រកាត់ដេរប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបានផ្តល់ប្រាក់ខែបន្ថែមចំនួន ៦ដុល្លាអាមេរិកក្នុងមួយនាក់ ក្នុងមួយខែជូនដល់កម្មករ ជាង ៣៦០.០០០នាក់ (ភាគច្រើនជាស្រ្តី) ចាប់ពីខែមេសា ឆ្នាំ២០០៨ ។ សរុបទឹកប្រាក់ទាំងអស់ ក្នុងឆ្នាំ២០០៨ មានចំនួន ២០លានដុល្លារ ។
- ចំណែកនៃប្រាក់បញ្ញើបម្រុងទុករបស់ធនាគារពាណិជ្ជនានា ដែលធនាគារទាំងនោះត្រូវបានតម្រូវឱ្យផ្ញើទុកជាទុនបម្រុងនៅក្នុងធនាគារជាតិនៃកម្ពុជា បានកើនឡើង ២ដង ពី ៨ភាគរយ ទៅ ១៦ភាគរយ ក្នុងគោលបំណងកំណត់បរិមាណ ការផ្គត់ផ្គង់សាច់ប្រាក់ក្នុងចរាចរណ៍ ។ លើសពីនេះ ធនាគារពាណិជ្ជ បានប្រឈមមុខនឹង ភាពមានកម្រិតនៃការឱ្យខ្ចីសម្រាប់អចលនទ្រព្យ ហើយធនាគារពាណិជ្ជ ត្រូវបានកំណត់ឱ្យបង្កើនឡើងបីដង នូវទុនមូលដ្ឋានរបស់ខ្លួន ។

[១] ប្រការដែលត្រូវបានទទួលស្គាល់នោះ គឺថា គោលនយោបាយទាំងឡាយ ខ្លួនឯងផ្ទាល់ អាចមានចរិតលក្ខណៈដែលបណ្តាលឱ្យមានអតិផរណា ។

២.៣៤ *ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* : ការដឹកនាំនិងការគ្រប់គ្រងដ៏រឹងមាំផ្នែកនយោបាយ រួមជាមួយនឹងគោលនយោបាយថវិកាដែលមានលក្ខណៈជឿនលឿន ប្រយ័ត្នប្រយែង និងតឹងរ៉ឹង ទាំងលើចំណូលនិងចំណាយថវិកា បានបង្កើនចំណូលរបស់រាជរដ្ឋាភិបាល ពី ១០,៦ភាគរយក្នុងឆ្នាំ២០០៥ ដល់ ១២,១ភាគរយ ក្នុងឆ្នាំ២០០៧ និងចំណាយពី ១៣,២ភាគរយនៅក្នុងឆ្នាំ២០០៥ ដល់ ១៤,៨ភាគរយក្នុងឆ្នាំ២០០៧ នៃផលិតផលក្នុងស្រុកសរុប ។ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានអនុវត្តតាំងពីខែកុម្ភៈ ឆ្នាំ២០០៥ មក គឺជាកម្មវិធីដ៏ទូលំទូលាយមួយ ដើម្បីគ្រប់គ្រងទាំងចំណូលនិងចំណាយហិរញ្ញវត្ថុសាធារណៈ ដោយធ្វើការដោះស្រាយបញ្ហាសំខាន់ៗនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងគណនេយ្យភាពដែលត្រូវបង្កើនឡើង និងការអនុវត្តដែលត្រូវលើកកម្ពស់ ។ វឌ្ឍនភាពជាបន្តបន្ទាប់ ត្រូវបានធ្វើឡើង នៅក្នុងការគ្រប់គ្រងអចលនទ្រព្យរដ្ឋ រួមទាំងទ្រព្យសម្បត្តិរូបិយ និងអរូបិយ ក៏ដូចជា សហគ្រាសរដ្ឋ និងសហគ្រាសចម្រុះរដ្ឋឯកជនតាមរូបភាពមួយដែលមានតម្លាភាពនិងមានប្រសិទ្ធភាព ដើម្បីការពារផលប្រយោជន៍របស់រដ្ឋ និងដើម្បីកែលម្អចំណូលឱ្យប្រសើរឡើង ។ ដើម្បីទទួលបាននូវគ្រប់កិច្ចសន្យារបស់រដ្ឋ វិធានការជាច្រើនត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីធ្វើឱ្យមានការគ្រប់គ្រង និងបទប្បញ្ញត្តិតឹងតែងសំដៅអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ដែលមានលក្ខណៈច្បាស់លាស់ ប្រកបដោយតម្លាភាព និងប្រកបដោយសមធម៌ក្នុងការលក់ឬជួលទ្រព្យសម្បត្តិ ឬសិទ្ធិរបស់រដ្ឋ ។ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមកំពុងត្រូវបានដាក់ឱ្យដំណើរការ ដើម្បីធានាថាវិភាជន៍ថវិកាសមស្របត្រូវបានផ្តល់ជូនគ្រប់វិស័យទាំងអស់ ។

២.៣៥ គោលដៅរយៈពេលវែង គឺត្រូវបន្តធ្វើដើម្បីឱ្យសម្រេចបាននូវកំណើនសេដ្ឋកិច្ចជាលំដាប់ ដែលមានស្ថេរភាព ដែលមានលក្ខណៈគាំទ្រអ្នកក្រ និងដែលផ្អែកលើមូលដ្ឋានច្រើន ។ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចដែលសម្រេចបានរួចហើយនោះបានបំពេញតួនាទីដ៏សំខាន់មួយក្នុងការផ្តល់មូលដ្ឋានគ្រឹះ សម្រាប់កំណើនរឹងមាំនៅក្នុងបណ្តាឆ្នាំថ្មីៗនេះ ហើយសម្រាប់ការកាត់បន្ថយភាពក្រីក្រ ហើយនឹងត្រូវបានថែរក្សា និងពង្រឹងថែមទៀតនាពេលអនាគត ។ ប្រទេសកម្ពុជាបានទទួលទំនុកចិត្តនិងបទពិសោធន៍ ដោយគ្រប់គ្រងប្រកបដោយជោគជ័យនូវស្ថានភាពសេដ្ឋកិច្ចសូម្បីតែនៅក្នុងពេលមានកត្តាសេដ្ឋកិច្ចពីខាងក្រៅ ដូចជា វិបត្តិអាស៊ីបូព៌ាក្នុងឆ្នាំ១៩៩៧ ការផ្លាស់ប្តូររចនាសម្ព័ន្ធដ៏ធំធេងដែលកើតមានចាប់តាំងពីពេលនោះមក ការឡើងថ្លៃប្រេងអន្តរជាតិបានចាប់ផ្តើមក្នុងឆ្នាំ២០០៤ ហើយដែលកើនឡើងខ្លាំងចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៧ ។ រាជរដ្ឋាភិបាលកម្ពុជារំពឹងថា នឹងអាចសម្រេចបាននូវស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានព្យាករណ៍ខាងលើនេះ ហើយអត្ថប្រយោជន៍នឹងអាចទទួលបានយ៉ាងទូលំទូលាយដើម្បីកាត់បន្ថយភាពក្រីក្រ ។ គោលដៅនិងវិធានការមួយចំនួន នៅក្នុងចំណោមគោលដៅ និងវិធានការធំៗដែលត្រូវអនុវត្ត រួមមាន :

រក្សាកំណើនផលិតផលក្នុងស្រុកសរុបឱ្យនៅត្រឹម ៧ភាគរយ ឬលើសពីនេះក្នុងមួយឆ្នាំដោយធ្វើឱ្យមានចំណូលក្នុងប្រជាជនម្នាក់ មានប្រមាណ ៨៧០ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៣ ។

ការសម្រេចបាននូវវឌ្ឍនភាពបន្ថែមទៀត នៅក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការខិតខំដាក់ឱ្យអនុវត្ត និងការធានាឱ្យបាននូវស្តង់ដារកាន់តែខ្ពស់នៃការគ្រប់គ្រង គណនេយ្យភាពនៅក្នុងការកៀរគរធនធានចរន្តនិងមូលធនទាំងអស់របស់រាជរដ្ឋាភិបាលកម្ពុជា និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានសម្រាប់អនុវត្ត*ផយអជ* និងកម្មវិធីអាទិភាពផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម នឹងមានប្រយោជន៏នៅក្នុងការធ្វើកម្មវិធីច្រើនឆ្នាំ ។

ថវិកាសម្រាប់កម្មវិធីត្រូវបានដាក់ឱ្យអនុវត្តសម្រាប់សកម្មភាពអាទិភាពរបស់ក្រសួងចំនួន៧ (ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៏ជនបទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ក្រសួងយុត្តិធម៌) ដែលនឹងមានផលប៉ះពាល់លើស្ថានភាពនៃភាពក្រីក្រ ។ ការបែងចែកជូនដល់ក្រសួងទាំងនេះ និងការប្រើប្រាស់ឱ្យបានទាន់ពេលនូវមូលនិធិនៅតាមក្រសួងទាំងនេះ នឹងត្រូវបានតាមដានត្រួតពិនិត្យយ៉ាងជិតដល់ ដើម្បីធានាឱ្យសម្រេចបាននូវលទ្ធផលដែលរំពឹងទុកធៀបនឹងសូចនាករនានា ដើម្បីកែលម្អការផ្តោតលើលទ្ធផល ។

ការកើនឡើងជាបណ្តើរៗនៅក្នុងវិភាជន៏ និងការធានាឱ្យបាននូវការបញ្ចេញមូលនិធិឱ្យបានទាន់ពេលជូនដល់វិស័យអាទិភាពដែលទ្រទ្រង់ប្រជាជនក្រីក្រ ជាពិសេស ដល់វិស័យកសិកម្ម និងការអភិវឌ្ឍជនបទ ។

## ប្រអប់ ២.៤
## បញ្ហាប្រឈមក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

១. ការបន្តចុះដុនដាបនៃស្ថានភាពពិភពលោកតាមរយៈកំណើនអតិផរណា ដែលបណ្ដាលមកពីតម្លៃខ្ពស់នៃ ប្រេងឥន្ធនៈ ស្បៀង អាហារនិងទំនិញប្រើប្រាស់ និងការខ្វះខាតស្បៀងអាហារ គឺជាបញ្ហាប្រឈមនិងហានិភ័យធំបំផុត ចំពោះស្ថេរភាពនិងកំណើនសេដ្ឋកិច្ច នៅក្នុងអនាគតដ៏ខ្លី ។ ការយកចិត្តទុកដាក់ខ្ពស់ដែលមានរួចមកហើយ កំពុងត្រូវបានផ្ដោតលើការរក្សាការតាមដានជាប្រចាំ និងការធ្វើសកម្មភាពកែតម្រូវ នៅទីណាដែលអាចធ្វើបាន ប៉ុន្តែផលប៉ះពាល់អវិជ្ជមានមកលើប្រទេសកម្ពុជា មិនអាចជៀសវាងផុតទាំងអស់បានឡើយ ។ អតិផរណាបានឡើងដល់លើ ២០ភាគរយនៅក្នុងរយៈពេលបីត្រីមាសដំបូង នៃឆ្នាំ២០០៨ ។ កំណើនផលិតផលក្នុងស្រុកសរុប នឹងធ្លាក់ចុះពីពីរខ្ទង់ ដែលធ្លាប់មានក្នុងរយៈពេលពីរ-បីឆ្នាំកន្លងមកនេះ មកត្រឹម ៧,៥ភាគរយក្នុងឆ្នាំ២០០៨ និងក្នុងពេលអនាគត ។

២. ចំពោះមូលហេតុទាំងឡាយ ដែលបានលើកឡើងនៅក្នុងប្រអប់ ២.១ ការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច គឺជាការងារបន្ទាន់ ទាំងតាមវិស័យ និងទាំងតាមទីតាំងភូមិសាស្ត្រ ។ សក្ដានុពលធំបំផុតសម្រាប់កំណើន និងពិពិធកម្ម ស្ថិតនៅក្នុងការពង្រីកវិស័យកសិកម្ម ដែលមិនផ្ដោតទៅលើការពង្រីកផ្ទៃដីកសិកម្មច្រើនទេ ប៉ុន្តែយកចិត្តទុកដាក់ដល់ការបង្កើនផលិតភាពវិញ ។ កិច្ចខិតខំប្រឹងប្រែងដែលផ្ដោតលើ ការអភិវឌ្ឍជនបទ នឹងជួយសម្រួលដល់កិច្ចការនេះ រួមជាមួយគំនិតផ្ដួចផ្ដើមពាក់ព័ន្ធផ្សេងៗទៀតជាច្រើន (ការលើកឡើងលើសពីនេះ ពីការបង្កើនផលិតភាព នឹងមាននៅក្នុង "វិស័យកសិកម្ម" នៅក្នុងផ្នែកខាងក្រោយនៃជំពូក ។

៣. ចំណូលថវិកា បាននិងកំពុងកើនឡើងក្នុងអត្រាដ៏ល្អមួយ ហើយនឹងបន្តកើនតទៅទៀត ។ ទោះជាដូចនេះក្ដី ការលំបាកនឹងកាន់តែមានការកើនឡើង ក្នុងការរក្សាបាននៅក្នុងអនាគតដ៏ខ្លី នូវអតិរេកថវិកាចរន្តសម្រាប់ការវិនិយោគ ដែលបច្ចុប្បន្ននេះ កំពុងស្ថិតនៅក្នុង ស្ថានភាពល្អប្រសើរ ។ ការលំបាកនេះគឺបណ្ដាលមកពីការថយចុះនៃល្បឿនកំណើនសេដ្ឋកិច្ច ក៏ដូចជាការមិនយកពន្ធ ដែលត្រូវបានធ្វើឡើងចំពោះការនាំចូលប្រេងនិងផលិតផលសំខាន់ៗផ្សេងទៀត ចំពោះការលើកទឹកចិត្តតាមរយៈពន្ធដែលផ្ដោតទៅរកការជំរុញការធ្វើពិពិធកម្ម និងចំពោះចំណាយចាំបាច់សម្រាប់ការឧបត្ថម្ភទុនផ្ទាល់ ដើម្បីទប់ទល់នឹងផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃអតិផរណា មកលើជនងាយរងគ្រោះ ។ ទោះជាដូចនេះក្ដី **រាជរដ្ឋាភិបាលកម្ពុជាប្ដេជ្ញារក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងអតិរេកថវិកាចរន្តគ្រប់គ្រាន់** ហើយនឹងអនុវត្តវិធានការចម្រុះដ៏ប្រុងប្រយ័ត្ន រួមទាំង ការត្បិតត្បៀតក្នុងចំណាយប្រភេទពន្ធ ដែលជ្រើសរើសដោយប្រុងប្រយ័ត្ន ។ល។

៤. វិសមភាពដែលជាផលវិបាកមិនអាចជៀសវាងបានរបស់កំណើនជាក់ស្ដែង កំពុងកើតឡើង ដោយបង្កើនគម្លាតនៅក្នុងកំណើននៃកម្រិតប្រាក់ចំណូលនិងការប្រើប្រាស់ ក៏ដូចជា កាលានុវត្តភាពសេដ្ឋកិច្ចរវាងទីក្រុង (ជាកន្លែងដែលកំណើនភាគច្រើនប្រមូលផ្ដុំនៅពេលនេះ) និងតំបន់ជនបទ ដោយមានលក្ខណៈកាន់តែខ្លាំងនៅតាមតំបន់ដាច់ស្រយាល និងរវាងក្រុមដែលមានប្រាក់ចំណូលខ្ពស់និងទាប ។ បញ្ហាទាំងនេះ អាចត្រូវបានដោះស្រាយ ដោយការយកចិត្តទុកដាក់បន្ថែមទៀតនិងដែលផ្ដោត លើតំបន់ជនបទនិងលើផលិតកម្មកសិកម្ម និងដោយធានាថា បណ្ដាញសុវត្ថិភាពសង្គមនឹងមានគ្រប់គ្រាន់ ដើម្បីទប់កុំឱ្យប្រជាជននៅក្នុងក្រុមដែលមានប្រាក់ចំណូលទាបធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញ ។

៥. រាជរដ្ឋាភិបាលកម្ពុជាផ្ដល់អាទិភាពយ៉ាងខ្ពស់ ក្នុងការកៀរគរចំណូលឱ្យបានច្រើនបំផុតនិងប្រកបដោយចីរភាព ពីគ្រប់ប្រភពធនធានធម្មជាតិជាពិសេស ប្រេងកាតនិងឧស្ម័ន ដើម្បីផ្ដល់ផលប្រយោជន៍ជូនប្រជាជនកម្ពុជាទាំងអស់ ។ បញ្ហាប្រឈមដ៏ធំចំពោះមុខគឺ ត្រូវត្រៀមរៀបចំនិងបង្កើតដោយប្រុងប្រយ័ត្ននូវយន្តការ សម្រាប់ការធ្វើឱ្យប្រសើរឡើងនិងការប្រើប្រាស់ដោយហ្មត់ចត់ ត្រឹមត្រូវ និងពេញលេញ នូវប្រាក់ចំណូលដែលបានពីការធ្វើអាជីវកម្ម ធនធានប្រេងកាតនិងឧស្ម័ន ដែលរំពឹងថានឹងទទួលបានចាប់ពីឆ្នាំ២០១១ ។ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើការសិក្សាមួយចំនួនជាមុនខ្លះមកហើយ ដោយពិនិត្យលើជម្រើសនានាដែលអាចមាននៅក្នុងបញ្ហាប្រើប្រាស់ចំណូលនេះ) ។ ការបង្កើតឡើងនូវស្ថាប័នគ្រប់គ្រង ដើម្បីធានាឱ្យបាននូវស្តង់ដារសមស្រប ដែលត្រូវរក្សាឱ្យមាននៅក្នុងការធ្វើអាជីវកម្មធនធានទាំងនេះ គឺជាតម្រូវការបន្ទាន់ ។ លើសពីនេះទៀត គម្រោងអាទិភាពខ្ពស់មួយចំនួន ត្រូវត្រៀមលក្ខណៈអនុវត្ត ដើម្បីទាញយកប្រយោជន៍ពីធនធានទាំងនេះ ក្នុងនោះរួមមាន ហេដ្ឋារចនាសម្ព័ន្ធ ជាពិសេស ផ្លូវថ្នល់ជនបទ សម្រាប់ភ្ជាប់ទៅតំបន់ដាច់ស្រយាល ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតំបន់ជនបទ ការបង្កើតវារីអគ្គិសនី និងការបញ្ជូនថាមពលអគ្គិសនី រួមទាំង អគ្គិសនីភាវូបនីយកម្មនៅតំបន់ជនបទ កំណែទម្រង់សេវារដ្ឋបាលសាធារណៈ ដើម្បីផ្ដល់ប្រាក់បំណាច់ឱ្យបានប្រសើរជាងមុន ឬប្រាក់បំណាច់ដែលខ្ពស់ជាងកម្រិតសម្រាប់តែរស់នៅបាន ជាពិសេស សម្រាប់ជនទាំងឡាយណាដែល បម្រើការងារនៅក្នុងតាមវិស័យសំខាន់ៗ ដូចជា គ្រូបង្រៀន គិលានុបដ្ឋាកយិកា អ្នកផ្សព្វផ្សាយកសិកម្ម និងអ្នកជំនាញផ្សេងៗទៀត ។

២.៣៦ *<u>វិស័យហិរញ្ញវត្ថុ</u>* : ប្រព័ន្ធហិរញ្ញវត្ថុនិងធនាគារ ត្រូវបានធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់ តាមរយៈប្រព័ន្ធបទប្បញ្ញត្តិថ្មី និងការពង្រឹងការអនុវត្តច្បាប់និងវិធានការច្បាប់ និងតាមរយៈការបង្កើតប្រព័ន្ធប្រតិបត្តិការធនាគារ ដូចជា ប្រព័ន្ធចែកចាយព័ត៌មានអំពីឥណទាន ។ ទិសដៅសំខាន់ៗរបស់គោលនយោបាយហិរញ្ញវត្ថុគឺដើម្បីរក្សាស្ថេរភាពថ្លៃ និងពង្រឹងការអភិវឌ្ឍប្រព័ន្ធធនាគារ ហើយទិសដៅទាំងពីរនេះត្រូវបានធ្វើឱ្យសម្រេចបានក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់ ។ កិច្ចខិតខំប្រឹងប្រែងដោយមានការសម្របសម្រួលយ៉ាងល្អពីស្ថាប័នពាក់ព័ន្ធទាំងឡាយ (ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌) នឹងបន្តធ្វើឱ្យប្រសើរឡើង និងពង្រឹងសមិទ្ធផលនៅក្នុងវិស័យហិរញ្ញវត្ថុ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ហើយមានសារៈសំខាន់សម្រាប់ជំហាននិងទិសដៅនៃកំណើនសេដ្ឋកិច្ច ព្រមទាំងបន្តលើកកម្ពស់ការកៀរគធនធានហិរញ្ញវត្ថុសម្រាប់ការវិនិយោគដែលមានលក្ខណៈជាផលិតកម្ម ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០៦-២០១៥ ព្យាករណ៍ពីការអភិវឌ្ឍនៃប្រព័ន្ធហិរញ្ញវត្ថុមួយដែលដំណើរការល្អ និងដែលផ្អែកលើទីផ្សារនៅក្នុងរយៈពេល ៥ឆ្នាំខាងមុខ ។ ទិដ្ឋភាពមួយចំនួននៅក្នុងចំណោមទិដ្ឋភាពសំខាន់ៗ រួមមាន :

- វិស័យហិរញ្ញវត្ថុបានកើនឡើងក្នុងទិសដៅមួយត្រឹមត្រូវ ហើយត្រូវបានពង្រឹងនិងពង្រីក ទន្ទឹមនឹងពេលដែលវិស័យនេះកាន់តែមានភាពរឹងមាំ ជាមួយនឹងការអនុវត្តវិធានការដ៏សកម្មដែលត្រូវបានអនុម័តយកដោយធនគារជាតិនៃកម្ពុជា ។ បញ្ញើរបស់វិស័យសាធារណៈ បានកើនឡើងពី ១៤,៦ភាគរយ ក្នុងឆ្នាំ ២០០៥ ដល់ ២៦,៦ភាគរយ ក្នុងឆ្នាំ២០០៧ នៃផលិតផលក្នុងស្រុកសរុប ។ កម្ចីពីធនាគារពាណិជ្ជកម្មបានកើនឡើងបីដង គឺពី ៥៩៨លានដុល្លារ ក្នុងឆ្នាំ២០០៥ ដល់ ១.៩៩៥លានដុល្លារ ក្នុងឆ្នាំ២០០៧ ។ អនុវិស័យធនាគារពាណិជ្ជកម្ម បច្ចុប្បន្ននេះមានធនាគារដែលមានអាជ្ញាប័ណ្ណពេញលេញចំនួន ១៧ និងធនាគារឯកទេសដែលមានអាជ្ញាប័ណ្ណចំនួន ៦ ។
- កំណែទម្រង់វិស័យហិរញ្ញវត្ថុនឹងផ្តោតការយកចិត្តទុកដាក់ផងដែរ លើការពង្រឹងការគ្រប់គ្រងដោយប្រុងប្រយ័ត្ន និងលើប្រព័ន្ធច្បាប់សម្រាប់ការធ្វើបញ្ញត្តិកម្មក្នុងវិស័យហិរញ្ញវត្ថុ ។ វិធានការច្បាប់សំខាន់ៗ រួមបញ្ចូលនូវការអនុម័តឱ្យប្រើប្រាស់ *ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់* និង *ច្បាប់ស្តីពីប្រតិបត្តិការដោយមានការធានា* ។
- សកម្មភាពដែលត្រៀមសម្រាប់ការអនុវត្ត នឹងត្រូវអនុវត្តនៅក្នុងការងារដែលពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រង ការបង្កើតទីផ្សារមូលធន និងការបង្កើតឡើងនូវមជ្ឈមណ្ឌលហិរញ្ញវត្ថុពិសេសមួយ ដើម្បីកៀរគធនធានហិរញ្ញវត្ថុឱ្យបានច្រើនជាងមុន ។
- ឆ្នាំ២០០៦ ត្រូវបានចាត់ទុកថា ជាឆ្នាំមីក្រូហិរញ្ញវត្ថុ ហើយសន្និសីទ និងសិក្ខាសាលាជាច្រើនស្តីពីមីក្រូហិរញ្ញវត្ថុត្រូវបានរៀបចំឡើងក្នុងគោលបំណងជំរុញឱ្យមានការយល់ដឹងប្រសើរជាងមុនពីនិងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃស្ថាប័នមីក្រូហិរញ្ញវត្ថុ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យនេះ ។

អនុវិស័យម៉ាក្រូហិរញ្ញវត្ថុ បានរីកចម្រើនយ៉ាងខ្លាំងដោយមានការប្រកួតប្រជែង និងការផ្តួចផ្តើមគំនិតថ្មីៗផ្នែកពាណិជ្ជកម្ម ។ អនុវិស័យនេះ កំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័សទាំងក្នុងចំនួនអតិថិជនទាំងក្នុងទំហំឥណទាន ដែលក្នុងនោះ ស្ថាប័នមួយចំនួនបាននិងកំពុងពង្រីកឥណទានរបស់ខ្លួនរហូតដល់ ២០០ភាគរយ ក្នុងមួយឆ្នាំ ដោយចាប់ផ្តើមពីមូលដ្ឋានមួយទាប ។ បច្ចុប្បន្ននេះ អនុវិស័យមីក្រូហិរញ្ញវត្ថុមានស្ថាប័នចំនួន ១៧ ដែលបានចុះបញ្ជីក្នុងការធ្វើប្រតិបត្តិការក្នុងអនុវិស័យនេះ ។ ទោះជាដូចនេះក្តី សមាមាត្រដ៏ធំនៃអ្នកក្រីក្រ និងតំបន់ជនបទដាច់ស្រយាលមិនទាន់ទទួលបានប្រកបដោយប្រសិទ្ធភាពនូវសេវាកម្មហិរញ្ញវត្ថុ ។ ភាពចាំបាច់ក្នុងការពង្រីកក្របខ័ណ្ឌការងារនេះ ឱ្យទៅដល់ប្រភេទផ្សេងទៀតនៃស្ថាប័នហិរញ្ញវត្ថុ ដូចជា សហករណ៍សេវាហិរញ្ញវត្ថុ សហគមន៍ឥណទាន និងធនាគារសញ្ជ័យភូមិ កំពុងត្រូវបានពិនិត្យសិក្សា ។

២.៣៧ រាជរដ្ឋាភិបាលកម្ពុជាដឹងច្បាស់ថា ដោយផ្អែកលើបទពិសោធន៍ពិភពលោក និងបទពិសោធន៍កន្លងមករបស់ខ្លួនផ្ទាល់ កំណើនសេដ្ឋកិច្ចខ្ពស់ នឹងបន្តនាំមុខដោយកម្លាំងទីផ្សារ កាលានុវត្តភាព តម្រូវការ និងការប្រឈម ។ កំណើននាំឱ្យមានការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ចដែលគេបានស្គាល់និងបានសាកល្បង និងនាំឱ្យមានការបន្តការកែតម្រូវរចនាសម្ព័ន្ធនៅក្នុងប្រជាជននិងសេដ្ឋកិច្ច ។ ជំនាញជាច្រើនត្រូវបានបង្កើតឡើងដើម្បីបំពេញសេចក្តីត្រូវការសម្រាប់ទីផ្សារទើបកើតឡើងថ្មីៗ ដែលជួនកាលធ្វើឱ្យមានការផ្លាស់ប្តូរប្រព័ន្ធអប់រំឧត្តមសិក្សា និងប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាការប្រសើរបំផុត គឺគប្បីខិតខំបង្កើតជំនាញឱ្យបានច្រើន ដើម្បីបម្រើប្រទេសជាតិក្នុងរយៈពេលវែង ។ ប៉ុន្តែ នៅពេលនេះ ឧស្សាហកម្មកាត់ដេរ វិស័យសំណង់ និងវិស័យទេសចរណ៍ គឺជាវិស័យចម្បងដែលធ្វើឱ្យមានកំណើន ។ ថ្វីបើមូលដ្ឋានសម្រាប់កំណើនទាំងនេះត្រូវបានគេចង់បានជាខ្លាំង ដោយសារវាបង្កើតការងារសម្រាប់ប្រជាជនជាច្រើនក៏ដោយ ក៏ការពឹងផ្អែកតែលើវិស័យមួយចំនួនតូចបែបនេះបាននាំមកជាមួយនូវផលវិបាកចំពោះស្ថេរភាពសេដ្ឋកិច្ចក្នុងរយៈពេលវែងដែរ ។ គោលនយោបាយ គប្បីផ្តោតការយកចិត្តទុកដាក់លើបញ្ហាសំខាន់ៗ ដូចខាងក្រោមនេះ :

កំណើនដ៏លឿន ក៏បង្កើនល្បឿនផងដែរនូវការធ្វើចំណាកស្រុកពីតំបន់បទទៅតំបន់ទីប្រជុំជន ដើម្បីស្វែងរកការងារនិងមុខរបរបន្ទាប់បន្សំ ដោយបន្ថយកម្លាំងពលកម្ម ដែលមានសម្រាប់សកម្មភាពកសិកម្មសំខាន់ៗ នៅតាមតំបន់ជនបទ ។

យុវជន ច្រើនមានបំណងធ្វើចំណាកស្រុក ដោយបន្សល់ទុកនៅតំបន់ជនបទនិងតំបន់ដាច់ស្រយាលនូវមនុស្សចាស់ជរាដែលមានផលិតភាពទាប ។

ដូចដែលបានឃើញរួចហើយពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៤ ថ្វីបើកំណើនមានផលប៉ះពាល់ខ្លាំងលើការកាត់បន្ថយកម្រិតនៃភាពក្រីក្រនៅក្នុងប្រទេសជារួមក្តី ក៏កម្រិតនៃភាពក្រីក្រទាំងនេះ នៅតែខ្ពស់នៅតាមតំបន់ដាច់ស្រយាល ។ ប្រការនេះ នឹងនៅបន្តកើតមាន និងកើនឡើង ប្រសិនបើកំណើនមិនត្រូវបានគ្រប់គ្រងឱ្យបានត្រឹមត្រូវ ។

២.៣៨ ដោយយល់ដឹងអំពីបញ្ហាប្រឈមទាំងនេះ និងកត្តាពាក់ព័ន្ធផ្សេងៗទៀតនៃការផ្លាស់ប្តូរ ដែលជាផល-វិបាកចម្បងនៃកំណើនសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជានឹងបន្តតាមដានជាប្រចាំនៅពេលដែលស្ថានភាពមានការវិវត្ត ហើយនឹងប្រើឧបករណ៍គោលនយោបាយសម្រាប់ជំរុញការអនុវត្តភ្លាមៗ និងការលើកទឹកចិត្តនានា ដើម្បីធ្វើពិពិធកម្មកំណើន ទាំងតាមវិស័យ ទាំងតាមភូមិសាស្ត្រ និងផ្តល់បណ្តាញសុវត្ថិភាពសង្គម ដើម្បីធានាថាប្រជាជនទាំងឡាយដែលមិនសូវត្រូវបានគិតគូរដល់ មិនត្រូវបានទុកចោកដោយគ្មានការគិតគូរដល់ជាបន្តទៀត និងកាន់តែងាយរងគ្រោះថែមទៀតឡើយ ។ យុទ្ធសាស្ត្រទាំងឡាយដែលគ្រោងសម្រាប់វិស័យជាច្រើនត្រូវបានលើកឡើងនៅក្នុងបណ្តាកថាខ័ណ្ឌ ខាងក្រោមនេះ ៖

២.៣៩ *សាសនា និង វប្បធម៌* ៖ បញ្ហាសាសនានិងវប្បធម៌ គឺជាគ្រឹះសម្រាប់កសាង ពង្រឹង និងថែរក្សា "*ទុនសង្គម*" ដ៏សំខាន់ ដែលកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចតែឯកឯងមិនអាចបង្កើតឬថែរក្សាបានឡើយ ។ រាជរដ្ឋាភិបាលកម្ពុជា បន្តផ្តល់អាទិភាពខ្ពស់ដល់ការការពារនិងការលើកស្ទួយកេរ្តិ៍ដំណែលដ៏ស្តុកស្តម្ភនិងគ្មានពីរ ដើម្បីថែរក្សាពង្រឹង និងអភិវឌ្ឍរចនាសម្ព័ន្ធសង្គម និងដើម្បីទាក់ទាញផងដែរនូវ "ទេសចរវប្បធម៌" ដើម្បីទស្សនានិងកោតសរសើរវប្បធម៌ពីអតីតកាលនិងបច្ចុប្បន្នរបស់កម្ពុជា ។

### ចតុកោណទី១៖ ការលើកស្ទួយវិស័យកសិកម្ម

២.៤០ មុំទាំងបួននៃចតុកោណនេះ រួមមាន ៖ *(១) ការលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម (រួមទាំងការចិញ្ចឹមសត្វ អាហារូបត្ថម្ភ និងអភិវឌ្ឍន៍ជនបទ) (២) កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន (៣) កំណែទម្រង់ជលផល និង (៤) កំណែទម្រង់ព្រៃឈើ (រួមទាំង ការការពារ និង អភិរក្សបរិស្ថាន)* ។ ប្រការគួរឱ្យកត់សម្គាល់ក្នុងរយៈពេលពីរឆ្នាំកន្លះចុងក្រោយនេះ រួមមាន ៖ កិច្ចប្រឹងប្រែងជាបន្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបញ្ឈប់ការធ្វើឱ្យរិចរិលធនធានធម្មជាតិនិងបរិស្ថាន ការស្តារឡើងវិញនិងការកែលម្អសក្តានុពលប្រព័ន្ធស្រោចស្រព ស្ថានភាពធាតុអាកាសល្អ ពិពិធកម្មខ្លះៗទៅក្នុងដំណាំសម្រាប់លក់ ការចេញប័ណ្ណកម្មសិទ្ធិដីធ្លីថែមទៀតជូនដល់កសិករ និងកែលម្អបន្ថែមទៀតនូវហេដ្ឋារចនាសម្ព័ន្ធជនបទ ។ យុទ្ធសាស្ត្រកសិកម្មនិងទឹក (ឆ្នាំ២០០៦-២០១០) ត្រូវបានរៀបចំឡើង តាមរយៈកិច្ចដំណើរការដែលមានការពិគ្រោះយោបល់ ហើយត្រូវបានអនុម័ត នៅក្នុងឆ្នាំ២០០៧ ។

២.៤១ **<u>ការលើកម្ពស់ផលិតភាពនិងពិពិធភាវូបនីយកម្មកសិកម្ម</u>** ៖ ផលិតកម្មស្រូវ ដែលជាផលិតកម្មចម្បងមួយសម្រាប់ទ្រទ្រង់ជីវភាពប្រជាជននៅជនបទស្ទើរតែទាំងអស់នៅក្នុងប្រទេសកម្ពុជា ក្រោយពីបានខ្លាំងឡើងដល់កម្រិតខ្ពស់បំផុតក្នុងរដូវបង្កបង្កើនផលឆ្នាំ២០០៥-២០០៦ បានបន្តកើនឡើងជាបណ្តើរៗតាំងពីពេលនោះមក ទោះបីក្នុងអត្រាមួយទាបជាងមុនក្តី (ប្រហែល ៦ភាគរយ) ។ ការកើនឡើងផលិតផលដំណាំមានកម្រិត ២៧,៦ ភាគរយ នៅក្នុងឆ្នាំ២០០៥ ៥,៥ភាគរយ នៅក្នុងឆ្នាំ២០០៦ និង ៨,២ភាគរយ នៅក្នុងឆ្នាំ២០០៧ (សូមមើលឧបសម្ព័ន្ធ ១.១) ។ ការប្រមូលផលបានល្អ គឺដោយសារពុំមានគ្រោះធម្មជាតិធំៗ ដូចជា គ្រោះរាំងស្ងួត ទឹកជំនន់

និងសត្វល្អិតចង្រៃជាដើម ព្រមទាំងដោយសារកំណើននៃការប្រើប្រាស់កត្តាផលិតកម្មល្អជាងមុន និងកំណើនផ្ទៃដីស្រោចស្រព រួមជាមួយនឹងការកែលម្អការគ្រប់គ្រងនៅតាមកសិដ្ឋាន ។ ការប្រើប្រាស់នូវវិធីដែលចំណាយទាប និងផ្តល់ផលខ្ពស់ កំពុងមានការកើនឡើង ដូចជា ប្រព័ន្ធធ្វើស្រែប្រពលវប្បកម្ម វិធីសាស្ត្រដាំដុះជាលក្ខណ:សរីរាង្គ និងការគ្រប់គ្រងចម្រុះលើសត្វល្អិតចង្រៃ ជាដើម ។ ការធ្វើពិពិធកម្មដំណាំសម្រាប់លក់ កំពុងមានការកើនឡើង ហើយការរកទីផ្សារសម្រាប់ផលិតផលកសិកម្ម កំពុងតែត្រូវបានធ្វើឱ្យប្រសើរឡើង ដោយមួយផ្នែកបណ្តាលមកពីស្ថានភាពនៃផលកម្រៃមានភាពអំណោយផលជាងមុន ។

## តារាង ២.២ : ចន្លោះភាព និង គោលដៅសម្រាប់វិស័យកសិកម្ម

| វាយមុខ | ឯកតា | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ ប៉ាន់ស្មាន | ២០១០ គោលដៅ |
|---|---|---|---|---|---|---|
| ផលិតកម្មស្រូវ | លានតោន | ៥,៩៨ | ៦,២៦ | ៦,៧២ | ៦,៩៨ | ៧,២៥ |
| ទិន្នផលស្រូវក្នុងមួយហិកតា | តោន | ២,៤៨ | ២,៤៩ | ២,៦២ | ២,៦០ | ២,៨០ |
| ការនេសាទ (ទឹកសាប សមុទ្រ និងវារីវប្បកសិកម្ម) | តោន | ៤១០.០០០ | ៥១៦.០០០ | ៤៨២.០០០ | ៥០០.០០០ | ៤៥០.០០០ |
| ផ្ទៃដីស្រោចស្រព រួមទាំងការស្រោចស្រពបន្ថែម | ពាន់ហិកតា | ៦៣២ | ៧២១ | ៧៧៣ | ៨២៧ | ៨៦៧ |
| កំណែទម្រង់ដី ចំនួនប័ណ្ណកម្មសិទ្ធិ ដែលផ្តល់ជូនកសិករ | %នៃផ្ទៃដីសរុប | ១៥ | ១៧ | ១៨,២ | ២០,០ | ២៤ |
| ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ | %នៃផ្ទៃដីសរុប | ៥៩ | ៥៩ | | | ៦០ |
| ការប្រើប្រាស់អុសធ្យូងសម្រាប់ដុត | %គ្រួសារសរុប | ៨៣,៩ | ៨៣,៩ | | | ៦១ |

២.៤២ ផលិតភាពរបស់ដំណាំស្រូវក្នុងមួយហិកតានៅមិនទាន់មានកម្រិតខ្ពស់នៅឡើយ ដោយទិន្នផលស្ថិតនៅក្នុងកម្រិតខ្ពស់ជាងបន្តិចធៀបនឹងកម្រិតឆ្នាំ២០០៥ ពោលគឺ ២,៤៨តោនក្នុងមួយហិកតា និងទាបជាងច្រើនធៀបនឹងប្រទេសជិតខាង ។ សក្តានុពលដ៏ធំធេងនៅមានសម្រាប់ការបង្កើនផលិតភាព តែទាមទារឱ្យមានវិធានការចាំបាច់មួយចំនួនថែមទៀត ។ កសិករដែលភាគច្រើនជាអ្នកក្រីក្រនៅតែបង្កបង្កើនផលសម្រាប់គ្រាន់តែការផ្គត់ផ្គង់ខ្លួនឯងប៉ុណ្ណោះ ។ កំណើននៅក្នុងផលិតភាព តាមរយៈការកែលម្អការដាំដុះ[១] នឹងផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ប្រជាកសិករក្រីក្រ ជំរុញការកាត់បន្ថយភាពក្រីក្របានរហ័ស និងការប្រើប្រាស់អាហារកាន់តែមានតុល្យភាពជាងមុន ដែលបណ្តាលមកពីការកើនឡើងនៃប្រាក់ចំណូល ហើយជាលទ្ធផល គឺជួយដល់ការធានាបាននូវការពង្រឹងអាហារូបត្ថម្ភ ។

[១] *ផយអជ* បានស្នើឡើងនៅក្នុងកំណត់យោងក្នុងកថាខណ្ឌ៤.០៩ នូវគម្រោងមួយសម្រាប់ជំនួយតែមួយលើកក្នុងការផ្តល់ពូជល្អនិងជីដល់កសិករក្រីក្រ ។ មុនកិច្ចប្រជុំកម្រិតខ្ពស់នាទីក្រុងរ៉ូម ថ្ងៃទី១ មិថុនា ២០០៨ ការលើកឡើងរបស់ប្រធានធនាគារពិភពលោក ត្រូវបានគេដកស្រង់ថា "ប្រការសំខាន់ដែលយើងត្រូវផ្តោតការយកចិត្តទុកដាក់លើនោះ គឺសកម្មភាពជាក់ស្តែង" គឺថា "ធនាគារពិភពលោកគួរតែបង្កើត Trust Fund មួយឡើងសម្រាប់ផ្តល់គ្រាប់ពូជ និងជីដល់កសិករដែលមានដីតូចតាច ។ "ទាំងនេះ មិនមែនជាបញ្ហា ...... ដែលអ្នកត្រូវការធ្វើការស្រាវជ្រាវមួយចំនួនជាមុននោះទេ" ។ លោកប្រធានធនាគារពិភពលោកបានលើកឡើងថា "ប្រជាជនដឹងនូវអ្វីដែលពួកគាត់ត្រូវធ្វើហើយ" ។ ទស្សន:ស្រដៀងគ្នានេះ ត្រូវបានលើកឡើងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## ប្រអប់ ២.៥
## តម្រូវសំខាន់ៗក្នុងវិស័យកសិកម្ម

១. សកម្មភាពនៅតាមកសិដ្ឋាននិងក្រៅកសិដ្ឋានរបស់កម្ពុជា ត្រូវតែពង្រីកសម្រាប់ការបង្កើនប្រាក់ចំណូលរបស់ប្រជាជននៅជនបទដែលមាន ៨០,៦ ភាគរយនៃចំនួនប្រជាជនទាំងអស់ និងដែលភាគច្រើនចូលរួមក្នុងវិស័យកសិកម្ម និងសម្រាប់ការលុបបំបាត់ភាពក្រីក្រ ។

២. ប្រទេសកម្ពុជាសម្បូណ៌ទៅដោយធនធាននិងដីមានជីជាតិបង្គួរ ដែលសមស្របសម្រាប់ដំណាំរយៈពេលវែងនិងប្រចាំឆ្នាំផ្សេងៗ ។ ប៉ុន្តែ ដំណាំសំខាន់ៗដែលដាំដុះនៅពេលនេះ គឺមានតែធុញ្ញជាតិតាមរដូវទេ ភាគច្រើនគឺស្រូវដែលប្រើប្រាស់ ៩០ភាគរយនៃផ្ទៃដីកសិកម្ម ។ សក្តានុពលបន្ថែមសម្រាប់ដាំដំណាំផ្សេងៗ ទៀតនៅមិនទាន់បានប្រើប្រាស់ឱ្យអស់លទ្ធភាពនៅឡើយ ។ ឧទាហរណ៍ ជាង ៧០ភាគរយ នៃ បន្លែ ផ្លែឈើ និងសូម្បីតែផ្កាសម្រាប់ឧស្សាហកម្មទេសចរណ៍ដែលកំពុងលូតលាស់ និងសម្រាប់ការប្រើប្រាស់ក្នុងស្រុក ត្រូវបាននាំចូលនៅពេលដែលដំណាំទាំងនេះអាចដាំយ៉ាងងាយស្រួលនៅក្នុងប្រទេសដើម្បីផ្តល់ការងារនិងប្រាក់ចំណូល ។

៣. ទោះបីជាប្រទេសកម្ពុជាអាចផលិតស្រូវសម្រាប់ផ្គត់ផ្គង់ខ្លួនឯងក្តី អតុល្យភាពខ្លះៗនៅតែកើតមាននៅក្នុងចំណោមខេត្តនិងស្រុកមួយចំនួន (ខេត្ត ៥ ក្នុងចំណោមខេត្តទាំង២៤ មិនអាចផលិតស្រូវបានគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ក្នុងមូលដ្ឋានឡើយ) ។ បរិមាណស្រូវដ៏ច្រើន ជាពិសេស បរិមាណស្រូវដែលមានគុណភាពខ្ពស់ត្រូវបាននាំចេញជារៀងរាល់ឆ្នាំ ហើយស្រូវមួយចំនួនដែលមានគុណភាពជាស្តង់ដារត្រូវបាននាំចូល ជាពិសេស នៅតាមតំបន់ជាប់ព្រំដែនជាមួយប្រទេសជិតខាង ។

៤. កំណើនដ៏ច្រើននៃផលិតកម្មស្រូវក្នុងទសវត្សរ៍កន្លងទៅនេះ បានកើតឡើង តាមរយៈ ការពង្រីកផ្ទៃដី រួមជាមួយនឹងការបង្កើនទិន្នផល ជាបណ្តើរៗ ។ ទិន្នផលស្រូវនៅប្រទេសកម្ពុជា មានប្រហែល ២,៦តោនក្នុងមួយហិកតា ទោះបីជាមានកម្រិតខ្ពស់សម្រាប់កម្ពុជាក៏ដោយ ក៏នៅតែទាបជាងតួលេខរបស់បណ្តាប្រទេសជិតខាង ដែលប្រើជីគីមីច្រើនជាង និងរបៀបដាំដុះប្រសើរជាង ។ លើសពីនេះទៀត ទិន្នផលជាមធ្យម ២,៦តោនក្នុងមួយហិកតា បង្ហាញឱ្យឃើញថា ចំនួនដ៏ច្រើននៃកសិករ គឺប្រហែល ៥០ភាគរយដែលមានដីស្រែតូចជាង ១ហិកតា ផលិតបានស្រូវតិចជាងច្រើនក្នុងមួយហិចតា ។ ក្នុងចំណោមកសិករទាំងអស់មានតែ ២០ភាគរយប៉ុណ្ណោះ ដែលផលិតស្រូវបានច្រើនលើស ពីតម្រូវការហូបចុករបស់ពួកគេ ។ ***ភាពចាំបាច់បន្ទាន់ក្នុងការបង្កើនផលិតភាពស្រូវចំពោះមុខ គឺជាប្រការជៀសមិនរួច ។ ការផ្តោតលើការយកចិត្តទុកដាក់ ដែលមានលក្ខណៈទូលំទូលាយអ្នកក្រីក្រ គឺជាអាទិភាពបន្ទាន់ ។***

៥. នៅក្នុងចំណោមប្រភេទដំណាំស្រូវធំៗទាំងពីរប្រភេទ ដំណាំស្រូវវស្សា គឺជាប្រភេទដំណាំ ដែលផលិតកម្មរបស់វាមានទំហំធំធេង ។ កំណើនទិន្នផលស្រូវរដូវវស្សាមានសក្តានុពលដោយផ្ទាល់និងធំធេង សម្រាប់ការបង្កើនប្រាក់ចំណូលនិងការកាត់បន្ថយភាពក្រីក្រ ។ ការប្រើប្រាស់ប្រភេទពូជស្រូវផ្តល់ទិន្នផលខ្ពស់តែមួយមុខ ដោយមិនទាន់គិតដល់កត្តាផ្សេងទៀត ដូចជា ការប្រែប្រួលធម្មជាតិ វិធីដាំដុះ ។ល។ ក៏អាចរួមចំណែកធ្វើឱ្យមានកំណើនទិន្នផលដែរ ។

៦. ទន្ទឹងនឹងពេលដែល កម្មវិធីផ្សេងៗ ដូចជា ប្រព័ន្ធធ្វើស្រែប្រពលវប្បកម្ម និងកសិកម្មចម្រុះ (រួមទាំងសកម្មភាពកសិដ្ឋានផ្សេងៗទៀត ដូចជាការចិញ្ចឹមសត្វ និងមច្ឆាវប្បកម្ម ជាដើម) ត្រូវតែផ្សព្វផ្សាយនិងពង្រីកាចាំបាច់ នោះការចែកចាយគ្រាប់ពូជដែលផ្តល់ទិន្នផលខ្ពស់ ដោយឥតគិតថ្លៃ ឱ្យបានច្រើនតាមតែអាចធ្វើបាន ប្រសិនបើចាំបាច់ គួរតែជាអាទិភាពមួយដែលត្រូវយកចិត្តទុដាក់ ។ ការបែងចែកគ្រាប់ពូជដល់ប្រជាជនក្រីក្រ អាចធ្វើទៅបានដោយប្រើប្រាស់ស្ថាប័ននានា ដូចជា សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលនៅតំបន់ជនបទជាដើម ។ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស គួរតែផ្តោតការយកចិត្តទុកដាក់ជាពិសេស ហើយប្រើប្រាស់ធានធានមួយចំនួនរបស់ខ្លួន ដើម្បីជួយដល់ប្រជាជនក្រីក្រ នៅមូលដ្ឋាន ។ (សូមអានក្នុងលេខយោងនៃកឋាខ័ណ្ឌ ២.៤២)

៧. ការពង្រីកសេវាផ្សព្វផ្សាយកសិកម្ម ឱ្យបានដល់ខេត្តនិងឃុំទាំងឡាយដែលក្រីក្រជាងគេ គឺជាអាទិភាពមួយដែលត្រូវយកចិត្តទុកដាក់ជាចាំបាច់ ។ កម្មវិធីផ្សព្វផ្សាយមួយដែលមានតម្លៃទាប អាចចាប់ផ្តើមបានដោយការប្រើប្រាស់ "អ្នកស្ម័គ្រចិត្តសម្រាប់ការអភិវឌ្ឍន៍សហគមន៍" មួយរូបនៅក្នុងឃុំកសិកម្មនីមួយៗ ។ អ្នកស្ម័គ្រចិត្តទាំងនោះ អាចផ្តល់នូវការបណ្តុះបណ្តាលកម្រិតសាមញ្ញមួយនៅមុនរដូវដាំដុះ និងត្រូវបានស្នើសុំ ឱ្យធ្វើការបង្ហាញផ្ទាល់នៅស្រែចំការពីវិធីដាំដុះតាមរយៈការអនុវត្តប្រសើរជាងមុន និងធ្វើការបង្រៀនកសិករពីវិធីសាស្ត្រទាំងនេះ ។

៨. ការប្រើប្រាស់ប្រព័ន្ធស្រោចស្រព នៅមានកម្រិតទាបនៅឡើយ គឺប្រហែល ៣០ភាគរយនៃផ្ទៃដីដាំស្រូវ (២.៥៨៥.០០០ហិកតា ក្នុងឆ្នាំ២០០៧) ។

**ប្រអប់ ២.៥ (ត)**

ស្រូវរដូវវស្សាត្រូវការនូវការស្រោចស្រពបន្ថែមតែតិចតួច គឺតែនៅក្នុងពេលដែលមានការរាំងស្ងួតអូសបន្លាយជាយថាហេតុ នៅក្នុងរដូវដាំដុះ ។ ប្រព័ន្ធស្រោចស្រពដែលមានតម្លៃទាប និងគ្រប់គ្រងដោយសហគមន៍ (រួមជាមួយនឹងការរក្សាទុកទឹកភ្លៀងប្រកបដោយប្រសិទ្ធភាព) សម្រាប់គោលបំណងខាងលើនេះ និងសម្រាប់ធ្វើឱ្យមានការដាំដុះពីររដូវ គឺជាអាទិភាពមួយដែលត្រូវយកចិត្តទុកដាក់ជាចាំបាច់ ។

៩. វិស័យមីក្រូហិរញ្ញវត្ថុកំពុងរីកលូតលាស់ ប៉ុន្តែប្រជាជននៅជនបទ និងពាណិជ្ជករតែមួយភាគតូចប៉ុណ្ណោះ ដែលទទួលបានផលប្រយោជន៍ពីការលូតលាស់នៃវិស័យនេះ ។ សេវាឥណទានដែលមានលក្ខណៈប្រសើរនិងថោកជាងមុនសម្រាប់ប្រជាកសិករ ត្រូវតែដាក់ឱ្យអនុវត្ត និងពង្រីកឱ្យបានឆាប់ ។

១០. ដើម្បីបង្កើនកម្លាំងចរចានិងកម្លាំងទ្រទ្រង់របស់កសិករ ក្នុងនោះរាប់ទាំង សម្រាប់ធ្វើឱ្យថ្លៃទំនិញនិងសំភារៈកសិកម្មមានភាពល្អជាងមុន ទល់នឹងអ្នកចងការប្រាក់និងអ្នកជំនួញ វិធីផ្សេងៗសម្រាប់រៀបចំពួកគាត់ឱ្យក្លាយជាអង្គការមួយ ដូចជា អង្គការកសិករ ឬសហករណ៍កសិករ ត្រូវយកមកសិក្សាមើលនិងអនុវត្ត ទន្ទឹមគ្នានឹងការធ្វើវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជាទ្រព្យរួម ដូចជា ប្រព័ន្ធកែច្នៃ និងប្រព័ន្ធរក្សាទុក ជាដើម ។

១១. ដំណាំសម្រាប់លក់ (ពោត សណ្ដែកសៀង ដំឡូងមី) កំពុងរីកលូតលាស់ ភាគច្រើនសម្រាប់ការនាំចេញ ក្រោមរូបភាព "ការដាំដុះតាមកិច្ចសន្យា" ដែលនៅក្នុងនោះ អ្នកជំនួញអាចជួយដល់ផលិតកម្ម (សំភារៈកសិកម្មនិងការផ្សព្វផ្សាយ) ហើយនឹងទទួលទិញផលិតផលទៅតាមតម្លៃមួយដែលត្រូវបានកំណត់ជាមុន ។ ការងារជាច្រើនទៀត ត្រូវតែបានធ្វើឡើង ដើម្បីបង្កើនផលិតកម្មដំណាំទាំងនេះ តាមរយៈការដាំច្រើនដងនៅក្នុងរដូវមិនធ្វើស្រែ ឬតាមវិធីផ្សេងៗទៀត ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នាត្រូវតែធ្វើឡើងជាចាំបាច់ ដើម្បីដាំផ្កា ផ្លែឈើ និងបន្លែ នៅក្នុងប្រទេស នាជិតតំបន់ទេសចរណ៍ ដើម្បីទាញយកឧត្តមភាពពីទីផ្សារដែលនាំមកនូវប្រាក់ចំណេញយ៉ាងច្រើន ។

១២. កៅស៊ូ ដែលគឺជាផលិតផលនាំចេញជាប្រពៃណីរបស់ប្រទេសកម្ពុជា ត្រូវបានដាំដុះដើម្បីធ្វើអាជីវកម្មឡើងវិញយ៉ាងសកម្ម ។ ផ្ទៃដីធំៗ ដែលត្រូវបានដាក់ជួលក្រោមកម្មវិធីសម្បទានដីសេដ្ឋកិច្ចត្រូវតែចាប់ផ្ដើមធ្វើការដាំដុះដាំឱ្យបានឆាប់នូវដំណាំពាណិជ្ជកម្មនានា ដូចជា ដូងប្រេង ជាដើម ដែលមានតម្រូវការខ្ពស់ និងលក់បានថ្លៃ ។ អង្គភាពកែច្នៃ គប្បីត្រូវបានបង្កើតបន្ថែមទៀតនៅក្នុងប្រទេសសម្រាប់កែច្នៃផលិតផលទាំងនេះ ។ ដើម្បីបង្កើនការងារនិងប្រាក់ចំណូលបន្ថែម ពាណិជ្ជករគួរតែត្រូវបានលើកទឹកចិត្តឱ្យបង្កើតឡើងនូវឧស្សាហកម្មកែច្នៃ ឱ្យបានជិតតំបន់ដាំដុះដំណាំទាំងនោះតាមដែលអាចធ្វើទៅបាន ។

១៣. ***វិធានការជាអាទិភាពនានាមួយចំនួន ត្រូវតែបានជ្រើសរើសសម្រាប់ការចាប់ផ្ដើមដំណើរការចំពោះមុខភ្លាមៗ ដែលអាចផ្ដល់នូវលទ្ធផល ភ្លាមៗ និងអាចលុបបំបាត់ភាពក្រីក្របានយ៉ាងច្រើន ។***

២.៤៣ បញ្ហាប្រឈមចំពោះមុខនៅក្នុងវិស័យនេះ រួមមាន ការបង្កើនផលិតភាពនៅក្នុងដំណាំស្រូវនិងដំណាំផ្សេងៗទៀត ការបង្កើននិងការកែលម្អលទ្ធភាពទទួលបានសេវាផ្សព្វផ្សាយឥណទាននិងកត្តាផលិតកម្ម ការបង្កើនការស្រោចស្រព ការធានាឱ្យមាននូវអត្ថប្រយោជន៍កាន់តែប្រសើរជាងមុនសម្រាប់កសិករតាមរយៈការរកទីផ្សារ ការកែលម្អការគ្រប់គ្រងក្រោយពេលប្រមូលផល ការជំរុញទីផ្សារនាំចេញនិងក្នុងស្រុកសម្រាប់កសិផលទាំងឡាយ (រាប់បញ្ចូលទាំង អង្ករ -- មិនមែនគិតតែស្រូវមួយមុខ ផ្លែឈើ និងបន្លែ) ការជំរុញកសិឧស្សាហកម្ម រួមទាំងការកែច្នៃក្រោយពេលប្រមូលផល ការកែលម្អគុណភាពនៃស្តង់ដារកសិផល ការបង្កើតសមាគមកសិករដើម្បីបង្កើនអំណាចតថ្លៃ គោលបំណងក្នុងការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវដីធ្លីនិងធនធានផ្សេងៗទៀត និងការលើកទឹកចិត្តនិងការបង្កើនការវិនិយោគនិងការចូលរួមរបស់ផ្នែកឯកជន ។

២.៤៤ *<u>ការចិញ្ចឹមសត្វ</u>* ភាគច្រើន រួមមាន គោក្របី ជ្រូក និងបសុបក្សី ដោយរួមចំណែកនៅក្នុងសេដ្ឋកិច្ច ហើយផ្នែកនេះ ហាក់ដូចជានៅទ្រឹងក្នុងកម្រិតដដែល (ប្រហែល ៤ភាគរយ) ។ អនុវិស័យនេះ ត្រូវធ្វើឱ្យមានការ

កើនឡើងសម្រាប់ការប្រើប្រាស់ក្នុងស្រុក ដើម្បីកែលម្អអាហារូបត្ថម្ភផង និងដើម្បីបម្រើដល់ឧស្សាហកម្ម ទេសចរណ៍ ដែលកំពុងរីកលូតលាស់យ៉ាងលឿនផង ។ ការចាប់ផ្តើមប្រើប្រាស់និងការផ្សព្វផ្សាយអំពីពូជផ្តល់ផលខ្ពស់ និងការពង្រីកសេវាបសុពេទ្យ នឹងត្រូវទទួលបានការយកចិត្តទុកដាក់ជាពិសេស ។

២.៤៥ *__សន្តិសុខស្បៀង និងអាហារូបត្ថម្ភ__* : ស្ថានភាពអាហារូបត្ថម្ភសមស្របរបស់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេស ប្រជាជនងាយរងគ្រោះ គឺជាចំណុចដ៏សំខាន់មួយដែលត្រូវបានទទួលស្គាល់នៅក្នុង*ផយអជ* ថាជាបញ្ហាពហុវិស័យមួយ ដែលពឹងផ្អែកលើការបូកបញ្ចូលគ្នានូវកំណើន និងលទ្ធផលពីសកម្មភាពតាមវិស័យជាច្រើន ដូចដែលមានចែងនៅក្នុង *"ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា ២០០៨-២០១២"* ។ *ផយអជ* បានលើកឡើងថា "ត្រឹមឆ្នាំ២០១០ ប្រជាជនកម្ពុជាក្រីក្រនិងប្រជាជនដែលស្ថិតក្នុងស្ថានភាពអសន្តិសុខស្បៀង នឹងមានលទ្ធភាពផ្នែកសេដ្ឋកិច្ចល្អប្រសើរច្រើន ក្នុងការទទួលបានស្បៀងអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងមានជីវជាតិ ដើម្បីបំពេញសេចក្តីត្រូវការរបបអាហារ និងចំណង់ចំណូលចិត្តរបស់ពួកគាត់នៅគ្រប់ពេលវេលា សម្រាប់ការរស់នៅដ៏សកម្មនិងមានសុខភាពមាំមួន" ។ ជារួម លទ្ធផលនៃសន្តិសុខស្បៀង (ស្ថានភាពអាហារូបត្ថម្ភ) មានវឌ្ឍនភាពល្អប្រសើរជាលំដាប់ ក្នុងរយៈពេលពីរឆ្នាំកន្លះចុងក្រោយនេះ ដោយសារកំណើនសេដ្ឋកិច្ច កំណើនផលិតផលកសិកម្ម ភាពល្អប្រសើរនៃភាពមានស្បៀងអាហារ ភាពទទួលបានស្បៀង និងការប្រើប្រាស់ និងការបឺតស្រូបស្បៀង ។ លើសពីនេះ ភាពល្អប្រសើរនៃស្ថានភាពអាហារូបត្ថម្ភ បានកើនមានឡើងដោយសារមានការកើនឡើងនៃការយល់ដឹងពីអាហារូបត្ថម្ភ តាមរយៈ ការអប់រំសុខភាពនិងអាហារូបត្ថម្ភ និងអន្តរាគមន៍ជាច្រើនផ្សេងទៀត ដូចជា កម្មវិធីផ្តល់បន្ថែមនិងបញ្ចូលមីក្រូសារជាតិក្នុងស្បៀងអាហារ (ជាតិដែក វីតាមីនអា) ការផលិតនិងការប្រើប្រាស់អំបិលអ៊ីយ៉ូដជាសាកល និងអនុវត្តស្តង់ដារសុវត្ថិភាពស្បៀង ។ វឌ្ឍនភាពដែលសម្រេចបានកន្លងមក នឹងត្រូវអាចរក្សាបានជាបន្តនៅពេលអនាគត ទោះបីជាការឡើងថ្លៃម្ហូបអាហារខ្លាំងបានគម្រាមកំហែងដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ក្រុមប្រជាជនក្រីក្រនិងក្រុមជនងាយរងគ្រោះខ្លាំងក៏ដោយ (សូមមើល ប្រអប់២.១)។ ដូចនេះ ការឡើងថ្លៃម្ហូបអាហារខ្លាំង ដែលគម្រាមកំហែងដល់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភសម្រាប់ក្រុមប្រជាជនក្រីក្រនិងក្រុមជនងាយរងគ្រោះខ្លាំង ត្រូវតែបានតាមដានត្រួតពិនិត្យឱ្យបានជិតដល់ ។ ការតាមដានមើលជាដំណាក់ៗពីវឌ្ឍនភាពឬការផ្លាស់ប្តូរនៅក្នុងសភាព "ក្រិន" និងសភាព "មិនគ្រប់ទម្ងន់" របស់កុមារ គឺមានសារៈសំខាន់ណាស់ (ជាសូចនាកររង)។

២.៤៦ *__អភិវឌ្ឍន៍ជនបទ__*[១] ដែលមានលក្ខណៈអន្តរវិស័យ គឺជាធាតុផ្សំដ៏សំខាន់មួយសម្រាប់លើកស្ទួយវិស័យកសិកម្ម និងការកាត់បន្ថយភាពក្រីក្រ ។ ចាប់តាំងពីឆ្នាំ២០០៦ ការអភិវឌ្ឍជនបទ ត្រូវបានជ្រើសរើសជាវិស័យអាទិភាពមួយ នៅក្នុងចំណោមវិស័យអាទិភាព ៦ ផ្សេងទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមកម្មវិធីកំណែទម្រង់

[១] តួលេខទាំងអស់សម្រាប់សកម្មភាពអភិវឌ្ឍន៍ជនបទដែលបង្ហាញជូនក្នុងផ្នែកនេះ បង្ហាញតែតួលេខដែលបានផ្តល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ ប៉ុណ្ណោះ។

ហិរញ្ញវត្ថុសាធារណៈសម្រាប់ការបែងចែកនិងការបញ្ចេញថវិកាឱ្យទាន់ពេលវេលា ។ ការអភិវឌ្ឍធនធានមនុស្ស សម្រាប់ការអភិវឌ្ឍជនបទ ការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ការផ្តល់និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ (ផ្លូវជនបទ ស្ពានតូច ប្រឡាយទឹក សាលារៀន មណ្ឌលសុខភាព ការផ្គត់ផ្គង់ទឹកជនបទ) ការលើកស្ទួយសេវាសុខាភិបាលនិងអនាម័យនៅតាមតំបន់ជនបទ និងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដែលជាសកម្មភាពចម្បងៗ នៅក្នុងវិស័យនេះ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ហើយនឹងបន្តនៅតែ ជាអាទិភាពនិងជាបញ្ហាប្រឈម នៅក្នុងពេលខាងមុខ ។

២.៤៧ ការកសាង ការកែលម្អ និងការថែទាំ ហេដ្ឋារចនាសម្ព័ន្ធជនបទ មានសំខាន់ណាស់សម្រាប់វឌ្ឍនភាពនៅតំបន់ជនបទ ដើម្បីជាប្រយោជន៍ដល់ការផ្តល់សេវាផ្សព្វផ្សាយនិងផ្តល់កត្តាផលិតកម្មទៅតំបន់ជនបទ និងដើម្បីជួយសម្រួលផលិតផលកសិកម្មពីតំបន់ជនបទមកកាន់ទីផ្សារ ។ ក្នុងឆ្នាំ២០០៦-២០០៧ ការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យអភិវឌ្ឍន៍ជនបទ សម្រេចបានចំនួន ២៣.៤០៥នាក់ -- ផ្លូវជនបទថ្មីប្រវែង ១.០៣០ គីឡូម៉ែត្រ ត្រូវបានកសាង -- ផ្លូវជនបទប្រវែង ១.៦០៤គីឡូម៉ែត្រ ត្រូវបានជួសជុល -- ហើយ ផ្លូវជនបទប្រវែង ៣.៧៦១គីឡូម៉ែត្រ ត្រូវបានថែទាំជាប្រចាំ ។ ចំណែកស្ពានតូចចំនួន ៩៦កន្លែង និងលូបង្ហូរកាត់ផ្លូវចំនួន ៧២៦ ត្រូវបានសាងសង់ ។ លើសពីនេះទៀត អាគារសាលារៀនថ្មីចំនួន ៥៤ខ្នង ត្រូវបានសាងសង់បន្ថែម -- អគារសិក្សាចាស់ចំនួន ៣ខ្នង ត្រូវបានជួសជុល -- ហើយ ផ្សារសហគមន៍ចំនួន ៣កន្លែង (២ នៅខេត្តកំពង់ធំ និង ១ នៅក្រុងភ្នំពេញ) ត្រូវបានបង្កើតឡើង ។

២.៤៨ សុខាភិបាលនិងអនាម័យនៅតាមតំបន់ជនបទ ៖ ក្នុងឆ្នាំ២០០៦ និង ២០០៧ អណ្តូងទឹកគ្រប់ប្រភេទចំនួន ៣.០២២អណ្តូង ត្រូវបានបង្កើតឡើង ហើយអណ្តូងទឹកគ្រប់ប្រភេទចំនួន ១.៣៣២អណ្តូង ត្រូវបានជួសជុល ។ សម្រាប់គោលបំណងនេះ សហគមន៍ជនបទទាំងឡាយនៅតាមតំបន់ខ្សត់ទឹក ក៏ត្រូវបានផ្តល់ជូនផងដែរនូវស្រះជីកចំនួន ៦២កន្លែង ។ ដើម្បីផ្តល់ទឹកបរិភោគដែលមានសុវត្ថិភាពជាងមុន ទឹកពីអណ្តូងចំនួន ៦.២៦០ ត្រូវបានធ្វើតេស្តពិសោធន៍រកមើលសារធាតុអាសេនិក ។ បង្គន់អនាម័យសាធារណៈ និងតាមគ្រួសារចំនួន ៥.៦៤៨បង្គន់ក៏ត្រូវបានសាងសង់ ផងដែរ ។

### តារាង ២.៧: វឌ្ឍនភាពនៅក្នុងការអភិវឌ្ឍជនបទ

| វាយមុខ | ២០០៥ | ២០០៦ | ២០០៧ | ២០១០ គោលដៅ |
|---|---|---|---|---|
| ការស្តារផ្លូវថ្នល់ជនបទ គម (ក្នុងចំណោមផ្លូវថ្នល់សរុប ប្រវែង ២៨.០០០ គីឡូម៉ែត្រ) | ២២.៧០០ | ២២.៩៦៤ | ២៣.៧២៧ | ២៥.០០០ |
| ការទទួលបានទឹកស្អាតនៅជនបទ (% នៃប្រជាជននៅជនបទ) | ៤១,៦ | ៤២,៦ | ៤៥,៥ | ៤៥ |
| ការទទួលបានអនាម័យនៅជនបទ (% នៃប្រជាជននៅជនបទ) | ១៦,៤ | ១៦,៥ | ១៦,៧ | ២៥ |

*ប្រភព : ក្រសួងអភិវឌ្ឍន៍ជនបទ*

២.៤៩ ការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ : មីក្រូឥណទានដែលមានអត្រាការប្រាក់ទាប ក្នុងទឹកប្រាក់ចំនួនជាង ១៣.០២០លានរៀល ត្រូវបានផ្តល់ជូនប្រជាជននៅជនបទ ។ លើសពីនេះទៀត ធនាគារស្រូវចំនួនជាង ៤៩២.២៣១តោន និងធនាគារគោ-ក្របីចំនួន ១៦៧ក្បាល ក៏បានដំណើរការដើម្បីជួយដល់ប្រជាជនក្រីក្រ ផងដែរ ។ ប្រព័ន្ធស្រោចស្រពខ្នាតតូចក៏ត្រូវបានកសាងផងដែរ ដើម្បីផ្គត់ផ្គង់ទឹកសម្រាប់វិស័យកសិកម្ម ។ ទំនប់ទឹកថ្មីប្រវែង ២២,៧៤គីឡូម៉ែត្រ និងប្រឡាយទឹកថ្មីប្រវែង ៤១,៣៩គីឡូម៉ែត្រ ត្រូវបានកសាងឡើង -- ទំនប់ទឹកប្រវែង ៥,២៩គីឡូម៉ែត្រ និង ប្រឡាយទឹកប្រវែង ១៣៦,២៧គីឡូម៉ែត្រ ត្រូវបានជួសជុល -- ហើយទ្វារទឹកចំនួន ៤ ត្រូវបានសាងសង់ឡើង ។

២.៥០ បញ្ហាប្រឈមបន្ទាន់នៅក្នុងវិស័យអភិវឌ្ឍន៍ជនបទ នៅក្នុងបរិបទនៃការកាត់បន្ថយភាពក្រីក្រ រួមមាន :

បន្តការគាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់នឹងត្រូវធ្វើបន្ត ដើម្បីអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជា ការស្តារនិងសាងសង់ផ្លូវថ្នល់ជនបទ ស្ពានតូចៗ លូកាត់ថ្នល់ អណ្តូងទឹក សំណង់សិល្បការ និងប្រព័ន្ធធារាសាស្ត្រខ្នាតតូចៗ សាលារៀន អនាម័យជនបទ ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះរួមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងផ្សេងៗ ដែលបានគ្រោងសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្មអាចផ្តល់កាលានុវត្តភាពការងារនិង រកចំណូលនៅតំបន់ជនបទ ហើយតាមរយៈនេះក៏អាចបញ្ឈប់ការផ្លាស់ប្តូរទីលំនៅក្នុងស្រុកពីជនបទ ទៅតំបន់ទីប្រជុំជនផងដែរ ។

ជំរុញអោយដំណើរការ "ភូមិមួយផលិតផលមួយ" ដើម្បីបង្កើតមុខរបរនិងវិជ្ជាជីវៈមូលដ្ឋានច្បាស់លាស់។

គ្រោងសិក្សាពី "ភូមិគំរូ" ក្នុងសហគមន៍ជនបទ ដើម្បីធ្វើឱ្យប្រសើរឡើង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅជនបទ ។

ធ្វើឱ្យប្រសើរឡើង និងការបង្កើនលទ្ធភាពប្រកបដោយចីរភាពក្នុងការទទួលបាននិងប្រើប្រាស់ទឹកស្អាតនៅជនបទ ជាពិសេស នៅសហគមន៍ជនបទដែលកំពុងខ្វះទឹកស្អាតប្រើប្រាស់ ។

ពង្រឹងឡើងវិញនូវតួនាទីរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ដើម្បីជំរុញនិងលើកទឹកចិត្តឱ្យមានការអភិវឌ្ឍដោយមានការចូលរួមពីសហគមន៍នៅមូលដ្ឋាន ។

ជុំរុញការប្រើប្រាស់ឥណទានជនបទឱ្យមានប្រសិទ្ធភាព តាមរយៈ ការពង្រីកមីក្រូហិរញ្ញវត្ថុ និងការប្រាក់ទាប ។

ផ្តល់ការបណ្តុះបណ្តាលមុខវិជ្ជាជីវៈ និងការការពារ ដល់ជនជាតិដើមភាគតិច ។

ដោះស្រាយបញ្ហាជូនប្រជាជន ដែលត្រូវរងផលប៉ះពាល់ពីការរុះរើទីលំនៅដោយមូលហេតុនៃការសាងសង់ផ្លូវថ្នល់ ដោយផ្អែកលើនិតិវិធីច្បាប់ និងដោយមធ្យោបាយសន្តិវិធី និងផ្តល់ដល់ពួកគាត់នូវចំណាយសមស្រប ក្នុងការរុះរើលំនៅដ្ឋាន។

ជួយសម្រួល និងណែនាំដល់ការបង្កើតសមាគមន៍កសិករ ដើម្បីជួយឱ្យពួកគេអាចទទួលបានកត្តាផលិតកម្ម ដែលមានតម្លៃថោក និងតម្លៃខ្ពស់សម្រាប់ផលិតផល ហើយជួយបង្កើតឃ្លាំងរួមសម្រាប់រក្សាផលិត ។

ជំរុញការស្តារ ការធ្វើឱ្យប្រសើរឡើង ហេដ្ឋារចនាសម្ព័ន្ធ (ឧទាហរណ៍ ពីផ្លូវក្រាលគ្រួសក្រហម ទៅផ្លូវជាក្រាលកៅស៊ូ) និងសាងសង់ផ្លូវថ្នល់ជនបទទាំងអស់ ជាពិសេស ផ្លូវថ្នល់ដើម្បីតភ្ជាប់ទៅតំបន់ទាំងឡាយណា ដែលផលិតកម្មកសិកម្មមានការកើនឡើង និងតំបន់ទាំងឡាយដែលមានកម្រិតភាពក្រីក្រខ្ពស់ជាពិសេស នៅតាមតំបន់ដាច់ស្រយាល ។

ជំរុញការផ្តល់ទឹកស្អាត និងអនាម័យ ។

ចាប់ផ្តើមអនុវត្តកម្មវិធីប្រើកម្លាំងពលកម្មច្រើន សម្រាប់កិច្ចប្រឹងប្រែងទាំងនេះ ដើម្បីផ្តល់ប្រាក់ចំណូលបន្ថែមទៀតជូនដល់ប្រជាជនក្រីក្រសំដៅជួយឱ្យពួកគេអាចទប់ទល់នឹងវិបត្តិស្បៀងអាហារ ។

ជួយសម្រួលឧស្សាហកម្មកែច្នៃធុនតូច ដោយពង្រីកបណ្តាញអគ្គិសនីដល់តំបន់ជនបទ ។

២.៥១ **កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន** : រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងជំរុញយ៉ាងសកម្មនូវការអនុវត្តកម្មវិធីកំណែទម្រង់ដីធ្លី ដែលបានដាក់ចេញសំដៅរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងកិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យប្រកបដោយចីរភាព ដោយបានផ្តោតការយកចិត្តទុកដាក់ជាអាទិភាពដល់ការពង្រឹងសុវត្ថិ-ភាពនៃការកាន់កាប់ដីធ្លីទាំងដីរដ្ឋ ទាំងដីឯកជន តាមរយៈ ការចុះបញ្ជីដីធ្លីទៅតាមនីតិវិធីពីរ ដើម្បីបង្កើនល្បឿននៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាជន ក៏ដូចជាស្ថាប័នដែលមានអាណត្តិកាន់កាប់ដីរដ្ឋបានច្បាស់លាស់ ។ កិច្ចខិតខំប្រឹងប្រែងធំៗ ក្នុងការធ្វើឱ្យសម្រេចនូវអាទិភាពនេះ និងនៅក្នុងការជំនះបញ្ហាប្រឈមទាំងឡាយ រួមមាន :

គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តិចាំបាច់ ដើម្បីអនុវត្តច្បាប់ភូមិបាលប្រកបដោយប្រសិទ្ធភាព ត្រូវបានរៀបចំ និងអនុម័តជាបន្តបន្ទាប់ ដែលមានតាំងពីអនុក្រឹត្យរបស់រាជរដ្ឋាភិបាល រហូតដល់ប្រកាសអន្តរក្រសួង ជាអាទិ៍ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ សារាចរណែនាំស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ប្រកាសស្តីពីការធ្វើអត្តសញ្ញាណកម្ម ធ្វើចំណាត់ថ្នាក់ និងធ្វើផែនទីដីរដ្ឋ និងប្រកាសអន្តរក្រសួងមួយចំនួន ដូចជា ប្រកាសរួមស្តីពីយន្តការផ្តល់សេវាផ្សព្វផ្សាយកសិកម្មដល់កសិករសម្បទានដីសង្គមកិច្ច សេចក្តីណែនាំរួមទាក់ទងនឹងការពង្រឹងការអនុវត្តរបស់គណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ។ល។ លើសពីនេះដើម្បីជំរុញដោះស្រាយវិវាទដីធ្លី អាជ្ញាធរដោះស្រាយវិវាទដីធ្លី ត្រូវបានបង្កើតឡើង ដើម្បីជំរុញកិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ ។

យន្តការដោះស្រាយវិវាទដីធ្លីតាមរយៈគណៈកម្មការសុរិយោដី មកដល់ពេលនេះ បានដោះស្រាយបញ្ចប់វិវាទបានចំនួន ១.៤០០ករណី ដែលពាក់ព័ន្ធគ្រួសារចំនួនជាង ៧.៥០០ ស្មើនឹងផ្ទៃដីជាង ២.៥០០ ហិកតា ។

កិច្ចប្រឹងប្រែងជាបន្តត្រូវបានធ្វើឡើងនៅក្នុងការកែលម្អនិងអភិវឌ្ឍនីតិវិធីចុះបញ្ជីដីធ្លី ទាំងពីររូបភាព គឺការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំៗ សម្រាប់ការផ្តល់ប័ណ្ណកម្ម-សិទ្ធិជូនប្រជាជន ។ យោងតាមអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ២០០៧ ៣៧ភាគរយនៃផ្ទៃដីកសិកម្មដែលកាន់កាប់និងធ្វើអាជីវកម្មដោយគ្រួសារ ត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិ (ធៀបនឹង ២៣ភាគរយ ក្នុងឆ្នាំ ២០០៤) ។ តួលេខនេះ មាន ៣១ភាគរយ ក្នុងឆ្នាំ២០០៧ សម្រាប់គ្រួសារក្រីក្របំផុតដែលបានកើនឡើងពី ១៦ភាគរយ ក្នុងឆ្នាំ២០០៤ ។

ចំនួនប័ណ្ណដែលបានចេញរួច នៅក្នុងឆ្នាំ២០០៦ មានចំនួន ២៨០.២០៧ (ជាប្រព័ន្ធ) និង ១១.៧៥៤ (ដាច់ដោយដុំ) និងនៅក្នុងឆ្នាំ២០០៧ មានចំនួន ២៥១.៣៨៧ (ជាប្រព័ន្ធ) និង ៨.៣៣៥ (ដាច់ដោយដុំ)។ មកដល់ពេលនេះ ប័ណ្ណកម្មសិទ្ធិសរុបដែលបានចេញរួច មានចំនួន ១,៣៧៥ លាន (ប័ណ្ណកម្មសិទ្ធិលើដីកសិកម្មមានចំនួន ១៨,២ភាគរយ នៃចំនួនក្បាលដីកសិកម្មសរុបទូទាំងប្រទេស) ។

កម្មសិទ្ធិរួមប្តីប្រពន្ធ ត្រូវបានជំរុញលើកទឹកចិត្តឱ្យមាន ។ ជាលទ្ធផលជាក់ស្តែង ក្នុងរយៈ កាលកន្លងមកនេះ ក្នុងចំណោមប័ណ្ណកម្មសិទ្ធិដីសរុបដែលបានចុះបញ្ជីរួចហើយ មាន៦៨ភាគរយ ជាកម្មសិទ្ធិ រួមប្តីប្រពន្ធ ២៥ភាគរយជាកម្មសិទ្ធិរបស់ប្រពន្ធ ៥ភាគរយជាកម្មសិទ្ធិរបស់ប្តី និង ២ភាគរយជាកម្មសិទ្ធិរបស់រដ្ឋ ។

តាមរយៈការអនុវត្តគោលនយោបាយអភិវឌ្ឍន៍នៅនឹងកន្លែង ការកសាងភូមិថ្មី ការតាំងលំនៅដ្ឋានថ្មី និងការបែងចែកដីដែលបានពីបោសសម្អាតមីនរួច រួមទាំង ដីដែលរឹបអូសពីការកាន់កាប់ខុសច្បាប់ផង នោះ គិតពីឆ្នាំ២០០២ ដល់ ឆ្នាំ២០០៧ មានផ្ទៃដីសរុបទំហំ ១២.០០០ហិកតា ត្រូវបានផ្តល់ជាអចលនទ្រព្យស្របច្បាប់ ដល់គ្រួសារក្រីក្រគ្មានដីចំនួន ២៧.០០០គ្រួសារ គិតចាប់តាំងពីឆ្នាំ២០០២ ដល់ ២០០៧ ។

តម្លាភាព និងគណនេយ្យភាពនៅក្នុងការផ្តល់សេវាកម្មនៅក្នុងវិស័យដីធ្លីនិងសំណង់ រួមទាំង ប្រព័ន្ធវាយតម្លៃដីធ្លីផងដែរ ត្រូវបានកែលម្អ ។

២.៥២ បញ្ហាប្រឈមបន្ទាន់ចំពោះមុខគឺ ការគ្រប់គ្រងនិងការបន្តទប់ស្កាត់ ការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ និងការប្រមូលផ្តុំដីបង្កកទុកក្នុងគោលបំណងមិនមែនផលិតកម្ម ។ សកម្មភាពនានា ដែលត្រូវយកចិត្តទុកដាក់អនុវត្ត រួមមាន :

ការពិនិត្យឡើងវិញនូវដីសម្បទានសេដ្ឋកិច្ចធំៗដែលបានចុះកិច្ចសន្យារួច ដោយការពង្រឹងការត្រួតពិនិត្យការអនុវត្តកិច្ចសន្យា ការផ្ទៀងផ្ទាត់ទំហំដីដែលបានអនុញ្ញាតរួច ដើម្បីដកហូតមកវិញនូវសម្បទានដែលមិនអនុវត្តស្របតាមកិច្ចសន្យា និងដីដែលលើសពីបញ្ញត្តិនៃច្បាប់ភូមិបាលឆ្នាំ២០០១ ក៏ដូចជា ដើម្បីពិនិត្យនិងដកចេញពី ដីសម្បទាននូវដីទាំងឡាយណាដែលមានជាប់ពាក់ព័ន្ធនឹង "តំបន់ការពារ" មកដាក់

ជាសម្បត្តិរដ្ឋ និងមកដាក់ជា "តំបន់ការពារ" វិញ ឬ ដើម្បីពិនិត្យនិងដកចេញពីដីដែលមានការប៉ះពាល់ជាមួយប្រជាពលរដ្ឋ ដើម្បីបង្វែរជូនប្រជាពលរដ្ឋវិញ ។

ការជំរុញការពង្រឹងការងារវាយតម្លៃផលប៉ះពាល់សង្គមនិងបរិស្ថាន ដោយមានការចូលរួម និងមានតម្លាភាព ជាពិសេស ក្នុងតំបន់នានាដែលនឹងគ្រោងធ្វើសម្បទាន ។

ការជំរុញការងារចុះបញ្ជីដីរដ្ឋតាមនីតិវិធីដែលបានកំណត់ក្នុងអនុក្រឹត្យស្ដីពីការគ្រប់គ្រងដីរដ្ឋ និងការចុះបញ្ជីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅជាសហគមន៍ ។

ការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវ សារាចរណែនាំស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ដើម្បីរកឱ្យឃើញជនខិលខូច និងដកហូតមកវិញនូវដីដែលបានកាន់កាប់ខុសច្បាប់ សម្រាប់គោលដៅអភិវឌ្ឍន៍សង្គម និងកិច្ចការពារបរិស្ថាន ។

ការពង្រឹងការយកពន្ធលើដីមិនប្រើប្រាស់ និងជំរុញការរៀបចំប្រព័ន្ធវាយតម្លៃថ្លៃដី និងប្រព័ន្ធព័ត៌មានដីធ្លីមួយច្បាស់លាស់ មានតម្លាភាព និងការកសាងប្លង់យុទ្ធសាស្ត្រអភិវឌ្ឍន៍ខេត្តក្រុង ពិសេសតំបន់ ដែលមានសក្ដានុពលសេដ្ឋកិច្ច ដើម្បីគ្រប់គ្រងការអភិវឌ្ឍ និងទប់ស្កាត់ការប្រមូលដីបង្កកទុកមិនប្រើប្រាស់ទុកលក់រកចំណេញ ។

ការជំរុញល្បឿននៃការងារចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធក្នុងក្របខ័ណ្ឌទូទាំងប្រទេស ជាពិសេស ក្នុងតំបន់ដែលមានសក្ដានុពលសេដ្ឋកិច្ច តាមរយៈការបង្កើតទីភ្នាក់ងារប្រតិបត្តិការពិសេស ។

ការជំរុញអនុវត្តសារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីផែនការបែងចែកដីសម្បទានសង្គមកិច្ច សម្រាប់ ៤១៦គ្រួសារក្នុង ខេត្ត-ក្រុងនីមួយៗ ដើម្បីពីនេះដល់ឆ្នាំ២០១០ សម្រេចឱ្យបាន ១០.០០០ គ្រួសារក្រីក្រដែលគ្មានដី ។

២.៥៣ កិច្ចខិតខំប្រឹងប្រែងជាបន្តនៅក្នុង**<u>ការបោសសម្អាតមីន</u>** បានរួមចំណែក ដល់ការកែលម្អស្ថានភាពសង្គម និងសេដ្ឋកិច្ចរបស់គ្រួសារកសិករក្រីក្រនៅតាមតំបន់ដាច់ស្រយាល និងដល់ការជំរុញកិច្ចអភិវឌ្ឍន៍ជនបទ នៅតាមតំបន់រងគ្រោះដោយសារមីន និងកាកសំណល់យុទ្ធភ័ណ្ឌសេសសល់ពីសង្គ្រាម ។ ការដោះមីននិងកាកសំណល់យុទ្ធភ័ណ្ឌសេសសល់ពីសង្គ្រាម បានបង្កើនផ្ទៃដីគ្មានមីនពី ៣៣.០៣៦ហិកតាដែលសម្រេចបានត្រឹមឆ្នាំ២០០៥ ដល់ ៤៣.៦៥០ហិកតា នៅត្រឹមខែឧសភា ឆ្នាំ២០០៨ ។ ចំនួនអ្នករងគ្រោះថ្នាក់ (របួសនិងស្លាប់) បានថយចុះយ៉ាងខ្លាំងពី ៨៧៥នាក់ក្នុងឆ្នាំ២០០៥ មកនៅត្រឹម ៣៥២នាក់ នៅក្នុងឆ្នាំ២០០៧ ។ ផ្ទៃដីដែលត្រូវបានបោសសម្អាតរួច ត្រូវបានផ្ទេរសម្រាប់គោលបំណងសង្គមនិងសេដ្ឋកិច្ច ដូចជា សម្រាប់ជាដីដាំដំណាំ សម្រាប់ជាដីលំនៅដ្ឋាន និងសម្រាប់បម្រើដល់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ផ្នែកសង្គមនិងសេដ្ឋកិច្ច ។

**ប្រអប់ ២.៦**

**បញ្ហាក្នុងការគ្រប់គ្រងដីធ្លី**

១. ដីគឺជាធនធានដ៏មានតម្លៃបំផុតនៃប្រទេសកម្ពុជា ។ គោលនយោបាយរួមរបស់រាជរដ្ឋាភិបាលកម្ពុជា គឺធានាឱ្យបានថា ដីទាំងអស់ត្រូវបានប្រើប្រាស់ឱ្យបានប្រសើរបំផុត តាមដែលអាចធ្វើទៅបាន សម្រាប់ជាអត្ថប្រយោជន៍របស់ប្រជាជនកម្ពុជាទាំងអស់ ទាំងនៅពេលនេះ និងទាំងនៅក្នុងពេលអនាគត ។ សេចក្ដីព្រាង*សេចក្ដីប្រកាសស្ដីពីគោលនយោបាយដីធ្លី* ដោះស្រាយបញ្ហាទាំងឡាយដែលទាក់ទងនឹង*រដ្ឋបាលដីធ្លី* (ដើម្បីបញ្ជាក់និងកត់ត្រាពីកម្មសិទ្ធិនិងសិទ្ធិផ្សេងៗទៀត) *ការគ្រប់គ្រងដីធ្លី* (ដើម្បីធានាថា ដីនិងធនធានធម្មជាតិ ត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព) និង*ការបែងចែកដីធ្លី* (ដើម្បីបែងចែកដីរដ្ឋសម្រាប់គោលបំណងសាធារណៈនិងឯកជន តាមរបៀបមួយដែលមានតម្លាភាព មានលក្ខណៈវិមជ្ឈការ និងមានភាពត្រឹមត្រូវ) ។

២. នៅក្នុងផ្ទៃដីទំហំ ១៨,១០៣៥លានហិកតា រដ្ឋជាម្ចាស់កម្មសិទ្ធិលើផ្ទៃដីទំហំ ១៤,៥លានហិកតា ហើយដីទំហំ ៣,៦លានហិកតា (២០%) គឺជារបស់ឯកជន ។ ច្បាប់ភូមិបាលកំណត់ប្រភេទដីទៅតាមការប្រើប្រាស់ កម្មសិទ្ធិ និងការគ្រប់គ្រង ។ គេឃើញមានដីបីប្រភេទ ដូចខាងក្រោម ៖

កម្មសិទ្ធិសាធារណៈរបស់រដ្ឋ គឺមិនអាចផ្ទេរបាន និងត្រូវបានរក្សាទុកសម្រាប់ជាគោលបំណងសាធារណៈ (អាគារនិងសំណង់នានារបស់រាជរដ្ឋាភិបាល ហេដ្ឋារចនាសម្ព័ន្ធ ។ល។) និងជាប្រយោជន៍ផ្នែកបរិស្ថាន ដូចជា ព្រៃឈើធម្មជាតិបម្រុង ទន្លេ បឹង ឆ្នេរសមុទ្រ និងទីកន្លែងផ្សេងៗទៀត ។

កម្មសិទ្ធិឯកជនរបស់រដ្ឋ ច្រើននៅទំនេរដែលអាចដាក់ឱ្យប្រើប្រាស់ឬផ្ទេរ រួមទាំងការផ្ដល់ដីសម្បទាន (សម្រាប់កសិដ្ឋានដាំដុះធំៗ ការធ្វើកសិកម្មបែបពាណិជ្ជកម្ម ការធ្វើអាជីវកម្មរ៉ែ និងការផ្ដល់ដីសម្បទានសង្គមកិច្ច) ។

កម្មសិទ្ធិឯកជនដែលកាន់កាប់ដោយរូបវន្តបុគ្គលឬនីតិបុគ្គលឯកជន ។

៣. ថ្វីបើការធ្វើអង្កេតសុរិយោដី ដែលគឺជាមូលដ្ឋាននៃការបែងចែកដីធ្លីជារួម នៅមិនទាន់មានភាពជឿនលឿនដល់កម្រិតធំដុំក្ដី ក៏ដោយ ក៏នៅចុងឆ្នាំ២០០៧ ផ្ទៃដីប្រហែល ២,៤៦លានហិកតា ស្ថិតនៅក្រោមការដាំដុះរបស់កសិករតូចតាច ផ្ទៃដីទំហំ ៩៤៣.០៦៩ហិកតា ត្រូវបានប្រគល់ឱ្យក្រុមហ៊ុនចំនួន ៥៧ តាមកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា និងដីទំហំ ៦៤.២០៨ហិកតា ថែមទៀតត្រូវបានប្រគល់ឱ្យក្រុមហ៊ុនចំនួន ៩ តាមកិច្ចព្រមព្រៀងគ្មានចុះហត្ថលេខា ជាដីសម្បទានសេដ្ឋកិច្ច សម្រាប់ផលិតកម្មជាលក្ខណៈពាណិជ្ជកម្មនៃដំណាំសំខាន់ៗ ក្រៅពីស្រូវ និងសម្រាប់កសិដ្ឋានដំណាំ ។

៤. សកម្មភាពជាអាទិភាពចាំបាច់មួយចំនួន រួមមាន ៖

ផ្ដល់ឱ្យបានឆាប់នូវ សិទ្ធិកាន់កាប់ដី និងប័ណ្ណកម្មសិទ្ធិដីសមូហភាព ជូនជនជាតិដើមភាគតិច (ដែលត្រូវបានប៉ាន់ស្មានថាមាន ១៧ក្រុម) និងប្រគល់ជូនពួកគាត់វិញនូវដីដែលបានទិញដោយមិនត្រឹមត្រូវពីពួកគាត់ដោយជនខិលខូច ។ គម្រោងសាកល្បងពីរ នៅខេត្តរតនៈគិរី និងគម្រោងសាកល្បងមួយនៅខេត្តមណ្ឌលគិរី កំពុងចាប់ផ្ដើមចុះបញ្ជីដីដែលកាន់កាប់ដោយក្រុមជនជាតិដើមភាគតិច ។

បន្តនិងបង្កើនល្បឿនចេញប័ណ្ណកម្មសិទ្ធិដី តាមនីតិវិធីដែលមានលក្ខណៈជាប្រព័ន្ធ និងមានលក្ខណៈដាច់ដោយដុំ ។

ផ្ដល់ដីជូនដល់ប្រជាជនក្រីក្រដែលគ្មានដីធ្លី នៅទីណាដែលអាចធ្វើទៅបាន។

ចាប់ផ្ដើមកិច្ចដំណើរការធ្វើផែនទីសុរិយោដីនៃដីទាំងអស់ ដែលគឺជាលក្ខខណ្ឌចាំបាច់មួយសម្រាប់ការរក្សាសណ្ដាប់ធ្នាប់ឯកសារដីធ្លី និងប័ណ្ណកម្មសិទ្ធិ ។

តាមរយៈការងារអប់រំនិងការផ្សព្វផ្សាយទូលាយ ដាស់តឿនប្រជាជនក្រីក្រកុំឱ្យលក់ដីរបស់ខ្លួន ដែលគឺជាប្រភពដ៏សំខាន់នៃជីវភាពរស់នៅរបស់ពួកគាត់ ឱ្យទៅអ្នកដណ្ដើមយកដីដើម្បីរកចំណេញដែលឱ្យតម្លៃហាក់ដូចជាខ្ពស់ សម្រាប់ប្រជាជនក្រីក្រដែលប្រើអស់យ៉ាងលឿននូវ "ទ្រព្យសម្បត្តិ" ដែលទើបទទួលបានថ្មីនេះ សម្រាប់ការប្រើប្រាស់ និងពុំមានសល់ប្រភពអ្វីទៀតសម្រាប់ ជីវភាពរស់នៅឡើយ ។

២.៥៤ <u>**កំណែទម្រង់ជលផល**</u> ៖ ដោយស្រូបយកប្រមាណ ៨១,៥ភាគរយ នៃរបបអាហារប្រូតេអ៊ីនសរុបរបស់ប្រជាជនកម្ពុជា ត្រីនិងផលិតផលត្រី (ប្រហុក) មានសារៈសំខាន់ណាស់ ហើយថែមទាំងជាប្រភពតែមួយនៃអាហារូបត្ថម្ភសម្រាប់ប្រជាជនជនបទភាគច្រើន ។ ប្រជាជនប្រមាណបួនលាននាក់ រកទទួលទានចិញ្ចឹមជីវិត

ដោយការនេសាទ ។ ផ្នែកនេះ រួមចំណែកប្រហែល ៧ភាគរយនៃផលិតផលក្នុងស្រុកសរុប ហើយប្រើប្រាស់កម្លាំងពលកម្មពេញម៉ោង ១០,៥ភាគរយ និង ៣៨ភាគរយមិនពេញម៉ោង នៃអ្នកមានការងារធ្វើសរុប ។ តំបន់នេសាទទឹកសាបសំខាន់ៗគឺ តំបន់អាងទន្លេមេគង្គ និងតំបន់បឹងទន្លេសាប ហើយតំបន់បឹងទន្លេសាបនេះ ក៏បង្កើតផងដែរនូវប្រព័ន្ធអេកូឡូស៊ីតែមួយគត់នៃតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការបន្តពូជត្រី ។ វារីវប្បកម្មទឹកសាបកំពុងកើនឡើងជាលំដាប់ ហើយអាចជាទិដ្ឋភាពមួយដ៏សំខាន់ក្នុងការធ្វើកសិកម្មចម្រុះនៅពេលដែលទិន្នផលស្រូវកើនឡើង ហើយដីកសិកម្មមួយផ្នែកអាចត្រូវបានទុកសម្រាប់វារីវប្បកម្មទឹកសាប ។ ការនេសាទទឹកសាបជួបប្រទះនឹងការថយចុះដោយសារការពង្រីកដែលបណ្ដាលមកពីការអភិវឌ្ឍ និងការបំពុលបរិស្ថាន កំពុងបំផ្លាញតំបន់នេសាទ និងតំបន់ត្រីពងកូន ។ ការនេសាទត្រីសមុទ្រភាគច្រើន សម្រាប់ការនាំចេញដែលភាគច្រើនត្រូវបានលក់នៅក្នុងសមុទ្រ ក្នុងទម្រង់មិនទាន់កែច្នៃ ។ តម្លៃបន្ថែម អាចត្រូវបង្កើតឡើងបានច្រើន ប្រសិនបើការកែច្នៃមួយចំនួនត្រូវបានធ្វើឡើង ហើយក៏អាចផ្ដល់ការងារផងដែរ ។

២.៥៥ ផ្អែកតាមច្បាប់ស្ដីពីជលផល ការនេសាទនៅកម្ពុជាត្រូវបានកំណត់ជាបីប្រភេទ ៖

- ការនេសាទជាលក្ខណៈគ្រួសារអាចប្រព្រឹត្តបានគ្រប់ពេលវេលា នៅក្នុងកន្លែងនេសាទបម្រុង កន្លែងនេសាទគ្រួសារ ឡូត៍នេសាទនៃដែននេសាទទឹកសាបក្នុងរដូវបិទនេសាទ ឬក្នុងដែននេសាទសមុទ្រដោយប្រើប្រាស់ឧបករណ៍នេសាទគ្រួសារ ។
- ការនេសាទជាលក្ខណៈសិប្បកម្ម អាចប្រព្រឹត្តទៅបានតែនៅក្នុងកន្លែងនេសាទបម្រុងនៃដែននេសាទទឹកសាប ក្នុងរដូវបើកនេសាទ ឬនៅក្នុងដែននេសាទសមុទ្រ ដោយប្រើឧបករណ៍នេសាទសិប្បកម្ម ។
- ការនេសាទជាលក្ខណៈឧស្សាហកម្ម អាចប្រព្រឹត្តទៅបាននៅក្នុងឡូត៍នេសាទនៃដែនសមុទ្រទឹកសាប ឬនៅក្នុងដែនសមុទ្រ ដោយប្រើឧបករណ៍ឧស្សាហកម្ម ។

តាំងពីឆ្នាំ២០០៥ មក កិច្ចប្រឹងប្រែងដ៏សកម្ម កំពុងត្រូវបានបន្តធ្វើក្នុងការគ្រប់គ្រងវិស័យនេះ នៅក្រោមក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិស័យជលផល ដែលបានផ្ដល់នូវមូលដ្ឋានមួយសម្រាប់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសធ្វើការតម្រឹមតម្រង់ធនធានរបស់ពួកគេមកជាមួយនឹងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រាជរដ្ឋាភិបាលកម្ពុជា ។ សមិទ្ធ-ផលដ៏គួរឱ្យកត់សម្គាល់មួយចំនួន រួមមាន ការរៀបចំនិងការធ្វើវិសោធនកម្មបទប្បញ្ញត្តិនានា ដើម្បីពង្រឹងការអនុវត្តច្បាប់ស្ដីពីជលផល ព្រះរាជក្រឹត្យស្ដីពីការបង្កើតសហគមន៍នេសាទ ការអភិវឌ្ឍវារីវប្បកម្ម ការស្រាវជ្រាវ ការអភិរក្ស ការបង្ក្រាបលើការនេសាទខុសច្បាប់ ។ល។ ហើយតំបន់ជាច្រើនទៀតត្រូវបានបម្រុងទុកសម្រាប់សហគមន៍នេសាទ ដែលប្រើប្រាស់វិធីសាស្ត្រប្រពៃណី និងចំណាយទាប ។ រហូតដល់ពេលនេះ សហគមន៍ចំនួន ៥១០ ត្រូវបានបង្កើតឡើង ក្នុងនោះ មានសហគមន៍នេសាទចំនួន ៤៤៨ ដែលពាក់ព័ន្ធនឹងការទាញយកធនធានជលផលពីដែនទឹកធម្មជាតិប្រកបដោយនិរន្តរភាព និងសហគមន៍ស្រះជម្រកត្រីមានចំនួន ៦២ ដែលពាក់ព័ន្ធនឹងការថែរក្សាពូជត្រី

ក្នុងដែនជម្រកធម្មជាតិ ។ ក្នុងចំណោមសហគមន៍ទាំងនោះ សហគមន៍ចំនួន ៤៧០ ស្ថិតនៅក្នុងដែននេសាទទឹកសាប និងសហគមន៍ចំនួន ៤០ទៀត ស្ថិតនៅក្នុងដែននេសាទតំបន់ឆ្នេរ ដោយមានប្រជាជនប្រមាណ ៤០០.០០០នាក់ ចូលរួមក្នុងការងារនេះ ។ ការប៉ះទង្គិចនិងទំនាស់ ដែលបានកើតមានឡើងម្តងម្កាលរវាងម្ចាស់ឡូតិ៍និងសហគមន៍មូលដ្ឋានកំពុងត្រូវបានដោះស្រាយ ។ អាទិភាពរបស់រដ្ឋាភិបាលកម្ពុជា បន្តផ្តល់និងធានាទទួលបាននូវធនធានជលផលសម្រាប់អ្នកក្រីក្រ ដើម្បីទ្រទ្រង់អាហារូបត្ថម្ភរបស់ពួកគាត់ និងដើម្បីកាត់បន្ថយភាពក្រីក្រ ។

២.៥៦ **កំណែទម្រង់ព្រៃឈើ :** ផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើមានសមាមាត្រមួយស្មើ គឺ ៥៩ភាគរយនៃផ្ទៃដីសរុប ។ ច្បាប់ព្រៃឈើធ្វើចំណាត់ថ្នាក់ព្រៃឈើ ជាធនធានព្រៃឈើអចិន្ត្រៃយ៍ និងព្រៃឈើឯកជន ។ ធនធានព្រៃឈើអចិន្ត្រៃយ៍ គឺជាផ្នែកនៃទ្រព្យសម្បត្តិសាធារណៈ ដែលមិនអាចផ្ទេរបាន ដែលរួមមាន (១) ព្រៃឈើសម្រាប់ផលិតកម្ម (២) ព្រៃឈើការពារ (សម្រាប់ជីវចម្រុះ ការការពារបរិស្ថាន និងការថែរក្សាដែនទឹកទាំងឡាយ) និង (៣) ព្រៃឈើដែលដាំដុះឡើងវិញ (តំបន់ផ្ទៃដីមិនប្រើប្រាស់ ដែលភាគច្រើនគ្របដណ្តប់ដោយដើមឈើតូចៗ) ។ វិស័យព្រៃឈើត្រូវបានគ្រប់គ្រងដោយរបបគ្រប់គ្រងបីយ៉ាង រួមមាន (១) ព្រៃសម្បទាន (២) សហគមន៍ព្រៃឈើ និង (៣) ការអភិរក្សនិងការដាំព្រៃឈើឡើងវិញ ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់លើការធ្វើឱ្យប្រសើរឡើង និងការតាមដានត្រួតពិនិត្យដ៏តឹងរ៉ឹង លើការធ្វើអាជីវកម្មព្រៃឈើ ដើម្បីការពារ និងធានានិរន្តរភាពព្រៃឈើ ដោយធ្វើការបង្កើតនូវព្រៃឈើបម្រុងគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ក្នុងស្រុក និងដោយធ្វើការការពារបរិស្ថាន ដើម្បីកាត់បន្ថយឥទ្ធិពលនៃភាពរាំងស្ងួត ទឹកជំនន់ និងការច្រោះដី ។ កម្មវិធីព្រៃឈើជាតិ កំពុងត្រូវបានរៀបចំឡើង ដើម្បីឈានទៅសម្រេចបាននូវចំណុចដៅរបស់ជាតិស្តីពីគម្របព្រៃឈើក្នុងកម្រិត ៦០ភាគរយនៃផ្ទៃដីសរុប ដូចដែលបានកំណត់នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ កម្មវិធីជាតិនេះផ្តោតលើ ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើនិងអភិបាលកិច្ច ការជំរុញល្បឿនការកំណត់ដែនព្រៃឈើ ការលើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រងនិងការថែរក្សាព្រៃឈើនិងសត្វព្រៃ ការបង្កើតឡើងនិងអនុវត្តកម្មវិធីសហគមន៍ព្រៃឈើ ការបង្កើនការដាំព្រៃឈើឡើងវិញ ការកសាងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស និងការសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយពីព្រៃឈើ ។

២.៥៧ ទិសដៅនៃកិច្ចអភិវឌ្ឍនៅក្នុងកំណែទម្រង់វិស័យព្រៃឈើ គឺដើម្បីគ្រប់គ្រងនិងប្រើប្រាស់ធនធានព្រៃឈើ តាមរបៀបមួយដែលមានចីរភាព សំដៅទាញយកប្រយោជន៍ឱ្យបានច្រើនបំផុត ពីការរួមចំណែករបស់វិស័យនេះ នៅក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច ។ នៅក្នុងដំណើរការនៃការការពារ ការត្រួតពិនិត្យ និងការលុបបំបាត់ភាពអនាធិតេយ្យក្នុងការប្រើប្រាស់ធនធានដ៏មានតម្លៃនេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តវិធានការជាច្រើនដំណាក់កាល ហើយសម្រេចបានជោគជ័យគួរឱ្យកត់សម្គាល់ជាច្រើន ដូចជា : សហគមន៍ព្រៃឈើ ត្រូវបានជំរុញឱ្យបង្កើតឡើងជាមួយទសវត្សរ៍មកហើយ ដែលសេចក្តីណែនាំពីការបង្កើតសហគមន៍នេះ

ត្រូវបានបញ្ចប់រួចរាល់នៅដើមឆ្នាំ២០០៦ ហើយបច្ចុប្បន្ននេះ ព្រៃឈើសហគមន៍ ជាង ១០០ក្រុម ដែលគ្របដណ្តប់លើផ្ទៃដីចំនួនប្រមាណ ២០០.០០០ហិកតា ត្រូវបានបង្កើតឡើង ។ ការធ្វើអាជីវកម្មព្រៃគុប របស់ក្រុមហ៊ុនព្រៃសម្បទានដែលបានផ្តល់ឱ្យរួចហើយ ត្រូវបានហាមឃាត់ ។ ប្រភេទបទល្មើសព្រៃឈើចំនួន ២.១៥៨ករណី ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ ។ ជនល្មើសចំនួន ៦០៦នាក់ត្រូវបានឃាត់ខ្លួន ធ្វើការណែនាំ និងបញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ ។ រណារយន្តអារ-កាត់ឈើចំនួន ១.៦៣៦គ្រឿង ឈើហ៊ុបមូល-ជ្រុងចំនួន ២.៧៧៦ម៉ែត្រគូប ឈើអារចំនួន ១៤.៩២៩មែត្រគូប សត្វព្រៃចំនួន ៦.៩៧១ក្បាលនិង៣.០៤៤គីឡូក្រាម ត្រូវបានចាប់ឃាត់ និងរឹបអូស ។ ដីព្រៃឈើទំហំ ២១៥.៩២១ហិកតា ត្រូវបានដកហូតយកមកវិញពីការចាប់យក និងការទន្ទ្រានយកដី ។ ជាមួយគ្នានេះដែរ ព្រៃគុបមួយចំនួនត្រូវបានដាក់ឱ្យដេញថ្លៃសម្រាប់ចូលរួមដោះស្រាយតម្រូវការប្រើប្រាស់ក្នុងស្រុក ។ សកម្មភាពដាំដុះដើមឈើនិងព្រៃឈើ មានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ ហើយអនុក្រឹត្យមួយរបស់រាជរដ្ឋាភិបាលកម្ពុជាក៏បានចែងពីវិធានប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ ដើម្បីបង្កលក្ខណៈសមស្រប និងជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ សហគមន៍ និងផ្នែកឯកជនឱ្យចូលរួមក្នុងសកម្មភាពនេះ ។ ទន្ទឹមនឹងនេះ ការអភិវឌ្ឍនិងពង្រឹងសមត្ថភាពសហគមន៍ព្រៃឈើ ក៏ត្រូវបានដំណើរការឡើងស្របគ្នានឹងការធ្វើនិយ័តកម្មសហគមន៍ព្រៃឈើដែលមានស្រាប់ និងការបង្កើតសហគមន៍ព្រៃឈើថ្មី ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាបានគាំទ្រ និងជំរុញឱ្យមានការអនុវត្តរបបគ្រប់គ្រងព្រៃឈើអន្តរជាតិទាំងថ្នាក់ជាតិនិងតំបន់ផងដែរ ជាពិសេស ការងារឥណទានកាបូនព្រៃឈើនៃ *យន្តការអភិវឌ្ឍស្អាត* និង *យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់និងរិចរិលព្រៃឈើ* ។ បន្ថែមលើនេះ គម្រោងឥណទានកាបូនសម្រាប់សហគមន៍ព្រៃឈើ ដែលជាគម្រោងការសាកល្បងទីមួយរបស់ពិភពលោក ត្រូវបាននិងកំពុងដំណើរការអនុវត្តនៅក្នុងខេត្តឧត្តរមានជ័យ ។ ទិដ្ឋភាពមួយចំនួន នៅក្នុងចំណោមទិដ្ឋភាពសំខាន់ៗក្នុងវិស័យនេះ រួមមាន :

សម្បទានិកព្រៃឈើមួយចំនួន កំពុងបន្តអនុវត្តខុសច្បាប់នៅក្នុងដំណើរការអាជីវកម្មរបស់ខ្លួន ដោយរំលោភលើលក្ខខណ្ឌទាំងឡាយនៃការធ្វើសម្បទាន រួមទាំងការកាប់ឈើក្នុងបរិមាណលើសពីបរិមាណកំណត់ ។ ការត្រួតពិនិត្យមើលដោយថ្នាក់ដឹកនាំកម្រិតខ្ពស់ គឺជាការចាំបាច់ និងកំពុងត្រូវបានយកចិត្តទុកដាក់ ។

ជាលក្ខណៈប្រពៃណី ព្រៃឈើគឺជាប្រភពដ៏សំខាន់នៃជីវភាពរស់នៅ សម្រាប់ប្រជាជនដែលរស់នៅតាមតំបន់ដាច់ស្រយាល ជាពិសេស នៅក្នុងតំបន់ឥសាន ផ្នែកខ្លះនៃភាគបស្ចិម និងតំបន់ព្រៃភ្នំនៃប្រទេស ។

២.៥៨ *ការការពារ អភិរក្ស និងការកែលម្អបរិស្ថាន* : ការការពារនិងអភិរក្សនូវ ប្រព័ន្ធអេកូឡូស៊ីដ៏ពិសេសដែលកម្ពុជាមាន ហើយការប្រើប្រាស់នូវធនធាននេះ ប្រកបដោយចីរភាពសម្រាប់ជាប្រយោជន៍ដល់ ប្រជាជនកម្ពុជាទាំងអស់ គឺជាទិសដៅចម្បងក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ។ វឌ្ឍនភាព កំពុងត្រូវបានធ្វើឱ្យកើតមានឡើងជាបន្ត

បន្ទាប់នៅក្នុងវិស័យនេះ ។ នៅក្នុងឆ្នាំ២០០៦-២០០៧ តំបន់អេកូទេសចរបីកន្លែងត្រូវបានបង្កើតឡើង ហើយពីរកន្លែងទៀតកំពុងត្រូវបានរៀបចំបង្កើតឡើង ។ ច្បាប់ស្តីពីតំបន់ការពារត្រូវបានដាក់ឱ្យប្រើប្រាស់នៅក្នុងឆ្នាំ ២០០៨ ដើម្បីផ្តល់អំណាចឱ្យក្រសួងបរិស្ថានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព លើប្រព័ន្ធតំបន់ការពាររបស់ជាតិ ។ សហគមន៍នេសាទនៅក្នុងតំបន់ដែលអាចប្រើប្រាស់បានច្រើនមុខនិងតំបន់បឹងទន្លេសាប និងសហគមន៍តំបន់ការពារត្រូវបានបង្កើតឡើងជាច្រើនថែមទៀត និងកំពុងរួមចំណែកក្នុងការកាត់បន្ថយការហូរច្រោះដីចូលក្នុងដែនទឹកធម្មជាតិ និងក្នុងការទប់ស្កាត់ការទន្ទ្រានយកដីខុសច្បាប់ និងការរិចរិលព្រៃឈើ ។ នៅឆ្នាំ២០០៦-២០០៧ ផ្ទៃដីដែលកាន់កាប់ដោយខុសច្បាប់នៅក្នុងតំបន់ការពារទំហំ ៣.៦០៦ហិកតាត្រូវបានរឹបអូសយកមកវិញ ជាបន្ថែមទៀត ។ រហូតមកទល់ឆ្នាំ២០០៧ សហគមន៍តំបន់ការពារចំនួន ៧៣ ត្រូវបានរៀបចំបង្កើតឡើង ។ ជាមួយគ្នានេះដែរ រហូតមកដល់ឆ្នាំ២០០៧ តំបន់ការពារធម្មជាតិចំនួន ១៨កន្លែង ត្រូវបានកំណត់ព្រំប្រទល់ ហើយការធ្វើផែនទីជាផ្លូវការសម្រាប់តំបន់ការពារទាំងនេះក៏ត្រូវបានរៀបចំឡើងដែរ ។ ទោះជាដូចនេះក្តី ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិនៅតែបន្តជួបប្រទះឧបសគ្គនានាដែលទាក់ទងនឹងក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌច្បាប់ ជាពិសេស ភាពទន់ខ្សោយនៃការសម្របសម្រួលក្នុងចំណោមស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ។ ការគ្រប់គ្រងកាកសំណល់រឹងនិងរាវរបស់រោងចក្រ កំពុងមានភាពប្រសើរឡើង ដោយរួមចំណែកដល់ការកាត់បន្ថយផលប៉ះពាល់បរិស្ថាន ផងដែរ ហើយត្រូវការនូវកិច្ចខិតខំប្រឹងប្រែងជាបន្ថែមទៀត នៅពេលដែលការអភិវឌ្ឍផ្នែកឧស្សាហកម្មចេះតែមានជាបន្ត ។

២.៥៩ បញ្ហាប្រឈមដ៏ធំចំពោះមុខ គឺសមត្ថភាពនិងភាពចាំបាច់របស់ប្រទេស ក្នុងការសម្របទៅនឹងការថយចុះក្នុងការប្រែប្រួលនៃកម្រិតទឹកនៅក្នុងទន្លេសំខាន់ៗ រវាងរដូវវស្សានិងរដូវប្រាំង ក៏ដូចជា ភាពអាចកើនឡើងនៃការធ្វើឱ្យកខ្វក់ទឹក ដែលអាចបណ្តាលមកពីការគ្រប់គ្រងលំហូរទឹក ដោយប្រទេសនៅលើដើមខ្សែទឹកដែលបានតម្លើងរបាំងជាបន្តបន្ទាប់ សម្រាប់បង្កើតថាមពលអគ្គិសនី និងប្រើប្រាស់ទឹកសម្រាប់ប្រព័ន្ធស្រោចស្រព និង ដែលបង្ហូរកាកសំណល់ឧស្សាហកម្មទៅក្នុងប្រព័ន្ធទន្លេ ។ ការប្រែប្រួលទាំងនេះ នឹងផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ីទាំងស្រុងនៅកម្ពុជា ហើយនឹងមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ លើដំណាំនិងការនេសាទ ។ ការឃ្លាំមើលនិងការពិភាក្សាជាប្រចាំ នឹងត្រូវបានធ្វើឡើង តាមរយៈគណៈកម្មការទន្លេមេគង្គ ។

### ចតុកោណទី២: ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

២.៦០ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ផ្តល់នូវប្រភពដ៏សម្រាប់វឌ្ឍនភាពសេដ្ឋកិច្ច ។ ចតុកោណសម្រាប់កំណើននៃយុទ្ធសាស្ត្រចតុកោណនេះ ដោះស្រាយ *(១) ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (ផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស) (២) ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ (៣) ការអភិវឌ្ឍវិស័យថាមពល*

*(រួមមាន ប្រេងកាតនិងឧស្ម័ន និងបណ្តាញអគ្គីសនី)* និង *(៣) ការអភិវឌ្ឍបច្ចេកវិទ្យាពតិមានគមនាគមន៍* ។ ហេដ្ឋារចនាសម្ព័ន្ធមិនត្រឹមតែមានឥទ្ធិពលទៅរចនាសម្ព័ន្ធកំណើនប៉ុណ្ណោះទេ ប៉ុន្តែកង្វះហេដ្ឋារចនាសម្ព័ន្ធរាំងដល់ការទទួលបាននូវសេវាសុខាភិបាល និងអប់រំ សេរីភាវូបនីយកម្មពាណិជ្ជកម្ម និងភាពងាយស្រួលចូលដល់ទីផ្សារ ។ អាទិភាពនៅក្នុងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសំខាន់ៗ រួមមាន ការកែលម្អ ការជួសជុល និងការថែទាំបណ្តាញផ្លូវថ្នល់ពីថ្នាក់ជាតិរហូតដល់ជនបទ ការកែលម្អការផ្គត់ផ្គង់ទឹកនិងអនាម័យ ការបង្កើតវិស័យថាមពលដ៏មានប្រសិទ្ធភាព អគ្គិសនីភាវូបនីយកម្មនៅជនបទ ការធ្វើឱ្យមានបណ្តាញទូរគមនាគមន៍ល្អជាងមុន ។ល។ ការធ្វើឱ្យប្រសើរឡើងសំខាន់ៗដែលសម្រេចបានក្នុងវិស័យទាំងនេះនៅក្នុងដំណាក់កាល *ផយអជ* កន្លងមកបានជួយឱ្យសម្រេចបាននូវការធ្វើឱ្យប្រសើរឡើងជាវិជ្ជមានក្នុង វិស័យអប់រំ សុខាភិបាល ទេសចរណ៍ ពាណិជ្ជកម្ម អភិវឌ្ឍន៍ជនបទ ក៏ដូចជាការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងពិភពលោក ។

២.៦១ **<u>ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍</u> :** ប្រទេសកម្ពុជាមានផ្លូវជាតិនិងផ្លូវខេត្តប្រវែង ១១.៤៩៤ គីឡូម៉ែត្រ រួមមាន ផ្លូវជាតិមួយលេខ មានប្រវែង ២.០៩៧គីឡូម៉ែត្រ ផ្លូវជាតិពីរលេខមានប្រវែង ២.៧០៥ គីឡូម៉ែត្រ និងផ្លូវខេត្ត[១] ប្រវែង ៦.៦៩២គីឡូម៉ែត្រ ។ ផ្លូវជាតិមួយលេខភាគច្រើន ត្រូវបានកំណត់ថា ជាផ្លូវអាស៊ី/អាស៊ាន ឬមហាអនុតំបន់ទន្លេមេគង្គ សម្រាប់សម្រួលដល់ការដឹកជញ្ជូនអន្តរជាតិ រួមទាំង ពាណិជ្ជកម្មអន្តរជាតិ និងទេសចរណ៍ឆ្លងដែន ។ បណ្តាញផ្លូវលំ តភ្ជាប់ទៅនិងផ្លូវជាតិសំខាន់ៗ ហើយពង្រឹងការតភ្ជាប់រវាងតំបន់សេដ្ឋកិច្ចមួយ ទៅតំបន់សេដ្ឋកិច្ចមួយទៀត ដូចជា រវាងតំបន់ទេសចរណ៍ទៅនិងតំបន់កសិឧស្សាហកម្មជាដើម ។

២.៦២ ការអភិវឌ្ឍន៍សំខាន់ៗក្នុងហេដ្ឋារចនាសម្ព័ន្ធ (រួមមាន ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការផ្គត់ផ្គង់ទឹកនៅតំបន់ទីក្រុង) នៅក្នុងរយៈពេលពីរឆ្នាំកន្លះ កន្លងមកនេះ រួមមាន :

ផែនការមេអភិវឌ្ឍន៍បណ្តាញផ្លូវ ឆ្នាំ២០០៦-២០១០ ត្រូវបានរៀបចំឡើង ។

គណៈកម្មាធិការអន្តរក្រសួងមួយត្រូវបានបង្កើតឡើង ដើម្បីសម្របសម្រួលការងារជួសជុល និងថែទាំផ្លូវថ្នល់ ។

ការដឹកជញ្ជូនតាមផ្លូវថ្នល់បន្តនៅតែមានឧត្តមភាពក្នុងផ្នែកដឹកជញ្ជូន ។ ប្រវែងសរុបនៃផ្លូវជាតិនិងផ្លូវខេត្តដែលបានសាងសង់ គឺ ២.៥១២គីឡូម៉ែត្រ នៅឆ្នាំ២០០៧ កើនឡើងពី ២.១០០គីឡូម៉ែត្រ ក្នុងឆ្នាំ ២០០៥ ។ ភាគច្រើននៃផ្លូវខេត្ត ត្រូវបានក្រាលគ្រួសក្រហម ហើយមានតែផ្លូវប្រវែង ១១០គីឡូម៉ែត្រ

[១] ប្រភព: ក្រុមការងារបច្ចេកទេស : ហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មក្នុងតំបន់ ': ខែមករា ឆ្នាំ ២០០៨

[៥] ប្រព័ន្ធព័ត៌មានសុខាភិបាល ឆ្នាំ២០០៧

ប៉ុណ្ណោះ ដែលត្រូវបានក្រាលកៅស៊ូ ។ ការស្តារ និងការកែលម្អផ្លូវទាំងអស់ (និងស្ពាននានា) បានកើនឡើងក្នុងឆ្នាំ២០០៦-២០០៧ ។

ច្បាប់ចរាចរជើងគោក ត្រូវបានដាក់ឱ្យអនុវត្តរួចហើយ ។ ការរៀបចំប្រព័ន្ធច្បាប់គ្រប់គ្រាន់និងប្រកបដោយប្រសិទ្ធភាព សម្រាប់វិស័យដឹកជញ្ជូន ហើយការអនុវត្តច្បាប់នៅតែបន្តជាការងារអាទិភាពមួយ ។

វិធានការសុវត្ថិភាពចរាចរត្រូវបានពង្រឹងតាមរយៈ (ក) ការធ្វើឱ្យកិច្ចដំណើរការរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរផ្លូវគោក (ខ) ការផលិតកម្មវិធីទូរទស្សន៍អំពីសុវត្ថិភាពចរាចរផ្លូវគោក និង (គ) ការបោះពុម្ពផ្សាយឯកសារដែលទាក់ទងនឹងសុវត្ថិភាពចរាចរផ្លូវគោក ។

ដើម្បីឆ្លើយតបទៅនឹងកំណើនយ៉ាងលឿននៃយានយន្ត (រថយន្ត និងទោចក្រយានយន្ត) ពី ៤៤៦.៩៥០ គ្រឿង ក្នុងឆ្នាំ២០០៣ ដល់ ៨៦៨.៨០០គ្រឿង ក្នុងឆ្នាំ២០០៧ ការចុះបញ្ជីយានយន្ត និងការផ្តល់ប័ណ្ណបើកបរ ត្រូវបានធ្វើប្រតិភូកម្មទៅឱ្យមន្ទីរសាធារណៈការនិងដឹកជញ្ជូនខេត្ត-ក្រុង ។

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មការមួយ ដើម្បីត្រួតពិនិត្យយានយន្តដែលដឹកជញ្ជូនទំនិញ និងអ្នកដំណើរលើសពីកម្រិតដែលបានកំណត់ ។

ការដឹកជញ្ជូនអ្នកធ្វើដំណើរនិងទំនិញតាមផ្លូវដែក ស្រូបយកសមាមាត្រតែមួយផ្នែកតូចប៉ុណ្ណោះ ប៉ុន្តែផែនការជាច្រើនកំពុងត្រូវបានរៀបចំឡើង ដើម្បីធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធនេះមានសារៈប្រយោជន៍ជាងមុន និងដើម្បីសម្របទៅនឹងបរិបទនៃបណ្តាញផ្លូវដែកក្នុងតំបន់ដែលបានស្នើឡើងផងដែរ ។ ការស្តារនិងការតភ្ជាប់ឡើងវិញ នូវកំណាត់ផ្លូវដែកពី ស៊ីសូផុន ទៅ ប៉ោយប៉ែត គឺជាសមិទ្ធផលដ៏សំខាន់មួយនៅក្នុងការងារស្តារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ។ ផែនការនិងការប៉ាន់ស្មានតម្លៃ ត្រូវបានរៀបចំឡើងសម្រាប់ការស្តារទាំងស្រុងនូវផ្លូវដែកទាំងពីរដែលតភ្ជាប់ទៅរាជធានីភ្នំពេញ ។

ការដឹកជញ្ជូនតាមផ្លូវទឹកក្នុងស្រុកមានកម្រិតមិនខ្ពស់ឡើយ ។ ការបូមដីពីផ្លូវទឹកសំខាន់ៗ ជាពិសេស ទន្លេមេគង្គនិងទន្លេសាប បាននិងកំពុងបន្តសម្រួលដល់ការដឹកជញ្ជូនតាមទន្លេ ហើយនៅតែជាអាទិភាពបន្ទាន់ ។ អត្រាទំនិញដឹកជញ្ជូន តាមផ្លូវទឹកដែលកាន់តែខ្ពស់ជាងមុន និងកង្វះខាតប្រសិទ្ធភាពការងារ គឺជាបញ្ហាប្រឈមដ៏ធំក្នុងការដឹកជញ្ជូនតាមផ្លូវទឹក ។

ការអភិវឌ្ឍកំពង់ផែអន្តរជាតិទាំងពីរ (កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងកំពង់ផែស្វយ័តក្រុងភ្នំពេញ ទទួលបានលទ្ធផលល្អប្រសើរ ។ បរិមាណទំនិញឆ្លងកាត់សរុបនៅកំពង់ផែក្រុងព្រះសីហនុ មាន ១,៨២ លានតោន ក្នុងឆ្នាំ២០០៧ ដោយបានកើនឡើង ២១ភាគរយ ធៀបនឹងឆ្នាំ២០០៤ ។ ការលើកដាក់ទំនិញឆ្លងកាត់ ត្រូវបានសម្រួលឱ្យបានឆាប់រហ័ស ហើយការបំពេញបែបបទ ចូលចត ផ្ទេរផ្ទុកទំនិញ ត្រូវបានកែលម្អ ។

ការកែលម្អហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានអន្តរជាតិទាំងបី បានជំរុញបន្ថែមទៀតនូវការអភិវឌ្ឍវិស័យទេសចរណ៍ ដែលរួមចំណែកដល់វឌ្ឍនភាពសេដ្ឋកិច្ច-សង្គមកិច្ច តាមរយៈឥទ្ធិពលពហុគុណរបស់វិស័យនេះ ។ អាកាសយានដ្ឋានក្នុងស្រុកទាំង ៨ ត្រូវបានជួសជុលនិងថែរក្សា ទៅតាមផែនការប្រចាំឆ្នាំ ជាពិសេស ផ្តែកសំខាន់ៗដូចជា ផ្លូវរត់ឡើងនិងចុះចត ចំណតយន្តហោះ ការកំណត់ព្រំដែនរបស់អាកាសយានដ្ឋាន ហើយអាកាសយានដ្ឋានពីរក្នុងចំណោមនេះ ត្រូវបានផ្តល់អាទិភាពក្នុងការស្តារឡើងវិញទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធរបស់វា ។ ចំនួនអ្នកដំណើរតាមជើងហោះហើរអន្តរជាតិ បានកើនឡើង ២៨ភាគរយ ក្នុងឆ្នាំ២០០៧ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៦ ។ ការអភិវឌ្ឍធនធានមនុស្សក្នុងជំនាញអាកាសចរណ៍ស៊ីវិល ដែលនៅតែជាអាទិភាពមួយសម្រាប់ការធ្វើឱ្យប្រសើរឡើងក្នុងវិស័យនេះក្នុងពេលខាងមុខ ។

ស្ថានីយ៍ចម្រោះទឹកកខ្វក់មួយ នៅក្រុងព្រះសីហនុ ត្រូវបានសាងសង់រួចរាល់ ហើយការសាងសង់ស្ថានីយ៍មួយទៀតកំពុងដំណើរការនៅក្រុងសៀមរាប ។

*ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន* : កិច្ចប្រឹងប្រែង ត្រូវបានធ្វើឡើងក្នុងការពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាត ពីប្រព័ន្ធផ្គត់ផ្គង់ដែលមានគុណភាពតាមស្តង់ដា នៅតាមតំបន់ទីប្រជុំជនខេត្ត-ក្រុងចំនួន ៩៤ ។ នៅរាជធានីភ្នំពេញ ការផលិតទឹកស្អាតបានកើនឡើងពី ៦៣,២៦លានម៉ែត្រគូប ក្នុងឆ្នាំ២០០៦ ដល់ ៧៩,៧០លាន ម៉ែត្រគូប ក្នុងឆ្នាំ២០០៧ ។ នៅក្នុងឆ្នាំ២០០៨ ប្រជាជនរស់នៅរាជធានីភ្នំពេញ ចំនួន ៩០ភាគរយ ទទួលបានទឹកស្អាតប្រើប្រាស់ ២៤ម៉ោង លើ ២៤ម៉ោង ។ ប្រជាជនក្រីក្រចំនួន ១៦.០០០ គ្រួសារ ត្រូវបានទទួលគោលនយោបាយឧបត្ថម្ភលើតម្លៃសិទ្ធិជាវទឹកប្រើប្រាស់ តាមស្ថានភាពជាក់ស្តែងនៃកម្រិតជីវភាពរស់នៅ ។

នៅឆ្នាំ២០០៧ ប្រជាជនរស់នៅតាមទីប្រជុំជនខេត្ត-ក្រុងទូទាំងប្រទេសប្រមាណ ៤០ភាគរយ ទទួលបានទឹកស្អាតប្រើប្រាស់ ។ សមត្ថភាពផ្គត់ផ្គង់ទឹកស្អាតរបស់រដ្ឋាករទឹកខេត្តបាត់ដំបង បានកើនដល់ ១១.៥០០ ម៉ែត្រគូប ក្នុងមួយថ្ងៃ ចំណែកឯសមត្ថភាពផ្គត់ផ្គង់ទឹករបស់រដ្ឋាករទឹក ក្រុងព្រះសីហនុ និងខេត្តសៀមរាប បានកើនឡើងដល់ ៨.០០០ម៉ែត្រគូប ក្នុងមួយថ្ងៃ ។ ទន្ទឹមនឹងនោះ សមត្ថភាពផលិតរបស់រដ្ឋាករទឹកខេត្តពោធិសាត់ កំពង់ធំ កំពង់ចាម កំពត និងស្វាយរៀង ត្រូវបានបង្កើន ពី ២.៥០០ ទៅ ៣.៥០០ម៉ែត្រគូប ក្នុងមួយថ្ងៃ ។ ផលិតកម្មទឹកស្អាតសរុប របស់ទីប្រជុំជនខេត្ត-ក្រុងខាងលើ បានកើនឡើងពី ៩.៧១៧.២៨៤ ម៉ែត្រគូប ក្នុងឆ្នាំ២០០៦ ដល់១០.៥៩៦.៧៤៦ម៉ែត្រគូប ក្នុងឆ្នាំ២០០៧ ។

២.៦៣ **ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ** : កិច្ចប្រឹងប្រែងរួម និងការវិនិយោគក្នុងវិស័យនេះក្នុងឆ្នាំ ២០០៦ និង ២០០៧ បាននាំមកនូវសមិទ្ធផលគួរឱ្យកត់សម្គាល់ ដូចខាងក្រោមនេះ :

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧ និងព្រឹទ្ធសភាថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៧ ។

ភាគច្រើននៃប្រព័ន្ធស្រោចស្រពនិងបង្ហូរដែលមានស្រាប់ ជាពិសេស ក្នុងតំបន់ដែលមានភាពក្រីក្រច្រើន និងតំបន់តាមព្រំដែន ត្រូវបានស្តារនិងកសាងឡើងវិញ ដោយមានលទ្ធភាពភាពផ្គត់ផ្គង់ទឹកសម្រាប់ផ្ទៃដីទំហំ ១៤១.២៧៧ហិកតា (១១២.២១០ហិកតា សម្រាប់ដំណាំស្រូវរដូវវស្សា និង ២៩.០៦៧ហិកតា សម្រាប់រដូវប្រាំង) ។

សមត្ថភាពអាងស្តុកទឹក ត្រូវបានពង្រីក ហើយបច្ចេកវិជ្ជាទាញយកទឹក ត្រូវបានជំរុញ ។

ការប្រើប្រាស់ទឹកក្រោមដីតាមរយៈអណ្តូងខួងសម្រាប់ការស្រោចស្រព កំពុងកើនឡើង ។

វិធានការការកាត់បន្ថយនិងការគ្រប់គ្រង ភាពរងគ្រោះដោយទឹកជំនន់និងភាពរាំងស្ងួត ត្រូវបានបង្កើតឡើង និងអនុវត្ត ។

សហគមន៍កសិករប្រើប្រាស់ទឹក ដោយមានកំណើនសមាជិកនិងការចូលរួមរបស់ស្ត្រី ត្រូវបានពង្រឹងនិងពង្រីក ។

ឧបករណ៍ឧតុនិយមចំនួន ២១ និងប៉ុស្តិ៍តម្រងទឹកភ្លៀង ១២កន្លែង ត្រូវបានតម្លើង និងកែលម្អ ដើម្បីអាចផ្តល់ជូនដល់ប្រជាពលរដ្ឋនូវការព្យាករណ៍ជលសាស្ត្រនិងឧតុនិយមប្រកបដោយគុណភាពខ្ពស់ ។

ស្ថានីយជលសាស្ត្រតាមដងទន្លេ និងស្ទឹងសំខាន់ៗចំនួន ១២កន្លែង ត្រូវបានជួសជុលនិងតម្លើង ។ ក្តារវាស់កម្ពស់ទឹកចំនួន ១៣កន្លែង ត្រូវបានតម្លើងឬជួសជុល ហើយឧបករណ៍វាស់ចរាចរទឹកចំនួន ៣កន្លែង ត្រូវបានតម្លើង នៅខេត្តបាត់ដំបង ពោធិសាត់ និងកំពង់ឆ្នាំង ។

២.៦៤ **<u>ការអភិវឌ្ឍវិស័យថាមពល និងបណ្តាញអគ្គិសនី</u>** : រាជរដ្ឋាភិបាលកម្ពុជា ផ្តល់អាទិភាពខ្ពស់លើការពង្រីកនិងការថែទាំយ៉ាងត្រឹមត្រូវ នូវហេដ្ឋារចនាសម្ព័ន្ធទូទាំងប្រទេស ដោយធ្វើការលើកទឹកចិត្តនិងទាក់ទាញការវិនិយោគ និងការចូលរួមរបស់ផ្នែកឯកជន នៅគ្រប់ទិដ្ឋភាពទាំងអស់ ដូចជា ការផលិត ការបញ្ជូននិងការចែកចាយថាមពលអគ្គិសនី ដើម្បីធ្វើឱ្យថ្លៃដើមនៃការផលិតថាមពលអគ្គិសនីមានតម្លៃទាបជាងថ្លៃ ដែលមានក្នុងពេលបច្ចុប្បន្ននេះ ។ ការអភិវឌ្ឍសំខាន់ៗក្នុងវិស័យនេះ ក្នុងរយៈពេលពីរឆ្នាំកន្លះកន្លងមកនេះ រួមមានដូចខាងក្រោម :

ផែនការយុទ្ធសាស្ត្រវិស័យថាមពល តម្រង់ទិសសកម្មភាពក្នុងវិស័យនេះ ។ ផែនការមេអគ្គិសនីកម្មជនបទ ត្រូវបានដាក់ឱ្យអនុវត្ត ។ បច្ចុប្បន្ននេះ ប្រហែល ២៥ភាគរយនៃគ្រួសារទាំងអស់ ទទួលបានអគ្គិសនីប្រើប្រាស់ (ពីគ្រប់ប្រភពទាំងអស់) ។

– កិច្ចប្រឹងប្រែងជាបន្ត ក្នុងការបន្តរៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យមនៃ *ផយអជ* សម្រាប់វិស័យថាមពល និងអគ្គិសនី បានកែលម្អស្ថានភាពអគ្គិសនីកម្មក្នុងប្រទេស ជាពិសេស នៅតំបន់ជនបទ ដែលនៅទីនោះសេវាឯកជនទ្រង់ទ្រាយតូច ធ្វើប្រតិបត្តិការ ទៅតាមច្បាប់អគ្គិសនី ។ ការផលិតថាមពលអគ្គិសនី

បានកើនឡើង ពី ៨៩៤,៥២គីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០០៥ ទៅ ១.៥០៥គីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០០៧ ។ អគ្គិសនីដែលបាននាំចូលពីប្រទេសថៃនិងវៀតណាម សម្រាប់ការប្រើប្រាស់ ជាពិសេស នៅតាមតំបន់ព្រំដែន ក៏បានកើនឡើងដែរ (នាំចូលពីថៃ កើនឡើងពី ៥៦,៨៣គីកាវ៉ាត់ម៉ោងក្នុងឆ្នាំ២០០៥ ដល់ ៩០,៣០គីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០០៧ និងពីវៀតណាម បានកើនឡើង ២៥,៤០គីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ ២០០៥ ដល់ ៧២,៥០គីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០០៧ ។

ថ្លៃអគ្គិសនីខ្ពស់ គឺជាការកង្វល់ដែលមានបន្ត ដោយសារវាបន្ថយភាពប្រកួតប្រជែងនៃផលិតផល របស់កម្ពុជា ។ សមត្ថភាពផលិតក្នុងស្រុកច្រើនជាងមុន ដោយការអភិវឌ្ឍប្រភពធនធានវារីអគ្គិសនី គួបផ្សំជាមួយនឹងរោងចក្រអគ្គិសនី ដើរដោយធ្យូងថ្ម និងប្រេងធ្ងន់ និង/ឬ ឧស្ម័ន នឹងត្រូវបានគ្រោងរៀបចំធ្វើ និងតម្លើង ។ ការនាំចូលអគ្គិសនីដោយមានកិច្ចព្រមព្រៀងច្បាស់លាស់ពីប្រទេសថៃ ឡាវ និងវៀតណាម ដែលជាផ្នែកមួយនៃពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងតំបន់ នឹងត្រូវពង្រីក មិនត្រឹមតែ សម្រាប់ការប្រើប្រាស់នៅតាមតំបន់ព្រំដែនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង សម្រាប់ផ្គត់ផ្គង់ដល់បណ្តាញអគ្គិសនីជាតិ នាពេលអនាគតទៀតផង ។

២.៦៥ *ប្រេងកាតនិងឧស្ម័ន* ក្នុងដែនសមុទ្រ គឺជាទ្រព្យសម្បត្តិរួមរបស់ប្រជាជនកម្ពុជាទាំងអស់ សម្រាប់ពេលបច្ចុប្បន្ននេះនិងក្នុងពេលអនាគត ជាមួយនឹងការរុករកប្រេងក្នុងដែនសមុទ្រលើកទី១ នៅឆ្នាំ២០០៤ អណ្តូងប្រេងចំនួន ២៧ កំពុងត្រូវបានខួង នៅតំបន់ដែលរំពឹងថានឹងមានប្រេងឆៅ ដើម្បីធ្វើការវាយតម្លៃដែលមានភាពប្រាកដនិយមជាបន្ថែមទៀត ចំពោះបរិមាណប្រេងដែលមាននៅក្រោមបាតសមុទ្រ ។ អាជ្ញាធរប្រេងកាតជាតិកម្ពុជា បានចុះហត្ថលេខាជាមួយក្រុមហ៊ុនមកពីប្រទេសផ្សេងៗគ្នាជាច្រើន ដើម្បីរុករកប្រេងនិងឧស្ម័ន នៅក្នុងតំបន់ចំនួន ៦ ផ្សេងទៀត ក្នុងដែនទឹកកម្ពុជា ក្នុងឈូងសមុទ្រថៃ ។ ការងាររុករកកំពុងបន្តទៅមុខ ទៅតាមការគ្រោងទុកក្នុងកិច្ចសន្យា ។ នៅពេលដែលបរិមាណប្រេងដែលមាននៅក្រោមបាតសមុទ្រ ត្រូវបានធ្វើការប៉ាន់ប្រមាណ នោះការងារជាបន្តទៀតនិងការវិនិយោគ នឹងត្រូវធ្វើឡើង ដើម្បីអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធមុននឹងការបូមយកប្រេងអាចចាប់ផ្តើមនៅក្នុងឆ្នាំ២០១១ តាមការរំពឹងទុកនាបច្ចុប្បន្ននេះ។ ដូចដែលបានលើកឡើងរួចហើយ (ប្រអប់ ២.៤) ការធ្វើផែនការដោយប្រុងប្រយ័ត្នជាមុន គួរតែចាប់ផ្តើមបច្ចុប្បន្ននេះ ដើម្បីរក្សានិងប្រើប្រាស់ដោយប្រុងប្រយ័ត្ននូវប្រភពថាមពលនេះនិងចំណូលដែលអាចបានពីប្រភពនេះ តាមរបៀបមួយល្អប្រសើរបំផុតសំដៅផ្តល់ផលប្រយោជន៍ដល់កម្ពុជានិងប្រជាពលរដ្ឋកម្ពុជា ក្នុងរយៈពេលខ្លីនិងវែង ។ អាទិភាពសម្រាប់ពេលបច្ចុប្បន្ននេះ រួមមាន :

រកចំណូលឱ្យបានជាអតិបរមាដល់រដ្ឋ តាមរយៈចំណូលច្រើនសណ្ឋាន ដូចជា កំរៃអាជីវកម្ម និងការចែករំលែកប្រាក់ចំណេញ និងពន្ធ ជាដើម ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើការពិចារណាជាមុនរួចហើយ អំពីជម្រើសដែលអាចមាន ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា កំពុងពិនិត្យសិក្សាពីការចូលរួមនៅក្នុង *ការផ្តួចផ្តើមគំនិតនៃតម្លាភាពក្នុងឧស្សាហកម្មទាញយកផល* ដែលជាមូលដ្ឋានមួយសម្រាប់អភិបាលកិច្ចល្អនៅក្នុងការប្រើប្រាស់ធនធានទាំងនេះ ។

បង្កើតយន្តការគតិយុត្តិនិងអង្គភាពនានា ដើម្បីផ្ដល់ការណែនាំដល់វិស័យនេះ និងតាមដានត្រួតពិនិត្យកិច្ចប្រតិបត្តិការ ដោយធានាឱ្យមានការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងផ្នែកបញ្ញត្តិច្បាប់ តម្លាភាព និងការញែកចេញពីគ្នាយ៉ាងច្បាស់លាស់នូវទិដ្ឋភាព ប្រតិបត្តិការ បទបញ្ញត្តិច្បាប់ និងគោលនយោបាយ ។

ពិចារណានិងរៀបចំផែនការសម្រាប់ ការប្រើប្រាស់ឧស្ម័នដ៏ច្រើនដែលពាក់ព័ន្ធនឹងប្រេង បើមិនដូច្នោះទេ ឧស្ម័នទាំងនោះ នឹងក្លាយជាកាកសំណល់ ដែលឆេះចោលនៅក្នុងខ្យល់ ។

បង្កើតអង្គភាពផលិតកម្មសម្រាប់កែច្នៃនិងប្រើប្រាស់ធនធាន សម្រាប់ការបង្កើតតម្លៃបន្ថែម និងសម្រាប់ការប្រើប្រាស់ ជាលក្ខណៈឧស្សាហកម្ម រួមមាន ការផលិតជីផង ។

រៀបចំនិងត្រៀមជាស្រេចនូវបញ្ជីគម្រោងអាទិភាពនិងការសិក្សាលទ្ធភាព សម្រាប់ការប្រើប្រាស់ធនធានហិរញ្ញវត្ថុបន្ថែម ដូចជា សម្រាប់ការតម្លើងសមត្ថភាពផលិតខ្ពស់ជាងមុននៃរោងចក្រវារីអគ្គិសនី ការតម្លើងខ្សែអគ្គិសនីសម្រាប់បណ្ដាញអគ្គិសនីជាតិ ការធ្វើអគ្គិសនីភាវូនីយកម្មជនបទ ការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ រួមទាំង ការផ្គត់ផ្គង់ទឹកនិងអនាម័យ កំណែទម្រង់រដ្ឋបាលសាធារណៈ និងការកែលម្អកម្រិតបៀវត្សរ៍[១] ។ល។

២.៦៦ **ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍** រួមមាន ទូរស័ព្ទនិងទូរគមនាគមន៍ ព្រមទាំងប្រព័ន្ធឃោសនា ។ ជាមួយនឹងការកើនឡើងនៃការប្រកួតប្រជែង ហើយភាគច្រើននាំមុខដោយប្រតិបត្តិករឯកជននៅប្រទេសកម្ពុជា ការប្រើប្រាស់ទូរស័ព្ទដៃមានការកើនឡើងយ៉ាងខ្លាំង ។ ភាពជឿនលឿនសំខាន់ៗ និងបញ្ហាប្រឈមមួយចំនួន ដែលនឹងអាចមាននៅក្នុងពេលខាងមុខ មានដូចខាងក្រោម :

អ្នកវិនិយោគឯកជនកាន់តែច្រើនឡើង បានចូលរួមក្នុងវិស័យនេះ ហើយបានរួមចំណែកយ៉ាងច្រើន ក្នុងការអភិវឌ្ឍវិស័យនេះ ។

គិតត្រឹមខែមេសា ឆ្នាំ២០០៨ ចំនួនទូរស័ព្ទដែលបានប្រើប្រាស់ មានចំនួន ២,៩៣២លានគ្រឿង (ក្នុងនោះ ២,៨៩៤លានគ្រឿងជាទូរស័ព្ទចល័ត ឬ៩៨,៧ភាគរយ និង ៣៨.១២៨គ្រឿង ជាទូរស័ព្ទខ្សែ) ឬប្រមាណជាង ២០ភាគរយនៃប្រជាជនសរុប គឺស្មើនឹងពីរដងបើប្រៀបធៀបនឹងឆ្នាំ២០០៦ ដែលមានតែ ១,១៧៩លានគ្រឿងប៉ុណ្ណោះ ហើយស្មើនឹងជាងបីដង បើប្រៀបធៀបនឹងឆ្នាំ២០០៥ ដែលមានតែ ០,៨៨២លានគ្រឿងប៉ុណ្ណោះ ។ ការរីកដុះដាលយ៉ាងឆាប់នេះ បានកើតឡើង ជាពិសេស នៅតំបន់ជនបទ ដោយមានការទទួលបានការប្រើប្រាស់អ៊ីម៉ែល និង អ៊ិនធឺណែត នៅក្នុងគ្រប់ ២៤ ខេត្ត-ក្រុង ។

ការប្រើប្រាស់បច្ចេកវិជ្ជាកុំព្យូទ័រនិងអ៊ិនធឺណែត ក៏កំពុងរីករាលដាលយ៉ាងលឿន ព្រមទាំងមានការកើនឡើងអ្នកជំនាញនៅក្នុងចំណោមប្រជាជនក្មេងៗ ។

[១] សូមមើលប្រអប់ ២.៤ ។

នៅពេលដែលការជឿនលឿននិងការប្រែប្រួលផ្នែកបច្ចេកវិជ្ជា កើតមានឡើងយ៉ាងលឿន ក្នុងផ្នែកព័ត៌មាន និងបច្ចេកវិជ្ជា នោះបទបញ្ញត្តិ ត្រូវវិវត្តឱ្យបានលឿន ដើម្បីធានាផលប្រយោជន៍អតិបរមាដល់គ្រប់គ្នាទាំងអស់ និងដើម្បីបញ្ឈប់ការលិចធ្លាយនៃប្រាក់ចំណូល។ ប្រការនេះ នឹងកែលម្អ និងបង្កើនគុណភាពបណ្តាញសេវាកម្ម ជាបន្ថែមទៀតសម្រាប់ការគ្រប់ដណ្តប់នៅទូទាំងប្រទេស ។

រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តអនុវត្ត *ប្រព័ន្ធព័ត៌មានរដ្ឋបាលរដ្ឋាភិបាល* និង រដ្ឋាភិបាល-អេឡិចត្រូនិក ។ ចំពោះការគ្របដណ្តប់ ប្រសិទ្ធភាព និងគុណភាព នៃប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋាភិបាល (ដូចជា វិទ្យុ ទូរទស្សន៍ និងទីភ្នាក់ងារសារព័ត៌មាន) ត្រូវបានពង្រីកនិងកែលម្អឱ្យកាន់តែប្រសើរឡើង ។ ប្រហែល ៧៥ភាគរយនៃប្រជាពលរដ្ឋកម្ពុជា អាចទទួលបាន ព័ត៌មាន ការអប់រំ និងការកំសាន្ត តាមរយៈ ប្រព័ន្ធផ្សព្វផ្សាយដែលមានស្រាប់ ទាំងរបស់រដ្ឋ និងរបស់ឯកជន ដែលអាចជួយលើកកម្ពស់អត្តសញ្ញាណជាតិ និងកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា ។

### ចតុកោណទី ៣: ការអភិវឌ្ឍវិស័យឯកជននិងការងារ

២.៦៧ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់និងឯកភាពលើចំណុចមួយដ៏សំខាន់ដែលថា ផ្នែកឯកជនជាកម្លាំងដ៏សំខាន់សម្រាប់ការវិនិយោគនិងកំណើនក្នុងប្រទេស ។ តួនាទីរបស់រាជរដ្ឋាភិបាល គឺជាអ្នកជំរុញ អ្នកលើកទឹកចិត្ត អ្នកជួយបង្កលក្ខណៈ អ្នកជួយសម្របសម្រួល និងជានិយ័តករ ។ កម្រិតដ៏ធំនៃការវិនិយោគ គឺជាតម្រូវការជាចាំបាច់ក្នុងពីរបីឆ្នាំខាងមុខ ដើម្បីថែរក្សា និងបង្កើនល្បឿនសន្ទុះ នៃកំណើនសេដ្ឋកិច្ចដែលត្រូវផ្អែកលើមូលដ្ឋានច្រើន ។ ផ្នែកឯកជនដែលមានកំណើនដ៏រឹងមាំ បំពេញបន្ថែមវិនិយោគសាធារណៈក្នុងវិស័យសង្គមកិច្ច ស្រូបយកអ្នកចូលក្នុងកំលាំងពលកម្មដែលចេះតែកើនឡើង និងបង្កើតជំនាញផ្សេងៗ ជាច្រើន ។ មុំទាំង៤ នៃចតុកោណនេះគឺ *(១) ការពង្រឹងវិស័យឯកជននិងការទាក់ទាញការវិនិយោគ (រួមមាន វិស័យកាត់ដេរ សម្លៀកបំពាក់ និងទេសចរណ៍) (២) ការបង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរជូនដល់កម្មករ និងនិយោជិក (៣) ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និង (៤) ការរៀបចំប្រព័ន្ធសុវត្ថិភាព សង្គមសម្រាប់មន្ត្រីបុគ្គលិកកម្មករ* ។ រាជរដ្ឋាភិបាលកម្ពុជា បានកាត់បន្ថយចំណាយក្នុងការធ្វើធុរៈកិច្ច បានពង្រីកលទ្ធភាពប្រើប្រាស់ទីផ្សារ បានកាត់បន្ថយចំណាយក្នុងការដឹកជញ្ជូនក្នុងស្រុក ហើយបានលើកកម្ពស់សុវត្ថិភាពតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ដែលជំរុញឱ្យមានផងដែរ នូវការបញ្ចូលគ្នារវាងសេដ្ឋកិច្ចទីប្រជុំជននិងសេដ្ឋកិច្ចជនបទ ។ វឌ្ឍនភាពដែលធ្វើឱ្យកើតមានឡើងមកទល់ពេលនេះ ដើម្បីធ្វើឱ្យសម្រេចបានអាទិភាពទាំងនេះ បានចូលរួមចំណែកយ៉ាងធំធេង ចំពោះការអភិវឌ្ឍថ្មីៗក្នុងវិស័យជាច្រើនផ្សេងទៀត និងចំពោះការពង្រឹងស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចរបស់ប្រជាជនជនបទ ជាពិសេស អ្នកក្រីក្រ ។

២.៦៨ **ការពង្រឹងវិស័យឯកជន និងការទាក់ទាញការវិនិយោគ** : ទិដ្ឋភាពសំខាន់ៗក្នុងការពង្រឹងវិស័យឯកជន និងការទាក់ទាញការវិនិយោគ ក្នុងរយៈពេលជាងពីរឆ្នាំកន្លងមក រួមមាន :

ការវិនិយោគក្នុងវិស័យឯកជន និងផ្នែកពាក់ព័ន្ធ កំពុងមានការកើនឡើងយ៉ាងឆាប់រហ័ស ដែលអាចពិនិត្យឃើញ នៅក្នុងសូចនាករម៉ាក្រូសេដ្ឋកិច្ចនិងរូបិយវត្ថុ[1] ដោយតាមរយៈនេះ បញ្ជាក់ថា ការជឿជាក់ និងភាពកក់ក្ដៅរបស់វិស័យឯកជនកំពុងមានការកើនឡើងនៅក្នុងប្រទេសកម្ពុជា ។ ប្រការនេះ គឺជាភស្តុតាងដ៏ធំនៃជោគជ័យរបស់គោលនយោបាយដែលជួយជំរុញឱ្យមានលទ្ធផលវិជ្ជមាន និងដែលមានលក្ខណៈជឿនលឿនរបស់រាជរដ្ឋាភិបាលកម្ពុជា (ការធានាឱ្យមានសន្តិភាព ស្ថេរភាពគោលនយោបាយ ច្បាប់និងសណ្ដាប់ធ្នាប់ ការគ្រប់គ្រងដោយច្បាប់ កំណើនម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយរូបិយវត្ថុ[2] និងការបង្កើតនូវបរិយាកាសអំណោយផលមួយ រួមទាំងការកាត់បន្ថយជាបណ្ដើរៗនូវអំពើពុករលួយ[3] ។

វេទិការដ្ឋាភិបាល-វិស័យឯកជន ដែលដឹកនាំដោយនាយករដ្ឋមន្ត្រី បានបន្តការជួបប្រជុំគ្នារៀងរាល់ប្រាំមួយខែម្ដង ។ វេទិកានេះ និងគណៈកម្មាធិការដឹកនាំ និងអនុគណៈកម្មាធិការជាច្រើនផ្សេងទៀត បានផ្ដល់នូវឱកាសដ៏សំខាន់មួយសម្រាប់កិច្ចសហប្រតិបត្តិការដ៏មានអត្ថន័យ និងដែលបង្កើតឱ្យមានការយល់គ្នារវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន ។ ក្រុមការងារបន្ថែមមួយទៀតសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងនិយោជក-និយោជិត ត្រូវបានបង្កើតឡើង ។ ដូចគ្នានេះដែរ ការគ្រប់គ្រងការធ្វើអាជីវកម្មធនធានរ៉ែ និងការពង្រឹងនិងលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម ត្រូវបានបន្ថែមជាការងារអាទិភាព សម្រាប់ការគិតគូរពិចារណា ។

ដើម្បីលើកកម្ពស់កំណើនដែលនាំមុខដោយការនាំចេញ និងដែលសម្រាប់គាំទ្រប្រជាជនក្រីក្រ តាមរយៈការធ្វើពិពិធកម្ម ការវិនិយោគរបស់វិស័យឯកជន ក្នុងផ្នែកអាទិភាពពិសេសៗមួយចំនួន ត្រូវបានលើកទឹកចិត្ត ជួយសម្រួល និងផ្ដល់ការគាំទ្រ ពីរដ្ឋាភិបាល ។ ឧស្សាហកម្មប្រើពលកម្មច្រើន និងវិស័យកែច្នៃសម្រាប់នាំចេញ និងកម្មន្តសាល ទេសចរណ៍និងសកម្មភាពពាក់ព័ន្ធទាំងឡាយ និងការអភិវឌ្ឍធនធានមនុស្ស មកទល់ពេលនេះ គឺជាចំណុចដៅដ៏សំខាន់នៃការវិនិយោគរបស់វិស័យឯកជន ។

ពាណិជ្ជកម្មបានក្លាយជាប្រភពដ៏សំខាន់ សម្រាប់កំណើនសេដ្ឋកិច្ច ដែលជាកត្តាសំខាន់មួយសម្រាប់ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងសម្រាប់ការកាត់បន្ថយភាពក្រីក្រ ។

ការនាំចេញសម្លៀកបំពាក់ បានមានការកើនឡើងក្នុងឆ្នាំ២០០៦និង២០០៧ គឺជាង ២,៦ពាន់លានដុល្លារក្នុងឆ្នាំ២០០៦ និង ២,៩ពាន់លានដុល្លាក្នុងឆ្នាំ២០០៧ ។ អង្ករ ១,៥លានតោន ត្រូវបាននាំចេញក្នុងឆ្នាំ២០០៦ មានចំនួនពីរដងនៃកម្រិតឆ្នាំ២០០៥ ។ នៅក្នុងឆ្នាំ២០០៧ ការនាំចេញអង្ករមានចំនួនប្រហាក់ប្រហែល ឆ្នាំ២០០៦ ដែរ ។

---

[1] តារាងសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗចំណុច ៤.០០ ដល់ ៦.០០ តារាង២.១ និងឧបសម្ព័ន្ធ១.១

[2] កថាខណ្ឌ ២.២៩ ដល់ ២.៣៦

[3] សូមមើលផងដែរនៅកថាខណ្ឌ ២.១៧

ដើម្បីទាក់ទាញឱ្យមានការវិនិយោគទាំងក្នុងនិងក្រៅប្រទេស នៅក្នុងប្រទេស *តំបន់សេដ្ឋកិច្ចពិសេស* ដែលជាចម្បងសម្រាប់ការនាំចេញ កំពុងត្រូវបានអនុម័តឱ្យផ្តល់នូវ "សេវាកម្មតាមច្រកចេញចូលតែមួយ" សម្រាប់ការបំពេញនីតិវិធីរដ្ឋបាល ។ *តំបន់សេដ្ឋកិច្ចពិសេស* បានចាប់ផ្តើមកិច្ចប្រតិបត្តិការ និងបានចាប់ផ្តើមដំណើរការផលិតកម្ម ។

២.៦៩ យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា លើកឡើងនូវបញ្ហាប្រឈមមួយចំនួនក្នុងចំណោមបញ្ហាប្រឈមថ្មីៗ ដូចជា "ទស្សនៈភាពប្រកួតប្រជែង" ។ សមត្ថភាពផលិតករនិងអ្នកនាំចេញកម្ពុជាក្នុងការប្រកួតប្រជែង នៅលើមូលដ្ឋានឧត្តមភាពនិងការអនុគ្រោះផ្នែកពន្ធគយ នឹងចុះខ្សោយទៅយ៉ាងលឿន ។ ដូច្នេះ ប្រទេសកម្ពុជា ត្រូវធ្វើការកែតម្រូវជាបន្ថែមទៀត ដើម្បីប្រណាំងប្រជែងដោយលើភាពខ្លាំងនៃសមត្ថភាពផ្គត់ផ្គង់នៅក្នុងស្រុករបស់ខ្លួន ។ បញ្ហាប្រឈមនានាដែលកំពុងបន្តក្នុងបច្ចុប្បន្ននេះ ហើយទំនងជានឹងលេចឡើងរួមមាន :

*<u>ឧស្សាហកម្មសម្លៀកបំពាក់</u>* ដែលជាអ្នកនាំមុខក្នុងកំណើនសេដ្ឋកិច្ចនិងការងារកន្លងមក កំពុងបង្ហាញនូវសញ្ញានៃការបាត់បង់ភាពប្រកួតប្រជែង ដោយសារ ប្រាក់បៀវត្សរ៍ខ្ពស់ជាងមុនដែលបណ្តាលមកពីអតិផរណាបង្កដោយកត្តាពីខាងក្រៅក្នុងពេលថ្មីៗនេះ ថ្លៃដឹកជញ្ជូនទំនិញខ្ពស់ជាងមុនដោយសារការកើនឡើងនៃថ្លៃប្រេង និងការប្រកួតប្រជែងដែលប្រទេសជិតខាងនឹងចាប់ផ្តើមសម្រាប់ទីផ្សារដូចគ្នាដែរ នៅពេលដែលតម្រូវការកំពុងថយចុះ នៅក្នុងទីផ្សារនៃទំនិញបែបនេះ ។ ដើម្បីការពារវិស័យនេះទល់នឹងអសមត្ថភាពបែបនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់រួចមកហើយនូវការលើកលែងពន្ធ ហើយបានចាប់ផ្តើមផ្តល់នូវឧបត្ថម្ភធនដើម្បីបន្ថែម ៦ដុល្លារអាមេរិកក្នុងមួយខែ ពីលើប្រាក់បៀវត្សរ៍របស់កម្មករ ។ (កម្មករជាង ៣៦០.០០០ នាក់ ដែលភាគច្រើនជាស្ត្រីវ័យក្មេង បច្ចុប្បន្នកំពុងបំរើការងារនៅក្នុងរោងចក្រកាត់ដេរចំនួន ៣០១) ។

*<u>សំណង់</u>* ដែលជាអ្នករួមចំណែកដ៏សំខាន់មួយទៀតដល់កំណើនកន្លងមក កំពុងបង្ហាញនូវសញ្ញាថយចុះដោយសារមានអតិផរណាអន្តរជាតិលើសំភារៈសំណង់នាំចូល ដូចជា ស៊ីម៉ងត៍ និងដែក ដែលកំពុងមានផលប៉ះពាល់មិនល្អ ។

កង្វះខាតស្រូវអង្ករទូទាំងពិភពលោក បានធ្វើឱ្យថ្លៃឡើងដល់កម្រិតដែលមិនធ្លាប់មានពីមុន ហើយការនាំចេញ ត្រូវបានកំហិត ។ ដូច្នេះ កម្រិតនាំចេញជាទូទៅអាចធ្លាក់ចុះក្នុងរយៈពេលខ្លី ។

ក្រៅពីប្រេងកាតនិងឧស្ម័នធម្មជាតិ សក្តានុពលដ៏ធំសម្រាប់ការរុករករ៉ែ កំពុងចាប់ផ្តើមទាក់ទាញការចាប់អារម្មណ៍របស់វិនិយោគិនក្រៅប្រទេស[១] ។ បទប្បញ្ញត្តិនិងនីតិវិធីដ៏ប្រុងប្រយ័ត្ន ត្រូវរៀបចំឡើង ជាចាំបាច់ ដើម្បីធានានិរភាពផ្នែកបរិស្ថាន ការកែច្នៃក្នុងស្រុកដែលមានតម្លៃបន្ថែម និងការរកចំណូលឱ្យបានច្រើនបំផុតដល់ថវិការដ្ឋ ។

រាជរដ្ឋាភិបាលកម្ពុជា នឹងជំរុញលើកទឹកចិត្តយ៉ាងសកម្ម ដល់ការវិនិយោគរបស់វិស័យឯកជន សម្រាប់ការពង្រីកនិងការធ្វើពិពិធកម្ម កម្មន្តសាលនិងផលិកម្មឧស្សាហាកម្ម ដើម្បីទាញយកឧត្តមភាពពីអំណោយទានផ្នែកធម្មជាតិរបស់ប្រទេស[2] ដោយរាប់បញ្ចូលទាំងការងារដែលមានតម្លៃបន្ថែមក្នុងវិស័យកសិកម្ម ដូចជា ការកែច្នៃកសិផល ជាដើម ។

ការនាំចេញផលិតផលកម្ពុជាផ្សេងទៀតនៅតែជួបប្រទះការលំបាកជាច្រើន ហើយដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ គំនិតផ្តួចផ្តើម និងវិធានការកំណែទម្រង់ ជាច្រើន ត្រូវបានបង្កើតឡើង ។

២.៧០ *ទេសចរណ៍* : ផ្នែកនេះគឺជាផ្នែកទីពីរបន្ទាប់ពីឧស្សាហកម្មសម្លៀកបំពាក់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងក្នុងការផ្តល់ការងារដល់ប្រជាជនកម្ពុជាដ៏ច្រើនក្នុងវិស័យពាក់ព័ន្ធផ្សេងៗជាច្រើន ដូចជា ការធ្វើបដិសណ្ឋារកិច្ចភ្ញៀវ ការដឹកជញ្ជូន និងវិស័យផ្សេងៗទៀត ទន្ទឹមនឹងការផ្តល់ការងារនិងប្រាក់ចំណូលដល់ប្រជាជនភាគច្រើន ក្នុងការងារបន្ទាប់បន្សំនិងវិស័យសេវាកម្ម ។ វិស័យទេសចរណ៍ មានកំណើនក្នុងល្បឿនយ៉ាងលឿន ក្នុងប៉ុន្មានឆ្នាំមុននេះ ។ ការបន្តសកម្មភាពដ៏សកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តគោលនយោបាយទេសចរណ៍ ដោយផ្អែកលើគោលការណ៍ជាមូលដ្ឋាន ដែលមានចែងនៅក្នុង*ផយអជ* (ការអនុវត្តគោលនយោបាយបើកចំហជើងមេឃ ការពង្រីកវិស័យទេសចរណ៍ក្នុងតំបន់ ការពង្រឹងសមត្ថភាពដើម្បីដោះស្រាយនូវរាល់ទម្រង់ណាមួយនៃសកម្មភាពឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍) និងក្នុងការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (ផ្លូវថ្នល់ អាកាសយានដ្ឋាន កំពង់ផែ) ក៏ដូចជា ការផ្តល់នូវបរិយាកាសសន្តិភាព និងច្បាប់និងសណ្តាប់ធ្នាប់សង្គម បាននាំមកនូវភាពរីកចម្រើនគួរឱ្យកត់សម្គាល់នៃវិស័យនេះ ។ ប្រទេសកម្ពុជា បានទទួលភ្ញៀវទេសចរអន្តរជាតិចំនួន ១.៧០០.០៤១ នាក់ ក្នុងឆ្នាំ២០០៦ គឺកើនឡើង ១៩,៥៩ភាគរយ ធៀប នឹងឆ្នាំ២០០៥ ។ ក្នុងឆ្នាំ២០០៧ ភ្ញៀវទេសចរមានចំនួន ២.០១៥.១២៨នាក់ គឺកើនឡើង ១៨,៥៣ភាគរយ ធៀបនឹងឆ្នាំ២០០៦ ដោយបានរួមចំណែកក្នុងការរកបាននូវរូបិយប័ណ្ណអន្តរជាតិចំនួន ១.៤០០លានដុល្លារ និងបង្កើតការងារចំនួន ៣០០.០០០កន្លែង ។ យុទ្ធនាការមួយត្រូវបានធ្វើឡើង ក្នុងខែកញ្ញា ឆ្នាំ២០០៨ ដើម្បីធ្វើឱ្យអ្នកទេសចរ ឱ្យងាយស្គាល់ ងាយចាំ ពីឈ្មោះ *"កម្ពុជា : រាជាណាចក្រអច្ឆរិយៈ"* ។ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តផ្តោតលើ និងប្រឹងប្រែងធ្វើការទាក់ទាញទេសចរ ឱ្យទៅកាន់គោលដៅជាច្រើនថែមទៀត ដើម្បីឱ្យទីកន្លែង ច្រើនជាងមុននៃប្រទេស អាចទទួលបាននូវផលប្រយោជន៍ ។

២.៧១ បញ្ហាប្រឈមមួយចំនួន ក្នុងចំណោមបញ្ហាប្រឈមចំពោះមុខ រួមមាន :

ការកើនឡើងនៃចំណាយក្នុងការធ្វើដំណើរមកកម្ពុជា ដែលបណ្តាលមកពីការកើនឡើងនៃតម្លៃប្រេង និងការកើនឡើងនៃថ្លៃក្នុងប្រទេសដែលបណ្តាលមកពីអតិផរណាពីខាងក្រៅ អាចនាំមកនូវការថយចុះនៃអត្រាកំណើនទេសចរមកកម្ពុជា ។

---

[1] ការរុករករ៉ែបុកស៊ីត បានចាប់ផ្តើមខេត្តភាគឦសាន ដែលបានក្លាយជាប្រភពសក្តានុពលថ្មីមួយមួយផងដែរ សម្រាប់ថ្មមានតម្លៃថ្នាក់លេខពីរ ។

[2] នាបច្ចុប្បន្ននេះ ក្រៅពីរោងចក្រកែវសម្រាប់ភេសជ្ជៈ និងរោងចក្របារី រោងចក្រស៊ីម៉ង់ត៍ ចំនួនបី កំពុងដំណើរការអាជីវកម្ម ហើយរោងចម្រាញ់ខ្នាតតូចមួយ ត្រូវបានគ្រោងឡើង ដោយផ្នែកឯកជនមួយ ។

ការកែលម្អបន្ថែមទៀតនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដែលតភ្ជាប់ទៅនឹងតំបន់ទេសចរណ៍សំខាន់ៗ ។

ការពង្រឹងវិធានការផ្សព្វផ្សាយពាណិជ្ជកម្ម និងក្របខ័ណ្ឌច្បាប់ក្នុងការគ្រប់គ្រងទេសចរណ៍ ។

ការទាក់ទាញទេសចរទៅទស្សនាកន្លែងផ្សេងៗជាច្រើនទៀត រួមមាន អេកូទេសចរណ៍ ដោយសារកន្លែងទេសចរណ៍ ត្រូវបានផ្តំតែក្នុងតំបន់សៀមរាប (សម្រាប់វប្បធម៌ និងកេរ្តិ៍ដំណែល) ភ្នំពេញ (ការទាក់ទាញរបស់រាជធានី) និងក្រុងព្រះសីហនុ (សម្រាប់ការកំសាន្ត) ។

ការដោះស្រាយបានល្អជាងមុននូវបញ្ហាបែងចែកផលប្រយោជន៍ដែលបានពីការចំណាយរបស់ទេសចរ ឱ្យទៅក្រុមហ៊ុននិងអ្នកផ្គត់ផ្គង់ទំនិញនិងសេវាកម្មក្នុងស្រុក ជាជាងទុកឱ្យមួយភាគធំនៃប្រាក់ចំណូល ត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសដើមវិញ ឬត្រូវបានប្រើសម្រាប់ទិញទំនិញពីក្រៅប្រទេស (សូមមើលប្រអប់ ២.៥) ។ ការងារសំខាន់ជាពិសេស គឺត្រូវបង្កើតនូវការផ្សារភ្ជាប់គ្នាយ៉ាងរឹងមាំ រវាងវិស័យទេសចរណ៍ និងវិស័យកសិកម្ម ដែលផ្អែកលើតំបន់ជនបទ ។

ការបន្ថយឥទ្ធិពលនៃហានិភ័យនិងផលប៉ះអវិជ្ជមាន ពីវិស័យទេសចរមកលើបិស្ថាន ជាពិសេស នៅសៀមរាប (ឧទាហរណ៍ ការប្រើប្រាស់ច្រើនហួសនូវទឹកក្រោមដី ដែលអាចនាំទៅដល់ ការស្រុតដី និងការបង្កការខូចខាតដល់ប្រាង្គប្រាសាទ) និងនៅក្រុងព្រះសីហនុ ។

២.៧២ **ការបង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរជូនដល់កម្មករនិងនិយោជិក** គឺជាគោលដៅបន្តរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ហើយជាចុងក្រោយបង្អស់ ដើម្បីកាត់បន្ថយភាពក្រីក្រ និងបង្កើនល្បឿនកំណើនសេដ្ឋកិច្ច ។ ភាពគ្មានការងារធ្វើ នៅកម្ពុជា គឺជាបញ្ហាដែលគ្របដណ្តប់ខ្លាំងលើយុវជន[១] ។ ក្នុងចំណោមអ្នកស្វែងរកការងារធ្វើនៅភ្នំពេញចំនួន ១០០នាក់ មាន ៧២នាក់ ស្ថិតនៅក្នុងអាយុពី ១៥-២៤ឆ្នាំ ។ អ្នកស្វែងរកការងារធ្វើបន្ថែមទៀតចំនួន ២៧៥.០០០ ត្រូវបានរំពឹងថា នឹងចូលក្នុងទីផ្សារពលកម្មជារៀងរាល់ឆ្នាំ ដោយធ្វើឱ្យមានផលប៉ះពាល់ជាច្រើន ដល់ភាពគ្មានការងារធ្វើរបស់យុវជន និងការកើនឡើងនៃភាពក្រីក្រ ។ ការងារធ្វើ និងមុខរបរដែលផ្តល់កម្រៃល្អ ទាំងក្នុងវិស័យផ្លូវការ និងមិនផ្លូវការ គឺជាលទ្ធផលនៃការវិនិយោគភាគច្រើនមាននៅក្នុងផ្នែកឯកជន ដែលឆ្លើយតបទៅនឹងកម្លាំងទីផ្សារ ។ តួនាទីនិងជោគជ័យ របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងផ្នែកនេះ ត្រូវបានបង្ហាញជាសង្ខេបក្នុងកថាខ័ណ្ឌខាងលើ (កថាខ័ណ្ឌ ២.៦៧ និង ២.៦៨) ។ ការផ្តោតការយកចិត្តទុកដាក់ដែលត្រូវបង្កើនឡើងលើការអភិវឌ្ឍជនបទនិងផលិតភាពកសិកម្ម នឹងបង្កើតដោយត្រង់ផ្ទាល់តែម្តង នូវកាលានុវត្តភាពការងារផ្ទាល់និងប្រយោលនៅជនបទ តាមរយៈ ការកើនឡើងនៃតម្រូវការទំនិញ និងសេវាកម្ម ។ កិច្ចអភិវឌ្ឍដែលបានសម្រេចកន្លងមករួមមាន :

[១] អង្គការពលកម្មអន្តរជាតិ -- ឯកសារគោលនយោបាយសង្ខេបស្តីពីយុវជននិងការងារធ្វើនៅកម្ពុជា ឆ្នាំ២០០៧

យកចិត្តទុកដាក់លើកិច្ចខិតខំប្រឹងប្រែងដែលប្រើពលកម្មច្រើន សម្រាប់ការបង្កើតហេដ្ឋារចនាសម្ព័ន្ធ ជាពិសេស នៅតំបន់ជនបទ ដើម្បីផ្ដល់នូវចំណូលតាមរដូវកាលនិងចំណូលបន្ថែម ដល់ប្រជាជនក្រីក្រ ។

រាជរដ្ឋាភិបាលដើរតួនាទីដ៏សំខាន់ ក្នុងការបង្កើតឱកាសការងារសម្រាប់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេស ជនក្រីក្រ ។ ដោយមានការជួយឧបត្ថម្ភរបស់រាជរដ្ឋាភិបាលកម្ពុជា ពលករកម្ពុជាចំនួន ៩.៥២៦នាក់ ត្រូវបានផ្ដល់ការងារជូននៅក្រៅប្រទេស ក្នុងឆ្នាំ២០០៧ បើធៀបទៅនឹងតួលេខឆ្នាំ២០០៦ មានចំនួន ៣.៦៣៦នាក់ តែប៉ុណ្ណោះ ។

ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវបានបង្កើតឡើង ដើម្បីបម្រើទាំងបុរសនិងស្ត្រី ប្រកបដោយសមធម៌ ជាពិសេស ជនក្រីក្រ ជនពិការ និងក្រុមជនងាយរងគ្រោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ រយៈពេលខ្លីនិងរយៈពេលវែង ។ ក្នុងឆ្នាំ២០០៧ សិស្ស-និស្សិតដែលបញ្ចប់ការសិក្សាពីតាមគ្រឹះស្ថានបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈសាធារណៈ មានចំនួន ២៣.៤៧៨នាក់ (ដោយមិនរាប់បញ្ចូលតួលេខសិស្ស-និស្សិត ដែលបានបណ្ដុះបណ្ដាលតាមរយៈ អង្គការក្រៅរដ្ឋាភិបាល សាលាឯកជននានា និងតាមប្រព័ន្ធលិខិតបញ្ជាក់) គឺមានការកើនឡើងចំនួន ៧.២៩៦នាក់ ធៀបនឹងតួលេខឆ្នាំ២០០៦ ។ ការធ្វើអង្កេតអំពីវិសមភាពយេនឌ័រក្នុងការបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវបានធ្វើឡើង នៅក្នុងខេត្ត-ក្រុង ជាច្រើន ហើយការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវបានចាប់ផ្ដើម ។

លក្ខខណ្ឌកន្លែងការងារដែលមានសុវត្ថិភាព សមរម្យ និងមានអនាម័យ និងលក្ខខណ្ឌកិច្ចសន្យាត្រឹមត្រូវ និងយុត្តិធម៌ចំពោះបុគ្គលិកកម្មករ រួមមាន ការកំណត់ប្រាក់បៀវត្សរ៍អប្បបរមានិងការឈប់សម្រាក ការកាត់បន្ថយវិសមភាពប្រាក់បៀវត្សរ៍រវាងបុរសនិងស្ត្រី ការផ្សះផ្សាវិវាទការងារ និងការខ្វែងគំនិតគ្នា ដោយសន្តិវិធី ដែលមិនបណ្ដាលឱ្យមានការផ្អាកការផលិតនិងការខាតបង់ប្រាក់បៀវត្សរ៍ដល់និយោជិក ត្រូវបានដោះស្រាយនិងធានា ជាប្រចាំ ។

កិច្ចប្រឹងប្រែងក្នុងការកាត់បន្ថយពលកម្មកុមារនៅក្នុងការងារដែលមានគ្រោះថ្នាក់ ត្រូវបានអនុវត្តតាមរយៈគម្រោង/កម្មវិធីផ្សេងៗ និងវិធានការគោលនយោបាយជាច្រើន ។ បន្ថែមពីលើការចូលរៀនដែលមានកម្រិតខ្ពស់ជាងនៅតាមសាលារៀននានា កុមារចំនួន ១៦.០០០នាក់ ត្រូវបានផ្ដល់ការអប់រំនិងការបណ្ដុះបណ្ដាលវិជ្ជាជីវៈក្រៅប្រព័ន្ធ ។ ផែនការប្រាំឆ្នាំ ស្ដីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ២០០៦-២០១២ និងបទប្បញ្ញត្តិផ្សេងៗ ដែលពាក់ព័ន្ធនឹងពលកម្មកុមារនិងបញ្ហាពាក់ព័ន្ធនឹងពលកម្ម ត្រូវបានរៀបចំឡើង ។

២.៧៣ **ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម :** ការអភិវឌ្ឍជាបន្តទៀតនៃផ្នែកនេះ បានរួមចំណែកផ្តល់ផលប្រយោជន៍ដល់សហគមន៍ជនបទ ក្នុងការកែច្នៃនិងផ្តល់តម្លៃបន្ថែមដល់ផលិតផល ក៏ដូចជា ការបង្កើតការងារផងដែរ ។ ផ្នែកនេះ ក៏បានបង្កើតទំនាក់ទំនងដ៏សំខាន់មួយជាមួយនឹងផ្នែកពាណិជ្ជកម្ម និងជាមួយសហគ្រាសធំៗផងដែរ ។ ការងារដែលត្រូវបានគ្រោងទុកទៅមុខ នឹងផ្តោតលើទិដ្ឋភាពបីធំៗ ពោលគឺ (១) ក្របខ័ណ្ឌច្បាប់ និងការកែតម្រូវ (ភាពមានកម្រិតនៃ នីតិវិធីអធិការកិច្ច និងការបញ្ជាក់លើភាពត្រឹមត្រូវនៃផលិតផលសម្រាប់នាំចេញនិងនាំចូល ដោយមិនភ្លេចគិតគូរដល់ទិដ្ឋភាពសំខាន់ៗពាក់ព័ន្ធនឹងគុណភាព ការរៀបចំនិងការអនុម័តយកនូវ អនុក្រឹត្យស្តីពីការសម្រួលធុរៈកិច្ចតាមរយៈការគ្រប់គ្រងហានិភ័យ និងការពង្រឹងការចុះបញ្ជីតាមរយៈអ៊ិនទ័រណិត) (២) ការធ្វើហិរញ្ញប្បទាន ការបង្កើតក្រុមជួលផ្នែកហិរញ្ញវត្ថុ ការធ្វើចំណាត់ថ្នាក់ដោយការដាក់ពិន្ទុតាមកេរ្តិ៍ឈ្មោះ និងការពង្រឹងអភិបាលកិច្ចនិងការធ្វើរបាយការណ៍ផ្នែកហិរញ្ញវត្ថុ និង (៣) សកម្មភាពគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម (ការបង្កើតនូវសេវាកម្មអភិវឌ្ឍន៍ធុរៈកិច្ចថ្មីមួយ ការការពារជាមុននូវការគេចពន្ធតាមគ្រប់ទ្រង់ទ្រាយ ការផ្តល់ឧបត្ថម្ភធនដល់សហគ្រាសធុនតូចនិងមធ្យមសម្រាប់ការនាំចេញ និងការដាក់បញ្ចូលនូវសហគ្រាសធុនតូចនិងមធ្យម ទៅក្នុងបណ្តាញខ្សែសង្វាក់ផលិតកម្មពិភពលោក) ។ ការទទួលយកនិងការជំរុញល្បឿនចលនា *"ភូមិមួយ ផលិតផលមួយ"* គឺជាវិធានការមួយ នៅក្នុងចំណោមវិធានការ ជាច្រើនផ្សេងទៀត ។

២.៧៤ **ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់មន្ត្រី បុគ្គលិក កម្មករ :** អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចដែលត្រូវបានកំណត់គោលដៅច្បាស់លាស់ មានសារៈសំខាន់ណាស់ ក្នុងការផ្តល់បណ្តាញសុវត្ថិភាពសង្គម ទៅដល់ជនដែលងាយរងគ្រោះជាងគេ ។ សមិទ្ធផលនិង បញ្ហាប្រឈមចម្បងៗ រួមមាន :

- ចំនួនជនដែលគ្មានផ្ទះសម្បែង ត្រូវបានកាត់បន្ថយជាបណ្តើរៗ ។ វិធានការសមស្របត្រូវបានអនុវត្តដើម្បីសម្រាលទុក្ខវេទនា និងការហូរចូលនៃជនគ្មានផ្ទះសម្បែង មកក្នុងតំបន់ទីប្រជុំជនធំៗ ។
- ព្រមគ្នាជាមួយការបង្កើតមណ្ឌលសម្រាប់ជនរងគ្រោះដោយការជួញដូរ ការធ្វើនីតិសម្បទា ដោយមិនរើសអើង និងសេវាអប់រំស្តីពីការថែទាំសុខភាព ត្រូវបានផ្តល់ដល់កម្មករ និងជនរងគ្រោះដោយការជួញដូរផ្លូវភេទ។
- កុមារមានទំនាស់ជាមួយច្បាប់និងកុមារញៀនថ្នាំចំនួន ១.៩៨៥នាក់ អ្នកញៀនថ្នាំចំនួន ១.២៣៨នាក់ និងអ្នកគ្មានផ្ទះសម្បែងនិងកុមារតាមចិញ្ចើមថ្នល់ចំនួន ៦៩៣នាក់ ត្រូវបានប្រមូល និងត្រូវបានធ្វើសមាហរណ-កម្មទៅក្នុងសហគមន៍វិញចំនួន ៨៣៨នាក់ ហើយត្រូវបានផ្តល់សេវាសុខភាពនិងការអប់រំផ្នែកសីលធម៌ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។ សិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ និងគោលនយោបាយថែទាំជំនួសចំពោះកុមារ ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ។ កម្ពុជាបានក្លាយជាប្រទេសមួយដែលអនុវត្តតាម

អនុសញ្ញាក្រុងឡាអេ សម្រាប់សុំកូនអន្តរប្រទេស ។ សេចក្តីព្រាងច្បាប់សុំកូនអន្តរប្រទេស ត្រូវបានរៀបចំរួចរាល់ ហើយកំពុងត្រៀមសុំការអនុម័តពីស្ថាប័ននីតិបញ្ញត្តិ ។ កម្ពុជាបានក្លាយជាប្រទេសមួយដែលអនុវត្តតាមអនុសញ្ញាក្រុងឡាអេ សម្រាប់សុំកូនអន្តរប្រទេស ។

សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ត្រូវបានបញ្ជូនទៅសភាជាតិ ដើម្បីសុំការអនុម័ត ។

កិច្ចខិតខំប្រឹងប្រែងកន្លងមកដើម្បីផ្តល់នូវប្រព័ន្ធសន្តិសុខសង្គមកិច្ច ត្រូវបានពង្រឹងបន្ថែមទៀត និងប្រកាសចេញជាផ្លូវការ នៅខែមករា ឆ្នាំ២០០៨ តាមរយៈព្រះរាជក្រឹត្យស្តីពី កម្មវិធីរបបសន្តិសុខសង្គមកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិល និងតាមរយៈការប្រកាសចេញនូវអនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិស្តីពីសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។

សមាគមអតីតយុទ្ធជនកម្ពុជា ត្រូវបានបង្កើតឡើង ក្នុងគោលបំណងដើម្បីលើកកម្ពស់សាមគ្គីភាព បំផុសស្មារតី ជួយឧបត្ថម្ភគ្នាទៅវិញទៅមក និងជួយលើកម្ពស់ជីវភាពរស់នៅរបស់អតីតយុទ្ធជន ។

គម្រោងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលត្រូវបានអនុវត្តតាមរយៈនីតិវិធីស្តង់ដារ បានចាប់ផ្តើមបង្កលក្ខណៈឱ្យរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស អាចផ្តល់សេវាកម្មនិងជំនួយអភិវឌ្ឍន៍ ទៅដល់ក្រុមជនគោលដៅ ។

បញ្ហាប្រឈមដ៏គួរឱ្យព្រួយបារម្ភមួយចំពោះមុខ គឺត្រូវចាប់ផ្តើម ការផ្តល់ឧបត្ថម្ភធនផ្ទាល់និងទៅតាមក្រុមគោលដៅ និងការលើកលែងពន្ធ ដើម្បីការពារទល់នឹងនៃការឡើងថ្លៃឥតឈប់ឈរចំពោះទំនិញចាំបាច់នានា ដែលបណ្តាលមកពីកត្តាខាងក្រៅ ទៅលើអ្នកក្រីក្រ និងដើម្បីទប់ស្កាត់ការកើនឡើងកម្រិតនៃភាពក្រីក្រ (សូមមើលប្រអប់ ២.១) ។

## ចតុកោណទី៤ : ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស

២.៧៥ ចតុកោណកំណើនចុងក្រោយនៃយុទ្ធសាស្ត្រចតុកោណ គ្របដណ្តប់ភាគច្រើនលើវិស័យសង្គមកិច្ច ដូចជា *(១) ការពង្រឹងគុណភាពវិស័យអប់រំ (២) ការលើកស្ទួយសេវាសុខាភិបាល (៣) ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និង (៤) ការអនុវត្តគោលនយោបាយជាតិប្រជាជន* ។ គេឃើញ*មានការរីកចំរើនគួរឱ្យកត់សម្គាល់ក្នុងវិស័យអប់រំ និងសុខាភិបាល* ដែលនៅទីនេះកិច្ចសហប្រតិបត្តិការ និងយន្តការសម្របសម្រួលក្នុងចំណោមអ្នកមានចំណែកពាក់ព័ន្ធនានា បានចាប់ផ្តើមតាំងតែពីមុនពេលមានការបង្កើតក្រុមការងារបច្ចេកទេសនៅចុងឆ្នាំ ២០០៣ មកម្ល៉េះ ។ យុទ្ធសាស្ត្រតាមវិស័យ ក្នុងវិស័យទាំងពីរ ត្រូវបានរៀបចំបានល្អ កំពុងត្រូវបានអនុវត្ត និងតាមដាន ត្រួតពិនិត្យយ៉ាងត្រឹមត្រូវ ។

២.៧៦ **ការងារអប់រំ :** ផ្នែកនេះគឺជាសមាសធាតុចាំបាច់និងសំខាន់សម្រាប់ការអភិវឌ្ឍមនុស្សនិងការកាត់បន្ថយភាពក្រីក្រ ។ យុទ្ធសាស្ត្រនិងអាទិភាពដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យអប់រំ ត្រូវបានចែងយ៉ាងច្បាស់ក្នុង *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ផយវអ) ឆ្នាំ២០០៦-២០១០* ។ ការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិនៃ *ផយវអ* បានប្រារព្ធធ្វើនៅក្នុងខែមីនា ឆ្នាំ២០០៨ កន្លងមកនេះ ។ *ផយវអ* គ្រោងសម្រេចឱ្យបាននូវចំណុចដៅទាំងឡាយ ដែលបានកំណត់នៅក្នុង*ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០០៣-២០១៥* ។ ការសង្កេតឃើញមានវឌ្ឍនភាពចម្បងៗក្នុងពេលថ្មីៗនេះ នៅក្នុងការអនុវត្ត *ផយវអ* ឆ្នាំ២០០៦-២០១០នេះ ជាពិសេស ក្នុងការបង្កើនចំនួនសាលាបឋមសិក្សានិងមធ្យមសិក្សា ការកើនឡើងនៃចំនួនសិស្សចុះឈ្មោះចូលរៀន នៅមធ្យមសិក្សាបឋមភូមិ (រួមចំណែកដល់ការបញ្ចប់ការអប់រំជាមូលដ្ឋាន៩ឆ្នាំ) និងកំណើននៃអត្រាអក្ខរកម្មមនុស្សពេញវ័យ (១៥-២៤) ។ ទោះជាដូចនេះក្ដី ក៏នៅមានការខ្វះខាតជាច្រើន ពាក់ព័ន្ធនឹងលទ្ធភាពផ្ដល់ការអប់រំដល់កុមារដែលមកពីគ្រួសារក្រីក្រ និងគ្រួសារនៅតាមតំបន់ដាច់ស្រយាល ។ តារាង ២.៤ ខាងក្រោម បង្ហាញតួលេខបច្ចុប្បន្នភាព របស់វិស័យនេះ ។

**តារាង ២.៤ : ផ្នែកអប់រំ : វឌ្ឍនភាពសំខាន់ៗ និង ចំណុចដៅ**

| ចំណុចដៅ និង សូចនាករ | | | ២០០៥/០៦ | ២០០៦/០៧ | ២០០៧/០៨ | ២០១០/១១ (ចំណុចដៅ) | ២០១៥/១៦ (ចំណុចដៅ) |
|---|---|---|---|---|---|---|---|
| ១ | **សាលាបឋមសិក្សា (១-៦)** | **(ចំនួន)** | ៦.២៧៧ | ៦.៣៦៥ | ៦.៤៧៦ | | |
| ២ | ចម្ងាយឆ្ងាយបំផុតពីភូមិទៅសាលាបឋមសិក្សា | (គ.ម) | ២,០០ | | | ១,៥ | |
| ៣ | អត្រាពិតនៃការសិក្សា (%) | សរុប | ៩១,៣ | ៩២,១ | ៩៣,៣ | ១០០ | ១០០ |
| ៤ | | ប្រុស | ៩៣,០ | ៩៣,២ | ៩៣,២ | ១០០ | ១០០ |
| ៥ | | ស្រី | ៨៩,៧ | ៩១,០ | ៩៣,៣ | ១០០ | ១០០ |
| ៦ | អត្រាពិតនៃការសិក្សា (%) | ទីប្រជុំជន | ៩១,២ | ៩៣,២ | ៩២,៧ | ១០០ | ១០០ |
| ៧ | | ជនបទ | ៩១,៧ | ៩២,២ | ៩៣,៦ | ១០០ | ១០០ |
| ៨ | | តំបន់ដាច់ស្រយាល | ៨៣,៧ | ៨៦,០ | ៨៨,៤ | ១០០ | ១០០ |
| ៩ | អត្រាគង់វង្ស (%) | | ៤៩,៣ | ៥២,៥ | ពុំទាន់មានតួលេខ | ១០០ | ១០០ |
| **១០** | **សាលាមធ្យមសិក្សាបឋមភូមិ (១-៩)** | **(ចំនួន)** | ៩១១ | ១.១២២ | ១.៣០៣ | | |
| ១១ | ចម្ងាយឆ្ងាយបំផុតពីភូមិទៅសាលាមធ្យមសិក្សាបឋមភូមិ (គ.ម) | | ៨ | | | | ៤ |
| ១២ | អត្រាពិតនៃការសិក្សា (%) | សរុប | ៣១,៣ | ៣៣,៧ | ៣៤,៨ | ៥០ | ១០០ |
| ១៣ | | ប្រុស | ៣២,១ | ៣៤,៣ | ៣៣,៧ | ៥០ | ១០០ |
| ១៤ | | ស្រី | ៣០,៤ | ៣៣,១ | ៣៥,៩ | ៣៨ | ១០០ |
| ១៥ | អត្រាពិតនៃការសិក្សា (%) | ទីប្រជុំជន | ៥០,១ | ៥៣,៥ | ៥៥,៩ | ៧៥ | ១០០ |
| ១៦ | | ជនបទ | ២៨,៦ | ៣០,៧ | ៣១,៥ | ៥០ | ៧៥ |
| ១៧ | | តំបន់ដាច់ស្រយាល | ៦,០ | ៩,០ | ១១,១ | ៥០ | |
| ១៨ | អត្រាគង់វង្ស (%) | | ២៦,៣ | ២៩,៣ | ពុំទាន់មានតួលេខ | ៥០ | ១០០ |
| ១៩ | អត្រាអក្ខរភាព (អាយុ ១៥-២៤) (%) | | ៨៤,៧ | ៨៤,៧ | ៨៤,៧ | ៩៥ | ១០០ |

*ប្រភព : ក្រសួងអប់រំ យុវជន និង កីឡា*

២.៧៧ សមិទ្ធផលនិងការវិវត្តសំខាន់ៗ តាំងពីឆ្នាំ ២០០៥ រួមមាន :

ច្បាប់អប់រំត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ក្នុងខែធ្នូ ឆ្នាំ២០០៧ ។ ផែនការសកម្មភាពដើម្បីអនុវត្តច្បាប់នេះ និងឧបករណ៍នីតិប្បញ្ញត្តិជាច្រើន កំពុងរៀបចំបន្តទៀត ។

ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃការអនុវត្ត *ផយវអ* ត្រូវបានប្រារព្ធធ្វើក្នុងខែមីនា ឆ្នាំ២០០៨ ហើយអនុសាសន៍ ដែលទទួលបានពីការពិនិត្យមើលឡើងវិញនោះ បានយកមកអនុវត្ត ។

កម្មវិធីសិក្សាថ្នាក់ជាតិ និងស្តង់ដារនៃការសិក្សា ដែលបានកែសម្រួលឡើងវិញ ត្រូវបានអនុម័តជាផ្លូវការក្នុងឆ្នាំ២០០៦ ។ សេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីសិក្សាថ្មី និងស្តង់ដារការសិក្សា សម្រាប់ការអប់រំមូលដ្ឋាន ត្រូវបានប្រកាសចេញឱ្យអនុវត្ត ។ ការរៀបចំផែនការសកម្មភាពសម្រាប់ណែនាំគ្រូបង្រៀន ស្តីពីគោលនយោបាយកម្មវិធីសិក្សាថ្មី និងការណែនាំសិស្សានុសិស្សដើម្បីជ្រើសរើសមុខវិជ្ជា នៅសាលាមធ្យមសិក្សាទុតិយភូមិ ត្រូវបានបញ្ចប់ ។ ក្របខ័ណ្ឌអភិវឌ្ឍន៍និងផ្គត់ផ្គង់ សៀវភៅសិក្សាគោល ត្រូវបានរៀបចំឡើង ។

លទ្ធភាពទទួលបានការសិក្សា ត្រូវបានធ្វើឱ្យប្រសើរឡើង ។ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច បង្ហាញថា ពីឆ្នាំ ២០០៤ ដល់ ២០០៧ អត្រានៃការសិក្សាក្នុងចំណោមគ្រួសារក្រីក្របំផុត បានកើនឡើងយ៉ាងឆាប់រហ័ស (ដូចនេះ អត្រាទាំងនេះ មានកម្រិតប្រហាក់ប្រហែលនឹង អត្រានៃការសិក្សាក្នុងចំណោមគ្រួសារមានបំផុតដែរ) ដោយឆ្លុះបញ្ចាំងឱ្យឃើញពីការថយចុះយ៉ាងរហ័ស នូវចំណាយចាយវាយក្រៅផ្លូវការ នៅក្នុងការសិក្សា ។

ចំនួនសាលាបឋមសិក្សាបានកើនឡើងពី ៦.១៨០ ក្នុងឆ្នាំ២០០៤-២០០៥ ទៅ ៦.៤៧៦ ក្នុងឆ្នាំ២០០៧-២០០៨ ហើយសាលាមធ្យមសិក្សាបឋមភូមិ បានកើនឡើងពី ៨០០ ក្នុងឆ្នាំ២០០៤-២០០៥ ដល់ ១.៣០៣ ក្នុងឆ្នាំ២០០៧-២០០៨ ។

សាលាបឋមសិក្សាជាច្រើនថែមទៀត ត្រូវបានសាងសង់នៅតំបន់ដាច់ស្រយាល ដើម្បីកាត់បន្ថយគម្លាតក្នុងការទទួលបានសេវាអប់រំសម្រាប់កុមារដែលមកពីគ្រួសារក្រីក្រ និងគ្រួសាររស់នៅតំបន់ដាច់ស្រយាល ។ នៅក្នុងឆ្នាំសិក្សា២០០៧-២០០៨ សាលាចំនួន ៥៣១ ត្រូវបានសាងសង់ឡើងនៅតំបន់ដាច់ស្រយាល ។

ទន្ទឹមនឹងការការពង្រីកវិសាលភាពរបស់សាលារៀន ការផ្តល់លទ្ធភាពសម្រាប់កុមារពិការឱ្យទទួលបានការអប់រំ ក៏ត្រូវបានយកចិត្តទុកដាក់បន្ថែមទៀត តាមរយៈ ការរៀបចំផ្លូវឡើងសម្រាប់រទេះជនពិការ និងបង្គន់អនាម័យ ជាដើម ។

អត្រាពិតនៃការសិក្សានៅបឋមសិក្សា (តាមភេទនិងតំបន់) និងអត្រាគង់វង្សសម្រាប់ថ្នាក់ទី១-៦ និងថ្នាក់ទី៧-៩ បានកើនឡើងជាបន្តបន្ទាប់ តាំងពីឆ្នាំសិក្សា២០០៥-២០០៦ មក ។

ចំនួនអ្នកគ្រូនៅបឋមសិក្សា មានកម្រិត ៥១,៥ភាគរយ នៃចំនួនសរុប ។

អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ (២០០៧-២០០៨) មាន ៧៨,៩ភាគរយ ទាបជាងចំណុចដៅ ដែលបានកំណត់ ៩០,០ភាគរយ ជាពិសេស អត្រាសម្រាប់សិស្សស្រីមាន ៧៨,៥ ភាគរយ ទាបជាងចំណុចដៅ ដែលបានកំណត់ ៨៨,០ភាគរយ ។

មធ្យមសិក្សាបឋមភូមិបានទទួលជោគជ័យគួរឱ្យកត់សម្គាល់ ជាពិសេស ការកើនឡើងនូវចំនួនសាលារៀន និងអត្រាពិតនៃការសិក្សា (តារាង ២.៤) ។

អត្រាឆ្លងភូមិសិក្សា ពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិ (២០០៦-២០០៧) មាន ៧១,៥ភាគរយ ខ្ពស់ ជាងចំណុចដៅដែលបានកំណត់ ៦៥,០ភាគរយ ជាពិសេស អត្រាសម្រាប់សិស្សស្រី មាន ៧១,០ភាគរយ ខ្ពស់ជាងអត្រាដែលបានកំណត់ ៦៧,០ភាគរយ ។

សមធម៌នៃការចូលរៀន និងគុណភាពសេវាអប់រំនៃសាលារៀនសាធារណៈ នៅតំបន់ទីក្រុងនិងជនបទ ត្រូវបានលើកកម្ពស់ សម្រាប់កុមារា និងកុមារី ។

ក្នុងអំឡុងឆ្នាំ២០០៦-២០០៨ អគារអន្តេវាសិកដ្ឋានចំនួន ៤ នៅភ្នំពេញ ដែលអាចឱ្យនិស្សិតស្នាក់នៅចំនួន ៥៦០នាក់ ត្រូវបានកសាងឡើង សម្រាប់និស្សិតក្រីក្រ ជាពិសេស និស្សិតស្រី ។

ដើម្បីបន្តនូវយុទ្ធសាស្ត្ររយៈពេលវែងក្នុងវិស័យនេះ ការបន្តការវិនិយោគនិងកិច្ចខិតខំប្រឹងប្រែង ត្រូវបានធ្វើឡើង សម្រាប់វឌ្ឍនភាពក្នុងការអប់រំនៅឧត្តមសិក្សា ។ សមធម៌ក្នុងការចុះឈ្មោះចូលសិក្សានៅឧត្តមសិក្សា ត្រូវបានធ្វើឱ្យប្រសើរឡើង តាមរយៈ គម្រោងផ្តល់អាហារូបករណ៍សម្រាប់និស្សិតឆ្នើម និស្សិតក្រីក្រ និស្សិតមកពីតំបន់ដាច់ស្រយាល និងនិស្សិតស្រី ។

បច្ចុប្បន្ន គ្រឹះស្ថានឧត្តមសិក្សាចំនួន ៦៦ ក្នុងនោះ ២៤ ជាគ្រឹះស្ថានសាធារណៈ និង ៤២ ជាគ្រឹះស្ថានឯកជន កំពុងផ្តល់នូវការអប់រំ ក្នុងកម្រិតឧត្តមសិក្សា ។

ទោះជាដូចនេះក្តី ការបង្កើតឡើងនូវយន្តការមួយសមស្រប សម្រាប់គ្រប់គ្រង និងវាយតម្លៃគុណភាពអប់រំឧត្តមសិក្សានិងការបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតែបន្តជាបញ្ហាប្រឈមមួយ នៅឡើយ ។

២.៧៨ គោលដៅនិងអាទិភាពដែលបានកំណត់សម្រាប់ផ្នែកអប់រំនៅក្នុង *ផយអជ* នៅតែបន្តមានសុពលភាព ហើយនឹងត្រូវបន្តអនុវត្តយ៉ាងសកម្មតាមរយៈផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ ។ ដោយសារវិស័យនេះ ជាអាទិភាពមួយនៅក្រោម *កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* ការបែងចែកនិងការប្រើប្រាស់ថវិកាជាតិ បានកើនឡើង ទាំងតម្លៃពិតនិងតម្លៃធៀប[១] ។ បញ្ហាប្រឈមជាច្រើនដែលស្ថិតនៅចំពោះមុខ រួមមាន សកម្មភាព ដែលត្រូវអនុវត្ត ដើម្បី :

[១] សូមអានឧបសម្ព័ន្ធ ១.៣

ដោះស្រាយបញ្ហារចនាសម្ព័ន្ធរបស់ការសិក្សាលើសអាយុចូលរៀន ដែលផ្សារភ្ជាប់ទៅនឹង ការរៀនសូត្រខ្សោយ អត្រាត្រួតថ្នាក់ខ្ពស់ និងអត្រាបោះបង់ចោលការសិក្សាខ្ពស់។

ធានាថា ម៉ោងពេលដែលត្រូវបានបែងចែកសម្រាប់ការសិក្សានៅតាមសាលារៀន ត្រូវបានប្រើប្រាស់ពេញលេញ និងត្រឹមត្រូវ ។

ធានាឱ្យអត្រាចូលក្នុងថ្នាក់រៀន មានកម្រិតដូចគ្នានឹង អត្រានៃការសិក្សា នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ។

កាត់បន្ថយកម្រិតនៃការរៀនត្រួតថ្នាក់ នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ។

កែលម្អអត្រាឆ្លងភូមិសិក្សា ពី បឋមសិក្សា ទៅ មធ្យមសិក្សា និងបន្ទាប់ពីកម្រិតទាំងនេះ ។

លើកកម្ពស់គុណភាពអប់រំ នៅគ្រប់កម្រិត ដោយរួមបញ្ចូលទាំង គុណភាព និងសមត្ថភាពរបស់គ្រូ ។

បញ្ហាប្រឈមធំមួយដ៏គួរឱ្យព្រួយបារម្ភ កើតចេញពីភាពងាយរងគ្រោះ នៃកម្មវិធីផ្ដល់ចំណីអាហារនៅតាមសាលារៀន ដែលមានភាពចាំបាច់ខ្លាំងក្នុងការទាក់ទាញ និងរក្សាសិស្សានុសិស្សឱ្យនៅរៀននៅសាលាបឋមសិក្សា ហើយការកាត់បន្ថយ ការផ្អាក ឬការលុបចោល នូវកម្មវិធីនេះ ដោយមូលហេតុចំណាយខ្ពស់លើថ្លៃម្ហូបអាហារ មិនត្រឹមតែ អាចបញ្ឈប់នូវវឌ្ឍនភាពដែលសម្រេចបានកន្លងមកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ធ្វើឱ្យខូចបង់នូវសមិទ្ធផលទាំងនោះ ទៀតផង ។

ដោះស្រាយបញ្ហានានា នៃការរីកលូតលាស់លឿនពេក របស់ឧត្ដមសិក្សាក្នុងវិស័យឯកជន ដែលបណ្ដាលឱ្យមានបញ្ហាជាច្រើន ដូចជា កង្វះសាស្ត្រាចារ្យដែលមានគុណភាព គុណភាពទាបនៃសញ្ញាប័ត្រមួយចំនួន និងភាពអាចរកការងារធ្វើបាននាពេលអនាគតរបស់និស្សិតដែលបានបញ្ចប់ការសិក្សា ។ នៅពេលដែល *គណៈកម្មាធិការពិនិត្យគុណភាពអប់រំកម្ពុជា* ចាប់ផ្ដើមដំណើរការ ក្នុងឆ្នាំ២០០៨ នោះការកែលម្អមួយចំនួន អាចត្រូវបានរំពឹងទុកថា នឹងកើតមាន នៅក្នុងការងារទាំងនេះ ។

២.៧៩ **<u>សុខាភិបាល</u>** : ផ្នែកនេះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ។ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០៥ ដែលបានធ្វើឡើងទៅតាមបទដ្ឋានអន្តរជាតិ បានធ្វើបច្ចុប្បន្នភាពនូវទិន្នន័យស្ដីពី ភាពបង្កើតកូន ផែនការគ្រួសារ មរណភាពទារក កុមារ និងមាតា សុខភាពមាតានិងកុមារ អាហារូបត្ថម្ភ ជម្ងឺគ្រុនចាញ់ ចំណេះដឹងអំពីមេរោគអេដស៍/ជម្ងឺអេដស៍ ប្រេវ៉ាឡង់នៃមេរោគអេដស៍ ស្ថានភាពស្ត្រី និងអំពើហិង្សាក្នុងគ្រួសារ ។ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០៥ គឺជាអង្កេតលើកទីមួយនៅកម្ពុជា ដើម្បីផ្ដល់នូវការប៉ាន់ស្មានប្រេវ៉ាឡង់ដែលផ្អែកលើប្រជាជន សម្រាប់មេរោគអេដស៍ ។ លទ្ធផលនៃអង្កេត ដែលបានផ្សព្វផ្សាយក្នុងឆ្នាំ២០០៦ បានធ្វើបច្ចុប្បន្នភាពនិង/ឬផ្លាស់ប្ដូរ ទិន្នន័យឆ្នាំគោល២០០៥ សម្រាប់សូចនាករសុខភាពសំខាន់ៗ ដែលត្រូវបានកំណត់យកក្នុងការរៀបចំ *ផយអជ* ។ តារាង២.៥ ខាងក្រោម បង្ហាញទិន្នន័យចុងក្រោយបំផុត ។ ប្រការដែលត្រូវកត់

សម្គាល់នោះ គឺថា សូចនាករដែលទាក់ទងនឹងមរណភាពមាតានិងកុមារ មិនអាចធ្វើការប៉ាន់ស្មានប្រចាំឆ្នាំបានទេ តែអាចធ្វើការវាស់វែងបានរាល់ប្រាំឆ្នាំ តាមរយៈ ការធ្វើអង្កេតប្រជាសាស្ត្រនិងសុខភាព ។ ប្រការដែលជាក់ច្បាស់នោះ គឺថា វឌ្ឍនភាពកន្លងមក កំពុងស្ថិតនៅក្នុងគន្លងត្រូវ ដើម្បីឈានទៅសម្រេចបាននូវចំណុចដៅនានា ដែលបានកំណត់សម្រាប់ឆ្នាំ២០១០ និង ២០១៥ លើកលែងតែមរណភាពមាតា។

### តារាង ២.៥ : វិស័យសុខាភិបាល : វឌ្ឍនភាពសំខាន់ៗ និង ចំណុចដៅ

| | ចំណុចដៅ និងសូចនាករ | ២០០៥ | ២០១០ (ចំណុចដៅ) | ២០១៥ (ចំណុចដៅ) |
|---|---|---|---|---|
| ១ | អត្រាមរណភាពកុមារក្រោមអាយុ ១ឆ្នាំ ក្នុង ១.០០០ កំណើតរស់ | ៦៦ | ៦០ | ៥០ |
| ២ | អត្រាមរណភាពកុមារ អាយុក្រោម ៥ឆ្នាំ ក្នុង ១.០០០ កំណើតរស់ | ៨៣ | ៧៥ | ៦៥ |
| ៣ | ភាគរយនៃកុមារអាយុក្រោម ១ឆ្នាំ ទទួលវ៉ាក់សាំងការពារជម្ងឺខាន់ស្លាក់-ក្អកមាន់-តេតាណូស និងជម្ងឺរលាកថ្លើមប្រភេទបេ លើកទី៣ | ៨៣ | ៩២ | ៩៥ |
| ៤ | ភាគរយនៃកុមារអាយុក្រោម ១ឆ្នាំទទួលវ៉ាក់សាំងការពារជម្ងឺកញ្ជ្រឹល | ៨០ | ៨៥ | ៩០ |
| ៥ | អត្រាមរណភាពមាតា ក្នុង ១០០.០០០ កំណើតរស់ | ៤៧២ | ២៤៣ | ១៤០ |
| ៦ | ប្រេវ៉ាឡង់ មេរោគអេដស៍/ជម្ងឺអេដស៍(%នៃមនុស្សពេញវ័យ ១៥-៤៩) | ០,៩ | <០,៦ | <០,៦ |
| ៧ | ករណីជម្ងឺគ្រុនចាញ់ : ទទួលការព្យាបាលនៅមូលដ្ឋានសុខភាពសាធារណៈ ក្នុងចំណោមប្រជាជនមួយពាន់នាក់ | ៧,៣ | ៣,៥ | ៣ |
| ៨ | ប្រេវ៉ាឡង់ជម្ងឺរបេង ក្នុងចំណោមអ្នកពិនិត្យសួត ១០០.០០០នាក់ | ២៦៩* | ២១៤ | ១៣៥ |

*ប្រភព : ក្រសួងសុខាភិបាល --(*) ប្រភព : អង្កេតប្រេវ៉ាឡង់ជម្ងឺរបេងជាតិ នៅកម្ពុជា ឆ្នាំ២០០២*

២.៨០ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០៥ បានកត់សម្គាល់ថា ខណៈដែលមានការប្រែប្រួលរវាង តំបន់ទីប្រជុំជន និងតំបន់ដាច់ស្រយាល ឬតំបន់ជនបទ មធ្យមភាគជាតិសរុប បង្ហាញថា :

- មាន"ការថយចុះគួរឱ្យកត់សម្គាល់" នៃមរណភាពទារក ដោយធ្លាក់ចុះ ៣០ភាគរយ តាំងពីឆ្នាំ២០០០។
- ពីរភាគបីនៃកុមារអាយុ១២-២៣ខែ បានទទួលការផ្តល់ថ្នាំបង្ការសំខាន់ៗ ។
- ស្ត្រី ៦៨ភាគរយ[៥] បានទទួលការថែទាំមុនពេលសម្រាលកូន បើធៀបទៅនឹងឆ្នាំ២០០០ ដែលមានតែ ៣៨ភាគរយ ប៉ុណ្ណោះ ។
- ៤៤ភាគរយនៃការសម្រាលកូន ត្រូវបានធ្វើដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ គឺកើនឡើងពី ៣៣ភាគរយ ក្នុងឆ្នាំ២០០០ ។
- ប្រេវ៉ាឡង់មេរោគអេដស៍មានកម្រិត ០,៩ភាគរយ[១] គឺទាបជាងពាក់កណ្តាល នៃ ១,៩ភាគរយ ដែលបានប៉ាន់ស្មានពីពេលមុន សម្រាប់ឆ្នាំ២០០៥ ។

---

[១] អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០៥ បានកំណត់តួលេខនេះ ស្មើនឹង ០,៦ភាគរយ ប៉ុន្តែការឯកភាពគ្នាក្នុងពេលក្រោយមកទៀត ក្នុងចំណោមអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ បានកែសម្រួលតួលេខនេះ ទៅជា ០,៩ភាគរយ វិញ ។

អត្រាមរណភាពមាតាមិនមានភាពប្រសើរឡើងច្រើនទេ ចាប់តាំងពីឆ្នាំ២០០០ មក ប៉ុន្តែប្រការនេះត្រូវចាត់ទុកថា ជាសូចនាករមួយដែលមានការប្រែប្រួលយឺត ។ ដោយសារការសម្រាលកូន កំពុងត្រូវបានធ្វើកាន់តែច្រើនឡើងដោយអ្នកដែលមានជំនាញ នៅមណ្ឌលសុខភាពនានា វឌ្ឍនភាពគួរឱ្យកត់សម្គាល់ អាចនឹងបង្ហាញឱ្យឃើញ នៅក្នុងឆ្នាំ២០១០ ។

២.៨១ សមិទ្ធផលមួយចំនួន នៅក្នុងចំណោមសមិទ្ធផលសំខាន់ៗផ្សេងទៀត ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ រួមមាន :

នៅចុងបញ្ចប់នៃ*ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល (ផែនការយុទ្ធសាស្ត្រឆ្នាំ២០០៣-២០០៧)* ផែនការថ្មីមួយសម្រាប់ឆ្នាំ២០០៨-២០១៥ ត្រូវបានបង្កើតឡើង ហើយកំពុងត្រូវបានអនុវត្ត ដោយមានកិច្ច-សហប្រតិបត្តិយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។ ការអនុវត្តសំណុំសកម្មភាពអប្បបរមា កំពុងវិវត្តទៅមុខបានល្អ ។

សូចនាករបណ្ដោះអាសន្ន ដែលមានតាំងពីឆ្នាំ២០០៥ បង្ហាញថា លទ្ធភាពទទួលបាន និងការផ្ដល់ នូវសេវាកម្ម បានបន្តមានភាពប្រសើរឡើង ហើយបច្ចុប្បន្ននេះ ប្រជាជនកម្ពុជាមានមណ្ឌលសុខភាព ដែលមានលក្ខណៈល្អប្រសើរជាងមុនច្រើន ។ អាហារូបត្ថម្ភរបស់កុមារ បានបន្តមានភាពប្រសើរឡើងផងដែរ ។

ចំនួនមណ្ឌលសុខភាពដែលផ្ដល់ សំណុំសកម្មភាពអប្បបរមា បានកើនឡើងដល់ ៤៤៧ ក្នុងឆ្នាំ២០០៧។

ចំនួនមន្ទីរពេទ្យបង្អែកដែលមានសំណុំសកម្មភាពបំពេញបង្គ្រប់ បានកើនឡើងពី ៦៩ក្នុងឆ្នាំ២០០៥ ដល់ ៧៤ ក្នុងឆ្នាំ២០០៧ ។

ការពិនិត្យព្យាបាលដោយឥតបង់ថ្លៃ សម្រាប់អ្នកជម្ងឺក្រីក្រ បច្ចុប្បន្ននេះ កំពុងត្រូវបានផ្ដល់ឱ្យ តាមរយៈមូលនិធិសមធម៌ នៅក្នុងស្រុកប្រតិបត្តិចំនួន ៣៦ ដោយបានកើនឡើងពីចំនួន ៧ ក្នុងឆ្នាំ២០០៣។ មន្ទីរពេទ្យជាតិចំនួន៦ និងស្រុកប្រតិបត្តិចំនួន៩ ក៏បានទទួលផងដែរ នូវការឧបត្ថម្ភធនពីរដ្ឋាភិបាល សម្រាប់ប្រជាជនក្រីក្រ ។

ករណីជម្ងឺគ្រុនចាញ់ដែលបានព្យាបាលនៅមណ្ឌលសុខភាពសាធារណៈ បានថយចុះពី ៧,៣ភាគពាន់ ក្នុងឆ្នាំ ២០០៥ មក ៤,០ភាគពាន់ ក្នុងឆ្នាំ២០០៧ ។

ការបែងចែកថវិកា និងការបញ្ចេញថវិកា សម្រាប់វិស័យសុខាភិបាល មានការកើនឡើង និងស្ថេរភាព ។

អង្គការក្រៅរដ្ឋាភិបាលចំនួនប្រហែល ១៣០ បានរួមចំណែកក្នុងការទ្រទ្រង់វិស័យសុខាភិបាល ដែលភាគច្រើននៃអង្គការទាំងនោះ កំពុងដំណើរការ នៅតំបន់ដាច់ស្រយាល ។

២.៨២ រាជរដ្ឋាភិបាលកម្ពុជា ផ្ដល់សារៈសំខាន់ដ៏ធំធេងដល់ការជំរុញសុខភាពល្អ (សុខភាពបន្តពូជ សុខភាពមាតា សុខភាពកុមារ និងសុខភាពទារក) និងអាហារូបត្ថម្ភនិងការការពារជាមុន ការរកឃើញនិងការព្យាបាល

ទាន់ពេលវេលានូវជម្ងឺទាំងឡាយ ក្នុងចំណោមប្រជាជន ដែលជាមធ្យោបាយមួយនៃការអភិវឌ្ឍធនធានមនុស្ស ដែលមានសារៈសំខាន់សម្រាប់វឌ្ឍនភាពប្រកបដោយចីរភាពផ្សេងទៀត ។ ការបែងចែកពីថវិកាជាតិ គិតទាំងតាមតម្លៃដាច់ខាតនិងតម្លៃធៀប នឹងបន្តកើនឡើង នៅក្រោមការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ក្នុងចំណោមបញ្ហាប្រឈមដែលនៅតែបន្តមានទាំងអស់ រួមមាន :

- ធ្វើឱ្យប្រសើរឡើងនូវបញ្ហាបុគ្គលិក និង បង្កើនបុគ្គលិកនៅមណ្ឌលសុខភាពនានានៅតំបន់ដាច់ស្រយាល រួមទាំង ការធ្វើឱ្យមានឆ្នបជំនាញនៅបម្រើការងារនៅទីនោះ ដោយដោះស្រាយបញ្ហា ដែលមាននៅក្នុងការជ្រើសរើស និងការផ្តល់ការងារដល់បុគ្គលិក ។
- ធ្វើឱ្យប្រសើរឡើង និងបង្កើន លំហូរផ្នែកហិរញ្ញវត្ថុ និង ការគាំទ្រផ្នែកសំភារៈ ដូចជា ឱសថ និងសំភារៈបរិក្ខានានា ទៅដល់មណ្ឌលសុខភាពទាំងឡាយ ។
- ជំរុញការអនុវត្តបទប្បញ្ញត្តិច្បាប់ផ្នែកសុខាភិបាល និងជំរុញការអនុវត្ត តាមការណែនាំជាស្តង់ដារ និងការធានា គុណភាពនិងការអនុវត្ត ។
- បញ្ចូលអ្នកផ្គត់ផ្គង់ផ្នែកឯកជន និងសេវាកម្មរបស់ពួកគេ មកក្នុងក្របខ័ណ្ឌនៃការអនុវត្តគោលនយោបាយសុខាភិបាលជាតិ ឱ្យបានប្រសើរជាងមុន ។

២.៨៣ *មេរោគអេដស៍/ជម្ងឺអេដស៍* : ក្រៅពីការបង្ហាញនូវកម្រិតទាបជាងខ្លាំងនៃការឆ្លង ដែលត្រូវបានប៉ាន់ស្មានពីដំបូង (ថយចុះដល់ ០,៩ភាគរយ[១] ពីតួលេខប៉ាន់ស្មានលើកមុន ១,៩ភាគរយ ក្នុងក្រុមអាយុ ១៥-៤៩) ការអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០០៥ បានបញ្ជាក់ច្បាស់ថា កម្មវិធីគាំទ្រ កម្មវិធីអប់រំនិងការលើកកម្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា បាននាំមកនូវលទ្ធផលគួរជាទីសង្ឃឹម ឧទាហរណ៍ ការយល់ដឹងពីមេរោគអេដស៍/ជម្ងឺអេដស៍ក្នុងចំណោមប្រជាជន មានកម្រិតខ្ពស់ ហើយជាង ៨០ភាគរយ នៃស្ត្រីនិងបុរស អាយុ ១៥-៤៩ឆ្នាំ ដឹងពីវិធី សំខាន់បីយ៉ាង នៃការបង្ការការឆ្លងមេរោគអេដស៍ ។ កម្មវិធីចម្រុះដ៏ល្អសម្រាប់ការបង្កើតការយល់ដឹងពីមេរោគអេដស៍/ជម្ងឺអេដស៍ ការការពារជាមុន ការធ្វើតេស្ត ការគាំទ្រមតិនិងសេវាគាំទ្រ និងការផ្តល់ការផ្គត់ផ្គង់ បានធ្វើឱ្យមានការចូលរួមពីសំណាក់អ្នកមានចំណែកពាក់ព័ន្ធទាំងអស់ តាមរបៀបមួយដែលមានការសម្របសម្រួលខ្ពស់ ។ ទោះបីជា ចំណុចដៅនៃអត្រាប្រេវ៉ាឡង់ ដែលត្រូវបានកំណត់ឱ្យនៅទាបជាង ០,៦ភាគរយ នៅឆ្នាំ២០១០ អាច នឹងសម្រេចបានក៏ដោយ ក៏បញ្ហាដែលយើង នឹងប្រឈមនៅក្នុងពេលខាងមុខ នឹងកាន់តែមានភាពលំបាក ដោយសារអត្រាប្រេវ៉ាឡង់ស្ទួល ត្រូវបានសម្រេច រួចហើយ ហើយដោយសារនៅក្នុងគ្រួសារទាំងឡាយ ការឆ្លងពីប្តីទៅប្រពន្ធ និងពីម្តាយទៅកូន នឹងអាចមានការកើនឡើងគួរឱ្យព្រួយបារម្ភ ។

[១] អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០៥ បានកំណត់តួលេខនេះ ស្មើនឹង ០,៦ភាគរយ ប៉ុន្តែការឯកភាពគ្នាក្នុងពេលក្រោយមកទៀតក្នុងចំណោមអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ បានកែសម្រួលតួលេខនេះ ទៅជា ០,៩ភាគរយ វិញ ។

២.៨៤ **សមភាពយេនឌ័រ:** ការលុបបំបាត់វិសមភាពយេនឌ័រ និងការលើកកម្ពស់យ៉ាងសកម្មនូវសិទ្ធិស្ត្រី និងស្ថានភាពស្មើភាពគ្នារបស់បុរស និងស្ត្រី នៅគ្រប់វិស័យនៃការអភិវឌ្ឍ មានសារៈសំខាន់ណាស់នៅក្នុងរបៀបវារៈសម្រាប់វឌ្ឍនភាពនៅប្រទេសកម្ពុជា ដែលស្ដែងឡើងតាមរយៈ ការតាមដាននិងអនុវត្តផែនការយុទ្ធសាស្ត្រ ៥ឆ្នាំសម្រាប់ស្ត្រី ដែលហៅថា *ផែនការនារីរតនៈទីពីរ* និងដែលគ្របដណ្ដប់លើគ្រប់វិស័យទាំងអស់ ។

២.៨៥ ចាប់តាំងពីការរៀបចំ *ផយអជ* មក កិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្ម បានបន្តធ្វើឡើង ដើម្បីលើកកម្ពស់ការបញ្ជ្រាបយេនឌ័រនៅគ្រប់ស្រទាប់នៃសង្គមកម្ពុជា រួមមាននៅក្នុងគោលនយោបាយ និងកម្មវិធីជាតិ ផែនការយុទ្ធសាស្ត្រតាមវិស័យ និងការរៀបចំផែនការវិនិយោគ និងថវិកាអភិវឌ្ឍន៍ឃុំសង្កាត់ ។ កិច្ចខំប្រឹងប្រែង ដើម្បីលើកម្ពស់សិទ្ធិ និងតួនាទីស្ត្រីនៅកម្ពុជាទាំងនេះ នឹងត្រូវបន្តអនុវត្តយ៉ាងហ្មត់ចត់ ។ ទោះជាដូចនេះក្ដី ការយល់ដឹងនិងសមត្ថភាពជាតិក្នុងការវិភាគអំពីបញ្ហាសមភាពយេនឌ័រ រួមទាំង អត្រាអក្ខរកម្មក្នុងចំណោមស្ត្រីពេញវ័យ និងតម្រូវការធនធានថវិកាសម្រាប់លើកកម្ពស់សមភាពយេនឌ័រតាមវិស័យ នៅមានកម្រិតនៅឡើយ ។ ប្រការនេះទាមទារឱ្យមានការ ប្ដេជ្ញាយ៉ាងមុតមាំ និងកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធ ក្នុងចំណោមភាគីពាក់ពន្ធ័ទាំងអស់ ។ សមិទ្ធផលសំខាន់ៗ រួមមាន:

មកទល់ពេលនេះ ក្រុមការងារបញ្ជ្រាបយេនឌ័រចំនួន ២៥ ត្រូវបានបង្កើតឡើង នៅតាមក្រសួង-ស្ថាប័ននានា ហើយក្រសួង-ស្ថាបន័ចំនួន ១៥ បានរៀបចំបង្កើតផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ តាមវិស័យរួចហើយ ដែលក្នុងចំណោមនោះ ក្រសួងចំនួន៦ បាននឹងកំពុងអនុវត្តផែនការរបស់ខ្លួន ដោយប្រើប្រាស់ថវិកាជាតិ និងជំនួយឧបត្ថម្ភរបស់ដៃគូអភិវឌ្ឍន៍ ។

សមាមាត្រស្ត្រីដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ បានកើនឡើងពី ៨ភាគរយ ក្នុងឆ្នាំ ២០០២ ដល់ ១៥ភាគរយ ក្នុងឆ្នាំ២០០៧ ។ រាជរដ្ឋាភិបាលកម្ពុជា កំពុងដំណើរការរៀបចំតែងតាំងស្ត្រីជា អភិបាលរងនៃខេត្ត-ក្រុង ស្រុក-ខណ្ឌ នៅទូទាំង ២៤ ខេត្ត-ក្រុង ។ ទន្ទឹមនឹងនោះ សេចក្ដីណែនាំស្ដីពីការកំណត់កូតាសម្រាប់ស្ត្រី ក្នុងការជ្រើសរើសមន្ត្រីរាជការ ត្រូវបានប្រកាសដាក់ឱ្យអនុវត្ត ។

កិច្ចខិតខំប្រឹងប្រែង បានបន្តធ្វើឡើងដើម្បីបង្កើនស្ថានភាពប្រាក់ចំណូលរបស់ស្ត្រី តាមរយៈ ការបង្កើនកាលានុវត្តភាពការងារ ការគាំទ្រសហគ្រាសធុនតូចនិងមធ្យម និងការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ដើម្បីផ្ដល់ជំនាញវិជ្ជាជីវៈ ជំនាញសហគ្រិន និងសេវាប្រឹក្សាអាជីវកម្ម នៅក្នុងខេត្ត-ក្រុងចំនួន ១១ ។

*ផែនការជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រី* ត្រូវបានរៀបចំឡើង និងកំពុងចាប់ផ្ដើមអនុវត្ត ដោយ អនុលោមទៅតាមច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះដែលបានអនុមត័នៅក្នុងឆ្នាំ២០០៥ ។ ប៉ុន្តែអំពើហិង្សាលើស្ត្រី នៅតែមានកម្រិតខ្ពស់នៅឡើយ នៅក្នុងសង្គមកម្ពុជា ។

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ បានទទួលការអនុម័ត ពីរដ្ឋសភាជាតិ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ដោយអនុលោមទៅតាមពិធីសារអង្គការសហប្រជាជាតិ ។

២.៨៦ **បញ្ហាប្រជាជន** : គោលនយោបាយជាតិប្រជាជនដ៏មានសារៈសំខាន់ និងដែលត្រូវបានរៀបចំឡើងបានល្អ ពាក់ព័ន្ធនឹងសកម្មភាពនានា នៅក្នុងវិស័យជាច្រើន ដូចជា សុខាភិបាល អប់រំ បរិស្ថាន ម៉ាក្រូសេដ្ឋកិច្ច យេនឌ័រ បម្លាស់ទីលំនៅ យុវជន ជនចាស់ជរា និងផ្នែកផ្សេងៗទៀត ។ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងបន្តអភិវឌ្ឍសមត្ថភាពធនធានមនុស្ស សម្រាប់ការដាក់បញ្ចូលនូវបញ្ហាប្រជាជនទាំងឡាយ ទៅក្នុងដំណើរការនៃផែនការអភិវឌ្ឍន៍នៅគ្រប់កម្រិត សម្រាប់អ្នករៀបចំផែនការនិងអ្នករៀបចំគោលនយោបាយ ។ អង្កេតប្រជា-សាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០៥ បាននូវផ្តល់ទិន្នន័យថ្មីៗ ដែលបង្ហាញពីលទ្ធផល វិជ្ជមាននៃការអនុវត្តគោល-នយោបាយ នេះ ។ សមិទ្ធផលសំខាន់ៗជាច្រើនក្នុងរយៈពេលពីរឆ្នាំកន្លះនេះ រួមមាន :

ការធ្វើជំរឿនប្រជាជនដប់ឆ្នាំម្តង ត្រូវបានធ្វើឡើងនៅខែមីនា ឆ្នាំ២០០៨ បន្ទាប់ពីការរៀបចំ ដោយប្រុងប្រយ័ត្ននិងដោយល្អិតល្អន់ ។ ការងារនេះត្រូវបានឡើងដោយបុគ្គលិកកម្ពុជាទាំងស្រុង ដែលចង្អុលបង្ហាញពីសមត្ថភាពដែលត្រូវបានកសាងឡើង សម្រាប់ការរាប់និងការងារវិភាគដ៏ធំបែបនេះ ។ ដោយបានប្រើប្រាស់នូវអ្នករាប់ប្រមាណ ៣៥.០០០នាក់ និងបានគ្របដណ្តប់លើ គ្រួសារទាំងអស់ (២,៨ លាន) និងលើប្រជាជនបណ្តោះអាសន្ន ការធ្វើជំរឿននេះ គឺជាការងារមួយដ៏ធំ ដែលត្រូវបានធ្វើឡើងប្រកបដោយប្រសិទ្ធភាព និងប្រកបដោយជោគជ័យ ។ ការវិភាគទិន្នន័យ ដែលមាននៅក្នុងកម្រងសំណួរនៃការរាប់ឥឡូវនេះកំពុងតែដំណើរការ ហើយនឹងផ្តល់នូវព័ត៌មានដ៏មានតម្លៃ ក្នុងរយៈពេលខាងមុខ សម្រាប់ការរៀបចំឬការកែតម្រូវគោលនយោបាយ ក្នុងពេលខាងមុខ ។

លទ្ធផលដំបូងដែលត្រូវបានប្រកាសផ្សាយនៅក្នុងដើមខែកញ្ញា ឆ្នាំ២០០៨ បានបង្ហាញថា នៅក្នុងកម្រិតជាតិទាំងមូល ប្រជាជនសរុបមាន ១៣,៤លាននាក់ តិចជាងការប៉ាន់ស្មានពីមុន ដែលមានប្រមាណ ១៣,៨លាននាក់ ដោយមានសមាមាត្រប្រមាណ ២,៣ភាគរយ នៃប្រជាជននៅអាស៊ីអគ្នេយ៍ទាំងមូល ដែលមាននៅក្នុងឆ្នាំ២០០៨ ។ អត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំ គិតចាប់តាំងពីការធ្វើជំរឿនចុងក្រោយក្នុងឆ្នាំ១៩៩៨ មានប្រមាណ ១,៥៤ភាគរយ តិចជាងការប៉ាន់ស្មានពីមុន ដែលមាន ១,៨ភាគរយ ប៉ុន្តែនៅតែខ្ពស់ជាងកម្រិតមធ្យមសម្រាប់តំបន់បន្តិចនៅឡើយ (១,៣ភាគរយ) ។ សមាមាត្រភេទ គឺ ស្ត្រីមាន ៩៤,២ភាគរយ ធៀបនឹងបុរស ១០០នាក់ ដោយកើនឡើងពី ៩៣ភាគរយ នៅក្នុងឆ្នាំ១៩៩៨ ។ ទំហំមធ្យមរបស់គ្រួសារ បានថយចុះមកនៅត្រឹម ៤,៨ ធៀបនឹងទំហំ ៥,២ ដែល មាននៅក្នុងឆ្នាំ១៩៩៨ ។ ប្រជាជននៅទីប្រជុំជនមាន ១៩,៥ភាគរយ ដោយបានកើនឡើងពី ១៧,៤ភាគរយ ដែលមាននៅក្នុងឆ្នាំ ១៩៩៨ ។ ផ្ទុយមកវិញ ប្រជាជននៅតំបន់ជនបទ មាន ៨០,៦ភាគរយ ដោយបានថយពី ៨២,៤ភាគរយ ដែលមាននៅក្នុងឆ្នាំ១៩៩៨ ។

តួលេខដំបូងដែលត្រូវបានលើកឡើងខាងលើ បានរំលេចយ៉ាងច្បាស់ពីជោគជ័យក្នុងការអនុវត្តគោល-នយោបាយជាតិប្រជាជន របស់រាជរដ្ឋាភិបាលកម្ពុជា ។

ស្ត្រីស្ទើរតែទាំងអស់ បានស្គាល់ច្បាស់ពីវិធីសាស្ត្របង្ការកំណើត ក្នុងនោះ ស្ត្រីរៀបការរួចចំនួន ៤០ភាគរយ កំពុងប្រើវិធីសាស្ត្រពន្យារកំណើត ហើយ ២៧,២ភាគរយ កំពុងប្រើវិធីពន្យារកំណើតទំនើប ។ ស្ត្រីអាយុ ១៥-៤៩ឆ្នាំ ចាប់ផ្តើមមានកូននៅក្នុងអាយុមធ្យម ២២ឆ្នាំ ។ ការមានកូនក្នុងវ័យជំទង់ គឺជាករណីកម្រ គឺមានតែប្រហែល ៨ភាគរយនៃស្ត្រីអាយុ ១៥-១៩ឆ្នាំ ដែលចាប់ផ្តើមមានកូន ។ អាយុមធ្យមនៃការរៀបការដំបូង គឺ ២១ឆ្នាំសម្រាប់ស្ត្រី ។ ចន្លោះរវាងកំណើត គឺមានរយៈពេលវែងបង្គួរនៅកម្ពុជា ។

អត្រាភាពបង្កើតកូនសរុបបានថយចុះពី ៤ ក្នុងស្ត្រីម្នាក់ក្នុងឆ្នាំ២០០០ មក ៣,៤ ក្នុងស្ត្រីម្នាក់ ក្នុងឆ្នាំ២០០៥ (អង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ឆ្នាំ២០០៥)។ ចំនួនកូនដែលចង់បានជាមធ្យមក្នុងស្ត្រីម្នាក់គឺ ៣,៣ ។

រចនាសម្ព័ន្ធអាយុនៃប្រជាជនកម្ពុជា បានប្រែប្រួល ធៀបទៅនឹងឆ្នាំ២០០០ ។ អង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ឆ្នាំ២០០៥ បង្ហាញថា សមាមាត្រប្រជាជន អាយុ ១៥-៦៤ឆ្នាំ មាន ៥៧ភាគរយ អាយុក្រោម ១៥ឆ្នាំ មាន៣៩ភាគរយ និងអាយុ ៦៥ឆ្នាំ និងលើស ៦៥ឆ្នាំ មាន ៥ភាគរយ ។ ព័ត៌មានលម្អិតជាងនេះ នឹងបានមកពីការវិភាគតួលេខជំរឿនទូទៅនៃប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨។

# ជំពូកទី៣

## គោលដៅនិងចំណុចដៅអាទិភាព

៣.០១ ដូចដែលបានបញ្ជាក់ក្នុង *ផយអជ* រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យយ៉ាងច្បាស់លាស់ សម្រាប់រយៈពេលវែង និងមានការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការធ្វើឱ្យសម្រេចបាននូវកម្ពុជាមួយ ដែលមានការឯកភាពគ្នាក្នុងសង្គម មានការអប់រំចម្រើនជឿនលឿន មានវប្បធម៌ល្អរឹងមាំ គ្មានភាពក្រីក្រ គ្មានអនក្ខរភាព និងគ្មានសុខភាពអន់ថយ ដើម្បីឱ្យជនកម្ពុជាគ្រប់រូបអាចរស់នៅ ក្នុងភាពសុខដុម រួចផុតពីភាពអត់ឃ្លាន វិសមភាព ការដាក់ឱ្យនៅក្រៅសង្គម និងភាពងាយរងគ្រោះ ហើយដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបអាចឈានទៅសម្រេចបានយ៉ាងពេញលេញនូវសក្តានុពល ក្នុងការជ្រើសរើសមុខវិជ្ជាជីវៈ សំដៅចូលរួមចំណែកក្នុងការបន្តអភិវឌ្ឍប្រទេស និងការលើកកម្ពស់កម្រិតជីវភាព រស់នៅរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើងថែមទៀត ។ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា គូសបញ្ជាក់យ៉ាងច្បាស់នូវកម្មវិធីជាបន្ទាន់ដូចតទៅ (១) ជំរុញឱ្យមានកំណើនសេដ្ឋកិច្ច (២) ការបង្កើតការងារសម្រាប់ពលករកម្ពុជាទាំងអស់ (៣) ការអនុវត្តកំណែទំរង់ដែលចាំបាច់ ដើម្បីធានាបាននូវសមធម៌ និងយុត្តិធម៌សង្គម និង (៤) ការលើកកម្ពស់ប្រសិទ្ធភាពនៃកម្មវិធីកំណែទម្រង់ទាំងឡាយក្នុងវិស័យទាំងអស់ សំដៅការកាត់បន្ថយភាពក្រីក្រ និងការសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ។ ក្នុងបរិបទនេះ *ផយអជ លើកឡើងអំពីជំហានការងារ និងគោលដៅបន្ទាន់និងរយៈពេលមធ្យម ដែលត្រូវធ្វើនៅពេលអនាគត* ដើម្បីឈានទៅសម្រេចបានយ៉ាងឆាប់រហ័ស នូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ។

៣.០២ ការកាត់បន្ថយភាពក្រីក្រតាមរបៀបមួយដ៏ឆាប់តាមដែលអាចធ្វើបាន គឺជាអាទិភាពចម្បងបំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ដោយហេតុថា ៩០ភាគរយនៃប្រជាជនក្រីក្ររស់នៅតំបន់ជនបទ ការយកចិត្តទុកដាក់ជាអាទិភាព ចាំបាច់ត្រូវធ្វើឡើង តាមរយៈ *ផយអជ* ដើម្បីជំរុញល្បឿននៃការអភិវឌ្ឍនៅតំបន់ជនបទ ។ នៅក្នុងបរិបទនេះ ការសម្រេចបាននូវ *គអសក* ជាពិសេស ការកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍធនធានមនុស្ស គឺជាអាទិភាពខ្ពស់ ប៉ុន្តែ ប្រការទាំងនេះ ផ្អែកជាសំខាន់លើការផ្គុំគ្នានិងលទ្ធផលនៃកិច្ចអភិវឌ្ឍនិងស្ថានភាពជាច្រើនផ្សេងទៀត ដូចជា សន្តិភាព ស្ថេរភាពនយោបាយនិងសង្គម ការគ្រប់គ្រងដោយច្បាប់ ការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ កំណែទម្រង់សំខាន់ៗក្នុងរដ្ឋបាលសាធារណៈនិងក្នុងវិស័យនានា ការលើកកម្ពស់សមធម៌យេនឌ័រ កំណើនម៉ាក្រូសេដ្ឋកិច្ចភាពដែលប្រកបដោយស្ថេរភាព ចីរភាព សន្ទុះខ្លាំង សមធម៌ តុល្យភាព និងដោយមានការបែងចែកល្អប្រសើរ (ក្នុងចំណោមតំបន់ភូមិសាស្ត្រ វិស័យ និងរវាងបុរសនិងស្ត្រី) ហើយដែលទាក់ទងនឹងគ្រប់វិស័យទាំងអស់ផ្សេងទៀត ដោយវិស័យនីមួយៗមានគោលដៅនិងចំណុចដៅផ្ទាល់របស់ខ្លួន ។ *ផយអជ* កំណត់យ៉ាងច្បាស់ថា វឌ្ឍនភាពចម្បងៗ នឹងមិនអាចកើតមានបាន ប្រសិនបើមិនមាន ៖

កំណើនម៉ាក្រូសេដ្ឋកិច្ចប្រកបដោយសន្ទុះខ្លាំងក្លា និងសមធម៌ ។

អតិផរណាដែលត្រូវបានរក្សាឱ្យស្ថិតនៅកម្រិតមួយ ដែលអាចគ្រប់គ្រងបាន ។

ការកើនឡើងគួរឱ្យកត់សម្គាល់នូវផលិតភាពនិងផលិតកម្មកសិកម្ម ។

ការការពារនិងការលើកកម្ពស់បរិស្ថាននិងធនធានធម្មជាតិ ។

ការពង្រីកនិងពង្រឹងនូវ ការធ្វើឱ្យប្រសើរឡើងជាប្រចាំនូវហេដ្ឋារចនាសម្ព័ន្ធ ។

កំណើនគួរឱ្យកត់សំគាល់នៃវិស័យឧស្សាហកម្ម ដែលបង្កើតការងារនិងប្រាក់ចំណូល ។

កំណែទម្រង់សំខាន់ៗក្នុងផ្នែករដ្ឋបាលសាធារណៈ រួមទាំង កំណែទម្រង់ច្បាប់និងតុលាការ និងកំណែទម្រង់តាមវិស័យនានា ។

កំណើនឆាប់រហ័សក្នុងការវិនិយោគរបស់ផ្នែកឯកជន នៅក្នុងវិស័យជាច្រើនខុសៗគ្នា ដើម្បីធ្វើឱ្យវឌ្ឍនភាពមានមូលដ្ឋានទូលំទូលាយ និងមានសន្ទុះខ្លាំងក្លា ដោយកាត់បន្ថយការចំណាយអន្តរកម្ម ដែលសព្វថ្ងៃនេះ រារាំងដល់ការវិនិយោគបែបនេះ និងដោយរៀបចំឱ្យមាននីតិវិធីសមស្រប ។

កំណើនដែលគ្មានការរារាំងក្នុងពាណិជ្ជកម្មអន្តរជាតិ ដើម្បីសម្រួលការទាញយកប្រយោជន៍ពីឧត្តមភាពប្រៀបធៀបរបស់កម្ពុជាក្នុងការផ្គត់ផ្គង់ទំនិញនិងសេវាកម្មនៅលើទីផ្សារក្រៅប្រទេស ក្នុងលក្ខខណ្ឌប្រកួត-ប្រជែង ហើយបង្កើតឱ្យមានទំនាក់ទំនងទៅវិញទៅមករវាងភាពប្រសើរឡើងនៃពាណិជ្ជកម្មអន្តរជាតិ និងភាពមានការងារធ្វើនៅក្នុងវិស័យផ្សេងៗគ្នាជាច្រើន ដែលបង្កើតឱ្យមានប្រាក់ចំណូលពីប្រភពផ្សេងៗគ្នា ដូចជា ផលិតកម្ម ការកែច្នៃកសិផល ការវេចខ្ចប់ ការដឹកជញ្ជូន និងការលក់ដូរ ។

កំណើនឆាប់រហ័សក្នុងវិស័យសេវាកម្ម (រួមទាំងទេសចរណ៍) ដើម្បីផ្ដល់ការងារ និងចំណូល ។ល។

៣.០៣ *ផយអជ* បានពិនិត្យពិចារណា លើរាល់ទិដ្ឋភាពសំខាន់ៗនៃតម្រូវការសេដ្ឋកិច្ច-សង្គមកិច្ចរបស់កម្ពុជា លើអាទិភាព គោលដៅនិងចំណុចដៅ និង*គអសក* ដែលបញ្ចូលគ្នាជាមួយនឹងកត្តាជាច្រើនផ្សេងទៀត រួមទាំងបញ្ហាអន្តរវិស័យ ដើម្បីនាំប្រទេសកម្ពុជាឱ្យបានលឿនទៅមុខ នៅលើផ្លូវទៅកាន់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចប្រកបដោយសមធម៌ ដោយផ្ដោតការយកចិត្តទុកដាក់ជាពិសេសលើការកាត់បន្ថយភាពក្រីក្រ ក៏ដូចជា លើការកាត់បន្ថយឱ្យបានច្រើននូវភាពខុសគ្នាតាមតំបន់ និងរវាងអ្នកមាននិងអ្នកក្រ ។ ក្នុងនាមជាក្របខណ្ឌដ៏ទូលំទូលាយមួយ ដើម្បីតម្រង់ទិសដល់ដំណើរការអភិវឌ្ឍន៍*ផយអជ* បានកំណត់តែគោលដៅនិងចំណុចដៅជាអាទិភាព ដោយទុកឱ្យវិស័យនីមួយៗ ធ្វើការកំណត់គោលដៅ ចំណុចដៅ និងយុទ្ធសាស្ត្រលម្អិត នៅក្នុងផែនការនិងយុទ្ធសាស្ត្រតាមវិស័យរៀងៗខ្លួន ។ គោលដៅនិងចំណុចដៅសំខាន់ៗក្នុងតារាង ៣.២ នៃ*ផយអជ* សម្រាប់ការកាត់បន្ថយភាពក្រីក្រដែលជាអាទិភាពខ្ពស់បំផុត នឹងនៅតែបន្តមានសុពលភាព ។ តារាង ៣.១ ខាងក្រោម ត្រូវបានរៀបចំឡើង

តាមលំនាំនៃតារាង ៣.២ នៃ*ផយអជ* ដោយមានការកែសម្រួលដែលបានធ្វើឡើង ដោយផ្អែកទៅតាមទិន្នន័យចុងក្រោយបំផុត ដែលមាននៅក្នុងឆ្នាំ២០០៥ ឆ្នាំ២០០៦ និងឆ្នាំ២០០៧ ។

៣.០៤ ទិន្នន័យនិងព័ត៌មានផ្សេងទៀត ដែលត្រូវបានបង្ហាញនៅក្នុងផ្នែកផ្សេងៗគ្នា ក្នុងជំពូក២ បានបង្ហាញពីវឌ្ឍនភាពដែលកើតមានឡើងរហូតមកដល់ពេលនេះ និងកម្មវិធីទាំងឡាយដែលត្រូវបានស្នើឡើងសម្រាប់ពេលខាងមុខ ។ ចំណុចដៅជាច្រើនដែលមានចែងនៅក្នុងតារាង ៣.២ ខាងក្រោម ត្រូវបានធ្វើការកែសម្រួល ដោយភាគច្រើនបំផុត ត្រូវបានកែសម្រួលឱ្យមានការកើនឡើង ដើម្បីបង្ហាញពីកម្រិតជាក់ស្តែងដែលអាចសម្រេចបាននៅឆ្នាំ២០១០។ តាមនិន្នាការដែលមានរហូតមកទល់ពេលនេះ និងវឌ្ឍនភាពដែលអាចមាន នៅពីរបីឆ្នាំខាងមុខប្រការដែលអាចលេចឡើងនោះ គឺថា ទោះបីជា គោលដៅនិងចំណុចដៅមួយចំនួន នឹងត្រូវអាចសម្រេចបាន ឬនឹងត្រូវអាចសម្រេចបានលើសពីការគ្រោងទុកក៏ដោយ ក៏នៅមានគោលដៅនិងចំណុចដៅមួយចំនួន ដែលពិបាកនឹងធ្វើឱ្យសម្រេចបាន ដូចដែលមានបង្ហាញ នៅក្នុងតារាង ៣.១ ខាងក្រោម ។

### តារាង ៣.១ : ស្ថានភាពនៃការសម្រេចបាននូវចំណុចដៅសំខាន់ៗ

| នឹងត្រូវសម្រេចបាន ឬ សម្រេចបានលើស | អាចមិនសម្រេចបាន |
|---|---|
| អត្រាមរណភាពទារក : ៦០ (ឆ្នាំ២០១០) & ៥០ (ឆ្នាំ២០១៥) | កម្រិតភាពក្រីក្រ : ២៥% ក្នុងឆ្នាំ២០១០ & ១៩.៥% ក្នុងឆ្នាំ២០១៥ |
| អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ : ៧៥ (ឆ្នាំ២០១០) & ៦៥ (ឆ្នាំ២០១៥) | ភាពក្រីក្រស្បៀងអាហារ : ១៣% (ឆ្នាំ២០១០) & ១០% (ឆ្នាំ២០១៥) |
| អត្រានៃការសម្រាលកូនដោយបុគ្គលិកជំនាញសុខាភិបាល : ៥៥% (ឆ្នាំ២០១០) & ៧០% (ឆ្នាំ២០១៥) | អត្រាមរណភាពមាតា : ២៤៣(ឆ្នាំ២០១០) & ១៤០ (ឆ្នាំ២០១៥) |
| ប្រេវ៉ាឡង់មេរោគអេដស៍/ជម្ងឺអេដស៍ : <0,៦% (ឆ្នាំ២០១០) | អត្រាគង់វង្ស : ថ្នាក់១-៦ ១០០% (ឆ្នាំ២០១០) & ១០០% (ឆ្នាំ២០១៥) |
| អត្រាពិតនៃការសិក្សានៅបឋមសិក្សា : ១០០% (ឆ្នាំ២០១០) | អត្រាពិតនៃការសិក្សានៅមធ្យមសិក្សា : ៥០% (ឆ្នាំ២០១០) ១០០% (ឆ្នាំ២០១៥) |
| អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ : ៥០% (ឆ្នាំ២០១០) | អត្រាគង់វង្ស : ថ្នាក់១-៩ ៥០% (ឆ្នាំ២០១០)& ១០០% (ឆ្នាំ២០១៥) |
| លទ្ធភាពទទួលបានទឹកស្អាតបរិភោគ - % នៃប្រជាជនជនបទ : ៤៥% (ឆ្នាំ២០១០) & ៥០% (ឆ្នាំ២០១៥) | លទ្ធភាពទទួលបានប្រព័ន្ធអនាម័យ % នៃប្រជាជនជនបទ ២៥% (២០១០) ៣០% (២០១៥) |
| កំណើន *ផសស* ប្រចាំឆ្នាំ : ៧% (២០១០) | |
| *ផសស* សម្រាប់មនុស្សម្នាក់ (ពាន់រៀល) - ២.៨៨៨ (២០១០) | |

***កំណត់សម្គាល់*** *: មានតែសូចនាករសំខាន់ៗ ដែលត្រូវបានយកមកបង្ហាញខាងលើនេះ ដោយដកស្រង់យកចេញពីតារាង ៣.២ ។ តួលេខទាំងឡាយជាចំណុចដៅនានា ដូចដែលបានបង្ហាញនៅក្នុងតារាង ៣.២ ។*

៣.០៥ រាជរដ្ឋាភិបាលកម្ពុជា នៅតែរក្សាការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីឈានសម្រេចបានគោលដៅ និងចំណុចដៅរួមទាំងអស់ ដែលបានកំណត់ក្នុងតារាង ៣.១ នៃ*ផយអជ* ព្រមទាំងគោលដៅនិងចំណុចដៅទាំងឡាយដែលត្រូវ បំបែកលម្អិតនៅតាមកម្រិតវិស័យ និងថ្នាក់ក្រោមជាតិ ។ រាជរដ្ឋាភិបាលកម្ពុជាមានការជឿជាក់ថាចំណុចដៅទាំងនោះ នឹងអាចសម្រេចបាន ប្រសិនបើធនធានមានគ្រប់គ្រាន់ និងត្រូវបានយកទៅប្រើប្រាស់សមស្រប សម្រាប់ការវិនិយោគនិងការអភិវឌ្ឍមនុស្ស ។ ដើម្បីសម្រេចបានជោគជ័យ រាជរដ្ឋាភិបាលកម្ពុជានឹងត្រូវអនុវត្តឱ្យបានខ្លាំងក្លានូវ រាល់យុទ្ធសាស្ត្រនិងសកម្មភាព ជាអាទិភាព តាមរយៈក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណ ជំហានទី២ ។

**តារាង ៣.២ : គោលដៅជាតិ និងសូចនាករសំខាន់ៗរបស់*ផយអជ* (ចំណុចដៅ)[១]**

**(*) - គោលដៅនិងចំណុចដៅរបស់*គអសក***

| | គោលដៅសំខាន់ៗ : ចំណុចដៅ/សូចនាករ | ២០០៥ | ២០១០ | គអសក-២០១៥ |
|---|---|---|---|---|
| | **លុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ (*)** | | | |
| ១* | ភាគរយនៃប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ២០០៤ | ៣៤,៦៧ | ២៥ | ១៩,៥ |
| ២* | ភាគរយនៃប្រជាជនតំបន់ជនបទ រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ២០០៤ | ៣៩,២ | | |
| ៣* | ប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រស្បៀងអាហារ ២០០៤ | ១៩,៧ | ១៣ | ១០ |
| | **លើកកម្ពស់ផលិតភាពនិងផលិតកម្មកសិកម្ម** | | | |
| ៤ | ទិន្នផលស្រូវក្នុងមួយហិកតា (តោន) | ២,៤៨ | ២,៨០ | |
| ៥ | ផ្ទៃដីស្រោចស្រព (រួមទាំងការស្រោចស្រពដោយប្រព័ន្ធធារាសាស្ត្រ) (%នៃផ្ទៃដាំស្រូវ) | ២០ | ២៥ | |
| ៦ | កំណែទម្រង់ដីធ្លី : ចំនួនប័ណ្ណកម្មសិទ្ធិដីធ្លីដែលផ្តល់ជូនកសិករ (%នៃផ្ទៃដីសរុប) | ១៥ | ២៤ | |
| | **លើកកម្ពស់ក្នុងវិស័យសុខាភិបាល (*)** | | | |
| ៧* | អត្រាមរណភាពទារក ក្នុង១.០០០កំណើតរស់ | ៦៦ | ៦០ | ៥០ |
| ៨* | អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ ក្នុង១.០០០កំណើតរស់ | ៨២ | ៧៥ | ៦៥ |
| ៩* | អត្រាមរណភាពមាតា ក្នុង១០០.០០០កំណើតរស់ | ៤៧២ | ២៤៣ | ១៤០ |
| ១០* | ការសម្រាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ (%) | ៤៤ | ៥៥ | ៨០ |
| ១១* | ប្រេវ៉ាឡង់មេរោគអេដស៍/ជម្ងឺអេដស៍ក្នុងចំណោមមនុស្ស ពេញវ័យអាយុពី១៥-៤៩ឆ្នាំ | ០,៩ | <០,៦ | <០,៦ |
| ១២* | ករណីជម្ងឺគ្រុនចាញ់ (កត់ត្រានៅក្នុងផ្នែកសាធារណៈ) ក្នុង ១.០០០នាក់ | ៧,៣ | ៣,៥ | |
| ១៣* | ករណីអ្នកផ្ទុកជម្ងឺរបេងក្នុង ១០០.០០០នាក់ | ២៦៩ | ២១៤ | ១៣៥ |
| ១៤* | ស្ត្រីរៀបការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើប (%) | ២០,១ | ៤០ | ៦០ |
| ១៥ | មណ្ឌលសុខភាពដែលផ្តល់សេវាសុខភាពបន្ទពូង | ៣៣ | ៤៥ | ៧០ |
| | **លើកកម្ពស់វិស័យអប់រំ (*)** | | | |
| ១៦* | អត្រាពិតនៃការសិក្សានៅបឋមសិក្សា : សរុប | ៩១,៩ | ១០០ | ១០០ |

[១] សូមអានព័ត៌មានពន្យល់នៅកថាខណ្ឌ ៣.១៣ ក្នុង*ផយអជ*

| | គោលដៅសំខាន់ៗ : ចំណុចដៅ/សូចនាករ | | ២០០៥ | ២០១០ | គអសហ-២០១៥ |
|---|---|---|---|---|---|
| | | ប្រុស | ៩៣.០ | ១០០ | ១០០ |
| | | ស្រី | ៨៩.៧ | ១០០ | ១០០ |
| ១៧* | អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ : | សរុប | ៣១.៣ | ៥០ | ១០០ |
| | | ប្រុស | ៣២.១ | ៥០ | ១០០ |
| | | ស្រី | ៣០.៤ | ៣៨ | ១០០ |
| ១៨* | អត្រាគង់វង្ស : ថ្នាក់១-៦ | | ៥៣.១ | ១០០ | ១០០ |
| ១៩* | អត្រាគង់វង្ស : ថ្នាក់១-៩ | | ២៩.៣ | ៥០ | ១០០ |
| ២០* | កុមារអាយុ ៦-១៤ឆ្នាំ មិនបានចូលរៀន (%) | | ១២.៣ | ១១ | 0 |
| | ***ការអភិវឌ្ឍជនបទ*** | | | | |
| ២១* | ផ្លូវជនបទដែលបានស្ដារ នៃប្រវែងផ្លូវសរុប ២៨.000 គម | | ២២.៧00 | ២៥.000 | ២៨.000 |
| ២២* | លទ្ធភាពទទួលបានទឹកស្អាតបរិភោគ (%នៃប្រជាជនជនបទ) | | ៤១.៦ | ៤៥ | ៥0 |
| ២៣* | លទ្ធភាពទទួលបានអនាម័យ (%នៃប្រជាជនជនបទ) | | ១៦.៤ | ២៥ | ៣0 |
| | ***ចីរភាពបរិស្ថាន (*)*** | | | | |
| ២៤* | ផ្ទៃដីគ្របដណ្ដប់ដោយព្រៃឈើ (%នៃផ្ទៃដីសរុប) | | ៥៩ | ៦0 | ៦0 |
| ២៥* | ការប្រើប្រាស់អុស-ធ្យូង : គ្រួសារ (%) | | ៨៣.៩ | ៦១ | ៥២ |
| ២៦* | ការទទួលបានប្រភពទឹកស្អាត (%នៃប្រជាជនទីប្រជុំជន) | | ៣៥ | ៧៥ | ៨0 |
| ២៧* | ការទទួលបានប្រព័ន្ធអនាម័យប្រសើរជាងមុន (%នៃប្រជាជនទីប្រជុំជន) | | ៥៥ | ៦៧ | ៧៤ |
| | ***សមធម៌យេនឌ័រ (*)*** [១] | | | | |
| ២៨ | បញ្ជ្រាបយេនឌ័រនៅគ្រប់មជ្ឈដ្ឋាន | | | | |
| ក | ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ | | ២ | ២៧ | |
| ខ | ក្រសួង-ស្ថាប័នដែលបានអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ | | ២ | ១៥ | ២៧ |
| ២៩* | ការចូលរួមរបស់ស្ត្រីក្នុងការងារទទួលកម្រៃគ្រប់វិស័យ % : | វិស័យកសិកម្ម | ៥២.៥ | ៥0 | ៥0 |
| | | វិស័យឧស្សាហកម្ម | ៥៣.៥ | ៥0 | ៥0 |
| | | វិស័យសេវាកម្ម | ២៧.0 | ៣៧ | ៥0 |
| ៣0* | កម្រិតយល់ដឹងថា អំពើហិង្សាប្រឆាំងនឹងស្ត្រី ជាឥរិយាបទខុសឆ្គងនិងជាឧក្រិដ្ឋកម្ម(%) | | ៤.៥ | ៥0 | ១00 |
| ក | ដីការតុលាការ និងរដ្ឋបាល ដែលបានរៀបចំឡើង | | 0 | ៩0 | |
| ខ | ការទទួលបានសេវា | | ៩ | ៥00 | |
| | ***កំណែទម្រង់*** | | | | |
| ៣១ | បង្កើនល្បឿនកំណែទម្រង់អភិបាលកិច្ច | | នឹងត្រូវបង្កើតឡើង | | |
| | ***ធ្វើឱ្យមានស្ថេរភាពកំណើនម៉ាក្រូសេដ្ឋកិច្ចខ្ពស់ (*)*** | | | | |
| ៣២ | កំណើន *ផសស* ប្រចាំឆ្នាំ គិតតាមថ្លៃថេរ (%) | | ១៣.៣0 | ៧.0 | |

[១] ចំណុចដៅដែលពាក់ព័ន្ធនឹងយេនឌ័រ ត្រូវបានបង្ហាញដាច់ដោយឡែកនៅក្នុងវិស័យអប់រំ និងសុខាភិបាល

| | គោលដៅសំខាន់ៗ : ចំណុចដៅ/សូចនាករ | ២០០៥ | ២០១០ | គអសក-២០១៥ |
|---|---|---|---|---|
| ៣៣ | *ផសស* សម្រាប់មនុស្សម្នាក់ គិតតាមថ្លៃថេរ (ពាន់រៀល) | ១.៨៦២ | ៣.៥០៥ | |
| ៣៤ | អត្រាអតិផរណា | ៥.៨ | ៤.០ | |
| | ***កែលម្អការប្រើប្រាស់ថវិកា*** | | | |
| ៣៥ | ចំណូលថវិការដ្ឋសរុប : (% នៃ *ផសស*) | ១០.៦០ | ១៣.១០ | |
| ៣៦ | ចំណាយថវិការដ្ឋសរុប : (% នៃ *ផសស*) | ១៣.២ | ១៤.០ | |
| | ***បង្កើនល្បឿនកំណើនក្នុងវិស័យឧស្សាហកម្មនិងការងារ*** | | | |
| ៣៧ | កំណើនប្រចាំឆ្នាំក្នុងផ្នែកកម្មន្តសាល គិតតាមថ្លៃថេរ (%) | ៩.៧ | ៧.៨ | |
| ៣៨* | ពលកម្មកុមារអាយុ ៥-១៧ឆ្នាំ (%) | ២២.៣ | ១០.៦ | ៨.០ |
| | ***ទេសចរណ៍*** | | | |
| ៣៩ | ចំនួនភ្ញៀវទេសចរណ៍ប្រចាំឆ្នាំ (ពាន់នាក់) | ១.៤២០ | ៣.២០០ | ៥.០០០ |
| | ***ការបោសសម្អាតមីន ការជួយសង្គ្រោះជនរងគ្រោះ (*)*** | | | |
| ៤០* | ចំនួនជនរងគ្រោះដោយសារមីន (ស្លាប់ និងរបួស) | ៨៧៥ | ២០៥ | ០ |
| ៤១* | តំបន់ដែលបានបោសសម្អាតមីន និងកាកសំណល់យុទ្ធភ័ណ្ឌសេសសល់ពីសង្គ្រាម (%) | ៥០.៣ | ៧៧ | ១០០ |
| | ***ហេដ្ឋារចនាសម្ព័ន្ធ*** | | | |
| ៤២ | ផ្លូវក្រាលកៅស៊ូ (ផ្លូវជាតិនិងផ្លូវខេត្ត) លើប្រវែងផ្លូវសរុប ១១.៤៥៤ គម | ២.១០០ | ៤.១០០ | |
| | ***ថាមពល*** | | | |
| ៤៣ | ការប្រើប្រាស់ថាមពលអគ្គិសនី (គីឡូវ៉ាត់ម៉ោង/នាក់/ឆ្នាំ) | ៦២ | ១៥៩ | |

# ជំពូកទី៤

## ការកំណត់ចំណាយ ធនធាន និង ការរៀបចំកម្មវិធី

៤.០១ ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ មានសារៈសំខាន់ណាស់ សម្រាប់ការអនុវត្តប្រកបដោយជោគជ័យនិងទាន់ពេល នូវយុទ្ធសាស្ត្រទាំងឡាយរបស់ *ផយអជ* និងការសម្រេចបាននូវចំណុចដៅនានារបស់ *ផយអជ* ។ *ផយអជ* បានយកចិត្តទុកដាក់ពិនិត្យមើល ជាសំខាន់ លើការចំណាយរបស់វិស័យសាធារណៈ ប៉ុន្តែក៏បានធ្វើការប៉ាន់ស្មានផងដែរអំពីការវិនិយោគរបស់វិស័យឯកជន (ជំពូកទី៥របស់ *ផយអជ*) ។ ជំពូកនេះ បង្ហាញពី : (១) វឌ្ឍនភាពដែលកើតមានក្នុងរយៈពេលបីឆ្នាំ (២០០៦-២០០៨) នៅក្នុងចំណាយសរុបដែលត្រូវបានគ្រោងនៅក្នុង *ផយអជ* (២) តម្រូវការសរុបដែលបានកែសម្រួលឡើងវិញ សម្រាប់រយៈពេលទាំងមូលរបស់ *ផយអជ* (២០០៦-២០១០) ដោយផ្អែកលើស្ថានភាពជាក់ស្តែងដែលកំពុងលេចឡើង (៣) ការកែសម្រួលឡើងវិញនូវការធ្វើវិភាជន៍តាមវិស័យដែលមាននៅក្នុង *ផយអជ* និង (៤) បញ្ហាពាក់ព័ន្ធផ្សេងៗទៀត ។

៤.០២ ចំណាយលើការងារអភិវឌ្ឍន៍វិស័យសាធារណៈនៅក្នុងប្រទេសកម្ពុជា សម្រាប់រយៈពេលបីឆ្នាំដំបូង (២០០៦-២០០៨) របស់ *ផយជអ* ត្រូវបានប៉ាន់ស្មានថាមានប្រមាណ ២.២៥០លានដុល្លារអាមេរិក ឬប្រហាក់ប្រហែលនឹងកម្រិតតួលេខ ២.១០០លានដុល្លារ ដែលជាតួលេខចំណែកជាមធ្យម នៃតួលេខសរុបដែលត្រូវបានសន្មតយកនៅក្នុង *ផយអជ* គឺ ៣.៥០០លានដុល្លារ សម្រាប់រយៈពេលប្រាំឆ្នាំ ។ ការចំណាយ បានមកពីប្រភពពីរ (សូមអាន តារាង ៤.១ ផងដែរ) :

> ៦៥០លានដុល្លារអាមេរិក មានប្រភពមកពីអតិរេកថវិកាចរន្តប្រចាំឆ្នាំ ដែលរាជរដ្ឋាភិបាលកម្ពុជាបានចំណាយសម្រាប់ការងារអភិវឌ្ឍន៍ ។ អតិរេកនេះដែលមានសម្រាប់បីឆ្នាំ (២០០៦-២០០៨) នឹងអាចមានចំនួនរហូតដល់ ៧០០លានដុល្លារអាមេរិក[១] ដែលមានកម្រិតជិតពីរដង នៃកម្រិតដែលត្រូវបានប៉ាន់ស្មាន នៅក្នុងកថាខ័ណ្ឌ ៥.១២ នៃ *ផយអជ* ។ ដោយសន្មតថា បរិមាណនេះ អាចត្រូវបានយកទៅប្រើប្រាស់សម្រាប់អាទិភាពក្រៅ *ផយអជ* នោះការរួមចំណែកចំពោះអាទិភាពរបស់ *ផយអជ* អាចមានត្រឹមតែ ៦៥០លានដុល្លារអាមេរិក ។ ចំណែកដ៏ធំមួយនៃការចំណាយអភិវឌ្ឍន៍ក្នុងស្រុក គឺត្រូវបានផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ រួមទាំង ផ្លូវថ្នល់ជនបទ ការងារធារាសាស្ត្រ ការអភិវឌ្ឍជនបទ អប់រំ និងសុខាភិបាល) ។
>
> ១.៦០០លានដុល្លារអាមេរិក មានប្រភពមកពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។ បរិមាណសរុប ត្រូវបានប៉ាន់ស្មានថាមាន ២.២៦៤លានដុល្លារអាមេរិក នៅក្នុងរយៈពេលបីឆ្នាំ (២០០៦-២០០៨) ។ បរិមាណនេះ

---
[១] សូមអានតារាង ២.១

បានរួមបញ្ចូល ទាំងជំនួយបច្ចេកទេសដាច់ៗគ្នា[១] ទាំងកម្មវិធីនិងគម្រោងដែលក្រៅអាទិភាព*ផយអជ* ។ (ក) ជំនួយបច្ចេកទេសដាច់ៗគ្នា នឹងអាចមានប្រហែល ៦៣០លានដុល្លារអាមេរិក ធៀបនឹងចំណុចដៅ ៥០០លានដុល្លាអាមេរិក ដែលត្រូវបានប៉ាន់ស្មានសម្រាប់ប្រាំឆ្នាំ នៅក្នុង*ផយអជ* ដោយមានតួលេខមធ្យមភាគចំនួន ៣០០លានដុល្លារអាមេរិក សម្រាប់បីឆ្នាំ ឬដោយមានបរិមាណលើសចំនួន ៣៣០ លានដុល្លារអាមេរិក ។ (ខ) នៅក្នុងស្ថានភាពដែលមិនមានព័ត៌មានច្បាស់លាស់ពីការតម្រឹមតម្រង់កម្មវិធីរបស់ដៃគូអភិវឌ្ឍន៍ មកជាមួយនឹង*ផយអជ* ប្រការដែលត្រូវបានសន្និដ្ឋានយ៉ាងសាមញ្ញ[២] នោះគឺថាប្រហែល ៣៣៤លានដុល្លារអាមេរិក (ពោលគឺ ២០ភាគរយនៃតុល្យភាព គឺ ១.៦៣៤លានដុល្លារអាមេរិក ឬ ២.២៦៤ ដក ៦៣០) ត្រូវបានចំណាយលើការងារក្រៅអាទិភាពរបស់*ផយអជ* ។ ដោយដកចេញនូវបរិមាណ ៣៣០លានដុល្លារអាមេរិក ដែលជាចំណាយលើសសម្រាប់ជំនួយបច្ចេកទេសដាច់ៗគ្នា និងបរិមាណ ៣៣៤លានដុល្លារអាមេរិក ដូចបានរៀបរាប់ខាងលើ តុល្យភាពទុន ដែលត្រូវអាចប៉ាន់ស្មានថាត្រូវបានចំណាយលើអាទិភាពរបស់*ផយអជ* នឹងអាចមានចំនួនប្រមាណ ១.៦០០លានដុល្លារអាមេរិក (២.២៦៤ ដក ៦៣៤) ។

**តារាង ៤.១ : ការប៉ាន់ស្មានចំណាយអភិវឌ្ឍន៍របស់វិស័យសាធារណៈឆ្នាំ ២០០៦-២០០៨ (បីឆ្នាំ)**

**(លានដុល្លារអាមេរិក)**

| | | | |
|---|---|---|---|
| ១ | ធនធានក្នុងស្រុក (អតិរេកថវិកាចរន្ត) | ៧០០ | |
| | ដកចេញនូវ ចំណាយក្រៅអាទិភាពនៃ*ផយអជ*ដែលអាចមាន | ៥០ | ៦៥០ |
| ២ | ធនធានក្រៅប្រទេសពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស - ចំណាយប៉ាន់ស្មាន | ២.២៦៤ | |
| | ដកចេញនូវ ជំនួយបច្ចេកទេសដាច់ៗគ្នា[៣] និងចំណាយក្រៅអាទិភាពនៃ*ផយអជ* | ៦៦៤ | ១.៦០០ |
| | | | |
| ៣ | **ការប៉ាន់ស្មានចំណាយលើអាទិភាព*ផយអជ* ២០០៦-២០០៨** | | **២.២៥០** |

៤.០៣ សម្រាប់រយៈពេលសរុបប្រាំឆ្នាំរបស់*ផយអជ* ២០០៦-២០១០ ដោយគិតគូរដល់កត្តាទាំងអស់ដែលកំពុងលេចឡើង រួមទាំង កម្រិតនៃកំណើនដែលបានគ្រោងទុក ការប៉ាន់ស្មានចំពោះកម្រិតដែលមានលក្ខណៈប្រាកដនិយមនៃការវិនិយោគ ត្រូវបានកែសម្រួលឱ្យកើនឡើងពីកម្រិតសរុប ៦.៤០១,១០លានដុល្លារអាមេរិក

---

[១] សូមមើល ៧.០១ និង ៧.០២ នៅក្នុងតារាងសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ

[២] តួលេខនេះអាចមានកម្រិតលើសពី ២០% ដូចដែលមានចែងនៅក្នុងកថាខណ្ឌ ៤.០៩ ខាងក្រោម ។ ៩៥%នៃ*កវស* នៅតែមិនទាន់មានទុនសម្រាប់អនុវត្ត ។

[៣] ក្នុងកថាខណ្ឌ ៥.១៥ នៃ*ផយអជ* បានប៉ាន់ស្មានថា ៩៩,១%នៃធនធានរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ត្រូវបានចំណាយលើជំនួយបច្ចេកទេសដាច់ៗគ្នា

ដូចមាន ចែងនៅក្នុង*ផយអជ* (កថាខណ្ឌ ៥.០២ នៃ*ផយអជ*) ដល់ ១២.០៧៩,៥០លានដុល្លារអាមេរិក ដោយភាគច្រើនបំផុតនៃកំណើនទាំងនេះ បានមកពីការវិនិយោគក្នុងវិស័យឯកជន ដោយប្រភពហិរញ្ញវត្ថុ ទាំងក្នុងស្រុក និងក្រៅប្រទេស -- សូមអានតួលេខកែសម្រួលលម្អិត នៅក្នុងឧបសម្ព័ន្ធ ១.៣ ។ ទោះជាដូចនេះក្តី ដោយផ្អែកលើនិន្នាការក្នុងបីឆ្នាំដំបូង ២០០៦-២០០៨ (តារាង ៤.១) និងដោយគិតគូរដល់អតិផរណាខ្ពស់ដែលមានចាប់តាំងពីចុងឆ្នាំ២០០៧ ប្រការដែលអាចសន្និដ្ឋានបាន សម្រាប់ពេលបច្ចុប្បន្ន នោះគឺថា ចំណាយសរុបក្នុងវិស័យសាធារណៈ សម្រាប់រយៈពេលប្រាំឆ្នាំនៃ*ផយអជ* (២០០៦-២០១០) នឹងអាចមានដល់ ៤.២០០លានដុល្លារអាមេរិក ដោយមាន ៧០០លានដុល្លារអាមេរិក ឬ ២០ភាគរយ ច្រើនជាងកម្រិត ដែលត្រូវបានប៉ាន់ស្មាន នៅក្នុងកថាខ័ណ្ឌ ៥.០៦ នៃ*ផយអជ* ពោលគឺ ៣.៥០០លានដុល្លារអាមេរិក ដោយក្នុងនោះរួមទាំង កម្រិតអតិបរមា ៥០០លានដុល្លារអាមេរិក សម្រាប់ជំនួយបច្ចេកទេស ដូចមានចែងក្នុងកថាខ័ណ្ឌ ៥.១៤ នៃ*ផយអជ* ។

**តារាង ៤.២ : កម្រិតនៃការវិនិយោគសាធារណៈដែលត្រូវការចាំបាច់សម្រាប់ ២០០៦-២០១០ (ប្រាំឆ្នាំ)**

(លានដុល្លារអាមេរិក)

| | |
|---|---|
| ១. ការវិនិយោគសាធារណៈ ដូចមានចែងក្នុង ឧបសម្ព័ន្ធ ១.៣ | ២.៩៣៣ |
| ២. តម្រូវការចាំបាច់បន្ថែមសម្រាប់វិស័យអាទិភាព : កសិកម្ម ហេដ្ឋចេនាសម្ព័ន្ធ វិស័យសង្គមកិច្ច | ៧៦៧ |
| ៣. ជំនួយបច្ចេកទេសដាច់ៗគ្នា | ៥០០ |
| **ចំណាយសរុប ២០០៦-២០១០** | **៤.២០០** |

៤.០៤ ប្រភពទាំងឡាយដូចមានខាងក្រោម ត្រូវបានរំពឹងថា នឹងរួមចំណែកដល់ការទទួលបរិមាណទុនសរុប ចំនួន ៤.២០០លានដុល្លារអាមេរិក សម្រាប់ចំណាយក្នុងវិស័យសាធារណៈ :

ប្រភពធនធានក្នុងស្រុកប្រមាណ ១.៣០០លានដុល្លារ (អតិរេកថវិកាចរន្ត) ដោយមានការបូកបន្ថែមនូវអតិរេក ដែលអាចមានក្នុងឆ្នាំ២០០៩-២០១០ ទៅលើចំនួន ៦៥០លានដុល្លារអាមេរិក ដូចដែលបានបង្ហាញនៅក្នុងកថាខ័ណ្ឌ ៤.០២ ។ តួលេខនេះ មានកម្រិតខ្ពស់ជាងច្រើនពីតួលេខ ៧៧៥លានដុល្លារអាមេរិក ដែលត្រូវបានរំពឹងទុកនៅក្នុង*ផយអជ* ប៉ុន្តែ តួលេខដែលមានការកើនឡើងនេះ ត្រូវបានគិតគូរដោយផ្អែកលើការប៉ាន់ស្មានចុងក្រោយបំផុត ដែលមានលក្ខណៈប្រាកដនិយមច្រើនជាង ដោយយោងទៅតាមកម្រិតនៃអតិរេកដែលមាននៅក្នុងបីឆ្នាំដំបូង និងដែលត្រូវបានរំពឹងទុកសម្រាប់ពីរឆ្នាំបន្ទាប់ទៀត ។

ប្រភពធនធានក្រៅប្រទេសប្រមាណ ២.៧៥០លានដុល្លារអាមេរិក (ដែលបានមកពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ក្នុងនេះរាប់បញ្ចូលទាំង ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសមិនមែនប្រពៃណីយ៍) ដោយធ្វើការព្យាករណ៍ចេញពីតួលេខ ១.៦០០លានដុល្លារអាមេរិក ដូចដែលមានបង្ហាញ នៅក្នុងកថាខ័ណ្ឌ ៤.០២ ។

ប្រភពធនធានបន្ថែមប្រមាណ ២៥០លានដុល្លារអាមេរិក ដែលភាគច្រើននឹងបានមកពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសមិនមែនប្រពៃណីយ៍ ។

៤.០៥ ដើម្បីធានាថា ការខ្វះនូវធនធាននឹងមិនកើតមានឡើង សម្រាប់ការងារវិនិយោគ ប្រការដែលមានសារៈសំខាន់ខ្លាំង នោះគឺថា ទាំងការបែងចែកធនធានក្នុងស្រុក ទាំងជំនួយគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ត្រូវបានតម្រឹមតម្រង់យ៉ាងពេញលេញ ទៅនឹងអាទិភាពរបស់ *ផយអជ* ។ អាស្រ័យហេតុនេះ បញ្ហាប្រឈមចម្បងៗចំពោះមុខ គឺត្រូវធានាថា (នៅរាល់ពេលណាដែលអាចធ្វើទៅបាន តាមរយៈយន្តការនៃក្រុមការងារបច្ចេកទេសដែលត្រូវបានបង្កើតឡើងរួចហើយ) :

គ្រប់កម្មវិធីនិងសកម្មភាពកំពុងដំណើរការ ដែលមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ត្រូវបានពិនិត្យមើលឡើងវិញដោយយកចិត្តទុកដាក់ ហើយត្រូវបានតម្រឹមតម្រង់ទៅនឹងអាទិភាពរបស់ *ផយអជ*[១] ។

ជាពិសេស សមាសភាគនៃជំនួយជាជំនួយបច្ចេកទេសដាច់ៗគ្នា ត្រូវបានកាត់បន្ថយឱ្យបានច្រើនតាមដែលអាចធ្វើបាន ដើម្បីសម្រេចបាននូវ ការផ្ទេរធនធានសុទ្ធសាធសម្រាប់ការវិនិយោគ ឱ្យបានច្រើនបំផុត[២] ។

កម្មវិធីថ្មីទាំងអស់ដែលគាំទ្រដោយធនធានក្នុងនិងក្រៅប្រទេស ត្រូវបានផ្សារភ្ជាប់ទៅនឹងអាទិភាពរបស់ *ផយអជ* ។

ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងឡាយ នឹងផ្តល់ជំនួយតែក្នុងទម្រង់ ជាជំនួយឥតសំណង និងជាកម្ចីដែលត្រូវពិនិត្យពិចារណាច្បាស់លាស់ (ភាគច្រើនក្នុងទម្រង់ជាឥណទានសម្បទាន) ដែលត្រូវបានកម្រិតយ៉ាងច្បាស់ សម្រាប់តែគម្រោងវិនិយោគជាមូលធន នានា ។

ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (ទ្វេភាគីនិងពហុភាគី) ចាប់ផ្តើមលុបចោលបំណុលពីអតីតកាល ឱ្យបានឆាប់តាមដែលអាចធ្វើបាន ។

គ្រប់វិធីសាស្ត្រនៃការផ្តល់ជំនួយក្រៅប្រទេស នឹងប្រើប្រាស់នីតិវិធីនិងដំណើរការទាំងឡាយ ដែលត្រូវបានអនុម័តយករួចមកហើយដោយរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការងាររបស់ខ្លួន នៅក្នុងគោលបំណង

---

[១] កថាខណ្ឌ ៥.២៥នៃ *ផយអជ* បានអំពាវនាវយ៉ាងច្បាស់ដល់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស មិនត្រឹមតែសូមឱ្យបញ្ជាក់ពីបរិមាណសរុបរួម ដែលពួកគេសន្យាផ្តល់ឱ្យជាជំនួយដល់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសូមឱ្យបញ្ជាក់ឱ្យច្បាស់នូវ : បរិមាណទាំងឡាយដែលត្រូវបែងចែកសម្រាប់វិស័យនីមួយៗ កម្មវិធីឬគម្រោង ទាំងឡាយដោយមានការបញ្ជាក់ពីការបែងចែកទុនសម្រាប់កម្មវិធីឬគម្រោង បរិមាណទាំងឡាយសម្រាប់ជំនួយបច្ចេកទេសដាច់ៗគ្នា ។ល។

[២] សូមអានកំណត់សម្គាល់នៃកថាខណ្ឌ ២.៣០ (នៅត្រង់ចំណុចមូលទីពីរ)

ចម្បងបង្អស់ គឺដើម្បីជំរុញឱ្យមានការប្រើប្រាស់ "ការគាំទ្រថវិកា" ដែលជាវិធីសាស្ត្រនៃការផ្តល់ជំនួយក្រៅប្រទេស ដែលរដ្ឋាភិបាលចង់បានបំផុត[១] ។

បង្កើនល្បឿនការរៀបចំយុទ្ធសាស្ត្រនិងផែនការសកម្មភាពទូទាំងវិស័យ ដោយផ្តោតអាទិភាពទៅលើវិស័យសំខាន់ៗ ដូចជា កសិកម្មដែលមានឥទ្ធិពលលើជីវភាពរស់នៅ និងការរស់នៅរបស់ប្រជាជនភាគច្រើន ។

៤.០៦ ព្យាករណ៍សម្រាប់ ការវិនិយោគរបស់ផ្នែកឯកជន ក្នុងផ្នែកផ្សេងៗនៃសកម្មភាពសេដ្ឋកិច្ច ត្រូវបានបង្កើនដល់ ៩.១៤៦,៧០លានដុល្លារអាមេរិក[២] ក្នុងរយៈពេលពីឆ្នាំ២០០៦-២០១០ បើប្រៀបធៀបនឹងការប៉ាន់ស្មាននៅក្នុង*ផយអជ* ដែលមានតែ ៤.០១៦,៥លានដុល្លារប៉ុណ្ណោះ ។ កំណើនប្រមាណជិត ២០០ភាគរយនេះ ហាក់ដូចជាមានភាពសុទិដ្ឋិនិយមពេក ប៉ុន្តែមានលក្ខណៈប្រាកដនិយម ដោយហេតុថា ស្ថានភាពជាក់ស្តែងដែលកំពុងលេចឡើង នៅក្នុងរយៈពេលពីរឆ្នាំកន្លះកន្លងមកនេះ ហើយកំណើននេះ ផ្អែកលើការកើនឡើងខ្ពស់ដែលត្រូវបានរំពឹងទុកថានឹងកើតមាននៅក្នុងការវិនិយោគរបស់វិស័យឯកជន ដែលត្រូវបានសង្ឃឹមថានឹងកើតឡើងពីប្រភពធនធានក្នុងនិងក្រៅប្រទេស[៣] ។ រាជរដ្ឋាភិបាលកម្ពុជា នឹងខិតខំប្រឹងប្រែងក្នុងការធ្វើឱ្យប្រសើរឡើងជាលំដាប់នូវបរិយាកាសវិនិយោគនៅកម្ពុជា តាមរយៈការផ្តោតកិច្ចខិតខំប្រឹងប្រែងនានា ក្នុងនោះរួមមាន ការធ្វើឱ្យល្អប្រសើរជាងមុននូវហេដ្ឋារចនាសម្ព័ន្ធ កំណែទម្រង់និងការពង្រឹងវិស័យហិរញ្ញវត្ថុ ដើម្បីបញ្ចេញទុនអសកម្មទៅឱ្យការវិនិយោគក្នុងផ្នែកផលិតកម្ម និងការគាំទ្រតាមរយៈការសម្រួលក្របខ័ណ្ឌច្បាប់និងនីតិវិធី ដើម្បីបង្កើតឡើងនូវបរិស្ថានមួយដែលមានស្ថេរភាពនិងមានភាពងាយស្រួល សម្រាប់សកម្មភាពទាំងឡាយដែលមានលក្ខណៈប្រកួតប្រជែង ។

៤.០៧ <u>ការបែងចែកធនធានរបស់*ផយអជ*និងព័ត៌មានលម្អិតស្តីពីចំណាយផ្នែកហិរញ្ញវត្ថុសរុប</u> : ការបែងចែកធនធានរបស់*ផយអជ* ដែលត្រូវបានធ្វើឡើងនៅក្នុងតារាង ៥.២ នៃ*ផយអជ* ត្រូវបានកែសម្រួលនៅពេលនេះដោយផ្អែកលើការប៉ាន់ស្មានកែសម្រួល នៃចំណាយសាធារណៈ សម្រាប់ដំណាក់កាលរបស់*ផយអជ* (កថាខ័ណ្ឌ ៤.០៣ ខាងលើ) ។ ដោយគិតគូរដល់អាទិភាពខ្ពស់ដែលត្រូវផ្តោតលើវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ ការបែងចែកទុនសម្រាប់វិស័យទាំងនេះ ត្រូវបានបង្កើនឡើង នៅពេលនេះ ដោយប្រើប្រាស់ឱ្យអស់នូវទុន "មិនប្រើប្រាស់" នៅក្នុងតារាង ៥.២ នៃ*ផយអជ* ។ ការចំណាយថ្មី ដែលមានចំនួន ៤.២០០លានដុល្លារអាមេរិក ត្រូវបានបែងចែកនៅពេលនេះ នៅក្នុងតារាង ៤.៣ នៃឯកសារនេះ ។ ដូចដែលបានបង្ហាញនៅទីនោះ ការបែងចែកទុនសរុបទៅដល់

---

[១] កថាខណ្ឌ ៥.១៧ នៃ*ផយអជ* ដែលកំណត់ថា កម្មវិធីជំនួយចាំបាច់ត្រូវតែរៀបចំអនុវត្តឱ្យបានប្រសើរជាងមុន តាមរយៈវិធីសាស្ត្រផ្សេងៗ ដូចជា អភិក្រមគ្រប់គ្រងទូទាំងវិស័យ ដើម្បីសម្រេចបាននូវភាពស៊ីសង្វាក់គ្នា ហើយដើម្បីចៀសវាងការអនុវត្តត្រួតគ្នា ។

[២] សូមអានឧបសម្ព័ន្ធ ១.៣

[៣] ការធ្លាក់ចុះភ្លាមៗយ៉ាងខ្លាំងនៃបរិមាណឥណទានសម្រាប់ការខ្ចីចងការពីធនាគារ ឬ ការកើនឡើងភ្លាមៗនៃតម្លៃការប្រាក់ខ្ចីពីធនាគារ ដែលកំពុងមាននៅក្នុងពិភពលោក នឹងបន្តមានផលប៉ះពាល់ មកលើ ការវិនិយោគផ្ទាល់ពីបរទេស និង ការវិនិយោគក្នុងស្រុក ។

តំបន់ជនបទ កើនឡើងពី ៦២ភាគរយ ទៅដល់ ៦៣ភាគរយ ហើយសម្រាប់វិស័យកសិកម្ម កើនឡើងពី ១០ ភាគរយ ដល់ ១៣,៥៧ភាគរយ ព្រមទាំងសម្រាប់វិស័យដទៃទៀត កើនឡើងក្នុងសមាមាត្រមួយសមស្រប ។

### ការរៀបចំកម្មវិធីចំណាយសម្រាប់ *ផយអជ*

៤.០៨ ការព្យាករណ៍ការធ្វើវិភាជន៍ថវិកាដែលបានធ្វើការកែសម្រួលឡើងវិញពេលនេះ សម្រាប់វិស័យនានានៅក្នុងក្របខ័ណ្ឌ *ផយអជ* (តារាង ៥.២) គឺជាការតម្រង់ទិសនិងការចង្អុលបង្ហាញជារួម សម្រាប់ការអភិវឌ្ឍ ។ ដើម្បីឱ្យអាចដំណើរការអនុវត្តជាក់ស្តែងបាន ការតម្រង់ទិសនិងការចង្អុលបង្ហាញទាំងនោះ ត្រូវធ្វើការបំបែកលម្អិតប្រចាំឆ្នាំបន្ថែមទៀត ឱ្យទៅជាសំណើគម្រោងសម្រាប់ចំណាយចរន្ត និងចំណាយមូលធន ។ ក្នុងន័យនេះ ឧបករណ៍មួយចំនួនខាងក្រោម ត្រូវបានដាក់ឱ្យដំណើរការ :

- កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (*កវស*) ដែលមានគម្រោងវិនិយោគជាទុន និងគម្រោងជំនួយបច្ចេកទេស ដែលប្រើប្រាស់ប្រភពធនធានពីថវិកាក្នុងស្រុកនិងពីក្រៅប្រទេស (ប៉ុន្តែពុំរាប់បញ្ចូលចំណាយចរន្តទេ) ត្រូវបានរៀបចំឡើងដោយក្រសួងផែនការ ។
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមបីឆ្នាំរំកិល ដែលរួមបញ្ចូលចំណាយថវិកា គិតទាំងចំណាយមូលធនទាំងចំណាយចរន្ត ត្រូវបានរៀបចំឡើង ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- ថវិកាប្រចាំឆ្នាំ (ដែលរួមបញ្ចូលទាំងចំណាយមូលធននិងចំណាយចរន្ត) ត្រូវរៀបចំឡើង ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- ការប្រជុំពិគ្រោះយោបល់យ៉ាងទៀតទាត់ រវាងរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ដែលត្រូវបានរៀបចំឡើង ដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា[១] និងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីធានាថាការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ពិតជាបានតម្រឹមតម្រង់យ៉ាងពេញលេញជាមួយអាទិភាពរបស់ *ផយអជ* ។

៤.០៩ កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលចំនួនបី សម្រាប់ឆ្នាំ២០០៦-២០០៨ ឆ្នាំ២០០៧-២០០៩ និងឆ្នាំ២០០៨-២០១០ និងឆ្នាំ២០០៩-២០១១[២] ដែលត្រូវបានរៀបចំរហូតមកទល់ពេលនេះ បានព្យាយាមតម្រឹមយ៉ាងជាក់លាក់ នូវគម្រោងទាំងឡាយទៅនឹងអាទិភាពរបស់ *ផយអជ* ទោះបីជាថវិកាប្រមាណ ៤៥ភាគរយដែលត្រូវការសម្រាប់ដំណាក់កាលឆ្នាំ ២០០៨-២០១០ (ស្មើ ១.០៤៩លានដុល្លារអាមេរិកនៃតម្រូវការ ដែលបានកំណត់

---

[១] គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីប្រសិទ្ធភាពជំនួយ ដែលពិនិត្យតាមដានមើលជំនួយរបស់ដៃគូរអភិវឌ្ឍន៍ក្រៅប្រទេស ផងដែរ ។

[២] សូមអានឧបសម្ព័ន្ធ ២.១ ដល់ឧបសម្ព័ន្ធ ២.៤ ។

ចំនួន ២.៣២៥ លានដុល្លារអាមេរិក) នៅតែចាំបាច់ត្រូវ ស្វែងរកឱ្យបាន ឬធានាឱ្យមានក៏ដោយ ។ ទន្ទឹមនឹងពេលដែលតារាង៤.២ បង្ហាញពីការធ្វើវិភាជន៍ ដែលចង់បានបំផុតនៅក្នុង*ផយអជ ករស ២០០៧-២០០៩* នៅក្នុងឧបសម្ព័ន្ធ២ បង្ហាញជាលម្អិតនូវកម្មវិធី និងគម្រោងទាំងឡាយ (រួមទាំងកម្មវិធីនិងគម្រោងជាច្រើន ដែលត្រូវបានបង្ហាញថាជាអាទិភាពខ្ពស់ ប៉ុន្តែនៅត្រូវការទុនដើម្បីអនុវត្ត) ដែលត្រូវបានគ្រោងទុកដោយរាជរដ្ឋាភិបាលកម្ពុជាថាជាការវិនិយោគចាំបាច់ៗ នៅក្នុងវិស័យសាធារណៈ ។

៤.១០ កិច្ចខិតខំប្រឹងប្រែងរួមគ្នាជាច្រើនថែមទៀត ត្រូវធ្វើឡើងជាចាំបាច់ ដើម្បី : (ក) សម្របសម្រួលការងាររៀបចំឯកសារសំខាន់ៗ ពោលគឺ កម្មវិធីវិនិយោគសាធារណៈ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ថវិកា និងរបាយការណ៍ស្តីពីប្រសិទ្ធភាពជំនួយ និងដើម្បីបង្កើតនូវកម្លាំងរួមគ្នា លំដាប់លំដោយការងារប្រសើរជាងមុន ភាពរលូននិងភាពស៊ីសង្វាក់គ្នារវាងឯកសារទាំងនោះ ហើយ (ខ) បន្ស៊ីគ្នា តម្រូវគ្នា និងធ្វើឱ្យមានភាពរលូនជាមួយគ្នាឱ្យបានឆាប់រហ័សនូវ ទិន្នន័យក្នុងកម្មវិធីវិនិយោគសាធារណៈដែលរៀបចំឡើងដោយក្រសួងផែនការ និងមូលដ្ឋានទិន្នន័យនៃជំនួយអភិវឌ្ឍន៍ផ្លូវការដែលគ្រប់គ្រងដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា[១] ។ ដំណើរការនេះ និងការតាមដានត្រួតពិនិត្យជារួមនូវវឌ្ឍនភាពនៃការអនុវត្ត*ផយអជ* កំពុងត្រូវបានអនុវត្ត ដូចបានគ្រោងទុកនៅក្នុងកឋាខ័ណ្ឌ ៥.២០ និង ៥.២៣ នៃ*ផយអជ* ដោយមានការសម្របសម្រួលនិងកិច្ចសហការយ៉ាងជិតស្និទ្ធ រវាងស្ថាប័នកណ្តាលទាំងបួន គឺ *ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និង គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា* ។ ទោះជាដូចនេះក្តី វឌ្ឍនភាពដ៏ខ្លាំងក្លាច្រើនជាងនេះទៀត ត្រូវតែធ្វើឱ្យកើតមានឡើង ឱ្យបានឆាប់រហ័ស នៅក្នុងការងារនេះ ដោយរួមបញ្ចូលទាំង នៅក្នុងបញ្ហាដែល ស្ថាប័នមួយនៅក្នុងចំណោមស្ថាប័នទាំងបួននេះ ត្រូវផ្តួចផ្តើមគំនិតនិងនាំមុខ ក្នុងការងារនេះ ។

[១] *ករស* ដាក់បញ្ចូលការវិនិយោគដែលប្រើប្រាស់ទុនទាំងក្នុង និងក្រៅប្រទេស ទន្ទឹមនឹងពេលដែល មូលដ្ឋានទិន្នន័យនៃជំនួយអភិវឌ្ឍន៍ផ្លូវការ មានការពាក់ព័ន្ធតែជាមួយនឹងជំនួយពីក្រៅប្រទេសប៉ុណ្ណោះ ។

## តារាង ៤.៣ : ទិន្នន័យរបស់ផយអជ តាមវិស័យ ២០០៦-២០១០

(គិតជាលានដុល្លារ)

| វិស័យ | បរិមាណ | ភាគរយ | ជនបទ | ភាគរយ | ទីប្រជុំជន | ភាគរយ | កំណត់ |
|---|---|---|---|---|---|---|---|
| | | | | | | | ១ |
| **វិស័យសង្គមកិច្ច** | | | | | | | |
| អប់រំ : (ក្នុងនោះ ការអប់រំមូលដ្ឋាន ៦០%) | ៦៧០ | ១៥,៩៥ | ៤០២ | ៦០ | ២៦៨ | ៤០ | ២ |
| សុខាភិបាល | ៧២០ | ១៧,១៤ | ៥០៤ | ៧០ | ២១៦ | ៣០ | |
| **សរុប** | **១.៣៩០** | **៣៣,១០** | | | | | |
| **វិស័យសេដ្ឋកិច្ច** | | | | | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី : ក្រៅពីដំណាំ | ២០០ | ៤,៧៦ | ១៩០ | ៩៥ | ១០ | ៥ | ៣ |
| ដំណាំតាមរដូវ : ស្រូវ និងផ្សេងៗ | ៣៧០ | ៨,៨១ | ៣៨០ | ១០០ | ០ | | |
| អភិវឌ្ឍន៍ជនបទ | ៤២០ | ១០,០០ | ៤២០ | ១០០ | ០ | | ៤ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ១០០ | ២,៣៨ | ១២ | ១៥ | ៦៨ | ៨៥ | ៥ |
| **សរុប** | **១.០៩០** | **២៥,៩៥** | | | | | |
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | |
| ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរ) | ៦៩០ | ១៦,៤៣ | ៣៥០ | ៥០ | ៣៥០ | ៥០ | ៦ |
| ទឹក និងអនាម័យ (មិនគិតនៅជនបទ) | ១៨០ | ៤,២៩ | ១៥ | ១០ | ១៧១ | ៩០ | ៧ |
| ថាមពល និងអគ្គិសនី | ១៦០ | ៣,៨១ | ៨០ | ៥០ | ៨០ | ៥០ | ៨ |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | ៧៥ | ១,៧៩ | ៣៥ | ៥០ | ៣៥ | ៥០ | ៩ |
| **សរុប** | **១.១០៥** | **២៦,៣១** | | | | | |
| **សេវាកម្ម និងកម្មវិធីអន្តរវិស័យ** | | | | | | | |
| ការបញ្ជ្រាបយេនឌ័រ | ៤០ | ០,៩៥ | ១២ | ៣០ | ២៨ | ៧០ | ១០ |
| ទេសចរណ៍ | ៤៥ | ១,០៧ | ១៣ | ២៥ | ៣៨ | ៧៥ | |
| បរិស្ថាន និងការអភិរក្ស | ១២០ | ២,៨៦ | ៩៩ | ៩០ | ១១ | ១០ | ១១ |
| សហគមន៍ និងសេវាកម្មសង្គម | ១០០ | ២,៣៨ | ៧៥ | ៧៥ | ២៥ | ២៥ | |
| វប្បធម៌ និងសិល្បៈ | ៤០ | ០,៩៥ | ២០ | ៥០ | ២០ | ៥០ | |
| អភិបាលកិច្ច និងរដ្ឋបាល | ២៧០ | ៦,៤៣ | ៥៤ | ២០ | ២១៦ | ៨០ | ១២ |
| **សរុប** | **៦.១៩០** | **១៩,៦៤** | | | | | |
| មិនទាន់បែងចែក | | | | | | | |
| **សរុបរួម** | **៤.២០០** | **១០០%** | **២.៦៦៥** | **៦៣%** | **១.៥៣៦** | **៣៧%** | **១៣** |

***កំណត់ពន្យល់ :***

១. ក. បរិមាណតាមវិស័យនីមួយៗ រួមមាន : ធនធានដែលបានមកពីគ្រប់ប្រភពទាំងអស់ : រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (ចំណាយផ្ទាល់ដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ឬតាមរយៈរាជរដ្ឋាភិបាលកម្ពុជា) ។

ខ. ចំណាយមូលធន ចំណាយចរន្តបន្ថែម ជំនួយបច្ចេកទេស ចំណាយក្នុងការតាមដានត្រួតពិនិត្យ ប្រមូលទិន្នន័យ ការថែរក្សាគេហទំព័រ ។

គ. តួលេខជនបទ-ទីប្រជុំជន ជាតួលេខចង្អុលបង្ហាញជាកំណត់សម្គាល់ និងត្រូវផ្តោតការយកចិត្តទុកដាក់លើ ។

ឃ. បរិមាណទាំងនេះ ក៏រួមបញ្ចូលផងដែរនូវប្រាក់ឧបត្ថម្ភទាំងអស់ទៅថ្នាក់ខេត្ត ស្រុក និងឃុំ ដែលនឹងត្រូវអនុវត្តដោយថ្នាក់ទាំងនោះ ។

២. ក. រួមបញ្ចូលទាំង យុវជន និងកីឡា ។

ខ. ៦០ភាគរយ នៃចំនួនសរុប នឹងត្រូវបែងចែកសម្រាប់ការអប់រំមូលដ្ឋាន ។

៣. រួមបញ្ចូលទាំង ការនេសាទ ការបោសសម្អាតមីន និងសកម្មភាពផ្សេងៗ លើកលែងតែដំណាំ"តាមរដូវ" ហើយមិនរាប់បញ្ចូលព្រៃឈើដែលបានបង្ហាញ នៅក្នុងផ្នែកបរិស្ថាននិងការអភិរក្ស ។

៤. ការអភិវឌ្ឍជនបទ : រួមបញ្ចូលទាំង ការងារអនុវត្តដោយ*ក.ជ.វ.វ.* ផ្លូវលំ ទីផ្សារ ប្រព័ន្ធធារាសាស្ត្រ ការផ្គត់ផ្គង់ទឹកនិងអនាម័យ វិមជ្ឈការនិងវិសហមជ្ឈការ អភិបាលកិច្ចមូលដ្ឋាន ។

៥. រួមបញ្ចូលនូវ : ការបង្កើតការងារ និងបញ្ហាកម្លាំងពលកម្ម ។

៦. រួមបញ្ចូលនូវ :

ក. ចំណាយបន្ថែមលើការថែទាំ

ខ. ផ្លូវជាតិនិងផ្លូវខេត្ត មានផលប្រយោជន៍ដល់តំបន់ជនបទ ដូច្នេះផ្លូវទាំងពីរប្រភេទនេះ មានសមាមាត្រ ៥០ភាគរយ ។

៧. មិនរាប់បញ្ចូលនូវសកម្មភាពនៅតំបន់ជនបទ ដែលបានកំណត់នៅក្នុងការអភិវឌ្ឍជនបទ ។

៨. ភាគច្រើនបំផុតនៃការវិនិយោគក្នុងវិស័យនេះ គប្បីត្រូវជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ។

៩. ភាគច្រើនបំផុតការវិនិយោគក្នុងវិស័យនេះ គប្បីត្រូវជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន ។

១០ ជាពិសេស សម្រាប់ការបង្កើតការយល់ដឹងនិងការបញ្ជ្រាប ។ វិស័យនីមួយៗផ្សេងទៀត នឹងបញ្ចូលសកម្មភាពនានាទៅក្នុងការងាររបស់គេ ។

១១ រួមបញ្ចូលទាំងព្រៃឈើ ។

១២ រួមបញ្ចូលទាំង :

ក. កំណែទម្រង់ទាំងអស់ ដូចជា កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ម៉ាក្រូសេដ្ឋកិច្ច កំណែទម្រង់សារពើពន្ធ និងកំណែទម្រង់ផ្សេងៗទៀត ។

ខ. ការសិក្សានិងការអង្កេតរបស់វិទ្យាស្ថានជាតិស្ថិតិ ដូចជា ជំរឿនប្រជាជនឆ្នាំ២០០៨ ការវាយតម្លៃភាពក្រីក្រ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ការតាមដានត្រួតពិនិត្យការអនុវត្ត*ផយអជ* ។ល។

គ. ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ល។

ឃ. ការបោះឆ្នោតនានា ។

ង. សកម្មភាពរដ្ឋបាលសាធារណៈផ្សេងៗទៀត ។

១៣. ភាពខុសគ្នាបន្តិចបន្តួចក្នុងតួលេខសរុបនានា (ជនបទនិងទីប្រជុំជន) និងតួលេខសរុបរួម អាស្រ័យទៅនឹងការគម្រឹមលេខទសភាគ ។

# ជំពូកទី៥

## ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

៥.០១ ការតាមដានត្រួតពិនិត្យជាប្រចាំនិងទៀងទាត់ លើការអនុវត្តនិងវឌ្ឍនភាពនៃ*ផយអជ* ត្រូវបានទទួលស្គាល់ថាជាកត្តាគន្លឹះ[១] ដើម្បីធានាថា ការអនុវត្ត*ផយអជ* ត្រូវបានធ្វើឡើងទៅតាមទិសដៅដែលចង់បាន និងទៅតាមល្បឿនដែលតម្រូវឱ្យមាន សំដៅធ្វើឱ្យសម្រេចបាននូវគោលដៅនិងចំណុចដៅដែលបានគ្រោងទុក ។ ការតាមដានត្រួតពិនិត្យនេះ ក៏មានភាពចាំបាច់ ផងដែរ ដើម្បីជួយក្នុងការតម្រង់ទិសឡើងវិញ និងការកែតម្រូវនូវគោលដៅនិងចំណុចដៅទាំងឡាយ ដោយផ្តោតការយកចិត្តទុកដាក់លើ និន្នាការនិងស្ថានភាពជាក់ស្តែងទាំងឡាយដែលកំពុងកើតមានឡើង ។

៥.០២ យោងតាមស្មារតីជំពូកទី៦នៃ*ផយអជ* ដែលបានកំណត់ទិសដៅនិងដំណើរការ សម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ក្របខ័ណ្ឌនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ*ផយអជ* មួយ ត្រូវបានរៀបចំឡើង ហើយត្រូវបានទទួលការឯកភាពពីស្ថាប័នកណ្តាលទាំងបួន រួមមាន ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការទីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា (សូមអាន ឧបសម្ព័ន្ធ ៣) ។ ក្របខ័ណ្ឌនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃនេះ បាននឹងកំពុងត្រូវបានអនុវត្តយ៉ាងសកម្ម ។ តាមរយៈសិក្ខា-សាលាពីរ ដែលបានរៀបចំឡើងដោយជោគជ័យនៅឆ្នាំ២០០៨ ជាមួយអ្នកដែលមានចំណែកពាក់ព័ន្ធទាំងអស់ បញ្ជីសូចនាករសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ត្រូវបានពិភាក្សានិងពិនិត្យមើលឡើងវិញ ។ ប្រការដែលត្រូវបានទទួលស្គាល់ នោះគឺថា *ផយអជ* បង្ហាញតែគោលដៅនិងចំណុចដៅរួមនិងសំខាន់ៗ នៅក្នុងតារាង ៣.២ ប៉ុណ្ណោះ ដោយទុកឱ្យវិស័យនីមួយៗរៀបចំបង្កើតឡើងនូវសូចនាកររងដែលមានលក្ខណៈលម្អិតជាង ដែលវិស័យទាំងនោះ អាចត្រូវការ ដើម្បីតាមដានត្រួតពិនិត្យការអភិវឌ្ឍសំខាន់ៗតាមកាលកំណត់ សម្រាប់គោលបំណងគ្រប់គ្រងរបស់សាម៉ីស្ថាប័ននីមួយៗ និងដើម្បីរាយការណ៍អំពីការអភិវឌ្ឍសំខាន់ៗ សម្រាប់ការដាក់បញ្ចូលទៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃការអនុវត្ត*ផយអជ* ។ ការពិនិត្យមើលឡើងវិញនៅឆ្នាំ២០០៨ ក៏បានបង្កើតឡើងផងដែរ នូវសូចនាកររងបែបនេះ ជាច្រើន ។ ជំរឿនកសិកម្ម ក៏ដូចជា អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ដែលមានលក្ខណៈទូលំទូលាយជាង នឹងរៀបចំឡើងនៅក្នុងឆ្នាំ២០០៩ ហើយជំរឿនសេដ្ឋកិច្ច ត្រូវបានគ្រោងធ្វើនៅឆ្នាំ២០១១ ។

៥.០៣ ក្របខ័ណ្ឌតាមដានត្រួតពិនិត្យទទួលស្គាល់ថា មិនមែនគ្រប់គោលដៅនិងចំណុចដៅ នៅក្នុងតារាង៣.២ សុទ្ធតែអាចត្រូវតាមដានត្រួតពិនិត្យបាន ឬ វាស់វែងបាន ជារៀងរាល់ឆ្នាំបាននោះទេ ដោយសារតែ ទិន្នន័យដែល

[១] ជំពូកទី៦ នៃ *ផយអជ*

ត្រូវការ អាចមាន ឬ ទទួលបានតែពីការអង្កេតតាមកាលកំណត់ប៉ុណ្ណោះ ដូចជា អង្កេតប្រជាសាស្ត្រនិងសុខភាព និងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ជាដើម ។ អាស្រ័យហេតុនេះ ដូចបានពណ៌នានៅក្នុងក្របខ័ណ្ឌតាមដានត្រួតពិនិត្យ មានតែសូចនាករដែលអាចវាស់វែងបានតែ ២៦ ប៉ុណ្ណោះ ដែលត្រូវអាចតាមដានត្រួតពិនិត្យបាន តាមរយៈទិន្នន័យដែលប្រមូលបាន ដោយប្រព័ន្ធរដ្ឋបាលដែលកំពុងដំណើការនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដោយវិជ្ជាស្ថានជាតិស្ថិតិ ឬ ក៏អាចបានមកពីការធ្វើអង្កេតតាមកាលកំណត់ នានា ។ ការធ្វើអង្កេតដើម្បីតាមដាន ដោយដាច់ៗគ្នា មិនត្រូវបានគ្រោងឡើង សម្រាប់គោលបំណងខាងលើនេះទេ ។ លើសពីនេះទៀត ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវបន្តប្រមូលទិន្នន័យសំខាន់ៗផ្សេងទៀតដែលទាក់ទង នឹងមុខងាររបស់ខ្លួន រួមទាំង ទិន្នន័យលម្អិតពាក់ព័ន្ធនឹង *គអសក* និងសូចនាកររង ។ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំធ្វើឡើងជាបន្ថែមទៀត នូវការវិភាគឱ្យលម្អិតនិងច្បាស់លាស់ជាងមុន អំពីមូលហេតុនៃជោគជ័យនិងការមិនសម្រេចបាន សំដៅធ្វើឱ្យក្រសួង-ស្ថាប័នទាំងនោះ អាចធ្វើការជ្រើសរើសនិងធ្វើការសម្រេចចិត្តលើ គោលនយោបាយ ផែនការ និងកម្មវិធី ទាំងឡាយដែលនឹងត្រូវធ្វើឱ្យសម្រេចបាន និងសកម្មភាពរដ្ឋបាលផ្សេងៗទៀតដែលនឹងត្រូវអនុវត្ត ដើម្បីឈានទៅសម្រេចបាននូវគោលដៅនិងចំណុចដៅតាមវិស័យរបស់ក្រសួង-ស្ថាប័ន ទាំងនោះ ។

៩.០៤ ទិន្នន័យរដ្ឋបាល ត្រូវប្រមូលនៅតាមកម្រិតផ្សេងៗគ្នាជាច្រើន ក្នុងនោះរួមទាំង នៅកម្រិតឃុំ-សង្កាត់ផងដែរ ។ ដោយជាផ្នែកមួយនៃអាណត្តិរបស់ខ្លួនក្នុងក្របខ័ណ្ឌនៃផែនការមេស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ នឹងធានាជាបន្តទៀត ក្នុងការធ្វើឱ្យប្រសើរឡើងនូវ គុណភាព ស្តង់ដារ និងភាពអាចជឿជាក់បាន នៃការប្រមូល ការវិភាគ និងការបង្ហាញ ទិន្នន័យ នៅគ្រប់កម្រិតទាំងអស់ តាមរយៈវិធានការអភិវឌ្ឍន៍សមត្ថភាព ។

# ជំពូកទី៦

## សេចក្ដីសន្និដ្ឋាន

៦.០១ វឌ្ឍនភាពនៅក្នុងការអនុវត្ត *ផយអជ* ក្នុងរយៈពេលពីរឆ្នាំកន្លះ (ឆ្នាំ២០០៦ ដល់ខែមិថុនា ឆ្នាំ២០០៨) កន្លងមកនេះ មានលក្ខណៈគួរជាទីពេញចិត្ត ដូចដែលបានបង្ហាញនិងពិភាក្សា នៅក្នុងជំពូកមុនៗ រួចមកហើយ ។ ការបន្តលើកកម្ពស់សន្តិភាព ស្ថេរភាពនយោបាយនិងសង្គម ការធ្វើឱ្យប្រសើរឡើងនូវច្បាប់និងសណ្ដាប់ធ្នាប់ ព្រមទាំង កំណើនម៉ាក្រូសេដ្ឋកិច្ចយ៉ាងខ្លាំងនិងល្អប្រសើរ បានជួយបង្កលក្ខណៈឱ្យមានវឌ្ឍនភាពនេះ ។ ទោះជាដូចនេះក្ដី សកម្មភាពជាច្រើនបន្ថែមទៀត ត្រូវធ្វើឡើងជាចាំបាច់ នៅក្នុងវិស័យជាច្រើន ។ បញ្ហាប្រឈមជាច្រើន ត្រូវបានទទួលរងសំពាធជាបន្ថែមទៀត ដោយសារស្ថានភាពសេដ្ឋកិច្ចពិភពលោក ដែលមិននឹងន ដូចមានអធិប្បាយលម្អិត នៅក្នុងប្រអប់ ២.១ ។

៦.០២ ស្ថានភាពមិនអំណោយផល ដែលកើតឡើងពីកត្តាមិនអំណោយផលទាំងឡាយ ដែលនៅតែមានការប្រែប្រួលនៅក្នុងពិភពលោក ក៏បង្ហាញផងដែរនូវ កាលានុវត្តភាពមួយចំនួនដែលមានចំពោះមុខ ដើម្បីពង្រីកនិងបង្កើនមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចឱ្យបានច្រើន ហើយជាមួយគ្នានោះដែរ ដើម្បីធ្វើឱ្យការគ្រោងទុករយៈពេលវែងសម្រាប់ពេលអនាគត មានលក្ខណៈចីរភាពជាងមុន និងមានភាពងាយរងគ្រោះទៅនឹងវិបត្តិខាងក្រៅប្រទេស តិចជាងមុន ទន្ទឹមពេលជាមួយគ្នានឹង ការកាត់បន្ថយភាពក្រីក្រ តាមរយៈការយកចិត្តទុកដាក់ច្រើនជាងមុនទៅលើតំបន់ជនបទ និងការធ្វើឱ្យប្រសើរឡើងផលិតភាពកសិកម្ម ។

៦.០៣ ជំពូកទី៣ នៃរបាយការណ៍ពាក់កណ្ដាលអាណត្តិនេះ បានកត់សម្គាល់ថា ទន្ទឹមនឹងពេលដែល គោលដៅសំខាន់ៗរបស់ *ផយអជ* ក្នុងឆ្នាំ២០១០ និង *គអសក ឆ្នាំ២០១៥* អាចនឹងត្រូវសម្រេចបាន ឬ ត្រូវបានសម្រេចនោះ គោលដៅមួយចំនួនផ្សេងទៀត ទំនងជាមិនអាចសម្រេចបានទេ (តារាង ៣.១) ។ រាជរដ្ឋាភិបាលកម្ពុជាប្ដេជ្ញាចិត្តថា នឹងចាត់វិធានការយ៉ាងខ្ជាប់ខ្ជួន ដើម្បីសម្រេចគោលដៅឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន ទៅតាមពេលវេលា ដែលបានកំណត់ ។

៦.០៤ កត្តាខាងក្នុង និងកត្តាខាងក្រៅ ដែលមិនអាចវាស់វែងបាន នៅតែមានជាច្រើន ហើយអាចបង្កើតហានិភ័យបាន នាពេលអនាគត ។ កត្តាទាំងនោះ រួមមាន :

សេដ្ឋកិច្ចពិភពលោក បន្តមានការប្រែប្រួលមិននឹងន និងអតិផរណាខ្ពស់ ។

ធនធានដែលរំពឹងទុក ពុំមានគ្រប់គ្រាន់ ជាពិសេស ពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។

ស្ថានភាពនយោបាយក្នុងតំបន់ និងពិភពលោក កំពុងធ្លាក់ចុះទៅក្នុងស្ថានភាពមិនល្អ ដោយសារអំពើភេរវកម្ម ។

របាំងពាណិជ្ជកម្មអន្តរជាតិ មិនត្រូវបានលុបបំបាត់ ឱ្យនៅត្រឹមកម្រិតដែលចង់បាន ។

ការរីករាលដាលនៃជម្ងឺផ្តាសាយបក្សី ។

គ្រោះធម្មជាតិ ដែលលេចឡើងក្នុងកម្រិតខ្ពស់ជាងធម្មតា ដូចជា ការកើតឡើងម្តងហើយម្តងទៀតនៃ គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ ដែលធ្វើឱ្យប៉ះពាល់ដល់ផលិតមកម្មដំណាំ និងធ្វើឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធ និងអចលនទ្រព្យ ។

៦.០៥ រហូតមកទល់ពេលនេះ សមិទ្ធផលជាច្រើនត្រូវបានបង្កើតឡើង ប៉ុន្តែផ្លូវដែលត្រូវដើរនៅក្នុងពេលខាងមុខកាន់តែមានលក្ខណៈប្រឈមច្រើនជាងមុន និងមានភាពលំបាកច្រើនជាងមុន ដែលទាមទារឱ្យមានវិធីសាស្ត្រថ្មីៗសម្រាប់ដោះស្រាយ នៅពេលអនាគត ។ ជាមួយនឹងការប្តេជ្ញាចិត្តជាថ្មីនិងឆន្ទៈមោះមុត រាជរដ្ឋាភិបាលកម្ពុជាមានការជឿជាក់ថា នឹងអាចអនុវត្តបាននូវគ្រប់ទិដ្ឋភាពទាំងអស់នៃ*ផយអជ* ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំ ដោយផ្តោតការយកចិត្តទុកដាក់លើស្ថានភាពជាក់ស្តែងដែលកំពុងដំណើរការ និងលទ្ធភាពធនធានដែលត្រូវការ ។ រាជរដ្ឋាភិបាលកម្ពុជារំពឹងថា នឹងមានកិច្ចសហការយ៉ាងពេញលេញពីគ្រប់ អ្នកមានចំណែកពាក់ព័ន្ធទាំងអស់ (ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស សង្គមស៊ីវិល និង ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា) ក្នុងការធ្វើឱ្យសម្រេចបានគោលដៅរបស់*ផយអជ* សំដៅធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ របស់ប្រជាជនកម្ពុជាជាពិសេស ដើម្បីកាត់បន្ថយភាពក្រីក្រ ឱ្យបានឆាប់រហ័ស ។

**ឧបសម្ព័ន្ធ ១.១**

# កម្ពុជា : សូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច

## ការព្យាករណ៍សម្រាប់ឆ្នាំ២០០៦-២០១០

| សូចនាករសំខាន់ៗ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|---|
| | | | | | | |
| ***ផសស*** **(ថ្លៃថេរ) ពាន់លានរៀល** | ២២.០០៩ | ២៤.៣៨០ | ២៦.៨៦៨ | ២៨.៧៣៦ | ៣០.៦០៧ | ៣២.៧៥៩ |
| កសិកម្ម (%) | ២៩,៤ | ២៨,០ | ២៦,៧ | ២៦,១ | ២៥,៥ | ២៤,៨ |
| ដំណាំ (%) | ១៥,០ | ១៤,២ | ១៤,០ | ១៣,៨ | ១៣,៦ | ១៣,៣ |
| បសុសត្វ និងបសុបក្សី (%) | ៤,៥ | ៤,៤ | ៤,២ | ៤,១ | ៤,១ | ៤,១ |
| នេសាទ (%) | ៧,៧ | ៧,៣ | ៦,៦ | ៦,៤ | ៦,១ | ៥,៩ |
| ព្រៃឈើ (%) | ២,២ | ២,១ | ១,៩ | ១,៨ | ១,៧ | ១,៦ |
